# សុត្តន្តបិដក





៣២

# SUTTANTA PITAKA

# ព្រះ
# ត្រៃបិដកបាលី
# និង
# សេចក្ដីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
# សំយុត្តនិកាយ និទានវគ្គ
# ចតុត្ថភាគ
# ៣២



ផ្សព្វផ្សាយដោយសម្ដេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្ដេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ
នៃព្រះរាជាណាចក្រកម្ពុជា

*ព. ស. ២៥៥៣*

# SUTTANTAPIṬAKA

## SAṂYUTTANIKĀYA

## NIDĀNAVAGGA

## CATUTTHABHĀGA

## 32

សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី

សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

# និយមវចនៈ

ព្រះត្រៃបិដកត្រូវបានបង្កើតឡើង ប្រមាណ៥០០ឆ្នាំប្លាយ ក្រោយអំពីការរំលត់ព្រះខន្ធចូលកាន់ ព្រះបរមនិព្វានរបស់សម្តេចព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូជាអម្ចាស់នៃយើងគ្រប់គ្នា ។ គ្រប់ប្រទេស អ្នកកាន់ព្រះពុទ្ធសាសនា និងប្រទេសខ្លះមួយចំនួនមិនមែនអ្នកកាន់ព្រះពុទ្ធសាសនា គ្រប់អង្គការ ពុទ្ធិកសមាគម និងតាមបណ្ណាល័យជាតិធំ ៗ តែងតែបានទទួលយកមកតម្កល់ទុកធ្វើជាគ្រឹះ ដើម្បីធ្វើការស្រាវជ្រាវសិក្សាស្វែងយល់ តាមអ្វីដែលហៅថាព្រះពុទ្ធវាចា (ពុទ្ធធម៌) ។ កាលដើមឡើយគេនាំគ្នា កត់ត្រាលើស្លឹករឹត ព្រមទាំងសរសេរចារឹកលើផែនថ្ម និងលើផែនលោហៈក៏មាន លុះចំណេរតមក ក៏បាននាំគ្នាបោះពុម្ពលើក្រដាសចងក្រងជាសៀវភៅ (គម្ពីរ) រហូតបច្ចុប្បន្ននេះ បច្ចេកវិជ្ជាកាន់តែ ចម្រើនឡើង គេបានវាយបញ្ចូលក្នុងកុំព្យូទ័រ តែទោះបីជាបច្ចេកទេសម៉ាស៊ីនចម្រើនឡើងយ៉ាងណា ក៏នៅមិនអាចបោះបង់សៀវភៅចោលបានឡើយ ដូច្នេះហើយទើបយើងខ្ញុំបានខិតខំធ្វើឲ្យកើតមាន ឡើងនូវក្រុមអក្សរព្រះត្រៃបិដក ដើម្បីជួយធ្វើឲ្យអក្ខរៈខ្លះដែលរលុបមិនអាចអានច្បាស់បាន ឲ្យមាន ការច្បាស់តាមតួអក្ខរៈឡើងវិញ ។

ដោយសទ្ធាជ្រះថ្លាដ៏មុតមាំដែលមានចំពោះព្រះពុទ្ធសាសនា ហើយក៏ជាកាតព្វកិច្ចមួយដ៏ធំក្នុងតួនាទីជាពុទ្ធបរិស័ទ ដែលបានប្រគល់កាយថ្វាយជីវិត អ្នកធ្វើដំណើរតាមស្នាមព្រះបាទសម្តេចព្រះពុទ្ធអង្គ រួមកម្លាំងទ្រទ្រង់ បានធ្វើការលះបង់កម្លាំងកាយ វាចា ចិត្ត ទ្រព្យធនផ្ទាល់ ព្រមទាំងបបួលពុទ្ធបរិស័ទ ញាតិមិត្តជិតឆ្ងាយ ក្នុងនិងក្រៅប្រទេសធ្វើឡើង ដើម្បីជាពុទ្ធបូជា ធម្មបូជា សង្ឃបូជា ។

សូមសេចក្តីឧស្សាហ៍ក្នុងការជាកុសលនេះសម្រេចប្រយោជន៍ជូនដល់ព្រះពុទ្ធសាសនាជូនដល់ពុទ្ធបរិស័ទ សូមបានប្រកបតែនឹងសេចក្តីសុខចម្រើនរុងរឿង ក្នុងលោកនេះផង និងលោកដទៃខាងមុខទៀតផង ជាភិយ្យោភាពតរៀងទៅ ។

វត្តបទុមជ. ថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ២០០៩

ប្ចួរ-គ្រី

VATT Botum Dhammavutt Sangkat Chatumuk Khan Daun Penh P.Penh

# ទំព័រទទេ

# សេចក្តីណែនាំក្នុងការអាន

១) ប្រសិនបើលោកអ្នកអាន បានឃើញពាក្យទាំងឡាយណា ដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ហើយបន្ទាប់មកបានឃើញព្យញ្ជនៈមួយតួទៀតនៅខាងចុងពាក្យនោះ សូមមេត្តាកត់សម្គាល់ថា ព្យញ្ជនៈដែលនៅខាងចុងនោះ គឺជាជើងរបស់ព្យញ្ជនៈដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ដោយកំហុសបច្ចេកទេសកុំព្យូទ័រ ។

ឧទាហរណ៍

-ពាក្យខ្មែរ: **សម̟ល** ក្នុងពាក្យនេះ ព្យញ្ជនៈ **ល** គឺជាជើងរបស់ព្យញ្ជនៈ **ម** ដូច្នេះពាក្យនេះគឺ **សម្ល** ។

-ពាក្យបាលី: **តស̟ស** គឺ **តស្ស** ។

២) ចំពោះពាក្យខ្មែរ យើងសម្រេចយកតាមវចនានុក្រមខ្មែរ របស់សម្តេចព្រះសង្ឃរាជជោតញ្ញាណោ (**ជួន-ណាត**) ជាគោល ។ ប៉ុន្តែបើពាក្យទាំងឡាយណា ដែលអាចសរសេរតាមបែបបុរាណក៏ត្រឹមត្រូវដែរនោះ យើងខ្ញុំសូមរក្សានូវពាក្យទាំងនោះទុកដដែល ។

៣) ចំពោះ **សន្លឹកប្រាប់ពាក្យខុស-ត្រូវ** ដែលមាននៅផ្នែកខាងចុងនៃព្រះត្រៃបិដកច្បាប់ដើម ក្រុមយើងខ្ញុំសូមមិនដាក់ទៀតទេ ព្រោះក្រុមការងារយើងបានកែតម្រូវតាមនោះរួចរាល់ហើយ ។

# សុត្តន្តបិដក

## សំយុត្តនិកាយ  និទានវគ្គ

## ចតុត្ថភាគ

## ៣២

ព. ស. ២៤០៦

# សុត្តន្តបិដកេ

# សំយុត្តនិកាយស្ស និទានវគ្គោ

# ចតុត្ថោ ភាគោ

---

## ធាតុសំយុត្តំ

### នានត្តវគ្គោ

[១] សាវត្ថិយំ វិហរតិ... ធាតុនានត្តំ វោ ភិក្ខវេ ទេសិស្សាមិ តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

[២] ភគវា ឯតទវោច កតមញ្ច ភិក្ខវេ ធាតុនា-នត្តំ ។ ចក្ខុធាតុ រូបធាតុ ចក្ខុវិញ្ញាណធាតុ សោតធាតុ សទ្ទធាតុ សោតវិញ្ញាណធាតុ ឃានធាតុ គន្ធធាតុ

# សុត្តន្តបិដក

# សំយុត្តនិកាយ  និទានវគ្គ

# ចតុត្ថភាគ

---

## ធាតុសំយុត្ត

## នានត្តវគ្គ

[១] *ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវធាតុ មានសភាពផ្សេងគ្នាដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវធាតុ មានសភាពផ្សេងគ្នានោះ ចូរធ្វើទុកក្នុងចិត្តឲ្យល្អ តថាគតនឹងសំដែង ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។*

[២] *ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ចុះធាតុមានសភាពផ្សេងគ្នាដូចម្តេច ។ ចក្ខុធាតុ រូបធាតុ ចក្ខុវិញ្ញាណ-ធាតុ សោតធាតុ សទ្ទធាតុ សោតវិញ្ញាណធាតុ ឃានធាតុ គន្ធធាតុ*

ឃានវិញ្ញាណធាតុ ជិវ្ហាធាតុ រសធាតុ ជិវ្ហាវិញ្ញាណ-
ធាតុ កាយធាតុ ផោដ្ឋព្វធាតុ កាយវិញ្ញាណធាតុ
មនោធាតុ ធម្មធាតុ មនោវិញ្ញាណធាតុ ។ ឥទំ វុច្ចតិ
ភិក្ខវេ ធាតុនានត្តន្តិ ។ បឋមំ ។

[៣] សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា...
ធាតុនានត្តំ ភិក្ខវេ បដិច្ច ឧប្បជ្ជតិ ផស្សនានត្តំ ។
កតមញ្ច ភិក្ខវេ ធាតុនានត្តំ ។ ចក្ខុធាតុ សោ-
តធាតុ ឃានធាតុ ជិវ្ហាធាតុ កាយធាតុ មនោធាតុ ។
ឥទំ វុច្ចតិ ភិក្ខវេ ធាតុនានត្តំ ។

ឃានវិញ្ញាណធាតុ ជិវ្ហាធាតុ រសធាតុ ជិវ្ហាវិញ្ញាណធាតុ កាយធាតុ ផោដ្ឋព្វធាតុ កាយវិញ្ញាណធាតុ មនោធាតុ ធម្មធាតុ មនោវិញ្ញាណ-ធាតុ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធាតុមានសភាពផ្សេងគ្នា ។

ចប់សូត្រទី ១ ។

[៣] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ក្នុងទីនោះឯង ព្រះមានព្រះភាគ... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ផស្សៈមានសភាពផ្សេងគ្នា រមែងកើតឡើង ព្រោះអាស្រ័យធាតុ មានសភាពផ្សេងគ្នា ។ ម្នាលភិក្ខុទាំងឡាយ ចុះធាតុមានសភាពផ្សេងគ្នា តើដូចម្តេច ។ ចក្ខុធាតុ សោតធាតុ ឃានធាតុ ជិវ្ហាធាតុ កាយ-ធាតុ មនោធាតុ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធាតុមានសភាពផ្សេងគ្នា ។

៣

ធាតុសំយុត្តស្ស នានត្តវគ្គេ ធាតុនានត្តំ

[៤] កាតមញ្ច ភិក្ខវេ ធាតុជានត្តំ បដិច្ច ឧប្ប-ជ្ជតិ ផស្សជានត្តំ ។ ចក្ខុធាតុំ ភិក្ខវេ បដិច្ច ឧប្ប-ជ្ជតិ ចក្ខុសម្ផស្សោ សោតធាតុំ បដិច្ច... ឃានធាតុំ បដិច្ច... ជិវ្ហាធាតុំ បដិច្ច... កាយធាតុំ បដិច្ច... មនោ-ធាតុំ បដិច្ច ឧប្បជ្ជតិ មនោសម្ផស្សោ ។ ឯវំ ខោ ភិក្ខវេ ធាតុជានត្តំ បដិច្ច ឧប្បជ្ជតិ ផស្សជានត្តន្តិ ។ ទុតិយំ ។

[៥] សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា... ធាតុ-ជានត្តំ ភិក្ខវេ បដិច្ច ឧប្បជ្ជតិ ផស្សជានត្តំ នោ ផស្សជានត្តំ បដិច្ច ឧប្បជ្ជតិ ធាតុជានត្តំ ។ កាត-មញ្ច ភិក្ខវេ ធាតុជានត្តំ ។ ចក្ខុធាតុ ។ បេ ។ ម-នោធាតុ ។ ឥទំ វុច្ចតិ ភិក្ខវេ ធាតុជានត្តំ ។

ធាតុសំយុត្ត នានត្តវគ្គ ធាតុមានសភាពផ្សេងៗ

[៤] ម្នាលភិក្ខុទាំងឡាយ ចុះផស្សៈមានសភាពផ្សេងគ្នា រមែងកើតឡើង ព្រោះអាស្រ័យធាតុមានសភាពផ្សេងគ្នា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុសម្ផស្សកើតឡើង ព្រោះអាស្រ័យចក្ខុធាតុ ព្រោះអាស្រ័យសោតធាតុ.... ព្រោះអាស្រ័យឃានធាតុ.... ព្រោះអាស្រ័យជិវ្ហាធាតុ... ព្រោះអាស្រ័យកាយធាតុ... មនោសម្ផស្សកើតឡើង ព្រោះអាស្រ័យមនោធាតុ ។ ម្នាលភិក្ខុទាំងឡាយ ផស្សៈមានសភាពផ្សេងគ្នា រមែងកើតឡើង ព្រោះអាស្រ័យធាតុ មានសភាពផ្សេងគ្នាយ៉ាងនេះឯង ។ ចប់សូត្រទី ២ ។

[៥] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ក្នុងទីនោះឯង ព្រះមានព្រះភាគ... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ផស្សៈមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យធាតុមានសភាពផ្សេងគ្នា មិនមែនធាតុមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យផស្សៈមានសភាពផ្សេងគ្នាទេ ។ ម្នាលភិក្ខុទាំងឡាយ ចុះធាតុមានសភាពផ្សេងគ្នា តើដូចម្តេច ។ ចក្ខុធាតុ ។ បេ ។ មនោធាតុ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធាតុមានសភាពផ្សេងគ្នា ។

[៦] កាតមញ្ច ភិក្ខវេ ធាតុនានត្តំ បដិច្ច ឧប្ប-
ជ្ជតិ ផស្សនានត្តំ ដោ ផស្សនានត្តំ បដិច្ច ឧប្បជ្ជតិ
ធាតុនានត្តំ ។ ចក្ខុធាតុំ ភិក្ខវេ បដិច្ច ឧប្បជ្ជតិ
ចក្ខុសម្ផស្សោ ដោ ចក្ខុសម្ផស្ស បដិច្ច ឧប្បជ្ជតិ
ចក្ខុធាតុ ។ បេ ។ មនោធាតុំ បដិច្ច ឧប្បជ្ជតិ មនោ-
សម្ផស្សោ ដោ មនោសម្ផស្សំ បដិច្ច ឧប្បជ្ជតិ មនោ-
ធាតុ ។ ឯវំ ខោ ភិក្ខវេ ធាតុនានត្តំ បដិច្ច ឧប្បជ្ជតិ
ផស្សនានត្តំ ដោ ផស្សនានត្តំ បដិច្ច ឧប្បជ្ជតិ
ធាតុនានត្តន្តិ ។ តតិយំ ។

[៧] សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា... ធាតុ-
នានត្តំ ភិក្ខវេ បដិច្ច ឧប្បជ្ជតិ ផស្សនានត្តំ ផស្សនា-
នត្តំ បដិច្ច ឧប្បជ្ជតិ វេទនានានត្តំ ។ កាតមញ្ច ភិក្ខវេ
ធាតុនានត្តំ ។ ចក្ខុធាតុ ។ បេ ។ មនោធាតុ ។ ឥទំ
វុច្ចតិ ភិក្ខវេ ធាតុនានត្តំ ។

[៦] ម្នាលភិក្ខុទាំងឡាយ ចុះផស្សៈមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យធាតុមានសភាពផ្សេងគ្នា មិនមែនធាតុមានសភាពផ្សេងគ្នាកើតឡើង ព្រោះអាស្រ័យផស្សៈមានសភាពផ្សេងគ្នា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុសម្ផស្សកើតឡើង ព្រោះអាស្រ័យចក្ខុធាតុ មិនមែនចក្ខុធាតុកើតឡើង ព្រោះអាស្រ័យចក្ខុសម្ផស្ស ។ បេ ។ មនោសម្ផស្សកើតឡើង ព្រោះអាស្រ័យមនោធាតុ មិនមែនមនោធាតុកើតឡើង ព្រោះអាស្រ័យមនោសម្ផស្សទេ ។ ម្នាលភិក្ខុទាំងឡាយ ផស្សៈមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យធាតុមានសភាពផ្សេងគ្នា មិនមែនធាតុមានសភាពផ្សេងគ្នាកើតឡើង ព្រោះអាស្រ័យផស្សៈមានសភាពផ្សេងគ្នា យ៉ាងនេះឯង ។ ចប់សូត្រទី ៣ ។

[៧] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ក្នុងទីនោះឯង ព្រះមានព្រះភាគ... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ផស្សៈមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យធាតុមានសភាពផ្សេងគ្នា វេទនាមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យផស្សៈមានសភាពផ្សេងគ្នា ។ ម្នាលភិក្ខុទាំងឡាយ ចុះធាតុមានសភាពផ្សេងគ្នា តើដូចម្តេច ។ ចក្ខុធាតុ ។ បេ ។ មនោធាតុ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធាតុមានសភាពផ្សេងគ្នា ។

៤

ធាតុសំយុត្តស្ស នានត្តវគ្គេ ធាតុនានត្តំ

[៨] កាតមញ្ច ភិក្ខវេ ធាតុនានត្តំ បដិច្ច ឧប្បជ្ជតិ ផស្សនានត្តំ ផស្សនានត្តំ បដិច្ច ឧប្បជ្ជតិ វេទនា-នានត្តំ ។ ចក្ខុធាតុំ ភិក្ខវេ បដិច្ច ឧប្បជ្ជតិ ចក្ខុ-សម្ផស្សោ ចក្ខុសម្ផស្សំ បដិច្ច ឧប្បជ្ជតិ ចក្ខុសម្ផ-ស្សជា វេទនា ។ បេ ។ មនោធាតុំ បដិច្ច ឧប្បជ្ជតិ មនោសម្ផស្សោ មនោសម្ផស្សំ បដិច្ច ឧប្បជ្ជតិ មនោ-សម្ផស្សជា វេទនា ។ ឯវំ ខោ ភិក្ខវេ ធាតុនានត្តំ បដិច្ច ឧប្បជ្ជតិ ផស្សនានត្តំ ផស្សនានត្តំ បដិច្ច ឧប្បជ្ជតិ វេទនានានត្តន្តិ ។ ចតុត្ថំ ។

៥

ធាតុសំយុត្ត នានត្តវគ្គ ធាតុមានសភាពផ្សេងៗ

[៨] ម្នាលភិក្ខុទាំងឡាយ ចុះផស្សៈមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យធាតុមានសភាពផ្សេងគ្នា វេទនាមានសភាពផ្សេងគ្នាកើតឡើង ព្រោះអាស្រ័យផស្សៈមានសភាពផ្សេងគ្នា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ចក្ខុសម្ផស្សកើតឡើង ព្រោះអាស្រ័យចក្ខុធាតុ វេទនាដែលកើតអំពីចក្ខុសម្ផស្ស ក៏កើតឡើង ព្រោះអាស្រ័យចក្ខុ-សម្ផស្ស ។ បេ ។ មនោសម្ផស្សកើតឡើង ព្រោះអាស្រ័យមនោធាតុ វេទនាកើតអំពីមនោសម្ផស្ស ក៏កើតឡើង ព្រោះអាស្រ័យមនោ-សម្ផស្ស ។ ម្នាលភិក្ខុទាំងឡាយ ផស្សៈមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យធាតុមានសភាពផ្សេងគ្នា វេទនាមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យផស្សៈមានសភាពផ្សេងគ្នា យ៉ាងនេះឯង ។

ចប់សូត្រទី ៤ ។

[៩] សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា... ធាតុ-
នានត្តំ ភិក្ខវេ បដិច្ច ឧប្បជ្ជតិ ផស្សនានត្តំ ផស្ស-
នានត្តំ បដិច្ច ឧប្បជ្ជតិ វេទនានានត្តំ នោ វេទនានា-
នត្តំ បដិច្ច ឧប្បជ្ជតិ ផស្សនានត្តំ នោ ផស្សនានត្តំ
បដិច្ច ឧប្បជ្ជតិ ធាតុនានត្តំ ។ កតមញ្ច ភិក្ខវេ
ធាតុនានត្តំ ។ ចក្ខុធាតុ ។ បេ ។ មនោធាតុ ។ ឥទំ
វុច្ចតិ ភិក្ខវេ ធាតុនានត្តំ ។

[១០] កតមញ្ច ភិក្ខវេ ធាតុនានត្តំ បដិច្ច
ឧប្បជ្ជតិ ផស្សនានត្តំ ផស្សនានត្តំ បដិច្ច ឧប្បជ្ជតិ
វេទនានានត្តំ នោ វេទនានានត្តំ បដិច្ច ឧប្បជ្ជតិ
ផស្សនានត្តំ នោ ផស្សនានត្តំ បដិច្ច ឧប្បជ្ជតិ ធាតុ-
នានត្តំ ។ ចក្ខុធាតុំ ភិក្ខវេ បដិច្ច ឧប្បជ្ជតិ ចក្ខុ-

[៩] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ក្នុងទីនោះឯង ព្រះមានព្រះភាគ... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ផស្សៈមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យធាតុមានសភាពផ្សេងគ្នា វេទនាមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យផស្សៈមានសភាពផ្សេងគ្នា មិនមែនផស្សៈមានសភាពផ្សេងគ្នាកើតឡើង ព្រោះអាស្រ័យវេទនាមានសភាពផ្សេងគ្នា មិនមែនធាតុមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យវេទនាមានសភាពផ្សេងគ្នាទេ ។ ម្នាលភិក្ខុទាំងឡាយ ចុះធាតុមានសភាពផ្សេងគ្នា តើដូចម្តេច ។ ចក្ខុធាតុ ។ បេ ។ មនោធាតុ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធាតុមានសភាពផ្សេងគ្នា ។

[១០] ម្នាលភិក្ខុទាំងឡាយ ចុះផស្សៈមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យធាតុមានសភាពផ្សេងគ្នា វេទនាមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យផស្សៈមានសភាពផ្សេងគ្នា មិនមែនផស្សៈមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យវេទនាមានសភាពផ្សេងគ្នា មិនមែនធាតុមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យផស្សៈមានសភាពផ្សេងគ្នា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ

៧

## ធាតុសំយុត្តស្ស នានត្តវគ្គេ ធាតុនានត្តំ

សម្ផស្សោ ចក្ខុសម្ផស្សំ បដិច្ច ឧប្បជ្ជតិ ចក្ខុសម្ផស្សជា វេទនា នោ ចក្ខុសម្ផស្សជំ វេទនំ បដិច្ច ឧប្បជ្ជតិ ចក្ខុសម្ផស្សោ នោ ចក្ខុសម្ផស្សំ បដិច្ច ឧប្បជ្ជតិ ចក្ខុធាតុ ។ បេ ។ មនោធាតុំ បដិច្ច ឧប្បជ្ជតិ មនោសម្ផស្សោ មនោសម្ផស្សំ បដិច្ច ឧប្បជ្ជតិ មនោសម្ផស្សជា វេទនា នោ មនោសម្ផស្សជំ វេទនំ បដិច្ច ឧប្បជ្ជតិ មនោសម្ផស្សោ នោ មនោសម្ផស្សំ បដិច្ច ឧប្បជ្ជតិ មនោធាតុ ។ ឯវំ ខោ ភិក្ខវេ ធាតុនានត្តំ បដិច្ច ឧប្បជ្ជតិ ផស្សនានត្តំ ផស្សនានត្តំ បដិច្ច ឧប្បជ្ជតិ វេទនានានត្តំ នោ វេទនានានត្តំ បដិច្ច ឧប្បជ្ជតិ ផស្សនានត្តំ នោ ផស្សនានត្តំ បដិច្ច ឧប្បជ្ជតិ ធាតុនានត្តន្តិ ។ បញ្ចមំ ។

៧

ធាតុសំយុត្ត នានត្តវគ្គ ធាតុមានសភាពផ្សេងៗ

ចក្ខុសម្ផស្សកើតឡើង ព្រោះអាស្រ័យចក្ខុធាតុ វេទនាដែលកើតអំពីចក្ខុសម្ផស្ស ក៏កើតឡើង ព្រោះអាស្រ័យចក្ខុសម្ផស្ស មិនមែនចក្ខុសម្ផស្សកើតឡើង ព្រោះអាស្រ័យវេទនា ដែលកើតអំពីចក្ខុសម្ផស្ស មិនមែនចក្ខុធាតុកើតឡើង ព្រោះអាស្រ័យមនោធាតុ វេទនាដែលកើតអំពីមនោសម្ផស្ស ក៏កើតឡើង ព្រោះអាស្រ័យមនោសម្ផស្ស មិនមែនមនោ-សម្ផស្សកើតឡើង ព្រោះអាស្រ័យវេទនា ដែលកើតអំពីមនោសម្ផស្ស មិនមែនមនោធាតុកើតឡើង ព្រោះអាស្រ័យមនោសម្ផស្សទេ ។ ម្នាលភិក្ខុទាំងឡាយ ផស្សៈមានសភាពផ្សេងគ្នាកើតឡើង ព្រោះអាស្រ័យធាតុមានសភាពផ្សេងគ្នា វេទនាមានសភាពផ្សេងគ្នាកើតឡើង ព្រោះអាស្រ័យផស្សៈមានសភាពផ្សេងគ្នា មិនមែនផស្សៈមានសភាពផ្សេងគ្នាកើតឡើង ព្រោះអាស្រ័យវេទនាមានសភាពផ្សេងគ្នា មិនមែនធាតុមានសភាពផ្សេងគ្នាកើតឡើង ព្រោះអាស្រ័យផស្សៈ មានសភាពផ្សេងគ្នាយ៉ាងនេះឯង ។ ចប់សូត្រទី ៥ ។

[១១] សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា... ធាតុនានត្តំ វោ ភិក្ខវេ ទេសិស្សាមិ តំ សុណាថ... កតមញ្ច ភិក្ខវេ ធាតុនានត្តំ ។ រូបធាតុ សទ្ទធាតុ គន្ធធាតុ រសធាតុ ផោដ្ឋព្វធាតុ ធម្មធាតុ ។ ឥទំ វុច្ចតិ ភិក្ខវេ ធាតុនានត្តន្តិ ។ ឆដ្ឋំ ។

[១២] សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា... ធាតុនានត្តំ ភិក្ខវេ បដិច្ច ឧប្បជ្ជតិ សញ្ញានានត្តំ សញ្ញានានត្តំ បដិច្ច ឧប្បជ្ជតិ សង្កប្បនានត្តំ សង្កប្ប-នានត្តំ បដិច្ច ឧប្បជ្ជតិ ឆន្ទនានត្តំ ឆន្ទនានត្តំ បដិច្ច ឧប្បជ្ជតិ បរិឡាហនានត្តំ បរិឡាហនានត្តំ បដិច្ច ឧប្បជ្ជតិ បរិយេសនានានត្តំ ។ កតមញ្ច ភិក្ខវេ ធាតុ-

[១១] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ក្នុងទីនោះឯង ព្រះមានព្រះភាគ... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវធាតុមានសភាពផ្សេងគ្នា ដល់អ្នកទាំងឡាយ អ្នកទាំងឡាយ ចូរស្តាប់នូវធាតុមានសភាពផ្សេងគ្នានោះ... ម្នាលភិក្ខុទាំង-ឡាយ ចុះធាតុមានសភាពផ្សេងគ្នា តើដូចម្តេច ។ រូបធាតុ សទ្ទធាតុ គន្ធធាតុ រសធាតុ ផោដ្ឋព្វធាតុ ធម្មធាតុ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធាតុមានសភាពផ្សេងគ្នា ។ ចប់សូត្រទី ៦ ។

[១២] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ក្នុងទីនោះឯង ព្រះមានព្រះភាគ... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សញ្ញាមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យធាតុមានសភាពផ្សេងគ្នា សង្កប្បៈ (សេចក្តីត្រិះរិះ) មានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យសញ្ញា មានសភាពផ្សេងគ្នា ឆន្ទៈ (សេចក្តីពេញចិត្ត) មានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យសង្កប្បៈ មានសភាពផ្សេងគ្នា បរិឡាហៈ (សេចក្តីក្រហល់ក្រហាយ) មានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យឆន្ទៈមានសភាពផ្សេងគ្នា បរិយេសនា (ការស្វែងរក) មានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យបរិឡាហៈ មានសភាពផ្សេងគ្នា ។ ម្នាលភិក្ខុទាំងឡាយ ចុះធាតុមានសភាព

ជានត្តំ ។ រូបធាតុ ។ បេ ។ ធម្មធាតុ ។ ឥទំ វុច្ចតិ ភិក្ខវេ ធាតុជានត្តំ ។

[១៣] កាតមញ្ច ភិក្ខវេ ធាតុជានត្តំ បដិច្ច ឧប្បជ្ជតិ សញ្ញាជានត្តំ សញ្ញាជានត្តំ បដិច្ច ឧប្បជ្ជតិ សង្កប្បជានត្តំ សង្កប្បជានត្តំ បដិច្ច ឧប្បជ្ជតិ ឆន្ទជានត្តំ ឆន្ទជានត្តំ បដិច្ច ឧប្បជ្ជតិ បរិឡាហជានត្តំ បរិឡាហជានត្តំ បដិច្ច ឧប្បជ្ជតិ បរិយេសនាជានត្តំ ។ រូបធាតុំ ភិក្ខវេ បដិច្ច ឧប្បជ្ជតិ រូបសញ្ញា រូបសញ្ញំ បដិច្ច ឧប្បជ្ជតិ រូបសង្កប្បោ រូបសង្កប្បំ បដិច្ច ឧប្បជ្ជតិ រូបច្ឆន្ទោ រូបច្ឆន្ទំ បដិច្ច ឧប្បជ្ជតិ រូបបរិឡាហោ រូបបរិឡាហំ បដិច្ច ឧប្បជ្ជតិ រូបបរិយេសនា ។ បេ ។ ធម្មធាតុំ បដិច្ច ឧប្បជ្ជតិ ធម្មសញ្ញា ធម្មសញ្ញំ បដិច្ច ឧប្បជ្ជតិ ធម្មសង្កប្បោ ធម្មសង្កប្បំ បដិច្ច ឧប្បជ្ជតិ ធម្មច្ឆន្ទោ

ផ្សេងគ្នា តើដូចម្តេច ។ រូបធាតុ ។ បេ ។ ធម្មធាតុ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធាតុមានសភាពផ្សេងគ្នា ។

[១៣] ម្នាលភិក្ខុទាំងឡាយ ចុះសញ្ញាមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យធាតុមានសភាពផ្សេងគ្នា សង្កប្បៈមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យសញ្ញាមានសភាពផ្សេងគ្នា ឆន្ទៈមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យសង្កប្បៈមានសភាពផ្សេងគ្នា បរិឡាហៈមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យឆន្ទៈមានសភាពផ្សេងគ្នា បរិយេសនាមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យបរិឡាហៈមានសភាពផ្សេងគ្នា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ រូបសញ្ញាកើតឡើង ព្រោះអាស្រ័យរូបធាតុ រូបសង្កប្បៈ (សេចក្តីត្រិះរិះក្នុងរូប) កើតឡើង ព្រោះអាស្រ័យរូបសញ្ញា រូបច្ឆន្ទៈ (សេចក្តីពេញចិត្តក្នុងរូប) កើតឡើង ព្រោះអាស្រ័យរូបសង្កប្បៈ រូបបរិឡាហៈ (សេចក្តីក្រហល់ក្រហាយក្នុងរូប) កើតឡើង ព្រោះអាស្រ័យរូបច្ឆន្ទៈ រូបបរិយេសនា (ការស្វែងរករូប) កើតឡើង ព្រោះអាស្រ័យរូបបរិឡាហៈ ។ បេ ។ ធម្មសញ្ញាកើតឡើង ព្រោះអាស្រ័យធម្មធាតុ ធម្មសង្កប្បៈ (សេចក្តីត្រិះរិះក្នុងធម៌) កើតឡើង ព្រោះអាស្រ័យធម្មសញ្ញា ធម្មច្ឆន្ទៈ (សេចក្តីពេញចិត្តក្នុងធម៌) កើតឡើង

១០

សុត្តន្តបិដកេ សំយុត្តនិកាយស្ស និទានវគ្គោ

ធម្មច្ឆន្ទំ បដិច្ច ឧប្បជ្ជតិ ធម្មបរិឡាហោ ធម្មបរិឡាហំ បដិច្ច ឧប្បជ្ជតិ ធម្មបរិយេសនា ។ ឯវំ ខោ ភិក្ខវេ ធាតុនានត្តំ បដិច្ច ឧប្បជ្ជតិ សញ្ញានានត្តំ សញ្ញា-នានត្តំ បដិច្ច ឧប្បជ្ជតិ សង្កប្បនានត្តំ សង្កប្បនានត្តំ បដិច្ច ឧប្បជ្ជតិ ឆន្ទនានត្តំ ឆន្ទនានត្តំ បដិច្ច ឧប្បជ្ជតិ បរិឡាហនានត្តំ បរិឡាហនានត្តំ បដិច្ច ឧប្បជ្ជតិ បរិយេសនានានត្តន្តិ ។ សត្តមំ ។

ព្រោះអាស្រ័យធម្មសង្កប្បៈ ធម្មបរិឡាហៈ (សេចក្តីក្រហល់ក្រហាយក្នុងធម៌) កើតឡើង ព្រោះអាស្រ័យធម្មច្ឆន្ទៈ ធម្មបរិយេសនា (ការស្វែងរកធម៌) កើតឡើង ព្រោះអាស្រ័យធម្មបរិឡាហៈ ។ ម្នាលភិក្ខុទាំងឡាយ សញ្ញាមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យធាតុមានសភាពផ្សេងគ្នា សង្កប្បៈមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យសញ្ញាមានសភាពផ្សេងគ្នា ឆន្ទៈមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យសង្កប្បៈមានសភាពផ្សេងគ្នា បរិឡាហៈមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យឆន្ទៈមានសភាពផ្សេងគ្នា បរិយេសនាមានសភាពផ្សេងគ្នាកើតឡើង ព្រោះអាស្រ័យបរិឡាហៈមានសភាពផ្សេងគ្នា យ៉ាងនេះឯង ។ ចប់សូត្រទី ៧ ។

១១

ធាតុសំយុត្តស្ស នានត្តវគ្គេ ធាតុនានត្តំ

[១៤] សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា... ធាតុនានត្តំ ភិក្ខវេ បដិច្ច ឧប្បជ្ជតិ សញ្ញានានត្តំ សញ្ញានានត្តំ បដិច្ច ឧប្បជ្ជតិ ។ បេ ។ បរិយេសនានា-នត្តំ នោ បរិយេសនានានត្តំ បដិច្ច ឧប្បជ្ជតិ បរិឡាហ-នានត្តំ នោ បរិឡាហនានត្តំ បដិច្ច ឧប្បជ្ជតិ ឆន្ទនានត្តំ នោ ឆន្ទនានត្តំ បដិច្ច ឧប្បជ្ជតិ សង្កប្បនានត្តំ នោ សង្កប្បនានត្តំ បដិច្ច ឧប្បជ្ជតិ សញ្ញានានត្តំ នោ សញ្ញានានត្តំ បដិច្ច ឧប្បជ្ជតិ ធាតុនានត្តំ ។ កាតមញ្ច ភិក្ខវេ ធាតុនានត្តំ ។ រូបធាតុ ។ បេ ។ ធម្មធាតុ ។ ឥទំ វុច្ចតិ ភិក្ខវេ ធាតុនានត្តំ ។

ធាតុសំយុត្ត នានត្តវគ្គ ធាតុមានសភាពផ្សេងគ្នា

[១៤] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ក្នុងទីនោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សញ្ញាមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យធាតុមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យសញ្ញាមានសភាពផ្សេងគ្នា ។ បេ ។ បរិយេសនាមានសភាពផ្សេងគ្នា មិនមែនបរិឡាហៈ មានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យបរិយេសនា មានសភាពផ្សេងគ្នា មិនមែនឆន្ទៈមានសភាពផ្សេងគ្នាកើតឡើង ព្រោះអាស្រ័យបរិឡាហៈ មានសភាពផ្សេងគ្នា មិនមែនសង្កប្បៈមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យឆន្ទៈមានសភាពផ្សេងគ្នា មិនមែនសញ្ញាមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យសង្កប្បៈ មានសភាពផ្សេងគ្នា មិនមែនធាតុមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យសញ្ញាមានសភាពផ្សេងគ្នាទេ ។ ម្នាលភិក្ខុទាំងឡាយ ចុះធាតុមានសភាពផ្សេងគ្នា តើដូចម្តេច ។ រូបធាតុ ។ បេ ។ ធម្មធាតុ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធាតុមានសភាពផ្សេងគ្នា ។

[១៤] កាតមញ្ច ភិក្ខវេ ធាតុនានត្តំ បដិច្ច ឧប្បជ្ជតិ សញ្ញានានត្តំ សញ្ញានានត្តំ បដិច្ច ឧប្បជ្ជតិ ។ បេ ។ បរិយេសនានានត្តំ ជោ បរិយេសនានានត្តំ បដិច្ច ឧប្បជ្ជតិ បរិឡាហនានត្តំ ជោ បរិឡាហនានត្តំ បដិច្ច ឧប្បជ្ជតិ ឆន្ទនានត្តំ ជោ ឆន្ទនានត្តំ បដិច្ច ឧប្បជ្ជតិ សង្កប្បនានត្តំ ជោ សង្កប្បនានត្តំ បដិច្ច ឧប្បជ្ជតិ សញ្ញានានត្តំ ជោ សញ្ញានានត្តំ បដិច្ច ឧប្បជ្ជ-តិ ធាតុនានត្តំ ។ រូបធាតុំ ភិក្ខវេ បដិច្ច ឧប្បជ្ជតិ រូបសញ្ញា ។ បេ ។ ធម្មធាតុំ បដិច្ច ឧប្បជ្ជតិ ធម្ម-សញ្ញា ធម្មសញ្ញំ បដិច្ច ឧប្បជ្ជតិ ។ បេ ។ ធម្ម-បរិយេសនា ជោ ធម្មបរិយេសនំ បដិច្ច ឧប្បជ្ជតិ ធម្មបរិឡាហោ ជោ ធម្មបរិឡាហំ បដិច្ច ឧប្បជ្ជតិ ធម្មច្ឆន្ទោ ជោ ធម្មច្ឆន្ទំ បដិច្ច ឧប្បជ្ជតិ ធម្មសង្កប្បោ

[១៥] ម្នាលភិក្ខុទាំងឡាយ ចុះសញ្ញាមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យធាតុមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យសញ្ញាមានសភាពផ្សេងគ្នា ។ បេ ។ បរិយេសនាមានសភាពផ្សេងគ្នា មិនមែនបរិឡាហៈមានសភាពផ្សេងគ្នាកើតឡើង ព្រោះអាស្រ័យបរិយេសនាមានសភាពផ្សេងគ្នា មិនមែនឆន្ទៈមានសភាពផ្សេងគ្នាកើតឡើង ព្រោះអាស្រ័យបរិឡាហៈមានសភាពផ្សេងគ្នា មិនមែនសង្កប្បៈមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យឆន្ទៈមានសភាពផ្សេងគ្នា មិនមែនសញ្ញាមានសភាពផ្សេងគ្នាកើតឡើង ព្រោះអាស្រ័យសង្កប្បៈមានសភាពផ្សេងគ្នា មិនមែនធាតុមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យសញ្ញាមានសភាពផ្សេងគ្នា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ រូបសញ្ញាកើតឡើង ព្រោះអាស្រ័យរូបធាតុ ។ បេ ។ ធម្មសញ្ញាកើតឡើង ព្រោះអាស្រ័យធម្មធាតុ កើតឡើង ព្រោះអាស្រ័យធម្មសញ្ញា ។ បេ ។ ធម្មបរិយេសនា មិនមែនធម្មបរិឡាហៈកើតឡើង ព្រោះអាស្រ័យធម្មបរិយេសនា មិនមែនធម្មច្ឆន្ទៈកើតឡើង ព្រោះអាស្រ័យធម្មបរិឡាហៈ មិនមែនធម្មសង្កប្បៈកើតឡើង ព្រោះអាស្រ័យធម្មច្ឆន្ទៈ

នោ ធម្មសង្កប្បំ បដិច្ច ឧប្បជ្ជតិ ធម្មសញ្ញា នោ ធម្មសញ្ញំ បដិច្ច ឧប្បជ្ជតិ ធម្មធាតុ ។ ឯវំ ខោ ភិក្ខវេ ធាតុនានត្តំ បដិច្ច ឧប្បជ្ជតិ សញ្ញានានត្តំ សញ្ញានានត្តំ បដិច្ច ឧប្បជ្ជតិ ។ បេ ។ បរិយេសនានានត្តំ នោ បរិយេសនានានត្តំ បដិច្ច ឧប្បជ្ជតិ ។ បេ ។ សញ្ញានានត្តំ នោ សញ្ញានានត្តំ បដិច្ច ឧប្បជ្ជតិ ធាតុនានត្តន្តិ ។ អដ្ឋមំ ។

[១៦] សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា... ធាតុនានត្តំ ភិក្ខវេ បដិច្ច ឧប្បជ្ជតិ សញ្ញានានត្តំ

មិនមែនធម្មសញ្ញាកើតឡើង ព្រោះអាស្រ័យធម្មសង្កប្បៈ មិនមែនធម្មធាតុកើតឡើង ព្រោះអាស្រ័យធម្មសញ្ញាទេ ។ ម្នាលភិក្ខុទាំងឡាយ សញ្ញាមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យធាតុមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យសញ្ញាមានសភាពផ្សេងគ្នា ។ បេ ។ បរិយេសនាមានសភាពផ្សេងគ្នា មិនមែនកើតឡើង ព្រោះអាស្រ័យបរិយេសនាមានសភាពផ្សេងគ្នា ។ បេ ។ សញ្ញាមានសភាពផ្សេងគ្នា មិនមែនធាតុមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យសញ្ញាមានសភាពផ្សេងគ្នា យ៉ាងនេះឯង ។ ចប់សូត្រទី ៨ ។

[១៦] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ក្នុងទីនោះឯង ព្រះមានព្រះភាគ... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សញ្ញាមានសភាពផ្សេងគ្នាកើតឡើង ព្រោះអាស្រ័យធាតុមានសភាពផ្សេងគ្នា

សញ្ញាធាតុំ បដិច្ច ឧប្បជ្ជតិ សង្កប្បធាតុំ សង្កប្ប-ធាតុំ បដិច្ច ឧប្បជ្ជតិ ផស្សធាតុំ ផស្សធាតុំ បដិច្ច ឧប្បជ្ជតិ វេទនាធាតុំ វេទនាធាតុំ បដិច្ច ឧប្បជ្ជតិ ឆន្ទធាតុំ ឆន្ទធាតុំ បដិច្ច ឧប្បជ្ជតិ បរិឡាហធាតុំ បរិឡាហធាតុំ បដិច្ច ឧប្បជ្ជតិ បរិយេសនាធាតុំ បរិយេសនាធាតុំ បដិច្ច ឧប្បជ្ជតិ លាភធាតុំ ។ កាតមញ្ច ភិក្ខវេ ធាតុនានត្តំ ។ រូបធាតុ ។ បេ ។ ធម្មធាតុ ។ ឥទំ វុច្ចតិ ភិក្ខវេ ធាតុនានត្តំ ។

[១៧] កាតមញ្ច ភិក្ខវេ ធាតុនានត្តំ បដិច្ច ឧប្បជ្ជតិ សញ្ញានានត្តំ ។ បេ ។ បរិយេសនានានត្តំ បដិច្ច ឧប្បជ្ជតិ ។ បេ ។ លាភនានត្តំ ។ រូបធាតុំ ភិក្ខវេ បដិច្ច ឧប្បជ្ជតិ រូបសញ្ញា រូបសញ្ញំ បដិច្ច ឧប្បជ្ជតិ រូប-

សង្កប្បៈមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យសញ្ញា មានសភាពផ្សេងគ្នា ផស្សៈមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យសង្កប្បៈមានសភាពផ្សេងគ្នា វេទនាមានសភាពផ្សេងគ្នាកើតឡើង ព្រោះអាស្រ័យផស្សៈមានសភាពផ្សេងគ្នា ឆន្ទៈមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យវេទនាមានសភាពផ្សេងគ្នា បរិឡាហៈមានសភាពផ្សេងគ្នាកើតឡើង ព្រោះអាស្រ័យឆន្ទៈមានសភាពផ្សេងគ្នា បរិយេសនាមានសភាពផ្សេងគ្នាកើតឡើង ព្រោះអាស្រ័យបរិឡាហៈ មានសភាពផ្សេងគ្នា លាភមានសភាពផ្សេងគ្នាកើតឡើង ព្រោះអាស្រ័យបរិយេសនាមានសភាពផ្សេងគ្នា ។ ម្នាលភិក្ខុទាំងឡាយ ចុះធាតុមានសភាពផ្សេងគ្នា តើដូចម្តេច ។ រូបធាតុ ។ បេ ។ ធម្មធាតុ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធាតុមានសភាពផ្សេងគ្នា ។

[១៧] ម្នាលភិក្ខុទាំងឡាយ ចុះសញ្ញាមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យធាតុមានសភាពផ្សេងគ្នា ។ បេ ។ កើតឡើង ព្រោះអាស្រ័យបរិយេសនា មានសភាពផ្សេងគ្នា ។ បេ ។ លាភមានសភាពផ្សេងគ្នា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ រូបសញ្ញាកើតឡើង ព្រោះអាស្រ័យរូបធាតុ រូបសង្កប្បៈកើតឡើង ព្រោះអាស្រ័យរូបសញ្ញា

សង្កប្បោ រូបសង្កប្បំ បដិច្ច ឧប្បជ្ជតិ រូបសម្ផស្សោ រូបសម្ផស្សំ បដិច្ច ឧប្បជ្ជតិ រូបសម្ផស្សជា វេទនា រូបសម្ផស្សជំ វេទនំ បដិច្ច ឧប្បជ្ជតិ រូបច្ឆន្ទោ រូបច្ឆន្ទំ បដិច្ច ឧប្បជ្ជតិ រូបបរិឡាហោ រូបបរិឡាហំ បដិច្ច ឧប្បជ្ជតិ រូបបរិយេសនា រូបបរិយេសនំ បដិច្ច ឧប្បជ្ជតិ រូបលាភោ ។ បេ ។ ធម្មធាតុំ បដិច្ច ឧប្បជ្ជតិ ធម្មសញ្ញា ធម្មសញ្ញំ បដិច្ច ឧប្បជ្ជតិ ធម្មសង្កប្បោ ធម្មសង្កប្បំ បដិច្ច ឧប្បជ្ជតិ ធម្មសម្ផស្សោ ធម្មសម្ផស្សំ បដិច្ច ឧប្បជ្ជតិ ធម្មសម្ផស្សជា វេទនា ធម្មសម្ផស្សជំ វេទនំ បដិច្ច ឧប្បជ្ជតិ ធម្មច្ឆន្ទោ ធម្មច្ឆន្ទំ បដិច្ច ឧប្បជ្ជតិ ធម្មបរិឡាហោ ធម្មបរិឡាហំ បដិច្ច ឧប្បជ្ជតិ ធម្មបរិយេសនា ធម្មបរិយេសនំ បដិច្ច ឧប្បជ្ជតិ ធម្មលាភោ ។ ឯវំ ខោ ភិក្ខវេ ធាតុនានត្តំ បដិច្ច ឧប្បជ្ជតិ សញ្ញានានត្តំ សញ្ញានានត្តំ បដិច្ច ឧប្បជ្ជតិ ។ បេ ។ បរិយេសនានានត្តំ បដិច្ច ឧប្បជ្ជតិ លាភនានត្តន្តិ ។ នវមំ ។

រូបសម្ផស្សកើតឡើង ព្រោះអាស្រ័យរូបសង្កប្បៈ វេទនាដែលកើតអំពីរូបសម្ផស្សកើតឡើង ព្រោះអាស្រ័យរូបសម្ផ័ស្ស រូបច្ឆន្ទៈកើតឡើង ព្រោះអាស្រ័យវេទនាដែលកើតអំពីរូបសម្ផ័ស្ស រូបបរិឡាហៈកើតឡើង ព្រោះអាស្រ័យរូបច្ឆន្ទៈ រូបបរិយេសនាកើតឡើង ព្រោះអាស្រ័យរូបបរិឡាហៈ រូបលាភកើតឡើង ព្រោះអាស្រ័យរូបបរិយេសនា ។ បេ ។ ធម្មសញ្ញាកើតឡើង ព្រោះអាស្រ័យធម្មធាតុ ធម្មសង្កប្បៈកើតឡើង ព្រោះអាស្រ័យធម្មសញ្ញា ធម្មសម្ផ័ស្សកើតឡើង ព្រោះអាស្រ័យធម្មសម្ផស្ស ធម្មច្ឆន្ទៈកើតឡើង ព្រោះអាស្រ័យវេទនាកើតអំពីធម្មសម្ផស្ស ធម្មបរិឡាហៈកើតឡើង ព្រោះអាស្រ័យធម្មច្ឆន្ទៈ ធម្មបរិយេសនាកើតឡើង ព្រោះអាស្រ័យធម្មបរិឡាហៈ ធម្មលាភកើតឡើង ព្រោះអាស្រ័យធម្មបរិយេសនា ។ ម្នាលភិក្ខុទាំងឡាយ សញ្ញាមានសភាពផ្សេងគ្នាកើតឡើង ព្រោះអាស្រ័យសញ្ញាមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យសញ្ញាមានសភាពផ្សេងគ្នា ។ បេ ។ លាភមានសភាពផ្សេងគ្នាកើតឡើង ព្រោះអាស្រ័យបរិយេសនា មានសភាពផ្សេងគ្នា យ៉ាងនេះឯង ។ ចប់សូត្រទី ៩ ។

[១៨] សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា ធា-
តុនានត្តំ ភិក្ខវេ បដិច្ច ឧប្បជ្ជតិ សញ្ញានានត្តំ សញ្ញា-
នានត្តំ បដិច្ច ឧប្បជ្ជតិ សង្កប្បនានត្តំ ផស្ស... វេទនា...
ឆន្ទ... បរិឡាហ... បរិយេសនានានត្តំ បដិច្ច ឧប្បជ្ជ-
តិ លាភនានត្តំ នោ លាភនានត្តំ បដិច្ច ឧប្បជ្ជតិ
បរិយេសនានានត្តំ នោ បរិយេសនានានត្តំ បដិច្ច
ឧប្បជ្ជតិ បរិឡាហនានត្តំ នោ បរិឡាហនានត្តំ បដិច្ច
ឧប្បជ្ជតិ ឆន្ទនានត្តំ វេទនា... ផស្ស... សង្កប្ប...
សញ្ញានានត្តំ នោ សញ្ញានានត្តំ បដិច្ច ឧប្បជ្ជតិ ធាតុ-
នានត្តំ ។ កតមញ្ច ភិក្ខវេ ធាតុនានត្តំ ។ រូបធាតុ
។ បេ ។ ធម្មធាតុ ។ ឥទំ វុច្ចតិ ភិក្ខវេ ធាតុនានត្តំ ។

[១៨] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ក្នុងទីនោះឯង ព្រះមានព្រះភាគ... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សញ្ញាមានសភាពផ្សេងគ្នាកើតឡើង ព្រោះអាស្រ័យធាតុ មានសភាពផ្សេងគ្នា សង្កប្បៈមានសភាពផ្សេងគ្នាកើតឡើង ព្រោះអាស្រ័យសញ្ញាមានសភាពផ្សេងគ្នា ផស្សៈ... វេទនា... ឆន្ទៈ... បរិឡាហៈ... លាភមានសភាពផ្សេងគ្នាកើតឡើង ព្រោះអាស្រ័យបរិយេសនា មានសភាពផ្សេងគ្នា មិនមែនបរិយេសនាមានសភាពផ្សេងគ្នាកើតឡើង ព្រោះអាស្រ័យលាភមានសភាពផ្សេងគ្នា មិនមែនបរិឡាហៈមានសភាពផ្សេងគ្នាកើតឡើង ព្រោះអាស្រ័យបរិយេសនាមានសភាពផ្សេងគ្នា មិនមែនឆន្ទៈមានសភាពផ្សេងគ្នាកើតឡើង ព្រោះអាស្រ័យបរិឡាហៈមានសភាពផ្សេងគ្នា វេទនា... ផស្សៈ... សង្កប្បៈ... សញ្ញាមានសភាពផ្សេងគ្នា មិនមែនធាតុមានសភាពផ្សេងគ្នាកើតឡើង ព្រោះអាស្រ័យសញ្ញាមានសភាពផ្សេងគ្នាទេ ។ ម្នាលភិក្ខុទាំងឡាយ ចុះធាតុមានសភាពផ្សេងគ្នា តើដូចម្តេច ។ រូបធាតុ ។ បេ ។ ធម្មធាតុ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធាតុមានសភាពផ្សេងគ្នា ។

ធាតុសំយុត្តស្ស នានត្តវគ្គោ ធាតុនានត្តំ

[១៩] កាតមញ្ច ភិក្ខវេ ធាតុនានត្តំ បដិច្ច ឧប្បជ្ជតិ សញ្ញានានត្តំ សញ្ញានានត្តំ បដិច្ច ឧប្បជ្ជតិ សង្កប្បនានត្តំ ផស្ស... វេទនា... ឆន្ទ... បរិឡាហ... បរិយេសនា... លាភនានត្តំ នោ លាភនានត្តំ បដិច្ច ឧប្បជ្ជតិ បរិយេសនានានត្តំ បរិឡាហ... ឆន្ទ... វេទនា... ផស្សនានត្តំ នោ សង្កប្បនានត្តំ បដិច្ច ឧប្បជ្ជតិ សញ្ញានានត្តំ នោ សញ្ញានានត្តំ បដិច្ច ឧប្បជ្ជតិ ធាតុនានត្តំ ។ រូបធាតុំ ភិក្ខវេ បដិច្ច ឧប្បជ្ជតិ រូបសញ្ញា ។ បេ ។ ធម្មធាតុំ បដិច្ច ឧប្បជ្ជតិ ធម្មសញ្ញា ធម្មសញ្ញំ បដិច្ច ឧប្បជ្ជតិ ។ បេ ។ ធម្មបរិយេសនា ធម្មបរិយេសនំ បដិច្ច ឧប្បជ្ជតិ ធម្មលាភោ នោ ធម្មលាភំ បដិច្ច ឧប្បជ្ជតិ ធម្មបរិយេសនា នោ ធម្មបរិយេសនានំ បដិច្ច ឧប្បជ្ជតិ ធម្មបរិឡាហោ

ធាតុសំយុត្ត នានត្តវគ្គ ធាតុមានសភាពផ្សេងគ្នា

[១៩] ម្នាលភិក្ខុទាំងឡាយ ចុះសញ្ញាមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យធាតុមានសភាពផ្សេងគ្នា សង្កប្បៈមានសភាពផ្សេងគ្នាកើតឡើង ព្រោះអាស្រ័យសញ្ញាមានសភាពផ្សេងគ្នា ផស្ស... វេទនា... ឆន្ទៈ... បរិឡាហៈ... បរិយេសនា... លាភមានសភាពផ្សេងគ្នា មិនមែនបរិយេសនាមានសភាពផ្សេងគ្នាកើតឡើង ព្រោះអាស្រ័យលាភមានសភាពផ្សេងគ្នា បរិឡាហៈ... ឆន្ទៈ... វេទនា... ផស្សៈមានសភាពផ្សេងគ្នា មិនមែនសញ្ញាមានសភាពផ្សេងគ្នាកើតឡើង ព្រោះអាស្រ័យសង្កប្បៈមានសភាពផ្សេងគ្នា មិនមែនធាតុមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យសញ្ញាមានសភាពផ្សេងគ្នា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ រូបសញ្ញាកើតឡើង ព្រោះអាស្រ័យរូបធាតុ ។ បេ ។ ធម្មសញ្ញាកើតឡើង ព្រោះអាស្រ័យធម្មធាតុ កើតឡើង ព្រោះអាស្រ័យធម្មសញ្ញា ។ បេ ។ ធម្មបរិយេសនា ធម្មលាភកើតឡើង ព្រោះអាស្រ័យធម្មបរិយេសនា មិនមែនធម្មបរិយេសនាកើតឡើង ព្រោះអាស្រ័យធម្មលាភ មិនមែនធម្មបរិឡាហៈកើតឡើង ព្រោះអាស្រ័យធម្មបរិយេសនា

១៨



នោ ធម្មបរិឡាហំ បដិច្ច ឧប្បជ្ជតិ ធម្មច្ឆន្ទោ នោ ធម្មច្ឆន្ទំ បដិច្ច ឧប្បជ្ជតិ ធម្មសម្ផស្សជា វេទនា នោ ធម្មសម្ផស្សជំ វេទនំ បដិច្ច ឧប្បជ្ជតិ ធម្មសម្ផស្សោ នោ ធម្មសម្ផស្សំ បដិច្ច ឧប្បជ្ជតិ ធម្មសង្កប្បោ នោ ធម្មសង្កប្បំ បដិច្ច ឧប្បជ្ជតិ ធម្មសញ្ញា នោ ធម្មសញ្ញំ បដិច្ច ឧប្បជ្ជតិ ធម្មធាតុ ។ ឯវំ ខោ ភិក្ខវេ ធាតុនានត្តំ បដិច្ច ឧប្បជ្ជតិ សញ្ញានានត្តំ សញ្ញានានត្តំ បដិច្ច ឧប្បជ្ជតិ សង្កប្បនានត្តំ ផស្ស... វេទនា... ឆន្ទ... បរិឡាហ... បរិយេសនា... លាភនានត្តំ នោ បរិយេសនានានត្តំ បដិច្ច ឧប្បជ្ជតិ បរិឡាហនានត្តំ នោ បរិឡាហនានត្តំ បដិច្ច ឧប្បជ្ជតិ ឆន្ទនានត្តំ នោ ឆន្ទនានត្តំ បដិច្ច ឧប្បជ្ជតិ វេទនានានត្តំ នោ វេទនានានត្តំ បដិច្ច ឧប្បជ្ជតិ ផស្សនានត្តំ នោ ផស្សនានត្តំ បដិច្ច ឧប្បជ្ជតិ សង្កប្បនានត្តំ

មិនមែនធម្មច្ឆន្ទៈកើតឡើង ព្រោះអាស្រ័យធម្មបរិឡាហៈ មិនមែនវេទនាដែលកើតអំពីធម្មសម្ផស្សៈកើតឡើង ព្រោះអាស្រ័យធម្មច្ឆន្ទៈ មិនមែនធម្មសម្ផស្សៈកើតឡើង ព្រោះអាស្រ័យវេទនាកើតអំពីធម្មសម្ផស្សៈ មិនមែនធម្មសង្កប្បៈកើតឡើង ព្រោះអាស្រ័យធម្មសម្ផស្សៈ មិនមែនធម្មសញ្ញាកើតឡើង ព្រោះអាស្រ័យធម្មសង្កប្បៈ មិនមែនធម្មធាតុកើតឡើង ព្រោះអាស្រ័យធម្មសញ្ញាទេ ។ ម្នាលភិក្ខុទាំងឡាយ សញ្ញាមានសភាពផ្សេងគ្នាកើតឡើង ព្រោះអាស្រ័យធាតុមានសភាពផ្សេងគ្នា សង្កប្បៈមានសភាពផ្សេងគ្នាកើតឡើង ព្រោះអាស្រ័យសញ្ញាមានសភាពផ្សេងគ្នា ផស្សៈ... វេទនា... ឆន្ទៈ... បរិឡាហៈ... បរិយេសនា... លាភមានសភាពផ្សេងគ្នា មិនមែនបរិយេសនាមានសភាពផ្សេងគ្នាកើតឡើង ព្រោះអាស្រ័យលាភមានសភាពផ្សេងគ្នា មិនមែនបរិឡាហៈមានសភាពផ្សេងគ្នាកើតឡើង ព្រោះអាស្រ័យបរិយេសនាមានសភាពផ្សេងគ្នា មិនមែនឆន្ទៈមានសភាពផ្សេងគ្នាកើតឡើង ព្រោះអាស្រ័យបរិឡាហៈមានសភាពផ្សេងគ្នា មិនមែនវេទនាមានសភាពផ្សេងគ្នាកើតឡើង ព្រោះអាស្រ័យឆន្ទៈមានសភាពផ្សេងគ្នា មិនមែនផស្សៈមានសភាពផ្សេងគ្នាកើតឡើង ព្រោះអាស្រ័យវេទនាមានសភាពផ្សេងគ្នា មិនមែនសង្កប្បៈមានសភាពផ្សេងគ្នាកើតឡើង ព្រោះអាស្រ័យផស្សៈមានសភាពផ្សេងគ្នា

១៩

ធាតុសំយុត្តស្ស នានត្តវគ្គេ ឧទ្ទានំ

នោ សង្កប្បនានត្តំ ឧប្បជ្ជតិ សញ្ញានានត្តំ នោ សញ្ញានានត្តំ បដិច្ច ឧប្បជ្ជតិ ធាតុនានត្តន្តិ ។ ទសមំ ។

នានត្តវគ្គោ បឋមោ ។

## តស្ស ឧទ្ទានំ

ធាតុសម្ផស្សញ្ច នោ ចេតំ
វេទនា អបរេ ទុវេ
ឯតំ អជ្ឈត្តបញ្ចកំ
ធាតុសញ្ញា ច នោ ចេតំ
ផស្សស្ស អបរេ ទុវេ
ឯតំ ពាហិរបញ្ចកំ ។

---

១៩

ធាតុសំយុត្ត នានត្តវគ្គ ឧទ្ទាន

មិនមែនសញ្ញាមានសភាពផ្សេងគ្នា កើតឡើង ព្រោះអាស្រ័យសង្កប្បៈ មានសភាពផ្សេងគ្នា មិនមែនធាតុមានសភាពផ្សេងគ្នា កើតឡើង ព្រោះ អាស្រ័យសញ្ញាមានសភាពផ្សេងគ្នា យ៉ាងនេះឯង ។ ចប់សូត្រទី ១០ ។

ចប់ នានត្តវគ្គ ទី ១ ។

# ឧទ្ទាននៃនានត្តវគ្គនោះគឺ

សំដែងអំពីធាតុ ១ អំពីសម្ផស្ស ១ អំពីធាតុមានសភាពផ្សេង គ្នា មិនអាស្រ័យនូវផស្សៈមានសភាពផ្សេងគ្នាជាដើម ១ អំពី វេទនាមានសភាពផ្សេងគ្នា អាស្រ័យនូវផស្សៈមានសភាព ផ្សេងគ្នា មានពីរលើក នេះហៅថា បញ្ចកៈខាងក្នុង អំពី ធាតុ ១ អំពីសញ្ញា ១ អំពីបរិឡាហៈមានសភាពផ្សេងគ្នា មិនអាស្រ័យនូវបរិយេសនា មានសភាពផ្សេងគ្នាជាដើម ១ អំពីផស្សៈមានពីរលើក នេះហៅថា បញ្ចកៈខាងក្រៅ ។

# សត្តធាតុវគ្គោ

[២០] សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា... សត្តិមា ភិក្ខវេ ធាតុយោ ។ កតមា សត្ត ។ អាភាធាតុ សុភាធាតុ អាកាសានញ្ចាយតនធាតុ វិញ្ញាណញ្ចាយតនធាតុ អាកិញ្ចញ្ញាយតនធាតុ នេវសញ្ញានាសញ្ញាយតនធាតុ សញ្ញាវេទយិតនិរោធធាតុ ។ ឥមា ខោ ភិក្ខវេ សត្ត ធាតុយោតិ ។ ឯវំ វុត្តេ អញ្ញតរោ ភិក្ខុ ភគវន្តំ ឯតទវោច យា ចាយំ ភន្តេ អាភាធាតុ យា ច សុភាធាតុ យា ច អាកាសានញ្ចាយតនធាតុ យា ច វិញ្ញាណញ្ចាយតនធាតុ យា ច អាកិញ្ចញ្ចាយតនធាតុ យា ច នេវសញ្ញានាសញ្ញាយតនធាតុ យា ច សញ្ញាវេទយិតនិរោធធាតុ ឥមា នុ ខោ ភន្តេ ធាតុយោ កឹ បដិច្ច បញ្ញាយន្តីតិ ។

# សត្តធាតុវគ្គ

[២០] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ក្នុងទីនោះឯង ព្រះមានព្រះភាគ... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធាតុទាំងឡាយនេះ មាន ៧ ប្រការ ។ ធាតុទាំង ៧ ប្រការ តើដូចម្តេចខ្លះ ។ អាភាធាតុ ១ សុភាធាតុ ១ អាកាសានញ្ចាយតនធាតុ ១ វិញ្ញាណញ្ចាយតនធាតុ ១ អាកិញ្ចញ្ញាយតនធាតុ ១ នេវសញ្ញានាសញ្ញាយតនធាតុ ១ សញ្ញាវេទយិតនិរោធធាតុ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងជាធាតុ ៧ ប្រការ ។ កាលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ភិក្ខុមួយរូប ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ធាតុដែលហៅថា អាភាធាតុក្តី សុភាធាតុក្តី អាកាសានញ្ចាយតនធាតុក្តី វិញ្ញាណញ្ចាយតនធាតុក្តី អាកិញ្ចញ្ញាយតនធាតុក្តី នេវសញ្ញានាសញ្ញាយតនធាតុក្តី សញ្ញាវេទយិតនិរោធធាតុក្តី បពិត្រព្រះអង្គដ៏ចម្រើន តើធាតុទាំងនេះ ប្រាកដឡើង ព្រោះអាស្រ័យអ្វី ។

## ២១

### ធាតុសំយុត្តស្ស សត្តធាតុវគ្គេ អាភាធាត្វាទិ

[២១] យាយំ ភិក្ខុ អាភាធាតុ អយំ ធាតុ អន្ធ-
ការំ បដិច្ច បញ្ញាយតិ ។ យាយំ ភិក្ខុ សុភាធាតុ
អយំ ធាតុ អសុភំ បដិច្ច បញ្ញាយតិ ។ យាយំ ភិក្ខុ
អាកាសានញ្ចាយតនធាតុ អយំ ធាតុ រូបំ បដិច្ច
បញ្ញាយតិ ។ យាយំ ភិក្ខុ វិញ្ញាណញ្ចាយតនធាតុ
អយំ ធាតុ អាកាសានញ្ចាយតនំ បដិច្ច បញ្ញាយតិ ។
យាយំ ភិក្ខុ អាកិញ្ចញ្ញាយតនធាតុ អយំ ធាតុ
វិញ្ញាណញ្ចាយតនំ បដិច្ច បញ្ញាយតិ ។ យាយំ
ភិក្ខុ នេវសញ្ញានាសញ្ញាយតនធាតុ អយំ ធាតុ អា-
កិញ្ចញ្ញាយតនំ បដិច្ច បញ្ញាយតិ ។ យាយំ ភិក្ខុ
សញ្ញាវេទយិតនិរោធធាតុ អយំ ធាតុ និរោធំ បដិច្ច
បញ្ញាយតីតិ ។ យា ចាយំ ភន្តេ អាភាធាតុ យា ច
សុភាធាតុ យា ច អាកាសានញ្ចាយតនធាតុ យា ច
វិញ្ញាណញ្ចាយតនធាតុ យា ច អាកិញ្ចញ្ញាយតនធាតុ
យា ច នេវសញ្ញានាសញ្ញាយតនធាតុ យា ច សញ្ញា-
វេទយិតនិរោធធាតុ ឥមា នុ ខោ ភន្តេ ធាតុយោ
កថំ សមាបត្តិ បត្តព្វាតិ ។

ធាតុសំយុត្ត សត្តធាតុវគ្គ អាភាធាតុជាដើម

[២១] ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុ ធាតុដែលហៅថា អាភាធាតុ (រស្មីឬពន្លឺ) នេះ ប្រាកដឡើង ព្រោះអាស្រ័យងងឹត ។ ម្នាលភិក្ខុ ធាតុដែលហៅថា សុភាធាតុនេះ ប្រាកដឡើង ព្រោះអាស្រ័យអសុភ ។ ម្នាលភិក្ខុ ធាតុដែលហៅថា អាកាសានញ្ចាយតនធាតុនេះ ប្រាកដឡើង ព្រោះអាស្រ័យរូប ។ ម្នាលភិក្ខុ ធាតុដែលហៅថា វិញ្ញាណញ្ចាយតនធាតុនេះ ប្រាកដឡើង ព្រោះអាស្រ័យអាកាសានញ្ចាយតនៈ ។ ម្នាលភិក្ខុ ធាតុដែលហៅថា អាកិញ្ចញ្ញាយតនធាតុនេះ ប្រាកដឡើង ព្រោះអាស្រ័យវិញ្ញាណញ្ចាយតនៈ ។ ម្នាលភិក្ខុ ធាតុដែលហៅថា នេវសញ្ញានាសញ្ញាយតនធាតុនេះ ប្រាកដឡើង ព្រោះអាស្រ័យអាកិញ្ចញ្ញាយតនៈ ។ ម្នាលភិក្ខុ ធាតុដែលហៅថា សញ្ញាវេទយិតនិរោធធាតុនេះ ប្រាកដឡើង ព្រោះអាស្រ័យនិរោធ ។ ភិក្ខុនោះក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ធាតុដែលហៅថា អាភាធាតុក្ដី សុភាធាតុក្ដី អាកាសានញ្ចាយតនធាតុក្ដី វិញ្ញាណញ្ចាយតនធាតុក្ដី អាកិញ្ចញ្ញាយតនធាតុក្ដី នេវសញ្ញានាសញ្ញាយតនធាតុក្ដី សញ្ញាវេទយិតនិរោធធាតុក្ដី បពិត្រព្រះអង្គដ៏ចម្រើន ធាតុទាំងនេះ ឈ្មោះថាជាសមាបត្តិអ្វី ដែលបុគ្គលគប្បីដល់ ។

[២២] យា ចាយំ ភិក្ខុ អាភាធាតុ យា ច សុភា-
ធាតុ យា ច អាកាសានញ្ចាយតនធាតុ យា ច វិញ្ញា-
ណញ្ចាយតនធាតុ យា ច អាកិញ្ចញ្ញាយតនធាតុ ឥមា
ធាតុយោ សញ្ញាសមាបត្តិ បត្តព្វា ។ យាយំ ភិក្ខុ
នេវសញ្ញានាសញ្ញាយតនធាតុ អយំ ធាតុ សង្ខារាវសេ-
សសមាបត្តិ បត្តព្វា ។ យាយំ ភិក្ខុ សញ្ញាវេទយិត-
និរោធធាតុ អយំ ធាតុ និរោធសមាបត្តិ បត្តព្វាតិ ។
បឋមំ ។

[២៣] សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា...
សនិទានំ ភិក្ខវេ ឧប្បជ្ជតិ កាមវិតក្កោ នោ អនិទានំ
សនិទានំ ឧប្បជ្ជតិ ព្យាបាទវិតក្កោ នោ អនិទានំ ស-
និទានំ ឧប្បជ្ជតិ វិហឹសាវិតក្កោ នោ អនិទានំ ។

[២២] ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុ ធាតុដែលហៅថា អាភាធាតុក្តី សុភាធាតុក្តី អាកាសានញ្ចាយតនធាតុក្តី វិញ្ញាណញ្ចាយតនធាតុក្តី អាកិញ្ចញ្ញាយតនធាតុក្តី ធាតុទាំងនេះ ឈ្មោះថា សញ្ញាសមាបត្តិ ដែលបុគ្គលគប្បីដល់ ។ ម្នាលភិក្ខុ ធាតុដែលហៅថា នេវសញ្ញានាសញ្ញាយតនធាតុនេះ ឈ្មោះថា សង្ខារាវសេសសមាបត្តិ ដែលបុគ្គលគប្បីដល់ ។ ម្នាលភិក្ខុ ធាតុដែលហៅថា សញ្ញាវេទយិតនិរោធធាតុនេះ ឈ្មោះថា និរោធសមាបត្តិ ដែលបុគ្គលគប្បីដល់ ។ ចប់សូត្រទី ១ ។

[២៣] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ក្នុងទីនោះឯង ព្រះមានព្រះភាគ... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាមវិតក្កៈ (សេចក្តីត្រិះរិះក្នុងកាម) ប្រកបដោយហេតុ ទើបកើតឡើងបាន មិនមែនជាមិនមានហេតុទេ ព្យាបាទវិតក្កៈ (សេចក្តីត្រិះរិះក្នុងការព្យាបាទ) ប្រកបដោយហេតុ ទើបកើតឡើងបាន មិនមែនជាមិនមានហេតុទេ វិហឹសាវិតក្កៈ (សេចក្តីត្រិះរិះក្នុងការបៀតបៀន) ប្រកបដោយហេតុ ទើបកើតឡើងបាន មិនមែនជាមិនមានហេតុទេ ។

ធាតុសំយុត្តស្ស សត្តធាតុវគ្គេ កាមវិតក្កាទិឧប្បត្តិ

[២៤] កថញ្ច ភិក្ខវេ សនិទានំ ឧប្បជ្ជតិ កាម-
វិតក្កោ នោ អនិទានំ សនិទានំ ឧប្បជ្ជតិ ព្យាបាទវិ-
តក្កោ នោ អនិទានំ សនិទានំ ឧប្បជ្ជតិ វិហឹសាវិ-
តក្កោ នោ អនិទានំ ។ កាមធាតុំ ភិក្ខវេ បដិច្ច
ឧប្បជ្ជតិ កាមសញ្ញា កាមសញ្ញំ បដិច្ច ឧប្បជ្ជតិ
កាមសង្កប្បោ កាមសង្កប្បំ បដិច្ច ឧប្បជ្ជតិ កា-
មច្ឆន្ទោ កាមច្ឆន្ទំ បដិច្ច ឧប្បជ្ជតិ កាមបរិឡាហោ
កាមបរិឡាហំ បដិច្ច ឧប្បជ្ជតិ កាមបរិយេសនា ។
កាមបរិយេសនំ ភិក្ខវេ បរិយេសមានោ អស្សុតវា
បុថុជ្ជនោ តីហិ ឋានេហិ មិច្ឆា បដិបជ្ជតិ កាយេន
វាចាយ មនសា ។ ព្យាបាទធាតុំ ភិក្ខវេ បដិច្ច
ឧប្បជ្ជតិ ព្យាបាទសញ្ញា ព្យាបាទសង្កប្បោ... ព្យាបា-
ទច្ឆន្ទោ... ព្យាបាទបរិឡាហោ... ព្យាបាទបរិយេសនា ។

ធាតុសំយុត្ត សត្តធាតុវគ្គ ការកើតឡើងនៃកាមវិតក្កជាដើម

[២៤] ម្នាលភិក្ខុទាំងឡាយ ចុះកាមវិតក្កប្រកបដោយហេតុ ទើបកើតឡើង មិនមែនជាមិនមានហេតុ ព្យាបាទវិតក្កៈប្រកបដោយហេតុ ទើបកើតឡើង មិនមែនជាមិនមានហេតុ វិហឹសាវិតក្កៈប្រកបដោយហេតុ ទើបកើតឡើង មិនមែនជាមិនមានហេតុទេ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កាមសញ្ញា (សេចក្តីសម្គាល់ក្នុងកាម) កើតឡើង ព្រោះអាស្រ័យកាមធាតុ កាមសង្កប្បៈ (សេចក្តីត្រិះរិះក្នុងកាម) កើតឡើង ព្រោះអាស្រ័យកាមសញ្ញា កាមច្ឆន្ទៈ (សេចក្តីប្រាថ្នាក្នុងកាម) កើតឡើង ព្រោះអាស្រ័យកាមសង្កប្បៈ កាមបរិឡាហៈ (សេចក្តីក្រហល់ក្រហាយក្នុងកាម) កើតឡើង ព្រោះអាស្រ័យកាមច្ឆន្ទៈ កាម-បរិយេសនា (ការស្វែងរកកាម) កើតឡើង ព្រោះអាស្រ័យកាម-បរិឡាហៈ ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនចេះដឹង កាលស្វែងរកនូវកាមបរិយេសនា រមែងប្រតិបត្តិខុសដោយស្ថានទាំង ៣ គ្គី គឺកាយ វាចា ចិត្ត ។ ម្នាលភិក្ខុទាំងឡាយ ព្យាបាទសញ្ញា (សេចក្តីសម្គាល់ក្នុងព្យាបាទ) កើតឡើង ព្រោះអាស្រ័យព្យាបាទធាតុ ព្យាបាទសង្កប្បៈ (សេចក្តីត្រិះរិះក្នុងការព្យាបាទ)... ព្យាបាទច្ឆន្ទៈ (សេចក្តីប្រាថ្នាក្នុងការព្យាបាទ)... ព្យាបាទបរិឡាហៈ (សេចក្តីក្រហល់ក្រហាយព្រោះការព្យាបាទ)... ព្យាបាទបរិយេសនា (ការស្វែងរកព្យាបាទ) ។

ព្យាបាទបរិយេសនំ ភិក្ខវេ បរិយេសមានោ អស្សុតវា បុថុជ្ជនោ តីហិ ឋានេហិ មិច្ឆា បដិបជ្ជតិ កាយេន វាចាយ មនសា ។ វិហឹសាធាតុំ ភិក្ខវេ បដិច្ច ឧប្បជ្ជតិ វិហឹសាសញ្ញា វិហឹសាសង្កប្បោ... វិហឹសា-ឆន្ទោ... វិហឹសាបរិឡាហោ... វិហឹសាបរិយេសនា ។ វិហឹសាបរិយេសនំ ភិក្ខវេ បរិយេសមានោ អស្សុតវា បុថុជ្ជនោ តីហិ ឋានេហិ មិច្ឆា បដិបជ្ជតិ កាយេន វាចាយ មនសា ។

[២៥] សេយ្យថាបិ ភិក្ខវេ បុរិសោ អាទិត្តំ តិ-ណុក្កំ សុក្ខេ តិណទាយេ និក្ខិបេយ្យ នោ ចេ ហត្ថេហិ ច បាទេហិ ច ខិប្បមេវ និព្វាបេយ្យ

ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនចេះដឹង កាលស្វែងរកនូវព្យាបាទ-បរិយេសនា រមែងប្រតិបត្តិខុសដោយស្ថានទាំង ៣ គឺ កាយ វាចា ចិត្ត ។ ម្នាលភិក្ខុទាំងឡាយ វិហឹសាសញ្ញា (សេចក្តីសម្គាល់ក្នុងការបៀតបៀន) កើតឡើង ព្រោះអាស្រ័យវិហឹសាធាតុ វិហឹសាសង្កប្បៈ (សេចក្តីត្រិះរិះក្នុងការបៀតបៀន)... វិហឹសាឆន្ទៈ (សេចក្តីប្រាថ្នាក្នុងការបៀតបៀន)... វិហឹសាបរិឡាហៈ (សេចក្តីក្រហល់ក្រហាយព្រោះការបៀតបៀន)... វិហឹសាបរិយេសនា (ការស្វែងរកនូវការបៀតបៀន) ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនចេះដឹង កាលស្វែងរកនូវវិហឹសាបរិយេសនា រមែងប្រតិបត្តិខុសដោយស្ថានទាំង ៣ គឺ កាយ វាចា ចិត្ត ។

[២៥] ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសដាក់គប់ស្មៅ ដែលភ្លើងកំពុងឆេះ ទៅក្នុងព្រៃស្មៅដ៏ស្ងួត បើបុរសនោះ មិនលត់ភ្លើងនោះឲ្យរលត់ដោយដៃទាំងឡាយផង ដោយជើងទាំងឡាយផង ឲ្យឆាប់ទេ

## ២៨



ឯវញ្ហិ ភិក្ខវេ យេ តិណកដ្ឋនិស្សិតា ចាណា តេ អ-
នយព្យសនំ អាបជ្ជេយ្យុំ ឯវមេវ ខោ ភិក្ខវេ យោ ហិ
កោចិ សមណោ វា ព្រាហ្មណោ វា ឧប្បន្នំ វិសម-
គតំ អកុសលសញ្ញំ ន ខិប្បមេវ បជហតិ វិនោទេតិ
ព្យន្តីករោតិ អនភាវំ គមេតិ សោ ទិដ្ឋេវ ធម្មេ ទុក្ខំ
វិហរតិ សវិឃាតំ សឧបាយាសំ សបរិឡាហំ កាយស្ស
ភេទា បរំ មរណា ទុគ្គតិ បាដិកង្ខា ។

[២៦] សនិទានំ ភិក្ខវេ ឧប្បជ្ជតិ នេក្ខម្មវិតក្កោ
នោ អនិទានំ សនិទានំ ឧប្បជ្ជតិ អព្យាបាទវិតក្កោ
នោ អនិទានំ សនិទានំ ឧប្បជ្ជតិ អវិហឹសាវិតក្កោ
នោ អនិទានំ ។

ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលអាស្រ័យនៅដោយស្មៅនិងឈើ គប្បីដល់នូវសេចក្តីមិនចម្រើន និងវិនាសដោយប្រការដូច្នេះឯង មានឧបមាដូចម្តេចវិញ ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ឯណានីមួយ មិនលះបង់ មិនបន្ទោបង់ មិនធ្វើឲ្យវិនាស នូវអកុសលសញ្ញា ដែលកើតឡើងមិនរាបសា ឲ្យដល់នូវភាវៈមិនមាន យ៉ាងឆាប់ទេ សមណ-ព្រាហ្មណ៍នោះ នៅជាទុក្ខ ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីតានតឹង ប្រកបដោយសេចក្តីក្តៅក្រហាយក្នុងបច្ចុប្បន្ន លុះបែកធ្លាយរាងកាយ ខាងនាយអំពីមរណៈទៅ ទុគ្គតិក៏រមែងប្រាកដ ក៏មានឧបមេយ្យដូច្នោះឯង ។

[២៦] ម្នាលភិក្ខុទាំងឡាយ នេក្ខម្មវិតក្កៈ (សេចក្តីត្រិះរិះក្នុងការចេញចាកកាម) ប្រកបដោយហេតុ ទើបកើតឡើង មិនមែនជាមិនមានហេតុទេ អព្យាបាទវិតក្កៈ (សេចក្តីត្រិះរិះក្នុងការមិនព្យាបាទ) អវិហឹសាវិតក្កៈ (សេចក្តីត្រិះរិះក្នុងការមិនបៀតបៀន) ប្រកបដោយហេតុ ទើបកើតឡើង មិនមែនជាមិនមានហេតុទេ ។

[២៧] កាថញ្ច ភិក្ខវេ សនិទានំ ឧប្បជ្ជតិ នេក្ខម្មវិតក្កោ នោ អនិទានំ សនិទានំ ឧប្បជ្ជតិ អព្យាបាទវិតក្កោ នោ អនិទានំ សនិទានំ ឧប្បជ្ជតិ អវិហឹសាវិតក្កោ នោ អនិទានំ ។ នេក្ខម្មធាតុំ ភិក្ខវេ បដិច្ច ឧប្បជ្ជតិ នេក្ខម្មសញ្ញា នេក្ខម្មសញ្ញំ បដិច្ច ឧប្បជ្ជតិ នេក្ខម្មសង្កប្បោ នេក្ខម្មសង្កប្បំ បដិច្ច ឧប្បជ្ជតិ នេក្ខម្មច្ឆន្ទោ នេក្ខម្មច្ឆន្ទំ បដិច្ច ឧប្បជ្ជតិ នេក្ខម្មបរិឡាហោ នេក្ខម្មបរិឡាហំ បដិច្ច ឧប្បជ្ជតិ នេក្ខម្មបរិយេសនា ។ នេក្ខម្មបរិយេសនំ ភិក្ខវេ បរិយេសមានោ សុតវា អរិយសាវកោ តីហិ ឋានេហិ សម្មា បដិបជ្ជតិ កាយេន វាចាយ មនសា ។ អព្យាបាទធាតុំ ភិក្ខវេ បដិច្ច ឧប្បជ្ជតិ អព្យាបាទសញ្ញា ។ បេ ។ អព្យាបាទសង្កប្បោ... អព្យាបាទច្ឆន្ទោ... អព្យាបាទបរិឡាហោ...

[២៧] ម្នាលភិក្ខុទាំងឡាយ ចុះនេក្ខម្មវិតក្កៈ ប្រកបដោយហេតុ ទើបកើតឡើង មិនមែនជាមិនមានហេតុទេ អព្យាបាទវិតក្កៈប្រកបដោយ ហេតុ ទើបកើតឡើង មិនមែនជាមិនមានហេតុទេ អវិហឹសាវិតក្កៈប្រកប ដោយហេតុ ទើបកើតឡើង មិនមែនជាមិនមានហេតុទេ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ នេក្ខម្មសញ្ញា (សេចក្តីសម្គាល់ក្នុងការចេញចាក កាម) កើតឡើង ព្រោះអាស្រ័យនេក្ខម្មធាតុ នេក្ខម្មសង្កប្បៈ (សេចក្តី ត្រិះរិះក្នុងការចេញចាកកាម) កើតឡើង ព្រោះអាស្រ័យនេក្ខម្មសញ្ញា នេក្ខម្មច្ឆន្ទៈ (សេចក្តីប្រាថ្នាក្នុងការចេញចាកកាម) កើតឡើង ព្រោះ អាស្រ័យនេក្ខម្មសង្កប្បៈ នេក្ខម្មបរិឡាហៈ (សេចក្តីក្រហល់ក្រហាយក្នុង ការចេញចាកកាម) កើតឡើង ព្រោះអាស្រ័យនេក្ខម្មច្ឆន្ទៈ នេក្ខម្មបរិ-យេសនា (ការស្វែងរកនូវការចេញចាកកាម) កើតឡើង ព្រោះអា-ស្រ័យនេក្ខម្មបរិឡាហៈ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកអ្នកចេះដឹង កាលស្វែងរកនេក្ខម្មបរិយេសនា តែងប្រតិបត្តិត្រូវដោយស្ថានទាំង ៣ យ៉ាង គឺ កាយ វាចា ចិត្ត ។ ម្នាលភិក្ខុទាំងឡាយ អព្យាបាទសញ្ញា កើតឡើង ព្រោះអាស្រ័យអព្យាបាទធាតុ ។ បេ ។ អព្យាបាទសង្កប្បៈ (សេចក្តីត្រិះរិះក្នុងការមិនព្យាបាទ)... អព្យាបាទច្ឆន្ទៈ (សេចក្តីប្រាថ្នា ក្នុងការមិនព្យាបាទ)... អព្យាបាទបរិឡាហៈ (សេចក្តីក្រហល់ក្រហាយ

អព្យាបាទបរិយេសនា ។ អព្យាបាទបរិយេសនំ ភិក្ខវេ បរិយេសមានោ សុតវា អរិយសាវកោ តីហិ ឋានេហិ សម្មា បដិបជ្ជតិ កាយេន វាចាយ មនសា ។ អវិហឹសាធាតុំ ភិក្ខវេ បដិច្ច ឧប្បជ្ជតិ អវិហឹសាសញ្ញា អវិហឹសាសញ្ញំ បដិច្ច ឧប្បជ្ជតិ អវិហឹសាសង្កប្បោ អវិហឹសាសង្កប្បំ បដិច្ច ឧប្បជ្ជតិ អវិហឹសាឆន្ទោ អវិហឹសាឆន្ទំ បដិច្ច ឧប្បជ្ជតិ អវិហឹសាបរិឡាហោ អវិហឹសាបរិឡាហំ បដិច្ច ឧប្បជ្ជតិ អវិហឹសាបរិយេសនា ។ អវិហឹសាបរិយេសនំ ភិក្ខវេ បរិយេសមានោ សុតវា អរិយសាវកោ តីហិ ឋានេហិ សម្មា បដិបជ្ជតិ កាយេន វាចាយ មនសា ។

[២៨] សេយ្យថាបិ ភិក្ខវេ បុរិសោ អាទិត្តំ តិណុក្កំ សុក្ខេ តិណទាយេ និក្ខិបេយ្យ តមេនំ ហត្ថេហិ ច បាទេហិ ច ខិប្បមេវ និព្វាបេយ្យ ឯវញ្ហិ ភិក្ខវេ យេ តិណកដ្ឋនិស្សិតា បាណា តេ ន អនយព្យសនំ

ក្នុងការមិនព្យាបាទ)... អព្យាបាទបរិយេសនា (ការស្វែងរកក្នុងការមិនព្យាបាទ) ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកអ្នកចេះដឹង កាលស្វែងរកអព្យាបាទបរិយេសនា តែងប្រតិបត្តិត្រូវដោយស្ថានទាំង ៣ គឺ កាយ វាចា ចិត្ត ។ ម្នាលភិក្ខុទាំងឡាយ អវិហឹសាសញ្ញាកើតឡើង ព្រោះអាស្រ័យអវិហឹសាធាតុ អវិហឹសាសង្កប្បៈកើតឡើង ព្រោះអាស្រ័យអវិហឹសាសញ្ញា អវិហឹសាឆន្ទៈកើតឡើង ព្រោះអាស្រ័យអវិហឹសាឆន្ទៈ អវិហឹសាបរិយេសនាកើតឡើង ព្រោះអាស្រ័យអវិហឹសាបរិឡាហៈ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកអ្នកចេះដឹង កាលស្វែងរកអវិហឹសាបរិយេសនា តែងប្រតិបត្តិត្រូវដោយស្ថានទាំង ៣ គឺ កាយ វាចា ចិត្ត ។

[២៨] ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសដាក់គប់ស្មៅ ដែលភ្លើងកំពុងឆេះ ក្នុងព្រៃស្មៅដ៏ស្ងួត គប្បីលត់គប់ស្មៅនោះ ដោយដៃទាំងឡាយផង ដោយជើងទាំងឡាយផង ជាឆាប់ ម្នាលភិក្ខុទាំងឡាយ ឯពួកសត្វដែលអាស្រ័យនៅដោយស្មៅនិងឈើ ក៏មិនគប្បីដល់នូវសេចក្តី

អាបជ្ជេយ្យុំ ឯវមេវ ខោ ភិក្ខវេ យោ ហិ កោចិ សម-
ណោ វា ព្រាហ្មណោ វា ឧប្បន្នំ វិសមគតំ អកុស-
លសញ្ញំ ខិប្បមេវ បជហាតិ វិនោទេតិ ព្យន្តីករោតិ
អនភាវំ គមេតិ សោ ទិដ្ឋេវ ធម្មេ សុខំ វិហរតិ អវិឃាតំ
អនុបាយាសំ អបរិឡាហំ កាយស្ស ភេទា បរំ មរណា
សុគតិ បាដិកង្ខាតិ ។ ទុតិយំ ។

[២៩] ឯកំ សមយំ ភគវា ញាតិកេ វិហរតិ
គិញ្ជកាវសថេ ។ តត្រ ខោ ភគវា ភិក្ខូ អា-
មន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ
បច្ចស្សោសុំ ។ ភគវា ឯតទវោច ធាតុំ ភិក្ខវេ បដិច្ច
ឧប្បជ្ជតិ សញ្ញា ឧប្បជ្ជតិ ទិដ្ឋិ ឧប្បជ្ជតិ វិតក្កោតិ ។

មិនចម្រើននិងវិនាស ដោយប្រការដូច្នេះឯង មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ សមណព្រាហ្មណ៍ឯណានីមួយ បានលះបង់ បានបន្ទោបង់ ធ្វើឲ្យវិនាសនូវអកុសលសញ្ញា ដែលកើតឡើងមិនរាប-សា ឲ្យដល់នូវភាវៈមិនមាន យ៉ាងឆាប់ ហើយសមណព្រាហ្មណ៍នោះ រមែងនៅជាសុខ មិនមានសេចក្តីចង្អៀតចង្អល់ មិនមានសេចក្តីតានតឹង មិនមានសេចក្តីក្តៅក្រហាយក្នុងបច្ចុប្បន្ន លុះបែកធ្លាយរាងកាយ ខាងនាយអំពីមរណៈទៅ សុគតិរមែងប្រាកដ ក៏មានឧបមេយ្យដូច្នោះឯង ។

ចប់សូត្រទី ២ ។

[២៩] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងមហា-ប្រាសាទដែលធ្វើដោយឥដ្ឋ ក្នុងស្រុករបស់ព្រះញាតិ (ទាំងពីរពួក) ។ ក្នុងទីនោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះមានព្រះភាគត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ សញ្ញា ទិដ្ឋិ វិតក្កៈ កើតឡើង ព្រោះអាស្រ័យធាតុ ។

## ២៩

### ធាតុសំយុត្តស្ស សត្តធាតុវគ្គេ អវិជ្ជាធាតុ

[៣០] ឯវំ វុត្តេ អាយស្មា កច្ចានោ[១] ភគវន្តំ ឯតទវោច យាយំ ភន្តេ ទិដ្ឋិ អសម្មាសម្ពុទ្ធេសុ សម្មាសម្ពុទ្ធាតិ អយំ នុ ខោ ភន្តេ ទិដ្ឋិ កឹ បដិច្ច បញ្ញាយតីតិ ។

[៣១] មហតី ខោ ឯសា កច្ចាន ធាតុ យទិទំ អវិជ្ជាធាតុ ។ ហីនំ កច្ចាន ធាតុំ បដិច្ច ឧប្បជ្ជតិ ហីនា សញ្ញា ហីនា ទិដ្ឋិ ហីនោ វិតក្កោ ហីនា ចេតនា ហីនា បត្ថនា[១] ហីនោ បណិធិ ហីនោ បុគ្គលោ ហីនា វាចា ហីនំ អាចិក្ខតិ ទេសេតិ បញ្ញបេតិ បដ្ឋបេតិ វិវរតិ វិភជតិ ឧត្តានីករោតិ ហីនា តស្ស ឧបបត្តីតិ វទាមិ ។ មជ្ឈិមំ កច្ចាន ធាតុំ បដិច្ច ឧប្បជ្ជតិ មជ្ឈិមា សញ្ញា មជ្ឈិមា ទិដ្ឋិ មជ្ឈិមោ វិតក្កោ មជ្ឈិមា ចេតនា មជ្ឈិមា បត្ថនា មជ្ឈិមោ បណិធិ មជ្ឈិមោ បុគ្គលោ មជ្ឈិមា វាចា

---

១ ឱ. អាយស្មា សទ្ធោ កច្ចាយនោ ។ ម. សទ្ធោ កច្ចានោ ។ ២ បដ្ឋនាតិបិ ទិស្សតិ ។

ធាតុសំយុត្ត សត្តធាតុវគ្គ អវិជ្ជាធាតុ

[៣០] កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះកច្ចានៈមានអាយុ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ទិដ្ឋិគឺសេចក្តីយល់ឃើញឯណា ក្នុងបុគ្គល មិនមែនជាសម្មាសម្ពុទ្ធ ថាជាសម្មាសម្ពុទ្ធ បពិត្រព្រះអង្គដ៏ចម្រើន ចុះទិដ្ឋិនេះ ប្រាកដឡើង ព្រោះអាស្រ័យអ្វី ។

[៣១] ម្នាលកច្ចានៈ ធាតុដែលធំទុំះ គឺអវិជ្ជាធាតុ ។ ម្នាលកច្ចានៈ សញ្ញាដ៏ថោកទាប ទិដ្ឋិដ៏ថោកទាប វិតក្កៈដ៏ថោកទាប ចេតនាដ៏ថោកទាប សេចក្តីប្រាថ្នាដ៏ថោកទាប សេចក្តីតាំងចិត្តដ៏ថោកទាប បុគ្គលដ៏ថោកទាប វាចាដ៏ថោកទាប កើតឡើង ព្រោះអាស្រ័យធាតុដ៏ថោកទាប តថាគតពោលថា បុគ្គលនោះ តែងប្រាប់ សំដែង ត្រដាង តម្កល់ទុក បើកបែក ធ្វើឲ្យរាក់ នូវអំពើដ៏ថោកទាប កំណើតរបស់បុគ្គលនោះ ក៏ថោកទាបដែរ ។ ម្នាលកច្ចានៈ សញ្ញាជាកណ្តាល ទិដ្ឋិជាកណ្តាល វិតក្កៈជាកណ្តាល ចេតនាជាកណ្តាល សេចក្តីប្រាថ្នាជាកណ្តាល សេចក្តីតាំងចិត្តជាកណ្តាល បុគ្គលជាកណ្តាល វាចាជាកណ្តាល កើតឡើង ព្រោះអាស្រ័យធាតុជា

មជ្ឈិមំ អាចិក្ខតិ ទេសេតិ បញ្ញបេតិ បដ្ឋបេតិ វិវរតិ វិភជតិ ឧត្តានីករោតិ មជ្ឈិមា តស្ស ឧបបត្តីតិ វទាមិ ។ បណីតំ ភិក្ខវេ ធាតុំ បដិច្ច ឧប្បជ្ជតិ បណីតា សញ្ញា បណីតា ទិដ្ឋិ បណីតោ វិតក្កោ បណីតា ចេតនា បណីតា បត្ថនា បណីតោ បណិធិ បណីតោ បុគ្គលោ បណីតា វាចា បណីតំ អាចិក្ខតិ ទេសេតិ បញ្ញបេតិ បដ្ឋបេតិ វិវរតិ វិភជតិ ឧត្តានីករោតិ បណីតា តស្ស ឧបបត្តីតិ វទាមីតិ ។ តតិយំ ។

[៣៦] សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា... ធាតុសោវ ភិក្ខវេ សត្តា សំសន្ទន្តិ សមេន្តិ ហីនាធិ... មុត្តិកា ហីនាធិមុត្តិកេហិ សទ្ធឹ សំសន្ទន្តិ សមេន្តិ

កណ្ដាល តថាគតពោលថា បុគ្គលនោះ រមែងប្រាប់ សំដែង ត្រដាង តម្កល់ទុក បើកបែក ធ្វើឲ្យរាក់ នូវអំពើជាកណ្ដាល កំណើត របស់បុគ្គលនោះ ក៏ជាកណ្ដាលដែរ ។ ម្នាលកច្ចានៈ សញ្ញាដ៏ឧត្តម ទិដ្ឋិដ៏ឧត្តម វិតក្កៈដ៏ឧត្តម ចេតនាដ៏ឧត្តម សេចក្ដីប្រាថ្នាដ៏ឧត្តម សេចក្ដី តាំងចិត្តដ៏ឧត្តម បុគ្គលដ៏ឧត្តម វាចាដ៏ឧត្តម កើតឡើង ព្រោះអាស្រ័យ ធាតុដ៏ឧត្តម តថាគតពោលថា បុគ្គលនោះ តែងប្រាប់ ត្រដាង តម្កល់ ទុក បើកបែក ធ្វើឲ្យរាក់ នូវអំពើដ៏ឧត្តម កំណើតរបស់បុគ្គលនោះ ក៏ឧត្តមដែរ ។ ចប់សូត្រទី ៣ ។

[៣២] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ក្នុង ទីនោះឯង ព្រះមានព្រះភាគ... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ ត្រូវគ្នា សមគ្នា[១] ដោយធាតុ គឺពួកជនមានអធ្យា- ស្រ័យដ៏ថោកទាប ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមានអធ្យាស្រ័យ

១ ស្មើគ្នា ប្រហែលគ្នា ប្រជុំគ្នា ជួបគ្នា ចូលចិត្តនឹងគ្នា ។

កល្យាណាជិមុត្តិកា កល្យាណាជិមុត្តិកេហិ សទ្ធឹ
សំសន្ទន្តិ សមេន្តិ ។ អតីតំបិ ភិក្ខវេ អទ្ធានំ ជាតុសោ វ
សត្តា សំសន្ទឹសុ សមឹសុ ហីជាជិមុត្តិកា ហីជាជិមុត្តិ-
កេហិ សទ្ធឹ សំសន្ទឹសុ សមឹសុ កល្យាណាជិមុត្តិកា
កល្យាណាជិមុត្តិកេហិ សទ្ធឹ សំសន្ទឹសុ សមឹសុ ។
អជាគតំបិ ភិក្ខវេ អទ្ធានំ ជាតុសោ វ សត្តា សំសន្ទិ-
ស្សន្តិ សមេស្សន្តិ ហីជាជិមុត្តិកា ហីជាជិមុត្តិកេហិ
សទ្ធឹ សំសន្ទិស្សន្តិ សមេស្សន្តិ កល្យាណាជិមុត្តិកា
កល្យាណាជិមុត្តិកេហិ សទ្ធឹ សំសន្ទិស្សន្តិ ស-
មេស្សន្តិ ។ ឯតរហិបិ ភិក្ខវេ បច្ចុប្បន្នំ អទ្ធានំ ជាតុសោ
វ សត្តា សំសន្ទន្តិ សមេន្តិ ហីជាជិមុត្តិកា ហីជាជិ-
មុត្តិកេហិ សទ្ធឹ សំសន្ទន្តិ សមេន្តិ កល្យាណាជិ-
មុត្តិកា កល្យាណាជិមុត្តិកេហិ សទ្ធឹ សំសន្ទន្តិ
សមេន្តីតិ ។ ចតុត្ថំ ។

ថោកទាប ពួកជនមានអធ្យាស្រ័យល្អ ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមានអធ្យាស្រ័យល្អ ។ ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងអតីតកាល សត្វទាំងឡាយ ត្រូវគ្នា សមគ្នា ដោយធាតុ គឺពួកជនមានអធ្យាស្រ័យថោកទាប ពួកជនមានអធ្យាស្រ័យល្អ ត្រូវគ្នា សមគ្នាជាមួយនឹងពួកជនមានអធ្យាស្រ័យល្អ ។ ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងអនាគតកាល សត្វទាំងឡាយ នឹងត្រូវគ្នា នឹងសមគ្នា ដោយធាតុ គឺពួកជនមានអធ្យាស្រ័យថោកទាប នឹងត្រូវគ្នា នឹងសមគ្នា ជាមួយនឹងពួកជនមានអធ្យាស្រ័យថោកទាប ពួកជនមានអធ្យាស្រ័យល្អ នឹងត្រូវគ្នា នឹងសមគ្នា ជាមួយពួកជនមានអធ្យាស្រ័យល្អ ។ ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងបច្ចុប្បន្នកាលនេះ សត្វទាំងឡាយ ត្រូវគ្នាសមគ្នា ដោយធាតុ គឺពួកជនមានអធ្យាស្រ័យថោកទាប ត្រូវគ្នាសមគ្នា ដោយធាតុ គឺពួកជនមានអធ្យាស្រ័យថោកទាប ពួកជនមានអធ្យាស្រ័យល្អ ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមានអធ្យាស្រ័យល្អ ។

ចប់សូត្រទី ៤ ។

៣២



[៣៣] ឯកំ សមយំ ភគវា រាជគហេ វិហរតិ គិជ្ឈកូដេ បព្វតេ ។ តេន ខោ បន សមយេន អាយស្មាបិ ខោ សារីបុត្តោ សម្ពហុលេហិ ភិក្ខូហិ សទ្ធឹ ភគវតោ អវិទូរេ ចង្កមតិ អាយស្មាបិ ខោ មហាមោគ្គល្លានោ សម្ពហុលេហិ ភិក្ខូហិ សទ្ធឹ ភគវតោ អវិទូរេ ចង្កមតិ អាយស្មាបិ ខោ មហាកស្សបោ សម្ពហុលេហិ ភិក្ខូហិ សទ្ធឹ ភគវតោ អវិទូរេ ចង្កមតិ អាយស្មាបិ ខោ អនុរុទ្ធោ សម្ពហុលេហិ ភិក្ខូហិ សទ្ធឹ ភគវតោ អវិទូរេ ចង្កមតិ អាយស្មាបិ ខោ បុណ្ណោ មន្តានីបុត្តោ សម្ពហុលេហិ ភិក្ខូហិ សទ្ធឹ ភគវតោ អវិទូរេ ចង្កមតិ អាយស្មាបិ ខោ ឧបាលិ សម្ពហុលេហិ ភិក្ខូហិ សទ្ធឹ ភគវតោ អវិទូរេ ចង្កមតិ អាយស្មាបិ ខោ អានន្ទោ សម្ពហុលេហិ ភិក្ខូហិ សទ្ធឹ ភគវតោ អវិទូរេ ចង្កមតិ ទេវទត្តោបិ ខោ សម្ពហុលេហិ ភិក្ខូហិ សទ្ធឹ ភគវតោ អវិទូរេ ចង្កមតិ ។

[៣៣] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ ក្បែរភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ ។ ក្នុងសម័យនោះឯង ព្រះសារីបុត្តដ៏មានអាយុ កំពុងចង្ក្រមក្នុងទីជិតព្រះមានព្រះភាគ ជាមួយនឹងភិក្ខុទាំង-ឡាយច្រើនរូប ព្រះមហាមោគ្គល្លានមានអាយុ កំពុងចង្ក្រមក្នុងទីជិតព្រះមានព្រះភាគ ជាមួយនឹងភិក្ខុទាំងឡាយច្រើនរូប ព្រះមហាកស្សបមានអាយុ កំពុងចង្ក្រមក្នុងទីជិតព្រះមានព្រះភាគ ជាមួយនឹងភិក្ខុទាំងឡាយច្រើនរូប ព្រះអនុរុទ្ធមានអាយុ កំពុងចង្ក្រមក្នុងទីជិតព្រះមានព្រះភាគ ជាមួយនឹងភិក្ខុទាំងឡាយច្រើនរូប ព្រះបុណ្ណ-មន្តានីបុត្តមានអាយុ កំពុងចង្ក្រមក្នុងទីជិតព្រះមានព្រះភាគ ជាមួយនឹងភិក្ខុទាំងឡាយច្រើនរូប ព្រះឧបាលិមានអាយុ កំពុងចង្ក្រមក្នុងទីជិតព្រះមានព្រះភាគ ជាមួយនឹងភិក្ខុទាំងឡាយច្រើនរូប ព្រះអានន្ទមានអាយុ កំពុងចង្ក្រមក្នុងទីជិតព្រះមានព្រះភាគ ជាមួយនឹងភិក្ខុទាំងឡាយច្រើនរូប ទេវទត្តកំពុងចង្ក្រមក្នុងទី ជិតព្រះមានព្រះភាគ ជាមួយនឹងភិក្ខុទាំងឡាយច្រើនរូបដែរ ។

៣៣

ធាតុសំយុត្តស្ស សត្តធាតុវគ្គេ ភិក្ខូ អាមន្តនំ

[៣៤] អថខោ ភគវា ភិក្ខូ អាមន្តេសិ បស្សថ នោ តុម្ហេ ភិក្ខវេ សារីបុត្តំ សម្ពហុលេហិ ភិក្ខូហិ សទ្ធឹ ចង្កមន្តន្តិ ។ ឯវំ ភន្តេ ។ សព្វេ ខោ ឯតេ ភិក្ខវេ ភិក្ខូ មហាបញ្ញា បស្សថ នោ តុម្ហេ ភិក្ខវេ មហាមោគ្គល្លានំ សម្ពហុលេហិ ភិក្ខូហិ សទ្ធឹ ចង្កមន្តន្តិ ។ ឯវំ ភន្តេ ។ សព្វេ ខោ ឯតេ ភិក្ខវេ ភិក្ខូ មហិទ្ធិកា បស្សថ នោ តុម្ហេ ភិក្ខវេ មហាកស្សបំ សម្ពហុលេហិ ភិក្ខូហិ សទ្ធឹ ចង្កមន្តន្តិ ។ ឯវំ ភន្តេ ។ សព្វេ ខោ ឯតេ ភិក្ខវេ ភិក្ខូ ធុតវាទា បស្សថ នោ តុម្ហេ ភិក្ខវេ អនុរុទ្ធំ សម្ពហុលេហិ ភិក្ខូហិ សទ្ធឹ ចង្កមន្តន្តិ ។ ឯវំ ភន្តេ ។ សព្វេ ខោ ឯតេ ភិក្ខវេ ភិក្ខូ ទិព្វចក្ខុកា បស្សថ នោ តុម្ហេ ភិក្ខវេ បុណ្ណំ មន្តានីបុត្តំ សម្ពហុលេហិ ភិក្ខូហិ សទ្ធឹ ចង្កមន្តន្តិ ។ ឯវំ ភន្តេ ។ សព្វេ ខោ ឯតេ ភិក្ខវេ ភិក្ខូ ធម្មកថិកា បស្សថ នោ តុម្ហេ ភិក្ខវេ ឧបាលឹ សម្ពហុលេហិ ភិក្ខូហិ សទ្ធឹ ចង្កមន្តន្តិ ។

ធាតុសំយុត្ត សត្តធាតុវគ្គ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយ

[៣៤] គ្រានោះឯង ព្រះមានព្រះភាគ ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញសារីបុត្ត កំពុងចង្រ្កមជាមួយនឹងពួកភិក្ខុច្រើនរូបដែរឬ ។ ភិក្ខុទាំងឡាយ ក្រាបបង្គំទូលថា ព្រះករុណា ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងអស់នុ៎ះ ជាអ្នកមានបញ្ញាច្រើន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញមហាមោគ្គល្លាន កំពុងចង្រ្កមជាមួយនឹងពួកភិក្ខុច្រើនរូបដែរឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងអស់នុ៎ះ ជាអ្នកមានឫទ្ធិច្រើន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញមហាកស្សប កំពុងចង្រ្កមជាមួយនឹងពួកភិក្ខុច្រើនរូបដែរឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងអស់នុ៎ះ ជាធុតវាទ (អ្នកពោលពាក្យកម្ចាត់បង់កិលេស) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញអនុរុទ្ធ កំពុងចង្រ្កមជាមួយនឹងពួកភិក្ខុច្រើនរូបដែរឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងអស់នុ៎ះ ជាអ្នកបានទិព្វចក្ខុ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញបុណ្ណមន្តានីបុត្ត កំពុងចង្រ្កមជាមួយនឹងពួកភិក្ខុច្រើនរូបដែរឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងអស់នុ៎ះ ជាធម្មកថិក ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញឧបាលិ កំពុងចង្រ្កមជាមួយនឹងពួកភិក្ខុច្រើនរូបដែរឬ ។

ឯវំ ភន្តេ ។ សព្វេ ខោ ឯតេ ភិក្ខវេ ភិក្ខូ វិនយធរា បស្សថ នោ តុម្ហេ ភិក្ខវេ អានន្ទំ សម្ពហុលេហិ ភិក្ខូហិ សទ្ធឹ ចង្កមន្តន្តិ ។ ឯវំ ភន្តេ ។ សព្វេ ខោ ឯតេ ភិក្ខវេ ភិក្ខូ ពហុស្សុតា បស្សថ នោ តុម្ហេ ភិក្ខវេ ទេវទត្តំ សម្ពហុលេហិ ភិក្ខូហិ សទ្ធឹ ចង្កមន្តន្តិ ។ ឯវំ ភន្តេ ។ សព្វេ ខោ ឯតេ ភិក្ខវេ ភិក្ខូ បាបិច្ឆា ។

[៣៥] ធាតុសោ វ ភិក្ខវេ សត្តា សំសន្ទន្តិ សមេន្តិ ហីនាធិមុត្តិកា ហីនាធិមុត្តិកេហិ សទ្ធឹ សំសន្ទន្តិ សមេន្តិ កល្យាណាធិមុត្តិកា កល្យាណាធិ-មុត្តិកេហិ សទ្ធឹ សំសន្ទន្តិ សមេន្តិ អតីតម្បិ ភិក្ខវេ អទ្ធានំ ធាតុសោ វ សត្តា សំសន្ទឹសុ សមឹសុ ហីនាធិមុត្តិកា ហីនាធិមុត្តិកេហិ សទ្ធឹ សំសន្ទឹសុ សមឹសុ កល្យាណាធិមុត្តិកា កល្យាណាធិមុត្តិកេហិ សទ្ធឹ សំសន្ទឹសុ សមឹសុ ។ អនាគតម្បិ ភិក្ខវេ អទ្ធានំ ធាតុសោ វ សត្តា សំសន្ទិស្សន្តិ សមេស្សន្តិ

ព្រះករុណា ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងអស់នុ៎ះ ជាវិនយធរ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញអានន្ទ កំពុងចង្រ្កមជាមួយនឹងពួកភិក្ខុច្រើនរូបដែរឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងអស់នុ៎ះ ជាពហុស្សូត ម្នាលភិក្ខុទាំង-ឡាយ អ្នកទាំងឡាយឃើញទេវទត្ត កំពុងចង្រ្កមជាមួយនឹងពួកភិក្ខុច្រើនរូបដែរឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងអស់នុ៎ះ ជាអ្នកមានសេចក្តីប្រាថ្នាលាមក ។

[៧៧] ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយនេះ មិនបានដឹងច្បាស់តាមពិត នូវអានិសង្សដោយអានិសង្សផង នូវទោសដោយទោសផង របស់ធាតុទាំង ៤ នេះ នូវការរលាស់ចេញដោយការរលាស់ចេញនូវធាតុទាំង ៤ នេះផង កំណត់ត្រឹមណា ម្នាលភិក្ខុទាំងឡាយ ពួកសត្វនេះមិនបានប្រាសចេញ មិនបានបែរចេញ មិនបានវាកចេញ មានចិត្តមិនបានរមៀលចេញចាកលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ចាកពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ចាកមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស កំណត់ត្រឹមនោះ ។ ម្នាលភិក្ខុទាំងឡាយ កាលណា បើសត្វទាំងឡាយនេះ បានដឹងច្បាស់តាមពិត នូវអានិសង្សដោយអានិសង្សផង នូវទោសដោយទោសផង របស់ធាតុទាំង ៤ នេះ នូវការរលាស់ចេញដោយការរលាស់ចេញនូវធាតុទាំង ៤ នេះផង ម្នាលភិក្ខុទាំងឡាយ ពួកសត្វនេះរមែងប្រាសចេញ បែរចេញ មានចិត្តរមៀលចេញចាកលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ចាកពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ចាកមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ក្នុងកាលនោះ ។ ចប់សូត្រទី ៤ ។

[៧៨] សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា... បឋវីធាតុញ្ច[១] ហិទំ ភិក្ខវេ ឯកន្តទុក្ខា អភវិស្ស ទុក្ខានុបតិតា ទុក្ខាវក្កន្តា អនវក្កន្តា សុខេន នយិទំ សត្តា បឋវីធាតុយា សារជ្ជេយ្យុំ ។ យស្មា ច ខោ ភិក្ខវេ បឋវីធាតុ សុខានុបតិតា សុខាវក្កន្តា អនវក្កន្តា ទុក្ខេន តស្មា សត្តា បឋវីធាតុយា សារជ្ជន្តិ ។ អាបោធាតុញ្ច ហិទំ ភិក្ខវេ... តេជោធាតុញ្ច ហិទំ ភិក្ខវេ... វាយោធាតុញ្ច ហិទំ ភិក្ខវេ ឯកន្តទុក្ខា អភវិស្ស ទុក្ខានុបតិតា ទុក្ខាវក្កន្តា អនវក្កន្តា សុខេន នយិទំ សត្តា វាយោធាតុយា សារជ្ជេយ្យុំ ។ យស្មា ច ខោ ភិក្ខវេ វាយោធាតុ សុខានុបតិតា សុខាវក្កន្តា អនវក្កន្តា ទុក្ខេន តស្មា សត្តា វាយោធាតុយា សារជ្ជន្តិ ។

---

១ ឱ. ម. បឋវីធាតុ ចេ ។

[៧៨] ទ្រង់គង់នៅទៀបក្រុងសាវត្ថី... ក្នុងទីនោះឯង ព្រះមានព្រះភាគ... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើបឋវីធាតុនេះ មានតែសេចក្តីទុក្ខ ដោយដាច់ខាត ត្រូវសេចក្តីទុក្ខធ្លាក់តាម មានសេចក្តីទុក្ខចូលមកលុកលុយ ឯសេចក្តីសុខមិនបានចូលមកលុកលុយ មានហើយ ពួកសត្វមិនគប្បីត្រេកអរ ក្នុងបឋវីធាតុនេះបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះបឋវីធាតុត្រូវសេចក្តីសុខធ្លាក់តាម មានសេចក្តីសុខចូលមកលុកលុយ សេចក្តីទុក្ខមិនបានចូលមកលុកលុយ មានខ្លះដែរ បានជាពួកសត្វ រមែងត្រេកអរក្នុងបឋវីធាតុ ។ ម្នាលភិក្ខុទាំងឡាយ បើអបោធាតុនេះ... ម្នាលភិក្ខុទាំងឡាយ បើតេជោធាតុនេះ... ម្នាលភិក្ខុទាំងឡាយ បើវាយោធាតុនេះ មានតែសេចក្តីទុក្ខដោយដាច់ខាត ត្រូវសេចក្តីទុក្ខធ្លាក់តាម មានសេចក្តីទុក្ខចូលមកលុកលុយ សេចក្តីសុខមិនបានមកលុកលុយ មានហើយ ពួកសត្វមិនគប្បីត្រេកអរវាយោធាតុបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះវាយោធាតុត្រូវសេចក្តីសុខធ្លាក់តាម មានសេចក្តីសុខចូលមកលុកលុយ សេចក្តីទុក្ខមិនបានចូលមកលុកលុយ មានខ្លះដែរ បានជាពួកសត្វរមែងត្រេកអរក្នុងវាយោធាតុ ។

៧១

ធាតុសំយុត្តស្ស ចតុធាតុវគ្គេ បឋវីធាតុសុខតា

[៧៩] បឋវីធាតុញ្ច ហិទំ ភិក្ខវេ ឯកន្តសុខា អភវិស្ស សុខានុបតិតា សុខាវក្កន្តា អនវក្កន្តា ទុក្ខេន នយិទំ សត្តា បឋវីធាតុយា និព្វិន្ទេយ្យុំ ។ យស្មា ច ខោ ភិក្ខវេ បឋវីធាតុ ទុក្ខា ទុក្ខានុបតិតា ទុក្ខាវក្កន្តា អនវក្កន្តា សុខេន តស្មា សត្តា ប-ឋវីធាតុយា និព្វិន្ទន្តិ ។ អាបោធាតុញ្ច ហិទំ ភិក្ខវេ... តេជោធាតុញ្ច ហិទំ ភិក្ខវេ... វាយោធាតុញ្ច ហិទំ ភិក្ខវេ ឯកន្តសុខា អភវិស្ស សុខានិបតិតា សុខាវក្កន្តា អនវក្កន្តា ទុក្ខេន នយិទំ សត្តា វាយោធាតុយា និព្វិន្ទេយ្យុំ ។ យស្មា ច ខោ ភិក្ខវេ វាយោធាតុ ទុក្ខា ទុក្ខានុបតិតា ទុក្ខាវក្កន្តា អនវក្កន្តា សុខេន តស្មា សត្តា វាយោធាតុយា និព្វិន្ទន្តីតិ ។ បញ្ចមំ ។

[៧៩] ម្នាលភិក្ខុទាំងឡាយ បើបឋវីធាតុនេះ មានតែសេចក្ដីសុខដោយដាច់ខាត ត្រូវសេចក្ដីសុខធ្លាក់តាម មានសេចក្ដីសុខចូលមកលុកលុយ សេចក្ដីទុក្ខមិនបានចូលមកលុកលុយ មានហើយ ពួកសត្វមិនគប្បីនឿយណាយចាកបឋវីធាតុនេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះបឋវីធាតុជាទុក្ខ ត្រូវសេចក្ដីទុក្ខធ្លាក់តាម មានសេចក្ដីទុក្ខចូលមកលុកលុយ សេចក្ដីសុខមិនបានចូលមកលុកលុយ មានខ្វះដែរ បានជាសត្វទាំងឡាយ តែងនឿយណាយចាកបឋវីធាតុ ។ ម្នាលភិក្ខុទាំងឡាយ បើអាបោធាតុនេះ... ម្នាលភិក្ខុទាំងឡាយ បើតេជោធាតុនេះ... ម្នាលភិក្ខុទាំងឡាយ បើវាយោធាតុនេះ មានតែសេចក្ដីសុខដោយដាច់ខាត ត្រូវសេចក្ដីសុខធ្លាក់តាម មានសេចក្ដីសុខចូលមកលុកលុយ សេចក្ដីទុក្ខមិនបានចូលមកលុកលុយ មានហើយ សត្វទាំងឡាយ មិនគប្បីនឿយណាយចាកវាយោធាតុនេះបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះវាយោធាតុជាទុក្ខ ត្រូវសេចក្ដីទុក្ខធ្លាក់តាម មានសេចក្ដីទុក្ខចូលមកលុកលុយ សេចក្ដីសុខមិនបានចូលមកលុកលុយ មានខ្វះដែរ បានជាពួកសត្វរមែងនឿយណាយចាកវាយោធាតុ ។ ចប់សូត្រទី ៥ ។

[៨០] សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា... យោ ភិក្ខវេ បឋវីធាតុំ អភិនន្ទតិ ទុក្ខំ សោ អភិនន្ទតិ ។ យោ ទុក្ខំ អភិនន្ទតិ អបរិមុត្តោ សោ ទុក្ខស្មាតិ វទាមិ ។ យោ អាបោធាតុំ អភិនន្ទតិ... យោ តេ-ជោធាតុំ អភិនន្ទតិ... យោ វាយោធាតុំ អភិនន្ទតិ ទុក្ខំ សោ អភិនន្ទតិ ។ យោ ទុក្ខំ អភិនន្ទតិ អបរិមុត្តោ សោ ទុក្ខស្មាតិ វទាមិ ។

[៨១] យោ ច ខោ ភិក្ខវេ បឋវីធាតុំ ន អភិនន្ទតិ ទុក្ខំ សោ ន អភិនន្ទតិ ។ យោ ទុក្ខំ ន អភិនន្ទតិ បរិមុត្តោ សោ ទុក្ខស្មាតិ វទាមិ ។ យោ អាបោធាតុំ... យោ តេជោធាតុំ... យោ វាយោធាតុំ ន អភិនន្ទតិ ទុក្ខំ សោ ន អភិនន្ទតិ ។ យោ ទុក្ខំ ន អភិនន្ទតិ បរិមុត្តោ សោ ទុក្ខស្មាតិ វទាមីតិ ។ ឆដ្ឋំ ។

[៨០] ទ្រង់គង់នៅទៀបក្រុងសាវត្ថី... ក្នុងទីនោះឯង ព្រះមានព្រះភាគ... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលឯណា ឱបអរនូវបឋវីធាតុ បុគ្គលនោះឈ្មោះថា ឱបអរនូវសេចក្តីទុក្ខ ។ បុគ្គលឯណា ឱបអរនូវសេចក្តីទុក្ខ តថាគតហៅបុគ្គលនោះថា មិនរួចចាកសេចក្តីទុក្ខឡើយ ។ បុគ្គលឯណា ឱបអរនូវអាបោធាតុ... បុគ្គលឯណា ឱបអរនូវតេជោធាតុ... បុគ្គលឯណា ឱបអរនូវវាយោធាតុ... បុគ្គលនោះឈ្មោះថា ឱបអរនូវសេចក្តីទុក្ខ ។ បុគ្គលឯណា ឱបអរនូវសេចក្តីទុក្ខ តថាគតហៅបុគ្គលនោះថា មិនរួចចាកសេចក្តីទុក្ខឡើយ ។

[៨១] ម្នាលភិក្ខុទាំងឡាយ បុគ្គលឯណា មិនឱបអរនូវបឋវីធាតុ បុគ្គលនោះឈ្មោះថា មិនឱបអរនូវសេចក្តីទុក្ខ ។ បុគ្គលឯណា មិនឱបអរនូវសេចក្តីទុក្ខ តថាគតហៅបុគ្គលនោះថា រួចចាកសេចក្តីទុក្ខ ។ បុគ្គលឯណា មិនឱបអរនូវអាបោធាតុ... បុគ្គលឯណា មិនឱបអរនូវតេជោធាតុ... បុគ្គលឯណា មិនឱបអរនូវវាយោធាតុ បុគ្គលនោះឈ្មោះថា មិនឱបអរនូវសេចក្តីទុក្ខ ។ បុគ្គលឯណា មិនឱបអរនូវសេចក្តីទុក្ខ តថាគតហៅបុគ្គលនោះថា រួចចាកសេចក្តីទុក្ខ ។ ចប់សូត្រទី ៦ ។

៧៣

## ធាតុសំយុត្តស្ស ចតុធាតុវគ្គេ បឋវីធាតុនិរោធោ

[៨២] សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា... យោ ភិក្ខវេ បឋវីធាតុយា ឧប្បាទោ ឋិតិ អភិនិព្វត្តិ បាតុភាវោ ទុក្ខស្សេសោ ឧប្បាទោ រោគានំ ឋិតិ ជរាមរណស្ស បាតុភាវោ ។ យោ អាបោធាតុយា... យោ តេជោធាតុយា... យោ វាយោធាតុយា ឧប្បាទោ ឋិតិ អភិនិព្វត្តិ បាតុភាវោ ទុក្ខស្សេសោ ឧប្បាទោ រោគានំ ឋិតិ ជរាមរណស្ស បាតុភាវោ ។

[៨៣] យោ ច ខោ ភិក្ខវេ បឋវីធាតុយា និរោធោ វូបសមោ អត្ថង្គមោ ទុក្ខស្សេសោ និរោធោ រោគានំ វូបសមោ ជរាមរណស្ស អត្ថង្គមោ ។ យោ អាបោធា-តុយា និរោធោ... យោ តេជោធាតុយា និរោធោ... យោ វាយោធាតុយា និរោធោ វូបសមោ អត្ថង្គមោ[១] ទុក្ខស្សេសោ និរោធោ រោគានំ វូបសមោ ជរាម-រណស្ស អត្ថង្គមោតិ ។ សត្តមំ ។

១ អដ្ឋង្គមោតិបិ ។

[៨២] ទ្រង់គង់នៅទៀបក្រុងសាវត្ថី... ក្នុងទីនោះឯង ព្រះមានព្រះភាគ... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការកើតឡើង ការស្ថិតនៅ ការវិលមក ការមានប្រាកដ នៃបឋវីធាតុឯណា នេះឈ្មោះថា ការកើតឡើងនៃសេចក្តីទុក្ខ ឈ្មោះថា ការស្ថិតនៅនៃរោគ ឈ្មោះថា មានប្រាកដនៃជរានិងមរណៈ ។ អាបោធាតុ... តេជោធាតុ... ការកើតឡើង ការស្ថិតនៅ ការវិលមក ការមានប្រាកដ នៃវាយោធាតុឯណា នេះឈ្មោះថា ការកើតឡើងនៃសេចក្តីទុក្ខ ឈ្មោះថា ការស្ថិតនៅនៃរោគ ឈ្មោះថា មានប្រាកដនៃជរានិងមរណៈ ។

[៨៣] ម្នាលភិក្ខុទាំងឡាយ ការរលត់ទៅ ការស្ងប់រម្ងាប់ និងអស់ទៅ នៃបឋវីធាតុឯណា នេះឈ្មោះថា រលត់សេចក្តីទុក្ខ ស្ងប់រម្ងាប់នៃរោគ អស់ទៅនៃជរានិងមរណៈ ។ សេចក្តីរលត់នៃអាបោធាតុឯណា... សេចក្តីរលត់នៃតេជោធាតុឯណា... សេចក្តីរលត់ សេចក្តីស្ងប់រម្ងាប់ ការអស់ទៅ នៃវាយោធាតុឯណា នេះឈ្មោះថា រលត់នៃសេចក្តីទុក្ខ ស្ងប់រម្ងាប់នៃរោគ អស់ទៅនៃជរានិងមរណៈ ។ ចប់សូត្រទី ៧ ។

៧៤



[៨៤] សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា... ចតស្សោ ឥមា ភិក្ខវេ ធាតុយោ កតមា ចតស្សោ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ ។ យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឥមាសំ ចតុន្នំ ធាតូនំ អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ នប្បជានន្តិ ន មេតេ ភិក្ខវេ សមណា វា ព្រាហ្មណា វា សមណេសុ វា សមណសម្មតា ព្រាហ្មណេសុ វា ព្រាហ្មណសម្មតា ន ច បន តេ អាយស្មន្តោ សាមញ្ញត្ថំ វា ព្រហ្មញ្ញត្ថំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តិ ។

[៨៥] យេ ច ខោ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឥមាសំ ចតុន្នំ ធាតូនំ អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ បជានន្តិ តេ ខោ មេ ភិក្ខវេ សមណា វា ព្រាហ្មណា វា សមណេសុ ចេវ សមណសម្មតា ព្រាហ្មណេសុ ច ព្រាហ្មណសម្មតា

[៨៤] ទ្រង់គង់នៅទៀបក្រុងសាវត្ថី... ក្នុងទីនោះឯង ព្រះមានព្រះភាគ... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធាតុនេះមាន ៤ ប្រការ ធាតុ ៤ តើអ្វីខ្លះ គឺបឋវីធាតុ ១ អាបោធាតុ ១ តេជោធាតុ ១ វាយោធាតុ ១ ។ ម្នាលភិក្ខុទាំងឡាយ សមណៈ ឬព្រាហ្មណ៍ឯណានីមួយ មិនដឹងច្បាស់តាមពិត នូវអានិសង្សនិងទោសនៃធាតុទាំង ៤ នេះផង នូវការរលាស់ចេញនូវធាតុទាំង ៤ នេះផង ម្នាលភិក្ខុទាំងឡាយ សមណៈ ឬព្រាហ្មណ៍ទាំងនុ៎ះ តថាគតមិនសន្មតថា ជាសមណៈក្នុងពួកសមណៈ មិនសន្មតថា ជាព្រាហ្មណ៍ក្នុងពួកព្រាហ្មណ៍ មួយទៀត អ្នកទាំងនោះ មិនបានធ្វើឲ្យជាក់ច្បាស់ មិនបានដល់ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងក្នុងបច្ចុប្បន្ន នូវប្រយោជន៍នៃសមណភាព ឬប្រយោជន៍នៃព្រាហ្មណភាពទេ ។

[៨៥] ម្នាលភិក្ខុទាំងឡាយ លុះតែពួកសមណៈ ឬព្រាហ្មណ៍ឯណានីមួយ ដឹងច្បាស់តាមពិត នូវអានិសង្សនិងទោស នៃធាតុទាំង ៤ នេះផង នូវការរលាស់ចេញនូវធាតុទាំង ៤ នេះផង ម្នាលភិក្ខុទាំងឡាយ សមណៈ ឬព្រាហ្មណ៍ទាំងនោះ ទើបតថាគតសន្មតថា ជាសមណៈក្នុងសមណៈផង សន្មតថា ជាព្រាហ្មណ៍ក្នុងពួកព្រាហ្មណ៍ផង

តេ ច បជាយស្មន្តោ សាមញ្ញត្ថញ្ច ព្រហ្មញ្ញត្ថញ្ច ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តីតិ ។ អដ្ឋមំ ។

[៨៦] សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា... ចតស្សោ ឥមា ភិក្ខវេ ធាតុយោ កតមា ចតស្សោ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ ។ យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឥមាសំ ចតុន្នំ ធាតូនំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អា-ទីនវញ្ច និស្សរណញ្ច យថាភូតំ ទប្បជានន្តិ (វិត្ថារេតព្វំ) បជានន្តិ... សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តីតិ ។ នវមំ ។

មួយទៀត អ្នកទាំងនោះ រមែងធ្វើឲ្យជាក់ច្បាស់ បានដល់ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងក្នុងបច្ចុប្បន្ន នូវប្រយោជន៍នៃសមណភាពផង នូវប្រយោជន៍នៃព្រាហ្មណភាពផង ។ ចប់សូត្រទី ៨ ។

[៨៦] ទ្រង់គង់នៅទៀបក្រុងសាវត្ថី... ក្នុងទីនោះឯង ព្រះមានព្រះភាគ... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធាតុទាំងឡាយនេះមាន ៤ ប្រការ ធាតុ ៤ តើអ្វីខ្លះ គឺបឋវីធាតុ ១ អាបោធាតុ ១ តេជោ-ធាតុ ១ វាយោធាតុ ១ ។ ម្នាលភិក្ខុទាំងឡាយ សមណៈ ឬព្រាហ្មណ៍ឯណានីមួយ មិនដឹងច្បាស់តាមពិត នូវសេចក្តីកើត សេចក្តីអស់ទៅ អានិសង្ស និងទោសនៃធាតុទាំង ៤ នេះផង នូវការរលាស់ចេញនូវធាតុទាំង ៤ នេះផង (បណ្ឌិតគប្បីឲ្យពិស្តារ) ដឹងច្បាស់... ធ្វើឲ្យជាក់ច្បាស់បានដល់ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ។ ចប់សូត្រទី ៩ ។

៧៦



[៨៧] សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា បឋវីធាតុំ នប្បជានន្តិ បឋវីធាតុសមុទយំ នប្បជានន្តិ បឋវីធាតុនិរោធំ នប្បជានន្តិ បឋវីធាតុនិរោធគាមិនឹ បដិបទំ នប្បជានន្តិ ។ អាបោធាតុំ នប្បជានន្តិ ។ បេ ។ តេជោធាតុំ នប្បជានន្តិ... វាយោធាតុំ នប្បជានន្តិ វាយោធាតុសមុទយំ នប្បជានន្តិ វាយោធាតុនិរោធំ នប្បជានន្តិ វាយោធាតុនិរោធគាមិនឹ បដិបទំ នប្បជានន្តិ ន មេតេ ភិក្ខវេ សមណា វា ព្រាហ្មណា វា សមណេសុ វា សមណសម្មតា ព្រាហ្មណេសុ វា ព្រាហ្មណសម្មតា ន ច បន តេ អាយស្មន្តោ សាមញ្ញត្ថំ វា ព្រហ្មញ្ញត្ថំ វា ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តិ ។

[៨៧] ទ្រង់គង់នៅទៀបក្រុងសាវត្ថី... ក្នុងទីនោះឯង ព្រះមានព្រះភាគ... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ឯណានីមួយ មិនដឹងច្បាស់នូវបឋវីធាតុ មិនដឹងច្បាស់នូវសេចក្តីកើតឡើងនៃបឋវីធាតុ មិនដឹងច្បាស់នូវសេចក្តីរលត់នៃបឋវីធាតុ មិនដឹងច្បាស់នូវបដិបទា ជាហេតុឲ្យដល់នូវសេចក្តីរលត់នៃបឋវីធាតុ... មិនដឹងច្បាស់នូវវាយោធាតុ មិនដឹងច្បាស់នូវសេចក្តីកើតឡើងនៃវាយោធាតុ មិនដឹងច្បាស់នូវសេចក្តីរលត់នៃវាយោធាតុ មិនដឹងច្បាស់នូវបដិបទា ជាហេតុឲ្យដល់នូវសេចក្តីរលត់នៃវាយោធាតុ ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ទាំងនុ៎ះ តថាគតមិនសន្មតថា ជាសមណៈក្នុងពួកសមណៈ មិនសន្មតថា ជាព្រាហ្មណ៍ក្នុងពួកព្រាហ្មណ៍ទេ មួយទៀត អ្នកទាំងនោះ មិនបានធ្វើឲ្យជាក់ច្បាស់ មិនបានដល់ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងក្នុងបច្ចុប្បន្ន នូវប្រយោជន៍នៃសមណភាព ឬប្រយោជន៍នៃព្រាហ្មណភាពទេ ។

## ៧៧

ធាតុសំយុត្តស្ស ចតុធាតុវគ្គេ បឋវីធាតុបជាននាទិ

[៨៨] យេ ច ខោ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា បឋវីធាតុំ បជានន្តិ បឋវីធាតុសមុទយំ បជានន្តិ បឋវីធាតុនិរោធំ បជានន្តិ បឋវីធាតុនិរោធគាមិនឹ បដិបទំ បជានន្តិ ។ អាបោធាតុំ បជានន្តិ ។ បេ ។ តេជោធាតុំ បជានន្តិ... វាយោធាតុំ បជានន្តិ វាយោធាតុសមុទយំ បជានន្តិ វាយោធាតុនិរោធំ បជានន្តិ វាយោធាតុនិរោធគាមិនឹ បដិបទំ បជានន្តិ តេ ខោមេ ភិក្ខវេ សមណា វា ព្រាហ្មណា វា សមណេសុ ចេវ សមណសម្មតា ព្រាហ្មណេសុ ច ព្រាហ្មណសម្មតា តេ ច បនាយស្មន្តោ សាមញ្ញត្ថញ្ច ព្រហ្មញ្ញត្ថញ្ច ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តីតិ ។ ទសមំ ។

ចតុធាតុវគ្គោ ចតុត្ថោ ។

## ៧៧

### ធាតុសំយុត្ត ចតុធាតុវគ្គ ការដឹងច្បាស់នូវបឋវីធាតុជាដើម

[៨៨] ម្នាលភិក្ខុទាំងឡាយ ពួកសមណៈ ឬព្រាហ្មណ៍ឯណានីមួយ ដឹងច្បាស់នូវបឋវីធាតុ ដឹងច្បាស់នូវសេចក្តីកើតឡើងនៃបឋវីធាតុ ដឹងច្បាស់នូវសេចក្តីរលត់នូវបឋវីធាតុ ដឹងច្បាស់នូវបដិបទាជាហេតុឲ្យដល់នូវសេចក្តីរលត់នៃបឋវីធាតុ ។ ដឹងច្បាស់នូវអាបោធាតុ ។ បេ ។ ដឹងច្បាស់នូវតេជោធាតុ... ដឹងច្បាស់នូវវាយោធាតុ ដឹងច្បាស់នូវសេចក្តីកើតឡើងនៃវាយោធាតុ ដឹងច្បាស់នូវសេចក្តីរលត់នៃវាយោធាតុ ដឹងច្បាស់នូវបដិបទា ជាហេតុឲ្យដល់នូវសេចក្តីរលត់នៃវាយោធាតុ ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ទាំងនោះ តថាគតសន្មតថា ជាសមណៈក្នុងពួកសមណៈផង សន្មតថាជាព្រាហ្មណ៍ក្នុងពួកព្រាហ្មណ៍ផង មួយទៀត អ្នកទាំងនោះ បានធ្វើឲ្យជាក់ច្បាស់ បានដល់ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងក្នុងបច្ចុប្បន្ន នូវប្រយោជន៍នៃសមណភាពផង នូវប្រយោជន៍នៃព្រាហ្មណភាពផង ។ ចប់សូត្រទី ១០ ។

ចប់វគ្គ ទី ៤ ។

៧៨

សុត្តន្តបិដកេ  សំយុត្តនិកាយស្ស  និទានវគ្គោ

# តស្ស  ឧទ្ទានំ

ចតស្សោ  បុព្វេ  អចរិ
យោ  ដោ  ចេដំ  ទុក្ខេន  ច
អភិនន្ទនញ្ច  ឧប្បាជំ[១]
តយោ  សមណព្រាហ្មណាតិ  ។

ធាតុសំយុត្តំ  ទុតិយំ  សមត្តំ  ។

---

១  ឧប្បាទោ  ។

# ឧទ្ទាននៃចតុធាតុវគ្គនោះគឺ

*និយាយពីធាតុទាំងបួន ១ កាលមុនដែលព្រះអង្គបាន ត្រាស់ ១ ព្រះអង្គប្រព្រឹត្តស្វែងរកនូវអានិសង្សនៃបឋវីធាតុ ជាដើម ១ ព្រះអង្គត្រាស់ថាបើអានិសង្សនៃបឋវីធាតុនេះមិន មានហើយ ១ សេចក្តីទុក្ខនៃបឋវីធាតុជាដើម ១ សេចក្តី ឱបអរនូវបឋវីធាតុជាដើម ១ សេចក្តីកើតឡើងនៃបឋវីធាតុជា ដើម ១ សមណព្រាហ្មណ៍ ៣ លើក ។*

ចប់ ធាតុសំយុត្ត ទី ២ ។

# អនមតគ្គសំយុត្តំ

## តិណកដ្ឋវគ្គោ

[៨៩] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សា-
វត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។
តត្រ ខោ ។ បេ ។ ឯតទវោច អនមតគ្គោយំ ភិក្ខវេ
សំសារោ បុព្វា កោដិ ន បញ្ញាយតិ អវិជ្ជានីវរណានំ
សត្តានំ តណ្ហាសញ្ញោជនានំ សន្ធាវតំ សំសរតំ ។

[៩០] សេយ្យថាបិ ភិក្ខវេ បុរិសោ យំ ឥមស្មឹ
ជម្ពុទីបេ តិណកដ្ឋសាខាបលាសំ តច្ឆេត្វា ឯកជ្ឈំ
សំហរេយ្យ ឯកជ្ឈំ សំហរិត្វា ចតុរង្គុលំ ចតុរង្គុលំ
ឃដិកំ ករិត្វា និក្ខិបេយ្យ អយំ មេ មាតា តស្សា មេ
មាតុ អយំ មាតាតិ ។ អបរិយាទិន្នា ច ភិក្ខវេ តស្ស
បុរិសស្ស មាតុ មាតរោ អស្សុ អថ ឥមស្មឹ ជម្ពុទីបេ
តិណកដ្ឋសាខាបលាសំ បរិក្ខយំ បរិយាទានំ គច្ឆេយ្យ
តំ កិស្ស ហេតុ អនមតគ្គោយំ ភិក្ខវេ សំសារោ

# អនមតគ្គសំយុត្ត

## តិណកដ្ឋវគ្គ

[៨៩] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ បេ ។ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ សង្សារនេះ មានទីបំផុតខាងដើមមិនប្រាកដ គឺទីបំផុតខាងដើម របស់សត្វទាំងឡាយ ដែលមាននីវរណៈគឺអវិជ្ជា មានសំយោជនៈគឺតណ្ហា អន្ទោលទៅ ត្រាច់រង្គាត់ទៅ មិនប្រាកដឡើយ[១] ។

[៩០] ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសកាត់ស្មៅ កំណាត់ឈើ មែកឈើ ស្លឹកឈើ ក្នុងជម្ពូទ្វីបនេះ ហើយប្រមូលទុកក្នុងទីជាមួយគ្នា លុះប្រមូលទុកក្នុងទីជាមួយគ្នារួចហើយ ក៏ធ្វើខ្នាច់ប្រវែង ៤ ធ្នាប់ ៗ ហើយតម្កល់ទុកថា នេះទុកជាមាតារបស់អញ នេះទុកជាមាតានៃមាតារបស់អញ ។ ម្នាលភិក្ខុទាំងឡាយ មាតាទាំងឡាយ របស់មាតានៃបុរសនោះ មិនអស់ឡើយ ឯស្មៅ កំណាត់ឈើ មែកឈើ និងស្លឹកឈើ ក្នុងជម្ពូទ្វីបនេះ គប្បីដល់នូវការអស់ទៅ ផុតទៅ សេចក្តីនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះសង្សារនេះ មានទីបំផុតខាងដើមមិនប្រាកដ

១-ទីបំផុតខាងដើមនៃសង្សារ មិនបាន ប៉ុន្តែអដ្ឋកថា ប្រាប់ថា សូម្បីទីបំផុតខាងចុង ក៏មិនប្រាកដដែរ ។

បុព្វា កោដិ ន បញ្ញាយតិ អវិជ្ជានីវរណានំ សត្តានំ តណ្ហាសញ្ញោជនានំ សន្ធាវតំ សំសរតំ ឯវំ ទីឃរត្តំ ខោ[១] ភិក្ខវេ ទុក្ខំ បច្ចនុភូតំ តិព្វំ បច្ចនុភូតំ ព្យសនំ បច្ចនុភូតំ កដសី វឌ្ឍិតា ។ យាវញ្ចិទំ ភិក្ខវេ អលមេវ សព្វសង្ខារេសុ និព្វិន្ទិតុំ អលំ វិរជ្ជិតុំ អលំ វិមុច្ចិតុន្តិ ។ បឋមំ ។

[៩១] សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា... អន-មតគ្គោយំ ភិក្ខវេ សំសារោ បុព្វា កោដិ ន បញ្ញាយតិ អវិជ្ជានីវរណានំ សត្តានំ តណ្ហាសញ្ញោជនានំ សន្ធាវតំ សំសរតំ ។

[៩២] សេយ្យថាបិ ភិក្ខវេ បុរិសោ ឥមំ មហាប-ថវឹ កោលដ្ឋិមត្តំ កោលដ្ឋិមត្តំ គុឡិកំ[២] ករិត្វា និក្ខិបេយ្យ អយំ[៣] មេ បិតា តស្ស មេ បិតុ អយំ បិតាតិ ។ អបរិយាទិន្នា ច ភិក្ខវេ តស្ស បុរិសស្ស បិតុ បិតរោ អស្សុ អថាយំ មហាបថវី

១ ឱ. វោ ។ ២ ឱ. ម. មត្តិកាគុឡិកំ ។ ៣ អយំ ខោ ។

គឺទីបំផុតខាងដើម របស់សត្វទាំងឡាយ ដែលមាននីវរណៈ គឺអវិជ្ជា មានសំយោជនៈ គឺតណ្ហា អន្ទោលទៅ ត្រាច់រង្គាត់ទៅ មិនប្រាកដឡើយ ម្នាលភិក្ខុទាំងឡាយ សេចក្តីទុក្ខ សេចក្តីព្រួយ សេចក្តីវិនាស ដែលសត្វទាំងនោះ បានសោយហើយ អស់កាលជាអង្វែងយ៉ាងនេះឯង ទីប៉ាឆា ក៏ចម្រើនឡើង ។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះ គួរដើម្បីនឿយណាយ គួរដើម្បីធុញទ្រាន់ គួរដើម្បីជិនឆ្អន់ ក្នុងសង្ខារទាំងពួង ។ ចប់សូត្រទី ១ ។

[៩១] ទ្រង់គង់នៅទៀបក្រុងសាវត្ថី... ក្នុងទីនោះឯង ព្រះមានព្រះភាគ... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សង្សារនេះ មានទីបំផុតខាងដើមមិនប្រាកដ គឺទីបំផុតខាងដើម របស់សត្វទាំងឡាយ ដែលមាននីវរណៈគឺអវិជ្ជា មានសំយោជនៈគឺតណ្ហា អន្ទោលទៅ ត្រាច់រង្គាត់ទៅ មិនប្រាកដឡើយ ។

[៩២] ម្នាលភិក្ខុទាំងឡាយ ដូចជាបុរស យកមហាប្រឹថពីនេះ មកសូន្យជាគុលិកាឲ្យប៉ុន ៗ គ្រាប់ក្រពៅហើយតម្កល់ទុកថា នេះជាបិតារបស់អញ នេះជាបិតានៃបិតារបស់អញ ។ ម្នាលភិក្ខុទាំងឡាយ បិតាទាំងឡាយរបស់បិតានៃបុរសនោះ មិនអស់ឡើយ ឯមហាប្រឹថពីនេះ

បរិក្ខយំ បរិយាទានំ គច្ឆេយ្យុំ តំ កិស្ស ហេតុ អនមតគ្គោយំ ភិក្ខវេ សំសារោ បុព្វា កោដិ ន បញ្ញាយតិ អវិជ្ជានីវរណានំ សត្តានំ តណ្ហាសញ្ញោជនានំ សន្ធាវតំ សំសរតំ ឯវំ ទីឃរត្តំ ខោ ភិក្ខវេ ទុក្ខំ បច្ចនុភូតំ តិព្វំ បច្ចនុភូតំ ព្យសនំ បច្ចនុភូតំ កដសី វឌ្ឍិតា ។ យាវញ្ចិទំ ភិក្ខវេ អលមេវ សព្វសង្ខារេសុ និព្វិន្ទិតុំ អលំ វិរជ្ជិតុំ អលំ វិមុច្ចិតុន្តិ ។ ទុតិយំ ។

[៩៣] សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា... អនមតគ្គោយំ ភិក្ខវេ សំសារោ ។ បេ ។ តំ កឹ មញ្ញថ ភិក្ខវេ កតមំ នុ ខោ ពហុតរំ យំ វា វោ ឥមិនា ទីឃេន អទ្ធុនា សន្ធាវតំ សំសរតំ អមនាបសម្បយោគា មនាបវិប្បយោគា កន្ទន្តានំ រោទន្តានំ អស្សុ បសន្ទំ[១] បគ្ឃរិតំ យំ វា ចតូសុ មហាសមុទ្ទេសុ ឧទកន្តិ ។ យថា ខោ មយំ ភន្តេ ភគវតា ធម្មំ ទេសិតំ អាជានាម

១ ម. បសន្នំ ។

គប្បីដល់នូវការអស់ទៅ ផុតទៅ សេចក្តីនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះសង្សារនេះ មានទីបំផុតខាងដើមមិនប្រាកដ គឺទីបំផុតខាងដើម របស់សត្វទាំងឡាយ ដែលមាននីវរណៈគឺអវិជ្ជា មានសំយោជនៈគឺតណ្ហា អន្ទោលទៅ ត្រាច់រង្គាត់ទៅ មិនប្រាកដឡើយ ម្នាលភិក្ខុទាំងឡាយ សេចក្តីទុក្ខ សេចក្តីព្រួយ សេចក្តីវិនាស ដែលសត្វទាំងនោះ បានសោយហើយ អស់កាលអង្វែងយ៉ាងនេះ ទីប៉ាធាក៏ចម្រើនឡើង ។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះ គួរដើម្បីនឿយណាយ គួរដើម្បីធុញទ្រាន់ គួរដើម្បីជិនធ្អន់ ក្នុងសង្ខារទាំងពួង ។ ចប់សូត្រទី ២ ។

[៩៣] ទ្រង់គង់នៅក្នុងក្រុងសាវត្ថី... ក្នុងទីនោះឯង ព្រះមានព្រះភាគ... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សង្សារនេះ មានទីបំផុតខាងដើម មិនប្រាកដ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់សេចក្តីនោះថា ដូចម្តេច កាលដែលអ្នកទាំងឡាយ អន្ទោលទៅ ត្រាច់រង្គាត់ទៅ កន្ទក់កន្ទេញ ទួញយំ ព្រោះជួបប្រទះនឹងរបស់ដែលមិនគាប់ចិត្ត ព្រាត់ប្រាសចាករបស់ដែលគាប់ចិត្ត ដោយកាលជាអង្វែងនេះ ទឹកភ្នែកឯណា ដែលហូរស្រក់ទៅក្តី ទឹកក្នុងមហាសមុទ្រទាំង ៤ ឯណាក្តី បណ្តាទឹកទាំងពីរនោះ ទឹកណាច្រើនជាង ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយ ដឹងច្បាស់នូវធម៌ ដែលព្រះមានព្រះភាគសំដែង

ឯតទេវ ភន្តេ ពហុតរំ យំ នោ ឥមិនា ទីឃេន អទ្ធុនា សន្ធាវតំ សំសរតំ អមនាបសម្បយោគា មនាបវិប្បយោគា កន្ទន្តានំ រោទន្តានំ អស្សុ បសន្ទំ[១] បគ្ឃរិតំ ន ត្វេវ ចតូសុ មហាសមុទ្ទេសុ ឧទកន្តិ ។

[៩៤] សាធុ សាធុ ភិក្ខវេ សាធុ ខោ មេ តុម្ហេ ភិក្ខវេ ឯវំ ធម្មំ ទេសិតំ អាជានាថ ឯតទេវ ភិក្ខវេ ពហុតរំ យំ វោ ឥមិនា ទីឃេន អទ្ធុនា សន្ធាវតំ សំសរតំ អមនាបសម្បយោគា មនាបវិប្បយោគា កន្ទន្តានំ រោទន្តានំ អស្សុ បសន្ទំ បគ្ឃរិតំ ន ត្វេវ ចតូសុ មហាសមុទ្ទេសុ ឧទកំ[២] ។ ទីឃរត្តំ វោ ភិក្ខវេ មាតុមរណំ បច្ចនុភូតំ តេសំ វោ មាតុមរណំ បច្ចនុភោន្តានំ អមនាបសម្បយោគា មនាបវិប្បយោគា កន្ទន្តានំ រោទន្តានំ អស្សុ បសន្ទំ បគ្ឃរិតំ ន ត្វេវ ចតូសុ មហាសមុទ្ទេសុ ឧទកំ ។

---

១ ម. បសន្នំ ។ ២ ន ត្វេវ ចតូសុ មហាសមុទ្ទេសុ ឧទកន្តិ ឥមេ បាឋា មរម្មបោត្ថកេ ន ទិស្សន្តិ ។

តាមពិតហើយ បពិត្រព្រះអង្គដ៏ចម្រើន កាលដែលខ្ញុំព្រះអង្គទាំងឡាយ អន្ទោលទៅ ត្រាច់រង្គាត់ទៅ កន្ទក់កន្ទេញ ទួញយំ ព្រោះជួបប្រទះនឹងរបស់ដែលមិនគាប់ចិត្ត ប្រាសចាករបស់ដែលគាប់ចិត្ត ដោយកាលជាអង្វែងនេះ ទឹកភ្នែកដែលហូរស្រក់ទៅច្រើនជាងដោយពិត ឯទឹកក្នុងមហាសមុទ្រទាំង ៤ មិនមែនច្រើនឡើយ ។

[៩៤] ម្នាលភិក្ខុទាំងឡាយ ត្រូវហើយ ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយដឹងច្បាស់នូវធម៌ ដែលតថាគតសំដែងហើយយ៉ាងនេះ ប្រពៃហើយ ម្នាលភិក្ខុទាំងឡាយ កាលដែលអ្នកទាំងឡាយ អន្ទោលទៅ ត្រាច់រង្គាត់ទៅ កន្ទក់កន្ទេញ ទួញយំ ព្រោះជួបប្រទះនឹងរបស់ដែលមិនគាប់ចិត្ត ព្រាត់ប្រាសចាករបស់ដែលគាប់ចិត្ត ដោយកាលជាអង្វែងនេះ ទឹកភ្នែកដែលហូរស្រក់ទៅច្រើនជាងដោយពិត ឯទឹកក្នុងមហាសមុទ្រទាំង ៤ មិនមែនច្រើនឡើយ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីស្លាប់របស់មាតា អ្នកទាំងឡាយបានទទួលរងអស់កាលជាអង្វែង កាលដែលអ្នកទាំងឡាយ ទទួលរងនូវសេចក្តីស្លាប់របស់មាតា កន្ទក់ន្ទេញ ទួញយំ ព្រោះជួបប្រទះនឹងរបស់ដែលមិនគាប់ចិត្ត ព្រាត់ប្រាសចាករបស់ដែលគាប់ចិត្ត ទឹកភ្នែកក៏ហូរស្រក់ទៅច្រើនជាង ទឹកក្នុងមហាសមុទ្រទាំង ៤ មិនមែនច្រើនឡើយ ។

៨៣

អនមតគ្គសំយុត្តស្ស តិណកដ្ឋវគ្គេ អស្សុពហុតរភាវោ

ទីឃរត្តំ វោ ភិក្ខវេ បិតុមរណំ បច្ចនុភូតំ... ភាតុមរណំ បច្ចនុភូតំ... ភគិនិមរណំ បច្ចនុភូតំ... បុត្តមរណំ បច្ចនុភូតំ... ធីតុមរណំ បច្ចនុភូតំ... ញាតិព្យសនំ បច្ចនុភូតំ... ភោគព្យសនំ បច្ចនុភូតំ... ទីឃរត្តំ វោ ភិក្ខវេ រោគព្យសនំ បច្ចនុភូតំ តេសំ វោ រោគព្យសនំ បច្ចនុភោន្តានំ អមនាបសម្បយោគា មនាបវិប្បយោគា កន្ទន្តានំ រោទន្តានំ អស្សុ បសន្នំ បគ្ឃរិតំ ន ត្វេវ ចតូសុ មហាសមុទ្ទេសុ ឧទកំ តំ កិស្ស ហេតុ អនមតគ្គោយំ ភិក្ខវេ សំសារោ ។ បេ ។ យាវញ្ចិទំ ភិក្ខវេ អលមេវ សព្វសង្ខារេសុ និព្វិន្ទិតុំ អលំ វិរជ្ជិតុំ អលំ វិមុច្ចិតុន្តិ ។ តតិយំ ។

ម្នាលភិក្ខុទាំងឡាយ សេចក្តីស្លាប់របស់បិតា អ្នកទាំងឡាយបានទទួលរងអស់កាលជាអង្វែង... សេចក្តីស្លាប់របស់បងប្អូនប្រុស អ្នកទាំងឡាយបានទទួលរង... សេចក្តីស្លាប់របស់បងប្អូនស្រី អ្នកទាំងឡាយបានទទួលរង... សេចក្តីស្លាប់របស់កូនប្រុស អ្នកទាំងឡាយបានទទួលរង... សេចក្តីស្លាប់របស់កូនស្រី អ្នកទាំងឡាយបានទទួលរង... សេចក្តីវិនាសនៃញាតិ អ្នកទាំងឡាយបានទទួលរង... សេចក្តីវិនាសភោគៈ អ្នកទាំងឡាយបានទទួលរង... ម្នាលភិក្ខុទាំងឡាយ សេចក្តីវិនាសព្រោះរោគ អ្នកទាំងឡាយបានទទួលរងអស់កាលជាអង្វែង កាលដែលអ្នកទាំងឡាយទទួលរងនូវសេចក្តីវិនាស ព្រោះរោគ កន្ទក់កន្ទេញ ទួញយំព្រោះជួបប្រទះនឹងរបស់ដែលមិនគាប់ចិត្ត ព្រាត់ប្រាសចាករបស់ ដែលគាប់ចិត្ត ទឹកភ្នែកក៏ហូរស្រក់ទៅច្រើនជាង ទឹកក្នុងមហាសមុទ្រទាំង ៤ មិនមែនច្រើនឡើយ សេចក្តីនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះសង្សារនេះ មានទីបំផុតខាងដើម មិនប្រាកដ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះ គួរដើម្បីនឿយណាយ គួរដើម្បីធុញទ្រាន់ គួរដើម្បីជិនឆ្អន់ ក្នុងសង្ខារទាំងពួងដោយពិត ។ ចប់សូត្រទី ៣ ។

[៩៨] សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា... អនមតគ្គោយំ ភិក្ខវេ សំសារោ ។ បេ ។ តំ កឹ មញ្ញថ ភិក្ខវេ កាតមំ នុ ខោ ពហុតរំ យំ វា វោ ឥមិនា ទីឃេន អទ្ធុនា សន្ធាវតំ សំសរតំ មាតុ ថញ្ញំ បីតំ យំ វា ចតូសុ មហាសមុទ្ទេសុ ឧទកន្តិ ។ យថា ខោ មយំ ភន្តេ ភគវតា ធម្មំ ទេសិតំ អាជានាម ឯតទេវ ភន្តេ ពហុតរំ យំ នោ ឥមិនា ទីឃេន អទ្ធុនា សន្ធាវតំ សំសរតំ មាតុ ថញ្ញំ បីតំ ន ត្វេវ ចតូសុ មហាសមុទ្ទេសុ ឧទកន្តិ ។

[៩៥] ទ្រង់គង់នៅទៀបក្រុងសាវត្ថី... ក្នុងទីនោះឯង ព្រះមានព្រះភាគ... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកមានទីបំផុតខាងដើម មិនប្រាកដ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់សេចក្តីនោះថា ដូចម្តេច កាលដែលអ្នកទាំងឡាយអន្ទោលទៅ ត្រាច់រង្គាត់ទៅ ដោយកាលជាអង្វែងនេះ បានផឹកនូវទឹកដោះឯណានៃមាតាក្តី ទឹកឯណាក្នុងមហាសមុទ្រទាំង ៤ ក្តី បណ្តាទឹកទាំងពីរនោះ ទឹកណាច្រើនជាង ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយ ដឹងច្បាស់នូវធម៌ ដែលព្រះមានព្រះភាគសំដែងហើយដោយពិត បពិត្រព្រះអង្គដ៏ចម្រើន កាលដែលខ្ញុំព្រះអង្គទាំងឡាយអន្ទោលទៅ ត្រាច់រង្គាត់ទៅ ដោយកាលជាអង្វែងនេះ បានផឹកទឹកដោះមាតាច្រើនជាងដោយពិត ឯទឹកក្នុងមហាសមុទ្រទាំង ៤ មិនមែនច្រើនឡើយ ។

[៩៦] សាធុ សាធុ ភិក្ខវេ សាធុ ខោ មេ តុម្ហេ ភិក្ខវេ ឯវំ ធម្មំ ទេសិតំ អាជានាថ ឯតទេវ ភិក្ខវេ ពហុតរំ យំ វោ ឥមិនា ទីឃេន អទ្ធុនា សន្ធាវតំ សំសរតំ មាតុ ថញ្ញំ បីតំ ន ត្វេវ ចតូសុ មហាសមុទ្ទេសុ ឧទកំ តំ កិស្ស ហេតុ អនមតគ្គោយំ ភិក្ខវេ សំសារោ ។ បេ ។ អលំ វិមុច្ចិតុន្តិ ។ ចតុត្ថំ ។

[៩៧] សាវត្ថិយំ វិហរតិ... អថខោ អញ្ញតរោ ភិក្ខុ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ។ បេ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច កីវទីឃោ នុ ខោ ភន្តេ កប្បោតិ ។ ទីឃោ ខោ ភិក្ខុ កប្បោ សោ ន សុករោ សង្ខាតុំ ឯត្តកានិ វស្សានិ ឥតិ វា ឯត្តកានិ វស្សសតានិ ឥតិ វា ឯត្តកានិ វស្សសហស្សានិ ឥតិ វា ឯត្តកានិ វស្សសតសហស្សានិ ឥតិ វាតិ ។ សក្កា បន ភន្តេ ឧបមា[១] កាតុន្តិ ។

១ ម. ឱបមំ ។

[៩៦] ម្នាលភិក្ខុទាំងឡាយ ត្រូវហើយ ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយដឹងច្បាស់ នូវធម៌ដែលតថាគតសំដែងហើយយ៉ាងនេះដោយប្រពៃ ម្នាលភិក្ខុទាំងឡាយ កាលដែលអ្នកទាំងឡាយអន្ទោលទៅ ត្រាច់រង្គាត់ទៅ ដោយកាលជាអង្វែងនេះ បានផឹកទឹកដោះរបស់មាតាច្រើនជាងដោយពិត ឯទឹកក្នុងមហាសមុទ្រទាំង ៤ មិនមែនច្រើនជាងឡើយ សេចក្តីនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះសង្សារនេះ មានទីបំផុតខាងដើម មិនប្រាកដ ។ បេ ។ គួរដើម្បីជិនធ្អន់ ។ ចប់សូត្រទី ៤ ។

[៩៧] ទ្រង់គង់នៅទៀបក្រុងសាវត្ថី... គ្រានោះឯង មានភិក្ខុមួយរូប ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ។ បេ ។ លុះភិក្ខុនោះ អង្គុយក្នុងទីដ៏សមគួរហើយ ក្រាបបង្គំទូលសួរ ព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន កប្បមានកាលវែងប៉ុន្មាន ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុ កប្បមានកាលវែងណាស់ កប្បនោះមិនងាយនឹងរាប់ថា ប៉ុណ្ណេះឆ្នាំក្តី ថាប៉ុណ្ណេះរយឆ្នាំក្តី ថាប៉ុណ្ណេះពាន់ឆ្នាំក្តី ថាប៉ុណ្ណេះសែនឆ្នាំក្តី បានឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះព្រះអង្គអាចធ្វើពាក្យឧបមាបានឬទេ ។

[៩៨] សក្កា ភិក្ខូតិ ភគវា អវោច សេយ្យ-
ថាបិ ភិក្ខុ មហាសេលោ បព្វតោ យោជនំ អាយា-
មេន យោជនំ វិត្ថារេន យោជនំ ឧព្វេធេន អច្ឆិទ្ទោ
អសុសិរោ ឯកឃនោ តមេនំ បុរិសោ វស្សសតស្ស
វស្សសតស្ស អច្ចយេន កាសិកេន វត្ថេន សកឹ
សកឹ បរិមជ្ជេយ្យ ខិប្បតរំ ខោ សោ ភិក្ខុ មហា-
សេលោ បព្វតោ ឥមិនា ឧបក្កមេន បរិក្ខយំ ប-
រិយាទានំ គច្ឆេយ្យ ន ត្វេវ កប្បោ ឯវំទីឃោ ខោ
ភិក្ខុ កប្បោ ។ ឯវំទីឃានំ ខោ ភិក្ខុ កប្បានំ
នេកោ កប្បោ សំសិតោ នេកំ កប្បសតំ សំសិតំ
នេកំ កប្បសហស្សំ សំសិតំ នេកំ កប្បសតស-
ហស្សំ សំសិតំ តំ កិស្ស ហេតុ អនមតគ្គោយំ
ភិក្ខុ សំសារោ ។ បេ ។ យាវញ្ចិទំ ភិក្ខុ អលមេវ
សព្វសង្ខារេសុ និព្វិន្ទិតុំ អលំ វិរជ្ជិតុំ អលំ វិមុច្ចិ-
តុន្តិ ។ បញ្ចមំ ។

[៩៦] ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុ អាចធ្វើបាន ហើយទ្រង់ត្រាស់តទៅទៀតថា ម្នាលភិក្ខុ ដូចភ្នំថ្មសុទ្ធដ៏ធំ បណ្តោយមួយយោជន៍ ទទឹងមួយយោជន៍ កំពស់ក៏មួយយោជន៍ មិនបានធ្លុះ មិនមានប្រហោង ជាភ្នំតាន់ កន្ទង់មួយរយឆ្នាំ ៗ ទៅ មានបុរសយកសំពត់កាសិកមកបោសភ្នំនោះម្តង ៗ ម្នាលភិក្ខុ ភ្នំថ្មសុទ្ធដ៏ធំនោះគប្បីដល់នូវការអស់ទៅ រេចទៅ ដោយសេចក្តីព្យាយាមនេះ ឆាប់ជាង ឯកប្បមិនទាន់អស់ទៅឡើយ ម្នាលភិក្ខុ កប្បមានកាលវែងយ៉ាងនេះឯង ។ ម្នាលភិក្ខុ បណ្តាកប្បដែលមានកាលវែងយ៉ាងនេះ សូម្បីកប្បមួយក៏រាប់មិនបាន កប្បមួយរយក៏រាប់មិនបាន កប្បមួយពាន់ក៏រាប់មិនបាន កប្បមួយសែនក៏រាប់មិនបាន សេចក្តីនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុ ព្រោះសង្សារនេះ មានទីបំផុតខាងដើមមិនប្រាកដ ។ បេ ។ ម្នាលភិក្ខុ ហេតុនេះ គួរដើម្បីនឿយណាយ គួរដើម្បីធុញទ្រាន់ គួរដើម្បីជិនឆ្អន់ ក្នុងសង្ខារទាំងពួង ។ ចប់សូត្រទី ៥ ។

៨៧

អនមតគ្គសំយុត្តស្ស តិណកដ្ឋវគ្គេ សាសបូបមា

[៩៩] សាវត្ថិយំ វិហរតិ... អថខោ អញ្ញតរោ ភិក្ខុ យេន ភគវា ។ បេ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច កីវទីឃោ នុ ខោ ភន្តេ កប្បោតិ ។ ទីឃោ ខោ ភិក្ខុ កប្បោ សោ ន សុករោ សង្ខាតុំ ឯត្តកានិ វស្សានិ ឥតិ វា ។ បេ ។ ឯត្តកានិ វស្សសតសហស្សានិ ឥតិ វាតិ ។ សក្កា បន ភន្តេ ឧបមា កាតុន្តិ ។

[១០០] សក្កា ភិក្ខូតិ ភគវា អវោច សេយ្យ-ថាបិ ភិក្ខុ អាយសំ នគរំ យោជនំ អាយាមេន យោជនំ វិត្ថារេន យោជនំ ឧព្វេធេន បុណ្ណំ សាសបានំ គុឡិកាពទ្ធំ តតោ បុរិសោ វស្សសតស្ស វស្សស-តស្ស អច្ចយេន ឯកមេកំ សាសបំ ឧទ្ធរេយ្យ

អនមតគ្គសំយុត្ត តិណកដ្ឋវគ្គ ឧបមាដោយគ្រាប់ស្ពៃ

[៩៩] ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... គ្រានោះឯង ភិក្ខុមួយរូប ចូលទៅគាល់ព្រះមានព្រះភាគ ។ បេ ។ លុះភិក្ខុនោះអង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលសួរព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន កប្បមានកាលវែងប៉ុន្មាន ។ ម្នាលភិក្ខុ កប្បមានកាលវែងណាស់ កប្បនោះ មិនងាយនឹងរាប់ថា ប៉ុណ្ណោះឆ្នាំក្តី ។ បេ ។ ថាប៉ុណ្ណោះសែនឆ្នាំក្តី បានឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះព្រះអង្គអាចធ្វើពាក្យឧបមាបានឬទេ ។

[១០០] ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុ អាចធ្វើបាន ហើយទ្រង់ត្រាស់តទៅទៀតថា ម្នាលភិក្ខុ ដូចជានគរដែលព័ទ្ធដោយកំពែង បណ្តោយមួយយោជន៍ ទទឹងមួយយោជន៍ កំពស់មួយយោជន៍ ពេញដោយគ្រាប់ស្ពៃ ជានគរគេបិទភ្ជាប់ ដោយដុំដីស្អិត កន្លងមួយរយឆ្នាំ ៗ ទៅ មានបុរសទៅរើសយកគ្រាប់ស្ពៃមួយគ្រាប់ ៗ អំពីនគរនោះ

ខិប្បតរំ ខោ សោ ភិក្ខុ មហាសាសបរាសិ ឥមិនា ឧបក្កមេន បរិក្ខយំ បរិយាទានំ គច្ឆេយ្យ ន ត្វេវ កប្បោ ឯវំទីឃោ ខោ ភិក្ខុ កប្បោ ។ ឯវំទីឃានំ ខោ ភិក្ខុ កប្បានំ នេកោ កប្បោ សំសិតោ នេកំ កប្បសតំ សំសិតំ នេកំ កប្បសហស្ស សំសិតំ នេកំ កប្បសតសហស្សំ សំសិតំ តំ កិស្ស ហេតុ អនមតគ្គោយំ ភិក្ខុ សំសារោ ។ បេ ។ អលំ វិមុច្ចិតុន្តិ ។ ឆដ្ឋំ ។

[១០១] សាវត្ថិយំ វិហរតិ... អថខោ សម្ពហុលា ភិក្ខូ យេន ភគវា ។ បេ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ កីវពហុកា នុ ខោ ភន្តេ កប្បា អព្ភតីតា អតិក្កន្តាតិ ។ ពហុកា ខោ ភិក្ខវេ កប្បា អព្ភតីតា អតិក្កន្តា តេ ន សុករា សង្ខាតុំ ឯត្តកា កប្បា ឥតិ វា ឯត្តកានិ កប្បសតានិ ឥតិ វា ឯត្តកានិ កប្បសហស្សានិ ឥតិ វា ឯត្តកានិ កប្បសតសហស្សានិ ឥតិ វាតិ ។ សក្កា បន ភន្តេ ឧបមា កាតុន្តិ ។

ម្នាលភិក្ខុ គំនរគ្រាប់ស្ពៃដ៏ធំនោះ គប្បីដល់នូវការអស់ទៅ រលីងទៅ ដោយសេចក្តីព្យាយាមនេះឆាប់ជាង ឯកប្បមិនទាន់អស់ទៅឡើយ ម្នាលភិក្ខុ កប្បមានកាលវែងយ៉ាងនេះឯង ។ ម្នាលភិក្ខុ បណ្តាកប្បដែលមានកាលវែងយ៉ាងនេះ សូម្បីកប្បមួយ ក៏រាប់មិនបាន កប្បមួយរយ ក៏រាប់មិនបាន កប្បមួយពាន់ ក៏រាប់មិនបាន កប្បមួយសែន ក៏រាប់មិនបាន សេចក្តីនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុ ព្រោះសង្សារនេះ មានទីបំផុតខាងដើមមិនប្រាកដ ។ បេ ។ គួរដើម្បីជិនធ្លន់ ។ ចប់សូត្រទី ៦ ។

[១០១] ទ្រង់គង់នៅទៀបក្រុងសាវត្ថី... គ្រានោះឯង ភិក្ខុច្រើនរូប ចូលទៅគាល់ព្រះមានព្រះភាគ ។ បេ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលសួរ ព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន កប្បដែលកន្លងរំលងទៅហើយ មានចំនួនច្រើនប៉ុន្មាន ។ ម្នាលភិក្ខុទាំងឡាយ កប្បដែលកន្លងរំលងទៅហើយ មានចំនួនច្រើនណាស់ កប្បទាំងនោះ មិនងាយនឹងរាប់ថា ប៉ុណ្ណោះកប្បក្តី ថាប៉ុណ្ណោះរយកប្បក្តី ថាប៉ុណ្ណោះពាន់កប្បក្តី ថាប៉ុណ្ណោះសែនកប្បក្តី បានឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះព្រះអង្គអាចធ្វើពាក្យឧបមាបានឬទេ ។

៨៩



[១០២] សត្ថា ភិក្ខវេតិ ភគវា អវោច ឥធស្សុ ភិក្ខវេ ចត្តារោ សាវកា វស្សសតាយុកា វស្សសតជីវិនោ តេ ចេ ទិវសេ ទិវសេ កប្បសតសហស្សំ កប្បសតសហស្សំ អនុស្សរេយ្យុំ ។ អននុស្សរិតា វ ភិក្ខវេ តេហិ កប្បា អស្សុ ។ អថខោ មេ ចត្តារោ សាវកា វស្សសតាយុកា វស្សសតជីវិនោ វស្សសតស្ស វស្សសតស្ស អច្ចយេន កាលំ ករេយ្យុំ ។ ឯវំ ពហុកា ខោ ភិក្ខវេ កប្បា អព្ភតីតា អតិក្កន្តា តេ ន សុករា សង្ខាតុំ ឯត្តកា កប្បា ឥតិ វា ឯត្តកានិ កប្បសតានិ ឥតិ វា ឯត្តកានិ កប្បសហស្សានិ ឥតិ វា ឯត្តកានិ កប្បសតសហស្សានិ ឥតិ វា តំ កិស្ស ហេតុ អនមតគ្គោយំ ភិក្ខវេ សំសារោ ។ បេ ។ អលំ វិមុច្ចិតុន្តិ ។ សត្តមំ ។

អនមតគ្គសំយុត្ត តិណកដ្ឋវគ្គ កប្បមានចំនួនច្រើនណាស់

[១០២] ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាចធ្វើបាន ហើយទ្រង់ត្រាស់តទៅទៀតថា ម្នាលភិក្ខុទាំងឡាយ ប្រសិនបើសាវ័ក ៤ រូប ក្នុងសាសនានេះ មានអាយុមួយរយឆ្នាំ រស់នៅមួយរយឆ្នាំ បើសាវ័កទាំងនោះ គប្បីរឭកបានមួយសែនកប្បម្នាក់ ៗ រាល់ ៗ ថ្ងៃ ។ ម្នាលភិក្ខុទាំងឡាយ សាវ័កទាំងនោះ ក៏មិនអាចនឹងរឭកកប្បឲ្យអស់បានឡើយ ។ គ្រានោះឯង សាវ័កទាំង ៤ របស់តថាគត មានអាយុមួយរយឆ្នាំ រស់នៅមួយរយឆ្នាំ កន្លងទៅមួយរយឆ្នាំម្នាក់ ៗ គប្បីធ្វើមរណកាលទៅ ។ ម្នាលភិក្ខុទាំងឡាយ កប្បដែលកន្លងរំលងទៅមានចំនួនច្រើនយ៉ាងនេះឯង កប្បទាំងនោះ មិនងាយនឹងរាប់ថាប៉ុណ្ណោះកប្បក្តី ថាប៉ុណ្ណោះរយកប្បក្តី ថាប៉ុណ្ណោះពាន់កប្បក្តី ថាប៉ុណ្ណោះសែនកប្បក្តី សេចក្តីនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះសង្សារនេះ មានទីបំផុតខាងដើមមិនប្រាកដ ។ បេ ។ គួរដើម្បីជិនធ្លន់ ។

ចប់សូត្រទី ៧ ។

[១០៣] ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ អថខោ អញ្ញតរោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ ព្រាហ្មណោ ភគវន្តំ ឯតទវោច កីវពហុកា នុ ខោ ភោ គោតម កប្បា អព្ភតីតា អតិក្កន្តាតិ ។ ពហុកា ខោ ព្រាហ្មណ កប្បា អព្ភតីតា អតិក្កន្តា តេ ន សុករា សង្ខាតុំ ឯត្តកា កប្បា ឥតិ វា ឯត្តកានិ កប្បសតានិ ឥតិ វា ឯត្តកានិ កប្បសហស្សានិ ឥតិ វា ឯត្តកានិ កប្បសតសហស្សានិ ឥតិ វាតិ ។ សក្កា បន ភោ គោតម ឧបមា កាតុន្តិ ។

[១០៤] សក្កា ព្រាហ្មណាតិ ភគវា អវោច សេយ្យថាបិ ព្រាហ្មណ យតោ ចាយំ គង្គានទី បហោតិ យត្ថ ច មហាសមុទ្ទំ អប្បេតិ យា ឯតស្មឹ អន្តរេ វាលិកា សា ន សុករា សង្ខាតុំ ឯត្តកា វាលិកា ឥតិ វា ឯត្តកានិ វាលិកសតានិ ឥតិ វា

[១០៣] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ គ្រានោះឯងព្រាហ្មណ៍ម្នាក់ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ទើបអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រាហ្មណ៍នោះ អង្គុយក្នុងទីដ៏សមគួរហើយ ក្រាបបង្គំទូលសួរព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន កប្បដែលកន្លងរំលងទៅ មានចំនួនច្រើនប៉ុន្មាន ។ ម្នាលព្រាហ្មណ៍ កប្បដែលកន្លងរំលងទៅមានចំនួនច្រើនណាស់ កប្បទាំងនោះ មិនងាយនឹងរាប់ថា ប៉ុណ្ណេះកប្បក្តី ថាប៉ុណ្ណេះរយកប្បក្តី ថាប៉ុណ្ណេះពាន់កប្បក្តី ថាប៉ុណ្ណេះសែនកប្បក្តី បានឡើយ ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះព្រះអង្គអាចធ្វើពាក្យឧបមាបានឬទេ ។

[១០៤] ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ អាចធ្វើបាន ហើយទ្រង់ត្រាស់តទៅទៀតថា ម្នាលព្រាហ្មណ៍ ដូចជាចាប់ដើមតាំងអំពីស្ទឹងគង្គានេះ កើតមានមក តែងហូរទៅកាន់មហាសមុទ្រក្នុងចន្លោះឯណា គ្រាប់ខ្សាច់ឯណាដែលមានក្នុងចន្លោះនោះ គ្រាប់ខ្សាច់នោះ មិនងាយនឹងរាប់ថា ប៉ុណ្ណេះគ្រាប់ខ្សាច់ក្តី ថាប៉ុណ្ណេះរយគ្រាប់ខ្សាច់ក្តី

ឯត្តកានិ វាលិកសហស្សានិ ឥតិ វា ឯត្តកានិ វាលិកសតសហស្សានិ ឥតិ វា ។ តតោ[១] ពហុតរា ខោ ព្រាហ្មណ កប្បា អព្ភតីតា អតិក្កន្តា តេ ន សុករា សង្ខាតុំ ឯត្តកា កប្បា ឥតិ វា ឯត្តកានិ កប្បសតានិ ឥតិ វា ឯត្តកានិ កប្បសហស្សានិ ឥតិ វា ឯត្តកានិ កប្បសតសហស្សានិ ឥតិ វា តំ កិស្ស ហេតុ អនមតគ្គោយំ ព្រាហ្មណ សំសារោ បុព្វា កោដិ ន បញ្ញាយតិ អវិជ្ជានីវរណានំ សត្តានំ តណ្ហាសញ្ញោជនានំ សន្ធាវតំ សំសរតំ ឯវំ ទីឃរត្តំ ខោ ព្រាហ្មណ ទុក្ខំ បច្ចនុភូតំ តិប្បំ បច្ចនុភូតំ ព្យសនំ បច្ចនុភូតំ កដសី វឌ្ឍិតា ។ យាវញ្ចិទំ ព្រាហ្មណ អលមេវ សព្វសង្ខារេសុ និព្វិន្ទិតុំ អលំ វិរជ្ជិតុំ អលំ វិមុច្ចិតុន្តិ ។

[១០៤] ឯវំ វុត្តេ សោ ព្រាហ្មណោ ភគវន្តំ ឯត-ទវោច អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម ។ បេ ។ ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណង្គតន្តិ ។ អដ្ឋមំ ។

---

១ ឱ. អតោ ។

ថាប៉ុណ្ណោះពាន់គ្រាប់ខ្សាច់ក្តី ថាប៉ុណ្ណោះសែនគ្រាប់ខ្សាច់ក្តី ។ ម្នាលព្រាហ្មណ៍ កប្បដែលកន្លងរំលងទៅហើយ ច្រើនជាងគ្រាប់ខ្សាច់នោះឯង កប្បនោះមិនងាយនឹងរាប់ថា ប៉ុណ្ណោះកប្បក្តី ថាប៉ុណ្ណោះរយកប្បក្តី ថាប៉ុណ្ណោះពាន់កប្បក្តី ថាប៉ុណ្ណោះសែនកប្បក្តី សេចក្តីនោះ ព្រោះហេតុដូចម្តេច ម្នាលព្រាហ្មណ៍ ព្រោះសង្សារនេះ មានទីបំផុតខាងដើមមិនប្រាកដ គឺទីបំផុតខាងដើមរបស់សត្វទាំងឡាយ ដែលមាននីវរណៈគឺអវិជ្ជា មានសំយោជនៈគឺតណ្ហា អន្ទោលទៅ ត្រាច់រង្គាត់ទៅ មិនប្រាកដឡើយ ម្នាលព្រាហ្មណ៍ សេចក្តីទុក្ខ សេចក្តីព្រួយ សេចក្តីវិនាស សត្វទាំងនោះទទួលរងហើយ អស់កាលជាអង្វែងយ៉ាងនេះ ទីប៉ាធាក៏ចម្រើនឡើង ។ ម្នាលព្រាហ្មណ៍ ហេតុនេះ គួរដើម្បីនឿយណាយ គួរដើម្បីធុញទ្រាន់ គួរដើម្បីជិនឆ្អន់ ក្នុងសង្ខារទាំងពួង ។

[១០៥] កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់ យ៉ាងនេះហើយ ព្រាហ្មណ៍នោះ ក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ ។ បេ ។ សូមព្រះគោតមដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសក ដល់នូវសរណៈស្មើដោយជីវិត ចាប់ដើមតាំងពីថ្ងៃនេះតទៅ ។

ចប់សូត្រទី ៨ ។

[១០៦] សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា... អនមតគ្គោយំ ភិក្ខវេ សំសារោ បុព្វា កោដិ ន បញ្ញាយតិ អវិជ្ជានីវរណានំ សត្តានំ តណ្ហាសញ្ញោជន-ានំ សន្ធាវតំ សំសរតំ ។ បេ ។

[១០៧] សេយ្យថាបិ ភិក្ខវេ ទណ្ឌោ ឧបរិវេហាសំ ខិត្តោ សកិម្បិ មូលេន និបតតិ សកិម្បិ មជ្ឈេន និបតតិ សកិម្បិ អគ្គេន និបតតិ ឯវមេវ ខោ ភិក្ខវេ អវិជ្ជានីវរណា សត្តា តណ្ហាសញ្ញោជនា សន្ធាវន្តា សំសរន្តា សកិម្បិ អស្មា លោកា បរំ លោកំ គច្ឆន្តិ សកិម្បិ បរស្មា លោកា ឥមំ លោកំ អាគច្ឆន្តិ តំ កិស្ស ហេតុ អនមតគ្គោយំ ភិក្ខវេ សំសារោ ។ បេ ។ អលំ វិមុច្ចិតុន្តិ ។ នវមំ ។

[១០៦] ទ្រង់គង់នៅទៀបក្រុងសាវត្ថី... ក្នុងទីនោះឯង ព្រះមានព្រះភាគ... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សង្សារនេះមានទីបំផុតខាងដើម មិនប្រាកដ គឺទីបំផុតខាងដើមរបស់សត្វទាំងឡាយ ដែលមាននីវរណៈ គឺអវិជ្ជា មានសំយោជនៈ គឺតណ្ហា អន្ទោលទៅ ត្រាច់រង្គាត់ទៅ មិនប្រាកដឡើយ ។ បេ ។

[១០៧] ម្នាលភិក្ខុទាំងឡាយ ដូចជាដំបងដែលគេចោលទៅឰដ៏អាកាសខាងលើ ចួនកាលក៏ធ្លាក់ចុះខាងគល់មកមុន ចួនកាលក៏ធ្លាក់ចុះត្រង់កណ្តាលមកមុន ចួនកាលក៏ធ្លាក់ចុះខាងចុងមកមុន ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ ដែលមាននីវរណៈគឺអវិជ្ជា មានសំយោជនៈគឺតណ្ហា អន្ទោលទៅ ត្រាច់រង្គាត់ទៅ ចួនកាលក៏ចេញអំពីលោកនេះទៅកាន់លោកខាងមុខ ចួនកាលក៏ចេញអំពីលោកខាងមុខ មកកាន់លោកនេះវិញយ៉ាងនោះឯង សេចក្តីនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះសង្សារនេះ មានទីបំផុតខាងដើម មិនប្រាកដ ។ បេ ។ គួរដើម្បីជិនធ្នន់ ។ ចប់សូត្រទី ៩ ។

៩៣

អនមតគ្គសំយុត្តស្ស តិណកដ្ឋវគ្គេ និគមវចនំ

[១០៨] ឯកំ សមយំ ភគវា រាជគហេ វិហរតិ គិជ្ឈកូដេ បព្វតេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

[១០៩] ភគវា ឯតទវោច អនមតគ្គោយំ ភិក្ខវេ សំសារោ ។ បេ ។ ឯកស្ស បុគ្គលស្ស ភិក្ខវេ កប្បំ សន្ធាវតោ សំសរតោ សិយា ឯវំ មហា អដ្ឋិកង្កលោ អដ្ឋិបុញ្ជោ អដ្ឋិរាសិ យថាយំ វេបុល្លោ បព្វតោ សចេ សំហារកោ អស្ស សម្ភតញ្ច ន វិនស្សេយ្យ តំ កិស្ស ហេតុ អនមតគ្គោយំ ភិក្ខវេ សំសារោ ។ បេ ។ អលំ វិមុច្ចិតុន្តិ ។

[១១០] ឥទមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា

អនមតគ្គសំយុត្ត តិណកដ្ឋវគ្គ និគមវចនៈ

[១០៨] *សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅលើភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះ ។ ក្នុងទីនោះឯង ព្រះមានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ដូច្នេះ ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ។*

[១០៩] *ព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ សង្សារនេះ មានទីបំផុតខាងដើម មិនប្រាកដ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ កាលដែលបុគ្គលម្នាក់ អន្ទោលទៅ ត្រាច់រង្គាត់ទៅ អស់មួយកប្ប រាងឆ្អឹង ពំនូតឆ្អឹង គំនរឆ្អឹងយ៉ាងធំ ប្រហែលគ្នានឹងភ្នំវេបុល្លនេះឯង ប្រសិនបើមានបុគ្គលអ្នកជញ្ជូនយកឆ្អឹង ដែលគេគរទុក ក៏មិនគប្បីអស់ទៅឡើយ សេចក្តីនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះសង្សារនេះ មានទីបំផុតខាងដើម មិនប្រាកដ ។ បេ ។ គួរដើម្បីជិនធ្នន់ ។*

[១១០] *ព្រះមានព្រះភាគ ទ្រង់ត្រាស់សូត្រនេះរួចហើយ លុះព្រះសុគតជាសាស្តា ត្រាស់សូត្រនេះហើយ ទើបទ្រង់ត្រាស់ពាក្យនេះតទៅទៀតថា ។*

ឯកស្សេកេន កប្បេន

បុគ្គលស្សដ្ឋិសញ្ចយោ

សិយា បព្វតសមោ រាសិ

ឥតិ វុត្តំ មហេសិនា

សោ ខោ បនាយំ អក្ខាតោ

វេបុល្លោ បព្វតោ មហា

ឧត្តរោ គិជ្ឈកូដស្ស

មគធានំ គិរិព្វជេ

យតោ ច អរិយសច្ចានិ

សម្មប្បញ្ញាយ បស្សតិ

ទុក្ខំ ទុក្ខសមុប្បាទំ

ទុក្ខស្ស ច អតិក្កមំ

អរិយញ្ចដ្ឋង្គិកំ មគ្គំ

គំនរនៃឆ្អឹងរបស់បុគ្គលម្នាក់ចំនួនមួយកប្ប គំនរនោះប្រ-ហែលគ្នានឹងភ្នំ ព្រះពុទ្ធជាមហេសី បានត្រាស់ហើយដូច្នេះ ភ្នំវេបុល្លនេះលោកពោលហើយថា ធំលើសលុបជាងភ្នំគិជ្ឈ-[១] កូដទៀបក្រុងគិរិព្វជៈ (រាជគ្រឹះ) របស់អ្នកមគធៈទាំងឡាយ មួយទៀត បុគ្គលឯណា ឃើញនូវអរិយសច្ចដោយប្រាជ្ញាដ៏ប្រពៃ គឺទុក្ខ ១ តណ្ហាដែលញុំាងទុក្ខឲ្យកើតឡើង ១ ព្រះនិព្វានជាគ្រឿងប្រព្រឹត្តកន្លងនូវទុក្ខ ១ អដ្ឋង្គិកមគ្គដ៏ប្រសើរ

១ ភ្នំវេបល្លៈនេះ បិតនៅខាងជើងនៃភ្នំគិជ្ឈកូដ ។ អដ្ឋកថា ។

៩៤

អនមតគ្គសំយុត្តស្ស តិណកដ្ឋវគ្គេ ឧទ្ទានំ

ទុក្ខូបសមគាមិនំ
សត្តក្ខត្តុបរមំ
សន្ធាវិត្វាន បុគ្គលោ
ទុក្ខស្សន្តករោ ហោតិ
សព្វសញ្ញោជនក្ខយាតិ ។ ទសមំ ។

តិណកដ្ឋវគ្គោ បឋមោ ។

## តស្ស ឧទ្ទានំ

តិណកដ្ឋញ្ច បថវី
អស្សុ ខីរញ្ច បព្វតំ
សាសបា សាវកោ គង្គា
ទណ្ឌោ ច បុគ្គលេន ចាតិ ។

---

ជាសភាវៈឲ្យដល់នូវសេចក្តីស្ងប់រម្ងាប់នៃទុក្ខ ១ បុគ្គលនោះ អន្ទោលទៅកំណត់ត្រឹម ៧ ជាតិ ជាយ៉ាងយូរ រមែងធ្វើនូវទីបំផុតនៃសេចក្តីទុក្ខ ព្រោះអស់ទៅនៃសំយោជនៈទាំងពួង ។

ចប់សូត្រទី ១០ ។

ចប់ តិណកដ្ឋវគ្គទី ១ ។

## ឧទ្ទាននៃតិណកដ្ឋវគ្គនោះគឺ

ទ្រង់សំដែងប្រៀបដូចស្មៅ និងកំណាត់ឈើជាដើម ១ ផែនដី ១ ទឹកភ្នែក ១ ទឹកដោះ ១ ភ្នំ ១ គ្រាប់ស្ពៃ ១ សាវ័ក ១ ស្ទឹងគង្គា ១ ដំបង ១ បុគ្គល ១ ។

---

# ទុគ្គតវគ្គោ

[១១១] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ។ បេ ។ តត្រ ខោ ភគវា... អនមតគ្គោយំ ភិក្ខវេ សំសារោ បុព្វា កោដិ ន បញ្ញាយតិ អវិជ្ជានីវរណានំ សត្តានំ តណ្ហាសញ្ញោជនានំ សន្ធាវតំ សំសរតំ ។ យំ ភិក្ខវេ បស្សេយ្យាថ ទុគ្គតំ ទុរូបេតំ និដ្ឋមេត្ថ គន្តព្វំ អម្ហេហិ ឯវរូបំ បច្ចនុភូតំ ឥមិនា ទីឃេន អទ្ធុនាតិ តំ កិស្ស ហេតុ អនមតគ្គោយំ ភិក្ខវេ សំសារោ ។ បេ ។ អលំ វិមុច្ចិតុន្តិ ។ បឋមំ ។

# ទុគ្គតវគ្គ

[១១១] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅទៀបក្រុងសាវត្ថី ។ បេ ។ ក្នុងទីនោះឯង ព្រះមានព្រះភាគ... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សង្សារនេះ មានទីបំផុតខាងដើមមិនប្រាកដ គឺទីបំផុតខាងដើមរបស់សត្វទាំងឡាយ ដែលមាននីវរណៈគឺអវិជ្ជា មានសំយោជនៈគឺតណ្ហា អន្ទោលទៅ ត្រាច់រង្គាត់ទៅ មិនប្រាកដឡើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីឃើញបុគ្គលកម្សត់ មានរូបរាងអាក្រក់ឯណា អ្នកទាំងឡាយ គប្បីដល់នូវសេចក្តីចូលចិត្តក្នុងបុគ្គលកម្សត់នុ៎ះថា រូបបែបនេះ យើងទាំងឡាយបានគប់ប្រសព្វហើយ អស់កាលជាអង្វែងដូច្នេះដែរ សេចក្តីនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះសង្សារនេះ មានទីបំផុតខាងដើមមិនប្រាកដ ។ បេ ។ គួរដើម្បីជិនឆ្អន់ ។ ចប់សូត្រទី ១ ។

អនមតគ្គសំយុត្តស្ស ទុគ្គតវគ្គេ ភគវន្តូបសង្កមនំ

[១១២] សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា... អនមតគ្គោយំ ភិក្ខវេ សំសារោ... យំ ភិក្ខវេ បស្សេយ្យាថ សុខិតំ សុសជ្ជិតំ និដ្ឋមេត្ថ គន្តព្វំ អម្ហេហិ ឯវរូបំ បច្ចនុភូតំ ឥមិនា ទីឃេន អទ្ធុនាតិ តំ កិស្ស ហេតុ អនមតគ្គោយំ ភិក្ខវេ សំសារោ បុព្វា កោដិ ន បញ្ញាយតិ ។ បេ ។ អលំ វិមុច្ចិតុន្តិ ។ តុតិយំ ។

[១១៣] រាជគហេ វិហរតិ វេឡុវនេ... អថខោ តឹសមត្តា ចាវេយ្យកា[១] ភិក្ខូ សព្វេ អារញ្ញិកា សព្វេ បិណ្ឌបាតិកា សព្វេ បំសុកូលិកា សព្វេ តេចីវរិកា សព្វេ សសញ្ញោជនា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។

១ បាវេយ្យកាតិបិ ។

[១១២] ទ្រង់គង់នៅទៀបក្រុងសាវត្ថី... ក្នុងទីនោះឯង ព្រះមានព្រះភាគ... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សង្សារនេះ មានទីបំផុតខាងដើមមិនប្រាកដ... ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីឃើញបុគ្គលឯណា ដល់នូវសេចក្តីសុខ ដល់នូវសេចក្តីសប្បាយ អ្នកទាំងឡាយគប្បីដល់នូវសេចក្តីចូលចិត្តក្នុងបុគ្គលនុ៎ះថា រូបបែបនេះ យើងទាំងឡាយ បានកប់ប្រសព្វហើយអស់កាលជាអង្វែងដូច្នេះដែរ សេចក្តីនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះសង្សារនេះ មានទីបំផុតខាងដើមមិនប្រាកដ គឺទីបំផុតខាងដើមមិនប្រាកដឡើយ ។ បេ ។ គួរដើម្បីជិនឆ្អន់ ។ ចប់សូត្រទី ២ ។

[១១៣] ទ្រង់គង់នៅក្នុងវត្តវេឡុវន ទៀបក្រុងរាជគ្រឹះ... គ្រានោះឯង បាវេយ្យកភិក្ខុ[១] ប្រមាណ ៣០ រូប ជាអ្នកប្រព្រឹត្តអារញ្ញិកធុតង្គទាំងអស់ ជាអ្នកប្រព្រឹត្តបិណ្ឌបាតិកធុតង្គទាំងអស់ ជាអ្នកប្រព្រឹត្តបង្សុកូលិកធុតង្គទាំងអស់ ជាអ្នកប្រព្រឹត្តតេចីវរិកធុតង្គទាំងអស់ តែនៅមានសំយោជនធម៌ទាំងអស់ នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។

១ ភិក្ខុនៅក្នុងប្រទេសបាវា ។

[១១៨] អថខោ ភគវតោ ឯតទហោសិ ឥមេ ខោ តឹសមត្តា បាវេយ្យកា ភិក្ខូ សព្វេ អារញ្ញិកា សព្វេ បិណ្ឌបាតិកា សព្វេ បំសុកូលិកា សព្វេ តេចីវរិកា សព្វេ សសញ្ញោជនា យន្នូនាហំ ឥមេសំ តថា ធម្មំ ទេសេយ្យំ យថា នេសំ ឥមស្មឹយេវ អាសនេ អនុបាទាយ អាសវេហិ ចិត្តានិ វិមុច្ចេយ្យុន្តិ ។ អថខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

[១១៩] ភគវា ឯតទវោច អនមតគ្គោយំ ភិក្ខវេ សំសារោ បុព្វា កោដិ ន បញ្ញាយតិ អវិជ្ជានីវរណានំ សត្តានំ តណ្ហាសញ្ញោជនានំ សន្ធាវតំ សំសរតំ ។ តំ កឹ មញ្ញថ ភិក្ខវេ កតមំ នុ ខោ ពហុតរំ យំ វា វោ ភិក្ខវេ ឥមិនា ទីឃេន អទ្ធុនា សន្ធាវតំ សំសរតំ សីសច្ឆិន្នានំ លោហិតំ បសន្នំ បគ្ឃរិតំ

[១១៤] គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ព្រះតម្រិះយ៉ាង នេះថា បាវេយ្យកភិក្ខុប្រមាណ ៣០ រូបនេះ សុទ្ធតែជាអ្នកប្រព្រឹត្ត អារញ្ញិកធុតង្គ សុទ្ធតែជាអ្នកប្រព្រឹត្តបិណ្ឌបាតិកធុតង្គ សុទ្ធតែជាអ្នក ប្រព្រឹត្តបង្សុកូលិកធុតង្គ សុទ្ធតែជាអ្នកប្រព្រឹត្តតេចីវរិកធុតង្គ តែនៅ មានសំយោជនធម៌ទាំងអស់ បើដូច្នោះគួរតែ តថាគតសំដែងធម៌ដល់ ភិក្ខុទាំងនោះ ដើម្បីធ្វើចិត្តភិក្ខុទាំងនោះ ឲ្យរួចចាកអាសវៈដោយមិនប្រកាន់ លើអាសនៈនេះឯង ។ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំង-ឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ក៏ទទួលព្រះពុទ្ធ-ដីកាព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ។

[១១៥] ព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុ ទាំងឡាយ សង្សារនេះ មានទីបំផុតខាងដើមមិនប្រាកដ គឺទីបំផុតខាង ដើមរបស់សត្វទាំងឡាយ ដែលមាននីវរណៈគឺអវិជ្ជា មានសំយោជនៈ គឺតណ្ហា អន្ទោលទៅ ត្រាច់រង្គាត់ទៅ មិនប្រាកដឡើយ ។ ម្នាល ភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់សេចក្តីនោះថាដូចម្តេច ម្នាល ភិក្ខុទាំងឡាយ កាលដែលអ្នកទាំងឡាយ អន្ទោលទៅ ត្រាច់រង្គាត់ទៅ ត្រូវគេកាត់ក្បាលដោយកាលជាអង្វែងនេះ ឈាមឯណាដែលហូរស្រក់ក្តី

អនមតគ្គសំយុត្តស្ស ទុគ្គតវគ្គេ សាធុការទានំ

យំ វា ចតូសុ មហាសមុទ្ទេសុ ឧទកន្តិ ។ យថា ខោ មយំ ភន្តេ ភគវតា ធម្មំ ទេសិតំ អាជានាម ឯតទេវ ភន្តេ ពហុតរំ យំ នោ ឥមិនា ទីឃេន អទ្ធុនា សន្ធាវតំ សំសរតំ សីសច្ឆិន្នានំ លោហិតំ បសន្នំ បគ្ឃរិតំ ន ត្វេវ ចតូសុ មហាសមុទ្ទេសុ ឧទកន្តិ ។

[១១៦] សាធុ សាធុ ភិក្ខវេ សាធុ ខោ មេ តុម្ហេ ភិក្ខវេ ឯវំ ធម្មំ ទេសិតំ អាជានាថ ឯតទេវ ភិក្ខវេ ពហុតរំ យំ វោ ឥមិនា ទីឃេន អទ្ធុនា សន្ធាវតំ សំសរតំ សីសច្ឆិន្នានំ លោហិតំ បសន្នំ បគ្ឃរិតំ ន ត្វេវ ចតូសុ មហាសមុទ្ទេសុ ឧទកំ ។ ទីឃរត្តំ វា ភិក្ខវេ គុន្នំ សតំ គោភូតានំ សីសច្ឆិន្នានំ

ទឹកឯណាក្នុងមហាសមុទ្រទាំង ៤ ក្តី បណ្តាទឹកទាំងពីរនោះ ទឹកណាច្រើនជាង ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយ ដឹងច្បាស់នូវធម៌ដែលព្រះមានព្រះភាគ សំដែងហើយដោយពិត បពិត្រព្រះអង្គដ៏ចម្រើន កាលដែលខ្ញុំព្រះអង្គទាំងឡាយ អន្ទោលទៅ ត្រាច់រង្គាត់ទៅ ត្រូវគេកាត់ក្បាល ដោយកាលជាអង្វែងនេះ ឈាមដែលហូរស្រក់ទៅច្រើនជាង ឯទឹកក្នុងមហាសមុទ្រទាំង ៤ មិនមែនច្រើនឡើយ ។

[១១៦] ម្នាលភិក្ខុទាំងឡាយ ត្រូវហើយ ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយដឹងច្បាស់នូវធម៌ ដែលតថាគតសំដែងហើយដោយប្រពៃយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ កាលដែលអ្នកទាំងឡាយអន្ទោលទៅ ត្រាច់រង្គាត់ទៅ ត្រូវគេកាត់ក្បាលដោយកាលជាអង្វែងនេះ ឈាមដែលហូរស្រក់ទៅច្រើនជាង ឯទឹកក្នុងមហាសមុទ្រទាំង ៤ មិនមែនច្រើនឡើយ ។ ម្នាលភិក្ខុទាំងឡាយ កាលដែលអ្នកទាំងឡាយកើតជាគោ មានសភាពជាគោ ត្រូវគេកាត់ក្បាលអស់កាលជាអង្វែង

លោហិតំ បសន្នំ បគ្ឃរិតំ ន ត្វេវ ចតូសុ មហាស-
មុទ្ទេសុ ឧទកំ ។ ទីឃរត្តំ វោ ភិក្ខវេ មហិសានំ
សតំ មហិសភូតានំ សីសច្ឆិន្នានំ លោហិតំ បសន្នំ
បគ្ឃរិតំ ។ ទីឃរត្តំ វោ ភិក្ខវេ ឧរព្ភានំ សតំ
ឧរព្ភភូតានំ ។ បេ ។ អជានំ សតំ អជភូតានំ ។ បេ ។
មិគានំ សតំ មិគភូតានំ ។ បេ ។ សូករានំ សតំ
សូករភូតានំ ។ បេ ។ កុក្កុដានំ សតំ កុក្កុដភូតានំ
។ បេ ។ ទីឃរត្តំ វោ ភិក្ខវេ ចោរា គាមឃាតកាតិ
គហេត្វា សីសច្ឆិន្នានំ លោហិតំ បសន្នំ បគ្ឃរិតំ ។
ទីឃរត្តំ វោ ភិក្ខវេ ចោរា ចារិបន្ថកាតិ គហេត្វា
។ បេ ។ ចោរា ចារទារិកាតិ គហេត្វា សីសច្ឆិន្នានំ
លោហិតំ បសន្នំ បគ្ឃរិតំ ន ត្វេវ ចតូសុ មហាស-
មុទ្ទេសុ ឧទកំ តំ កិស្ស ហេតុ អនមតគ្គោយំ
ភិក្ខវេ សំសារោ ។ បេ ។ អលំ វិមុច្ចិតុន្តិ ។

ឈាមដែលហូរស្រក់ទៅច្រើនជាង ឯទឹកក្នុងមហាសមុទ្រទាំង ៤ មិនមែនច្រើនឡើយ ។ ម្នាលភិក្ខុទាំងឡាយ កាលដែលអ្នកទាំងឡាយកើតជាក្របី មានសភាពជាក្របី ត្រូវគេកាត់ក្បាលអស់កាលជាអង្វែង ឈាមដែលហូរស្រក់ទៅច្រើនជាង ។ ម្នាលភិក្ខុទាំងឡាយ កាលដែលអ្នកទាំងឡាយកើតជាចៀម មានសភាពជាចៀម អស់កាលជាអង្វែង ។ បេ ។ កើតជាពពែ មានសភាពជាពពែ ។ បេ ។ កើតជាម្រឹគ មានសភាពជាម្រឹគ ។ បេ ។ កើតជាជ្រូក មានសភាពជាជ្រូក ។ បេ ។ កើតជាមាន់ មានសភាពជាមាន់ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ កាលដែលអ្នកទាំងឡាយត្រូវគេប្រចាប់ថា ជាចោរបៀតបៀនអ្នកស្រុក ហើយគេកាត់ក្បាលអស់កាលជាអង្វែង ឈាមដែលហូរស្រក់ទៅច្រើនជាង ។ ម្នាលភិក្ខុទាំងឡាយ កាលដែលអ្នកទាំងឡាយ ត្រូវគេប្រចាប់ថា ជាចោរចាំស្ទាក់ក្បែរផ្លូវ អស់កាលជាអង្វែង ។ បេ ។ កាលដែលអ្នកទាំងឡាយត្រូវគេប្រចាប់ថា ជាចោរលួចប្រពន្ធគេ ហើយគេកាត់ក្បាល ឈាមដែលហូរស្រក់ទៅច្រើនជាង ឯទឹកក្នុងមហាសមុទ្រទាំង ៤ មិនមែនច្រើនឡើយ សេចក្តីនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះសង្សារនេះ មានទីបំផុតខាងដើមមិនប្រាកដឡើយ ។ បេ ។ គួរដើម្បីជិនធ្អន់ ។

អនមតគ្គសំយុត្តស្ស ទុគ្គតវគ្គោ អនបិតុភូតបុព្វភាវោ

[១១៧] ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុំ ។ ឥមស្មិញ្ច បន វេយ្យាករណស្មឹ ភញ្ញមានេ តឹសមត្តានំ ភិក្ខូនំ អនុបាទាយ អាសវេហិ ចិត្តានិ វិមុច្ចឹសូតិ ។ តតិយំ ។

[១១៨] សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា... អនមតគ្គោយំ ភិក្ខវេ សំសារោ ។ បេ ។ ន សោ ភិក្ខវេ សត្តោ សុលភរូបោ យោ ន មាតា ភូតបុព្វោ ឥមិនា ទីឃេន អទ្ធុនា តំ កិស្ស ហេតុ អនមតគ្គោយំ ភិក្ខវេ សំសារោ ។ បេ ។ អលំ វិមុច្ចិតុន្តិ ។ ចតុត្ថំ ។

(សព្វេសំ ឯវំ បេយ្យាលោ)

[១១៩] សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា... អនមតគ្គោយំ ភិក្ខវេ សំសារោ ។ បេ ។ ន សោ ភិក្ខវេ សត្តោ សុលភរូបោ យោ ន បិតា ភូតបុព្វោ ។ បេ ។ បញ្ចមំ ។

[១១៧] លុះព្រះមានព្រះភាគ ទ្រង់ត្រាស់សូត្រនេះចប់ហើយ ពួកភិក្ខុនោះ ជាអ្នកមានសេចក្តីត្រេកអរ បានត្រេកអរចំពោះភាសិតរបស់ព្រះមានព្រះភាគ ។ កាលដែលព្រះមានព្រះភាគ ទ្រង់ត្រាស់វេយ្យាករណ៍នេះ ចិត្តរបស់បាវេយ្យកភិក្ខុប្រមាណ ៣០ រូប ក៏រួចស្រឡះចាកអាសវៈដោយមិនប្រកាន់ ។ ចប់សូត្រទី ៣ ។

[១១៨] ទ្រង់គង់នៅទៀបក្រុងសាវត្ថី... ក្នុងទីនោះឯង ព្រះមានព្រះភាគ... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សង្សារនេះមានទីបំផុតខាងដើមមិនប្រាកដ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ សត្វឯណាមិនធ្លាប់កើតជាមាតា សត្វនោះមិនងាយរកបាន ដោយកាលជាអង្វែងនេះ សេចក្តីនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះសង្សារនេះ មានទីបំផុតខាងដើមមិនប្រាកដ ។ បេ ។ គួរដើម្បីជិនធ្នន់ ។ ចប់សូត្រទី ៤ ។

( ពាក្យបំប្រួញសេចក្តីទាំងអស់យ៉ាងនេះ )

[១១៩] ទ្រង់គង់នៅទៀបក្រុងសាវត្ថី... ក្នុងទីនោះឯង ព្រះមានព្រះភាគ... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សង្សារនេះមានទីបំផុតខាងដើមមិនប្រាកដ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ សត្វឯណាមិនធ្លាប់កើតជាបិតា សត្វនោះមិនងាយរកបាន ។ បេ ។ ចប់សូត្រទី ៥ ។

[១២០] សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា... អនមតគ្គោយំ ភិក្ខវេ សំសារោ ។ បេ ។ ន សោ ភិក្ខវេ សត្តោ សុលភរូបោ យោ ន ភាតា ភូតបុព្វោ ។ បេ ។ ឆដ្ឋំ ។

[១២១] សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា... អនមតគ្គោយំ ភិក្ខវេ សំសារោ ។ បេ ។ ន សោ ភិក្ខវេ សត្តោ សុលភរូបោ យោ ន ភគិនី ភូត-បុព្វោ ។ បេ ។ សត្តមំ ។

[១២២] សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា... អនមតគ្គោយំ ភិក្ខវេ សំសារោ ។ បេ ។ ន សោ ភិក្ខវេ សត្តោ សុលភរូបោ យោ ន បុត្តោ ភូត-បុព្វោ ។ បេ ។ អដ្ឋមំ ។

[១២០] ទ្រង់គង់នៅទៀបក្រុងសាវត្ថី... ក្នុងទីនោះឯង ព្រះមានព្រះភាគ... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សង្សារនេះមានទីបំផុតខាងដើមមិនប្រាកដ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ សត្វឯណាមិនធ្លាប់កើតជាបងប្អូនប្រុស សត្វនោះ មិនងាយរកបាន ។ បេ ។ ចប់សូត្រទី ៦ ។

[១២១] ទ្រង់គង់នៅទៀបក្រុងសាវត្ថី... ក្នុងទីនោះឯង ព្រះមានព្រះភាគ... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សង្សារនេះមានទីបំផុតខាងដើមមិនប្រាកដ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ សត្វឯណាមិនធ្លាប់កើតជាបងប្អូនស្រី សត្វនោះ មិនងាយរកបាន ។ បេ ។ ចប់សូត្រទី ៧ ។

[១២២] ទ្រង់គង់នៅទៀបក្រុងសាវត្ថី... ក្នុងទីនោះឯង ព្រះមានព្រះភាគ... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សង្សារនេះមានទីបំផុតខាងដើមមិនប្រាកដ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ សត្វឯណាមិនធ្លាប់កើតជាកូនប្រុស សត្វនោះ មិនងាយរកបាន ។ បេ ។ ចប់សូត្រទី ៨ ។

១០៣

អនមតគ្គសំយុត្តស្ស ទុគ្គតវគ្គេ ភិក្ខាមន្ទនំ

[១២៣] សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា... អនមតគ្គោយំ ភិក្ខវេ សំសារោ បុព្វា កោដិ ន បញ្ញាយតិ អវិជ្ជានីវរណានំ សត្តានំ តណ្ហាសញ្ញោជនានំ សន្ធាវតំ សំសរតំ ។ ន សោ ភិក្ខវេ សត្តោ សុលភរូបោ យោ ន ធីតា ភូតបុព្វោ ឥមិនា ទីឃេន អទ្ធុនា តំ កិស្ស ហេតុ អនមតគ្គោយំ ភិក្ខវេ សំសារោ បុព្វា កោដិ ន បញ្ញាយតិ អវិជ្ជានីវរណានំ សត្តានំ តណ្ហាសញ្ញោជនានំ សន្ធាវតំ សំសរតំ ។ ឯវំ ទីឃរត្តំ វោ ភិក្ខវេ បច្ចនុភូតំ តិព្វំ បច្ចនុភូតំ ព្យសនំ បច្ចនុភូតំ កដសី វឌ្ឍិតា ។ យាវញ្ចិទំ ភិក្ខវេ អលមេវ សព្វសង្ខារេសុ និព្វិន្ទិតុំ អលំ វិរជ្ជិតុំ អលំ វិមុច្ចិតុន្តិ ។ នវមំ ។

អនមតគ្គសំយុត្ត ទុគ្គតវគ្គ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយ

[១២៣] ទ្រង់គង់នៅទៀបក្រុងសាវត្ថី... ក្នុងទីនោះឯង ព្រះមានព្រះភាគ... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សង្សារនេះមានទីបំផុតខាងដើមមិនប្រាកដ គឺទីបំផុតខាងដើម របស់សត្វទាំងឡាយដែលមាននីវរណៈគឺអវិជ្ជា មានសំយោជនៈគឺតណ្ហា អន្ទោលទៅ ត្រាច់រង្គាត់ទៅ មិនប្រាកដឡើយ ។ ម្នាលភិក្ខុទាំងឡាយ សត្វឯណាមិនធ្លាប់កើតជាកូនស្រី សត្វនោះ មិនងាយរកបានដោយកាលជាអង្វែងនេះសេចក្ដីនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះសង្សារនេះមានទីបំផុតខាងដើមមិនប្រាកដ គឺទីបំផុតខាងដើមរបស់សត្វទាំងឡាយដែលមាននីវរណៈគឺអវិជ្ជា មានសំយោជនៈគឺតណ្ហា អន្ទោលទៅ ត្រាច់រង្គាត់ទៅ មិនប្រាកដឡើយ ។ ម្នាលភិក្ខុទាំងឡាយ សេចក្ដីទុក្ខសេចក្ដីព្រួយ សេចក្ដីវិនាស ដែលអ្នកទាំងឡាយ បានទទួលរងហើយអស់កាលជាអង្វែងយ៉ាងនេះ ទីប៉ាធាក៏ចម្រើនឡើង ។ ម្នាលភិក្ខុទាំងឡាយហេតុនេះ គួរដើម្បីនឿយណាយ គួរដើម្បីធុញទ្រាន់ គួរដើម្បីជិនឆ្អន់ក្នុងសង្ខារទាំងពួង ។ ចប់សូត្រទី ៩ ។

[១២៤] ឯកំ សមយំ ភគវា រាជគហេ វិហរតិ គិជ្ឈកូដេ បព្វតេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

[១២៥] ភគវា ឯតទវោច អនមតគ្គោយំ ភិក្ខវេ សំសារោ បុព្វា កោដិ ន បញ្ញាយតិ អវិជ្ជានីវរណានំ សត្តានំ តណ្ហាសញ្ញោជនានំ សន្ធាវតំ សំសរតំ ។ ភូតបុព្វំ ភិក្ខវេ ឥមស្ស វេបុល្លស្ស បព្វតស្ស បាចីនវំសោត្វេវ សមញ្ញា ឧទបាទិ ។ តេន ខោ បន ភិក្ខវេ សមយេន មនុស្សានំ តិវរាត្វេវ[១] សមញ្ញា ឧទបាទិ ។ តិវរានំ ភិក្ខវេ មនុស្សានំ ចត្តាឡីសវស្សសហស្សានិ អាយុប្បមាណំ អហោសិ ។ តិវរា ភិក្ខវេ មនុស្សា បាចីនវំសំ បព្វតំ ចតូហេន អារោហន្តិ ចតូហេន ឱរោហន្តិ ។ តេន ខោ បន ភិក្ខវេ សមយេន កកុសន្ធោ ភគវា អរហំ សម្មាសម្ពុទ្ធោ លោកេ ឧប្បន្នោ ហោតិ ។ កកុសន្ធស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស វិធុរសញ្ជីវន្នាម សាវកយុគំ អហោសិ

១ សិវរាត្វេវ ឥតិ វា បាឋោ ។

[១២៤] *សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅនាភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះ ។ ក្នុងទីនោះឯង ព្រះមានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ។*

[១២៥] *ព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ សង្សារនេះ មានទីបំផុតខាងដើមមិនប្រាកដ គឺទីបំផុតខាងដើមរបស់សត្វទាំងឡាយ ដែលមាននីវរណៈគឺអវិជ្ជា មានសំយោជនៈគឺតណ្ហា អន្ទោលទៅ ត្រាច់រង្គាត់ទៅ មិនប្រាកដឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភ្នំឈ្មោះថា វេបុល្លនេះ មានឈ្មោះថា បាចីនវំសៈដូច្នេះ កើតឡើងហើយ ក្នុងអតីតកាល ។ ម្នាលភិក្ខុទាំងឡាយ មនុស្សទាំង-ឡាយ មានឈ្មោះថា តិវរៈដូច្នេះ កើតឡើងហើយ ក្នុងសម័យនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សតិវរៈមានអាយុប្រមាណ ៤ ហ្មឺនឆ្នាំ ។ ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សតិវរៈឡើងភ្នំបាចីនវំសៈអស់ ៤ ថ្ងៃ ចុះមកវិញអស់ ៤ ថ្ងៃ ។ ម្នាលភិក្ខុទាំងឡាយ ព្រះមានព្រះភាគ ព្រះនាមកកុសន្ធៈ អរហន្តសម្មាសម្ពុទ្ធ បានកើតឡើងក្នុងលោកក្នុងសម័យនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ព្រះមានព្រះនាមកកុសន្ធៈ អរហន្តសម្មាសម្ពុទ្ធ មានគូសាវ័កឈ្មោះ វិធុរៈ និងសញ្ជីវៈ*

អត្ថំ ភទ្ទយុតំ ។ បស្សថ ភិក្ខវេ សា ចេតិមស្ស បព្វតស្ស សមញ្ញា អន្តរហិតា តេ ច មនុស្សា កាលកតា សោ ច ភគវា បរិនិព្វុតោ ។ ឯវំ អនិច្ចា ភិក្ខវេ សង្ខារា ឯវំ អទ្ធុវា ភិក្ខវេ សង្ខារា ឯវំ អនស្សាសិកា ភិក្ខវេ សង្ខារា ។ យាវញ្ចិទំ ភិក្ខវេ អលមេវ សព្វសង្ខារេសុ និព្វិន្ទិតុំ អលំ វិរជ្ជិតុំ អលំ វិមុច្ចិតុំ ។

[១២៦] ភូតបុព្វំ ភិក្ខវេ ឥមស្ស វេបុល្លស្ស បព្វតស្ស វង្កកោត្វេវ សមញ្ញា ឧទបាទិ ។ តេន ខោ បន ភិក្ខវេ សមយេន មនុស្សានំ រោហិតស្សាត្វេវ សមញ្ញា ឧទបាទិ ។ រោហិតស្សានំ ភិក្ខវេ មនុស្សានំ តីសវស្សសហស្សានិ អាយុប្បមាណំ អហោសិ ។ រោហិតស្សា ភិក្ខវេ មនុស្សា វង្កកំ បព្វតំ តីហេន អារោហន្តិ

ជាគូដ៏ប្រសើរ ជាគូដ៏ថ្លៃថ្លា ។ ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយមើលចុះ ឯឈ្មោះនោះរបស់ភ្នំនេះ ក៏អន្តរធានបាត់ទៅ មនុស្សទាំងនោះក៏ធ្វើមរណកាលទៅ ទាំងព្រះមានព្រះភាគអង្គនោះ ក៏បរិនិព្វានទៅហើយ ។ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយមិនទៀងយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយមិនឋិតថេរយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយមិនស្រួលយ៉ាងនេះ ។ ម្នាលភិក្ខុទាំង-ឡាយ ហេតុនេះ គួរដើម្បីនឿយណាយ គួរដើម្បីធុញទ្រាន់ គួរដើម្បីជិនឆ្អន់ ក្នុងសង្ខារទាំងពួង ។

[១២៦] ម្នាលភិក្ខុទាំងឡាយ ភ្នំឈ្មោះថា វេបុល្លនេះ មានឈ្មោះថា វង្កតដូច្នេះ កើតឡើង ក្នុងអតីតកាល ។ ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សមានឈ្មោះថា រោហិតស្សៈដូច្នេះ កើតឡើង ក្នុងសម័យនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សរោហិតស្សៈ មានអាយុប្រមាណ ៣ ហ្មឺនឆ្នាំ ។ ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សរោហិតស្សៈឡើងភ្នំវង្កតអស់ ៣ ថ្ងៃ

តីហេន អារោហន្តិ ។ តេន ខោ បន ភិក្ខវេ សម-
យេន កោណាគមនោ ភគវា អរហំ សម្មាសម្ពុទ្ធោ
លោកេ ឧប្បន្នោ ហោតិ ។ កោណាគមនស្ស ភិក្ខវេ
ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ភិយ្យោ សុត្តរំ
នាម សាវកយុគំ អហោសិ អគ្គំ ភទ្ទយុគំ ។ បស្សថ
ភិក្ខវេ សា ចេវិមស្ស បព្វតស្ស សមញ្ញា អន្តរហិតា
តេ ច មនុស្សា កាលកតា សោ ច ភគវា បរិនិព្វុ-
តោ ។ ឯវំ អនិច្ចា ភិក្ខវេ សង្ខារា ។ បេ ។ អលំ
វិមុច្ចិតុំ ។

[១២៧] ភូតបុព្វំ ភិក្ខវេ ឥមស្ស វេបុល្លស្ស បព្វ-
តស្ស សុបស្សោតេ្វវ សមញ្ញា ឧទបាទិ ។ តេន ខោ
បន ភិក្ខវេ សមយេន មនុស្សានំ សុប្បិយាតេ្វវ ស-
មញ្ញា ឧទបាទិ ។ សុប្បិយានំ ភិក្ខវេ មនុស្សានំ វីស-
តិវស្សសហស្សានិ អាយុប្បមាណំ អហោសិ ។ សុប្បិ-
យា ភិក្ខវេ មនុស្សា សុបស្សំ បព្វតំ ទ្វីហេន អារោហន្តិ

ចុះមកវិញក៏អស់ ៣ ថ្ងៃ ។ ម្នាលភិក្ខុទាំងឡាយ ព្រះមានព្រះភាគ ព្រះនាមកោនាគមនៈ អរហន្តសម្មាសម្ពុទ្ធ បានកើតឡើងក្នុងលោក ក្នុងសម័យនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ព្រះមានព្រះភាគ ព្រះនាមកោនាគមនៈ អរហន្តសម្មាសម្ពុទ្ធ មានគូសាវ័កឈ្មោះ ភិយ្យោសៈ និងឧត្តរៈ ជាគូដ៏ប្រសើរ ជាគូដ៏ថ្លៃថ្លា ។ ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយមើលចុះ ឯឈ្មោះនោះរបស់ភ្នំនេះ ក៏អន្តរធានបាត់ទៅ មនុស្សទាំងនោះ ក៏ធ្វើមរណកាលទៅ ទាំងព្រះមានព្រះភាគអង្គនោះ ក៏បរិនិព្វានទៅហើយ ។ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ មិនទៀងយ៉ាងនេះ ។ បេ ។ គួរដើម្បីជិនធ្នន់ ។

[១២៧] ម្នាលភិក្ខុទាំងឡាយ ភ្នំឈ្មោះវេបុល្លនេះ មានឈ្មោះថា សុបស្សៈដូច្នេះ កើតឡើង ក្នុងអតីតកាល ។ ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សមានឈ្មោះថា សុប្បិយៈដូច្នេះ កើតឡើង ក្នុងសម័យនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សសុប្បិយៈ មានអាយុប្រមាណ ២ ហ្មឺនឆ្នាំ ។ ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សសុប្បិយៈឡើងភ្នំសុបស្សៈ

ក្ខីហេន ឱរោហន្តិ ។ តេន ខោ បន ភិក្ខវេ សមយេន កស្សបោ ភគវា អរហំ សម្មាសម្ពុទ្ធោ លោកេ ឧប្បន្នោ ហោតិ ។ កស្សបស្ស ភិក្ខវេ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស តិស្សភារទ្វាជំ ជាម សាវ-កយុគំ អហោសិ អគ្គំ ភទ្ទយុគំ ។ បស្សថ ភិក្ខវេ សា ចេវិមស្ស បព្វតស្ស សមញ្ញា អន្តរហិតា តេ ច មនុស្សា កាលកតា សោ ច ភគវា បរិនិព្វុតោ ។ ឯវំ អនិច្ចា ភិក្ខវេ សង្ខារា ឯវំ អទ្ធុវា ភិក្ខវេ សង្ខារា ឯវំ ។ បេ ។ អលំ វិមុច្ចិតុំ ។

[១២៨] ឯតរហិ ខោ បន ភិក្ខវេ ឥមស្ស វេ-បុល្លស្ស បព្វតស្ស វេបុល្លោត្វេវ សមញ្ញា ឧទបាទិ ។ ឯតរហិ ខោ បន ភិក្ខវេ ឥមេសំ មនុស្សានំ មាគធ-កាត្វេវ សមញ្ញា ឧទបាទិ ។ មាគធកានំ ភិក្ខវេ ម-នុស្សានំ អប្បកំ អាយុប្បមាណំ បរិត្តកំ លហុកំ យោ

អស់ ២ ថ្ងៃ ចុះមកវិញក៏អស់ ២ ថ្ងៃ ។ ម្នាលភិក្ខុទាំងឡាយ ព្រះមានព្រះភាគព្រះនាមកស្សបៈ អរហន្តសម្មាសម្ពុទ្ធ កើតឡើងក្នុងលោកក្នុងសម័យនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ព្រះមានព្រះភាគ ព្រះនាមកស្សបៈ អរហន្តសម្មាសម្ពុទ្ធអង្គនោះ មានគូសាវកឈ្មោះ តិស្សៈនិងភារទ្វាជៈ ជាគូដ៏ប្រសើរ ជាគូដ៏ថ្លៃថ្លា ។ ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយមើលចុះ ឯឈ្មោះនោះរបស់ភ្នំនេះ ក៏អន្តរធានបាត់ទៅ មនុស្សទាំងនោះ ក៏ធ្វើមរណកាលទៅ ទាំងព្រះមានព្រះភាគអង្គនោះ ក៏បរិនិព្វានទៅដែរ ។ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ មិនទៀងយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ មិនឋិតថេរយ៉ាងនេះ ។ បេ ។ គួរដើម្បីផុតធ្ងន់ ។

[១២៨] ម្នាលភិក្ខុទាំងឡាយ ក្នុងកាលឥឡូវនេះ ភ្នំវេបុល្លនេះមានឈ្មោះថា វេបុល្លដូច្នេះ កើតឡើងហើយ ។ ម្នាលភិក្ខុទាំង-ឡាយ ពួកមនុស្សនេះ មានឈ្មោះថា មាគធកៈដូច្នេះ កើតឡើងហើយក្នុងកាលឥឡូវនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សឈ្មោះមាគ-ធកៈ មានប្រមាណនៃអាយុតិចតួចស្តួចស្តើងឆាប់រហ័ស មនុស្សឯណា

១០៨



ចិរំ ជីវតិ សោ វស្សសតំ អប្បំ វា ភិយ្យោ វា ។ មាគធកា ភិក្ខវេ មនុស្សា វេបុល្លំ បព្វតំ មុហុត្តេនេវ អារោហន្តិ មុហុត្តេន ឱរោហន្តិ ។ ឯតរហិ ខោ ប-ណាយំ ភិក្ខវេ អរហំ សម្មាសម្ពុទ្ធោ លោកេ ឧប្បន្នោ ។ មយ្ហំ ខោ បន ភិក្ខវេ សារីបុត្តមោគ្គល្លានំ ណាម សា-វកយុគំ អគ្គំ ភទ្ទយុគំ ។ ភវិស្សតិ ភិក្ខវេ សោ ស-មយោ យា អយញ្ចេវិមស្ស បព្វតស្ស សមញ្ញា អន្តរ-ធាយិស្សតិ ឥមេ ច មនុស្សា កាលំ ករិស្សន្តិ អ-ហញ្ច បរិនិព្វាយិស្សាមិ ។ ឯវំ អនិច្ចា ភិក្ខវេ សង្ខារា ឯវំ អទ្ធុវា ភិក្ខវេ សង្ខារា ឯវំ អនស្សាសិកា ភិក្ខវេ សង្ខារា ។ យាវញ្ចិទំ ភិក្ខវេ អលមេវ សព្វសង្ខារេសុ និព្វិន្ទិតុំ អលំ វិរជ្ជិតុំ អលំ វិមុច្ចិតុន្តិ ។

រស់នៅយ៉ាងយូរ មនុស្សនោះរស់នៅត្រឹម ១០០ ឆ្នាំ ឬតិចជាងក៏មាន ច្រើនជាងក៏មាន ។ ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សឈ្មោះមាគធកៈ ឡើងភ្នំវេបុល្លមួយរំពេច ចុះមកវិញក៏មួយរំពេច ។ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលឥឡូវនេះ ព្រះអរហន្តសម្មាសម្ពុទ្ធ គឺតថាគតនេះ បានកើតឡើងក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ តថាគតមានគូសាវ័កឈ្មោះ សារីបុត្តនិងមោគ្គល្លាន ជាគូដ៏ប្រសើរ ជាគូដ៏ថ្លៃថ្លា ។ ម្នាលភិក្ខុទាំងឡាយ មុខជានឹងមានកាលដែលឈ្មោះនេះ របស់ភ្នំនេះ ត្រូវអន្តរធានបាត់ទៅ មនុស្សទាំងនេះ ក៏នឹងធ្វើមរណកាលទៅ ឯតថាគតក៏គង់នឹងបរិនិព្វានទៅ ។ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ មិនទៀងយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ មិនឋិតថេរយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ មិនស្រួលយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះ គួរដើម្បីនឿយណាយ គួរដើម្បីធុញទ្រាន់ គួរដើម្បីជិនឆ្អន់ ក្នុងសង្ខារទាំងពួង ។

[១២៩] ឥទមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា

ចាចីនវំសោ តិវរានំ
រោហិតស្សាន វង្កតោ
សុប្បិយានំ សុបស្សោបិ(១)
មាគធានញ្ច វេបុលោ
អនិច្ចា វត សង្ខារា
ឧប្បាទវយធម្មិនោ
ឧប្បជ្ជិត្វា និរុជ្ឈន្តិ
តេសំ វូបសមោ សុខោតិ ។ ទសមំ ។

ទុគ្គតវគ្គោ ទុតិយោ ។

១ ឱ. ម. សុបស្សាតិ ។

អនមតគ្គសំយុត្ត ទុគ្គតវគ្គ និគមវចនៈ

[១២៩] ព្រះមានព្រះភាគ ទ្រង់ត្រាស់សូត្រនេះហើយ លុះព្រះសុគតជាសាស្តា ទ្រង់ត្រាស់សូត្រនេះហើយ ទើបទ្រង់ត្រាស់ពាក្យនេះតទៅទៀតថា

ភ្នំបាចីនវំសៈរបស់ពួកមនុស្សតិវរៈ ភ្នំវង្កតរបស់ពួកមនុស្សរោហិតស្សៈ ភ្នំសុបស្សៈរបស់ពួកមនុស្សសុប្បិយៈ ភ្នំវេបុល្លរបស់ពួកមនុស្សមាគធៈ សង្ខារទាំងឡាយ មិនទៀងមែនពិតមានកិរិយាកើតឡើង និងវិនាសទៅជាធម្មតា លុះកើតឡើងហើយរលត់ទៅវិញ ការរម្ងាប់នូវសង្ខារទាំងឡាយនោះ នាំមកនូវសេចក្តីសុខ ។ ចប់សូត្រទី ១០ ។

ចប់ ទុគ្គតវគ្គ ទី ២ ។

១១០

សុត្តន្តបិដកេ សំយុត្តនិកាយស្ស និទានវគ្គោ

# តស្ស ឧទ្ទានំ

ទុគ្គតំ សុខិតញ្ចេវ
តឹសមាតា បិតេន ច
ភាតា ភគិនី បុត្តោ ច
ធីតា វេបុល្លបព្វតំ ។

អនមតគ្គសំយុត្តំ តតិយំ សមត្តំ ។

---

# ឧទ្ទាននៃទុគ្គតវគ្គនោះគឺ

*និយាយពីបុគ្គលកម្សត់ ១ បុគ្គលដល់នូវសេចក្ដីសុខ ១ ភិក្ខុ ៣០ រូប ១ បុគ្គលធ្លាប់កើតជាមាតា ១ ជាបិតា ១ ជាបងប្អូនប្រុស ១ ជាបងប្អូនស្រី ១ ជាកូនប្រុស ១ ជាកូនស្រី ១ ភ្នំឈ្មោះវេបុល្ល ១ ។*

ចប់ អនមតគ្គសំយុត្ត ទី ៣ ។

# កស្សបសំយុត្តំ

[១៣០] សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា... សន្តុដ្ឋាយំ ភិក្ខវេ កស្សបោ ឥតរីតរេន ចីវរេន ឥតរីតរចីវរសន្តុដ្ឋិយា ច វណ្ណវាទី ន ច ចីវរហេតុ អនេសនំ អប្បដិរូបំ អាបជ្ជតិ អលទ្ធា ច ចីវរំ ន បរិតស្សតិ លទ្ធា ច ចីវរំ អគធិតោ អមុច្ឆិតោ អនជ្ឈាបន្នោ អាទីនវទស្សាវី និស្សរណបញ្ញោ បរិភុញ្ជតិ ។ សន្តុដ្ឋាយំ ភិក្ខវេ កស្សបោ ឥតរីតរេន បិណ្ឌបាតេន ឥតរីតរបិណ្ឌបាតសន្តុដ្ឋិយា ច វណ្ណវាទី ន ច បិណ្ឌបាតហេតុ អនេសនំ អប្បដិរូបំ អាបជ្ជតិ អលទ្ធា ច បិណ្ឌបាតំ ន បរិតស្សតិ លទ្ធា ច បិណ្ឌបាតំ អគធិតោ អមុច្ឆិតោ អនជ្ឈាបន្នោ អាទីនវទស្សាវី និស្សរណបញ្ញោ បរិភុញ្ជតិ ។ សន្តុដ្ឋាយំ ភិក្ខវេ កស្សបោ ឥតរីតរេន សេនាសនេន

# កស្សបសំយុត្ត

[១៣០] ព្រះមានព្រះភាគ គង់នៅទៀបក្រុងសាវត្ថី... ក្នុងទីនោះឯង ព្រះមានព្រះភាគ... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កស្សបភិក្ខុនេះ ជាអ្នកសន្តោសដោយចីវរតាមមានតាមបានផង ជាអ្នកពោលសរសើរគុណនៃការសន្តោស ដោយចីវរតាមមានតាមបានផង មិនដល់នូវអនេសនៈដែលជាធម៌មិនសមគួរ ព្រោះហេតុចីវរផង មិនតក់ស្លុតព្រោះមិនបានចីវរផង មិនត្រេកអរ មិនវង្វេង មិនជ្រុលជ្រប់ ព្រោះបានចីវរផង ជាអ្នកឃើញទោស ក្នុងការដល់នូវអនេសនៈនិងការប្រើប្រាស់ដោយសេចក្តីចំពាក់ចិត្ត ជាប្រក្រតី ជាអ្នកមានបញ្ញាសម្រាប់រើខ្លួន ប្រើប្រាស់ (នូវចីវរ) ។ ម្នាលភិក្ខុទាំងឡាយ កស្សបភិក្ខុនេះ ជាអ្នកសន្តោស ដោយបិណ្ឌបាតតាមមានតាមបានផង ជាអ្នកពោលសរសើរគុណនៃសេចក្តីសន្តោស ដោយបិណ្ឌបាតតាមមានតាមបានផង មិនដល់នូវអនេសនៈដែលជាធម៌មិនសមគួរ ព្រោះហេតុបិណ្ឌបាតផង មិនតក់ស្លុត ព្រោះមិនបានបិណ្ឌបាតផង មិនត្រេកអរ មិនវង្វេង មិនជ្រុលជ្រប់ ព្រោះបានបិណ្ឌបាតផង ជាអ្នកឃើញទោសជាប្រក្រតី មានបញ្ញាសម្រាប់រើខ្លួន បរិភោគ (នូវបិណ្ឌបាត) ។ ម្នាលភិក្ខុទាំងឡាយ កស្សបភិក្ខុនេះ ជាអ្នកសន្តោស ដោយសេនាសនៈតាមមានតាមបានផង

ឥតរីតរសេនាសនសន្តុដ្ឋិយា ច វណ្ណវាទី ន ច សេនាសនហេតុ អនេសនំ អប្បដិរូបំ អាបជ្ជតិ អលទ្ធា ច សេនាសនំ ន បរិតស្សតិ លទ្ធា ច សេនាសនំ អគធិតោ អមុច្ឆិតោ អនជ្ឈាបន្នោ អាទីនវទស្សាវី និស្សរណប្បញ្ញោ បរិភុញ្ជតិ ។ សន្តុដ្ឋាយំ ភិក្ខវេ កស្សបោ ឥតរីតរេន គិលានប្បច្ចយភេសជ្ជបរិក្ខារេន ឥតរីតរគិលានប្បច្ចយភេសជ្ជបរិក្ខារសន្តុដ្ឋិយា ច វណ្ណវាទី ន ច គិលានប្បច្ចយភេសជ្ជបរិក្ខារហេតុ អនេសនំ អប្បដិរូបំ អាបជ្ជតិ អលទ្ធា ច គិលានប្បច្ចយភេសជ្ជបរិក្ខារំ ន បរិតស្សតិ លទ្ធា ច គិលានប្បច្ចយភេសជ្ជបរិក្ខារំ អគធិតោ អមុច្ឆិតោ អនជ្ឈាបន្នោ អាទីនវទស្សាវី និស្សរណប្បញ្ញោ បរិភុញ្ជតិ ។

ជាអ្នកពោលសរសើរគុណនៃសេចក្ដីសន្ដោស ដោយសេនាសនៈ តាមមានតាមបានផង មិនដល់នូវអនេសនៈដែលជាធម៌មិនសមគួរ ព្រោះហេតុនៃសេនាសនៈផង មិនតក់ស្លុត ព្រោះមិនបានសេនាសនៈផង មិនត្រេកអរ មិនវង្វេង មិនជ្រុលជ្រប់ ព្រោះបានសេនាសនៈផង ជាអ្នកឃើញទោសជាប្រក្រតី មានបញ្ញាសម្រាប់រើខ្លួន ប្រើប្រាស់ (នូវសេនាសនៈ) ។ ម្នាលភិក្ខុទាំងឡាយ កស្សបៈនេះ ជាអ្នកសន្ដោសដោយគិលានប្បច្ចយ-ភេសជ្ជបរិក្ខារតាមមានតាមបានផង ជាអ្នកពោលសរសើរគុណនៃសេចក្ដីសន្ដោស ដោយគិលានប្បច្ចយភេសជ្ជបរិក្ខារតាមមានតាមបានផង មិនដល់នូវអនេសនៈដែលជាធម៌មិនសមគួរ ព្រោះហេតុនៃគិលានប្បច្ចយ-ភេសជ្ជបរិក្ខារផង មិនតក់ស្លុត ព្រោះមិនបានគិលានប្បច្ចយភេសជ្ជ-បរិក្ខារផង មិនត្រេកអរ មិនវង្វេង មិនជ្រុលជ្រប់ ព្រោះបានគិលា-នប្បច្ចយភេសជ្ជបរិក្ខារផង ជាអ្នកឃើញទោសជាប្រក្រតី មានបញ្ញាសម្រាប់រើខ្លួន បរិភោគ (នូវគិលានប្បច្ចយភេសជ្ជបរិក្ខារ) ។

កស្សបសំយុត្តស្ស បឋមសុត្តេ សន្តុដ្ឋភាវោ

[១៣១] តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ សន្តុដ្ឋា ភវិស្សាម ឥតរីតរេន ចីវរេន ឥតរីតរចីវរសន្តុដ្ឋិយា ច វណ្ណវាទិនោ ន ច ចីវរហេតុ អនេសនំ អប្បដិរូបំ អាបជ្ជិស្សាម អលទ្ធា ច ចីវរំ ន បរិតស្សិស្សាម លទ្ធា ច ចីវរំ អគធិតា អមុច្ឆិតា អនជ្ឈាបន្នា អាទីនវទស្សាវិនោ និស្សរណបញ្ញា បរិភុញ្ជិស្សាម ។

( ឯវំ សព្វំ កាតព្វំ )

សន្តុដ្ឋា ភវិស្សាម ឥតរីតរេន បិណ្ឌបាតេន ។ បេ ។ សន្តុដ្ឋា ភវិស្សាម ឥតរីតរេន សេនាសនេន ។ បេ ។ សន្តុដ្ឋា ភវិស្សាម ឥតរីតរេន គិលានប្បច្ចយភេសជ្ជបរិក្ខារេន ឥតរីតរគិលានប្បច្ចយភេសជ្ជបរិក្ខារសន្តុដ្ឋិយា ច វណ្ណវាទិនោ ន ច គិលានប្បច្ចយភេសជ្ជបរិក្ខារហេតុ អនេសនំ អប្បដិរូបំ អាបជ្ជិស្សាម អលទ្ធា ច គិលានប្បច្ចយភេសជ្ជបរិក្ខារំ ន បរិតស្សិស្សាម លទ្ធា ច គិលានប្បច្ចយភេសជ្ជបរិក្ខារំ អគធិតា អមុច្ឆិតា អនជ្ឈាបន្នា អាទីនវទស្សាវិនោ

កស្សបសំយុត្ត បឋមសូត្រ ភាពនៃបុគ្គលអ្នកសន្តោស

[១៣១] ម្នាលភិក្ខុទាំងឡាយ ហេតុដូច្នោះ ភិក្ខុក្នុងសាសនានេះ គប្បីសិក្សាយ៉ាងនេះថា ពួកយើងនឹងជាអ្នកសន្តោសដោយចីវរតាមមានតាមបានផង ជាអ្នកពោលសរសើរគុណនៃសេចក្តីសន្តោសដោយចីវរតាមមានតាមបានផង មិនដល់នូវអនេសនៈដែលជាធម៌មិនសមគួរ ព្រោះហេតុនៃចីវរ មិនតក់ស្លុត ព្រោះមិនបានចីវរផង មិនត្រេកអរ មិនវង្វេង មិនជ្រុលជ្រប់ ព្រោះបានចីវរផង ជាអ្នកឃើញទោសជាប្រក្រតី មានបញ្ញាសម្រាប់រើខ្លួន នឹងបរិភោគ (នូវចីវរ) ។

( ពាក្យទាំងអស់ បណ្ឌិតត្រូវធ្វើយ៉ាងនេះចុះ )

យើងទាំងឡាយ នឹងជាអ្នកសន្តោសដោយបិណ្ឌបាត តាមមានតាមបាន ។ បេ ។ យើងទាំងឡាយ នឹងជាអ្នកសន្តោសដោយសេនាសនៈតាមមានតាមបាន ។ បេ ។ យើងទាំងឡាយ នឹងជាអ្នកសន្តោសដោយគិលានប្បច្ចយភេសជ្ជបរិក្ខារ តាមមានតាមបានផង ជាអ្នកពោលសរសើរគុណនៃសេចក្តីសន្តោស ដោយគិលានប្បច្ចយភេសជ្ជបរិក្ខារតាមមានតាមបានផង មិនដល់នូវអនេសនៈដែលជាធម៌មិនសមគួរ ព្រោះហេតុនៃគិលានប្បច្ចយភេសជ្ជបរិក្ខារផង ជាអ្នកមិនតក់ស្លុត ព្រោះមិនបានគិលានប្បច្ចយភេសជ្ជបរិក្ខារផង មិនត្រេកអរ មិនវង្វេង មិនជ្រុលជ្រប់ ព្រោះបានគិលានប្បច្ចយភេសជ្ជបរិក្ខារផង ជាអ្នកឃើញទោសជាប្រក្រតី

និស្សរណបញ្ញា បរិភុញ្ជិស្សាមាតិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វំ ។ កស្សបេន វា ហិ វោ ភិក្ខវេ ឱវទិស្សាមិ យោ វា បនស្ស កស្សបសទិសោ[១] ឱវទិតេហិ ច បន វោ តថត្តាយ បដិបជ្ជិតព្វន្តិ ។ បឋមំ ។

[១៣២] ឯវម្មេ សុតំ ។ ឯកំ សមយំ អាយស្មា ច មហាកស្សបោ អាយស្មា ច សារីបុត្តោ ពារាណសិយំ វិហរន្តិ ឥសិបតនេ មិគទាយេ ។ អថខោ អាយស្មា សារីបុត្តោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេនាយស្មា មហាកស្សបោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា មហាកស្សបេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។

១ ឱ. យោ វា កស្សបសទិសោ ។

មានបញ្ញាសម្រាប់រើខ្លួន នឹងបរិភោគ (នូវគិលានប្បច្ចភេសជ្ជបរិក្ខារ) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងទូន្មាននូវអ្នកទាំងឡាយ តាមបែបកស្សបភិក្ខុ ឬថាតាមបែបភិក្ខុឯណា ដែលប្រហែលនឹងកស្សបភិក្ខុ អ្នកទាំងឡាយដែលតថាគតទូន្មានហើយ ក៏ត្រូវប្រតិបត្តិតាមបែបនោះចុះ ។ ចប់សូត្រទី ១ ។

[១៣២] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមហាកស្សបៈមានអាយុ និងព្រះសារីបុត្តមានអាយុ នៅក្នុងឥសិបតនមិគទាយវន ទៀបក្រុងពារាណសី ។ គ្រានោះឯង ព្រះសារីបុត្តមានអាយុ ចេញអំពីទីស្ងាត់ក្នុងវេលាថ្ងៃរសៀល ហើយចូលទៅរកព្រះមហាកស្សបៈមានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះមហាកស្សបៈមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។

[១៣៣] ឯកាមន្តំ និសិន្នោ ខោ អាយស្មា សារីបុត្តោ អាយស្មន្តំ មហាកស្សបំ ឯតទវោច វុច្ចតិ ហិទំ អាវុសោ កស្សប អនាតាបី អនោត្តាបី អភព្វោ សម្ពោធាយ អភព្វោ និព្វានាយ អភព្វោ អនុត្តរស្ស យោគក្ខេមស្ស អធិគមាយ អាតាបី ច ខោ ឱត្តាបី ភព្វោ សម្ពោធាយ ភព្វោ និព្វានាយ ភព្វោ អនុត្តរស្ស យោគក្ខេមស្ស អធិគមាយ[១] កិត្តាវតា នុ ខោ អាវុសោ អនាតាបី ហោតិ អនោត្តាបី អភព្វោ សម្ពោធាយ អភព្វោ និព្វានាយ អភព្វោ អនុត្តរស្ស យោគក្ខេមស្ស អធិគមាយ កិត្តាវតា ច បនាវុសោ អាតាបី ហោតិ ឱត្តាបី ភព្វោ សម្ពោធាយ ភព្វោ និព្វានាយ ភព្វោ អនុត្តរស្ស យោគក្ខេមស្ស អធិគមាយាតិ ។

---

១ ឱ. អធិគមាយាតិ ។

កស្សបសំយុត្ត ទុតិយសូត្រ ភាពនៃបុគ្គលមិនមានសេចក្ដីព្យាយាមដុតកម្ដៅកិលេស

[១៣៣] លុះព្រះសារីបុត្តមានអាយុ អង្គុយក្នុងទីដ៏សមគួរ ហើយ បានពោលពាក្យនេះ នឹងព្រះមហាកស្សបៈមានអាយុថា ម្នាលកស្សបៈមានអាយុ ព្រះមានព្រះភាគ បានត្រាស់ព្រះពុទ្ធដីកានេះថា បុគ្គលដែលមិនមានសេចក្ដីព្យាយាមដុតកម្ដៅកិលេស មិនមានសេចក្ដីខ្លាចបាប មិនគួរដើម្បីត្រាស់ដឹង មិនគួរដើម្បីព្រះនិព្វាន មិនគួរដើម្បីបាននូវធម៌ដ៏ក្សេមចាកយោគៈដ៏ប្រសើរឡើយ លុះតែបុគ្គលមានសេចក្ដីព្យាយាម មានសេចក្ដីខ្លាចបាប ទើបគួរដើម្បីត្រាស់ដឹង គួរដើម្បីព្រះនិព្វាន គួរបាននូវធម៌ដ៏ក្សេមចាកយោគៈដ៏ប្រសើរ ម្នាលអាវុសោ បុគ្គលដែលមិនមានសេចក្ដីព្យាយាមដុតកម្ដៅកិលេស មិនមានសេចក្ដីខ្លាចបាប មិនគួរដើម្បីត្រាស់ដឹង មិនគួរដើម្បីព្រះនិព្វាន មិនគួរដើម្បីបាននូវធម៌ដ៏ក្សេមចាកយោគៈដ៏ប្រសើរទេ ដោយហេតុដូចម្ដេចហ្ន៎ ម្នាលអាវុសោ ចំណែកបុគ្គលជាអ្នកមានសេចក្ដីព្យាយាមដុតកម្ដៅកិលេស ជាអ្នកមានសេចក្ដីខ្លាចបាប គួរដើម្បីត្រាស់ដឹង គួរដើម្បីព្រះនិព្វាន គួរដើម្បីបាននូវធម៌ក្សេមចាកយោគៈដ៏ប្រសើរ តើដូចម្ដេចខ្លះ ។

[១៣៤] ឥធាវុសោ ភិក្ខុ អនុប្បន្នា មេ បាបកា អកុសលា ធម្មា ឧប្បជ្ជមានា អនត្ថាយ សំវត្តេយ្យុន្តិ ន អាតប្បំ ករោតិ ឧប្បន្នា មេ បាបកា អកុសលា ធម្មា អប្បហីយមានា អនត្ថាយ សំវត្តេយ្យុន្តិ ន អាតប្បំ ករោតិ អនុប្បន្នា មេ កុសលា ធម្មា អនុប្បជ្ជមានា អនត្ថាយ សំវត្តេយ្យុន្តិ ន អាតប្បំ ករោតិ ឧប្បន្នា មេ កុសលា ធម្មា និរុជ្ឈមានា អនត្ថាយ សំវត្តេយ្យុន្តិ ន អាតប្បំ ករោតិ ។ ឯវំ ខោ អាវុសោ អនាតាបី ហោតិ ។

[១៣៤] ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ មិនធ្វើសេចក្តីព្យាយាមដុតកម្តៅកិលេសថា ពួកអកុសលធម៌ដ៏លាមក ដែលមិនទាន់កើតឡើងដល់អាត្មាអញ កាលបើកើតឡើង គប្បីប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ មិនធ្វើសេចក្តីព្យាយាមដុតកម្តៅកិលេសថា ពួកអកុសល-ធម៌ដ៏លាមក ដែលកើតឡើងដល់អាត្មាអញ កាលបើអាត្មាអញមិនបានលះបង់ទេ គប្បីប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ឡើយ មិនធ្វើសេចក្តីព្យាយាមដុតកម្តៅកិលេសថា ពួកកុសលធម៌ដែលមិនទាន់កើតឡើងដល់អាត្មាអញ កាលបើមិនកើតឡើង គប្បីប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ មិនធ្វើសេចក្តីព្យាយាមដុតកម្តៅកិលេសថា ពួកកុសល-ធម៌ដែលកើតឡើងដល់អាត្មាអញហើយ កាលបើរលត់ទៅវិញ គប្បីប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ឡើយ ។ ម្នាលអាវុសោ បុគ្គលជាអ្នកមិនមានសេចក្តីព្យាយាមដុតកម្តៅកិលេសដោយហេតុយ៉ាងនេះឯង ។

កស្សបសំយុត្តស្ស ទុតិយសុត្តេ អនោត្តាបិភាវោ

[១៣៨] កាថញ្ចាវុសោ អនោត្តាបី ហោតិ ។ ឥធាវុសោ ភិក្ខុ អនុប្បន្នា មេ បាបកា អកុសលា ធម្មា ឧប្បជ្ជមានា អនត្ថាយ សំវត្តេយ្យុន្តិ ន ឱត្តប្បតិ ឧប្បន្នា មេ បាបកា អកុសលា ធម្មា អប្បហីយមានា អនត្ថាយ សំវត្តេយ្យុន្តិ ន ឱត្តប្បតិ អនុប្បន្នា មេ កុសលា ធម្មា អនុប្បជ្ជមានា អនត្ថាយ សំវត្តេយ្យុន្តិ ន ឱត្តប្បតិ ឧប្បន្នា មេ កុសលា ធម្មា និរុជ្ឈមានា អនត្ថាយ សំវត្តេយ្យុន្តិ ន ឱត្តប្បតិ ។ ឯវំ ខោ អាវុសោ អនោត្តាបី ហោតិ ។ ឯវំ ខោ អាវុសោ អនាតាបី អនោត្តាបី អភព្វោ សម្ពោធាយ អភព្វោ និព្វានាយ អភព្វោ អនុត្តរស្ស យោគក្ខេមស្ស អធិគមាយ ។

កស្សបសំយុត្ត ទុតិយសូត្រ ភាពនៃបុគ្គលមិនមានសេចក្តីខ្លាចបាប

[១៣៥] ម្នាលអាវុសោ ចុះបុគ្គលមិនមានសេចក្តីខ្លាចបាប តើដូចម្តេច ។ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ មិនខ្លាចបាប ដោយគិតថា ពួកអកុសលធម៌ដ៏លាមក មិនទាន់កើតឡើងដល់អាត្មាអញ កាលបើកើតឡើង គប្បីប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ មិនខ្លាចបាប ដោយគិតថា ពួកអកុសលធម៌ដ៏លាមក កើតឡើងដល់អាត្មាអញហើយ កាលបើអាត្មាអញមិនបានលះបង់ចេញ គប្បីប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ មិនខ្លាចបាប ដោយគិតថា ពួកកុសលធម៌ដែលមិនទាន់កើតឡើងដល់អាត្មាអញ កាលបើមិនទាន់កើតឡើងទេ គប្បីប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ មិនខ្លាចបាប ដោយគិតថា ពួកអកុសលធម៌ដែលកើតឡើងដល់អាត្មាអញហើយ កាលបើរលត់ទៅវិញ គប្បីប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ។ ម្នាលអាវុសោ បុគ្គលមិនមានសេចក្តីខ្លាចបាបយ៉ាងនេះឯង ។ ម្នាលអាវុសោ បុគ្គលជាអ្នកមិនមានសេចក្តីព្យាយាមដុតកម្តៅកិលេស មិនមានសេចក្តីខ្លាចបាបយ៉ាងនេះ មិនគួរដើម្បីត្រាស់ដឹង មិនគួរដើម្បីព្រះនិព្វាន មិនគួរដើម្បីបាននូវធម៌ដ៏ក្សេមចាកយោគៈដ៏ប្រសើរយ៉ាងនេះឯង ។

[១៣៦] កថញ្ចាវុសោ អាតាបី ហោតិ ។ ឥធា-
វុសោ ភិក្ខុ អនុប្បន្នា មេ បាបកា អកុសលា
ធម្មា ឧប្បជ្ជមានា អនត្ថាយ សំវត្តេយ្យុន្តិ អាតប្បំ
ករោតិ ឧប្បន្នា មេ បាបកា អកុសលា ធម្មា អប្ប-
ហីយមានា អនត្ថាយ សំវត្តេយ្យុន្តិ អាតប្បំ ករោតិ
អនុប្បន្នា មេ កុសលា ធម្មា អនុប្បជ្ជមានា អនត្ថា-
យ សំវត្តេយ្យុន្តិ អាតប្បំ ករោតិ ឧប្បន្នា មេ កុសលា
ធម្មា និរុជ្ឈមានា អនត្ថាយ សំវត្តេយ្យុន្តិ អាតប្បំ ក-
រោតិ ។ ឯវំ ខោ អាវុសោ អាតាបី ហោតិ ។

[១៣៦] ម្នាលអាវុសោ ចុះបុគ្គលជាអ្នកមានសេចក្តីព្យាយាមដុតកម្តៅកិលេស តើដូចម្តេច ។ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ ធ្វើនូវសេចក្តីព្យាយាមដុតកម្តៅកិលេស ដោយគិតថា ពួកអកុសលធម៌ដ៏លាមក មិនទាន់កើតឡើងដល់អាត្មាអញ កាលបើកើតឡើង គប្បីប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ធ្វើសេចក្តីព្យាយាមដុតកម្តៅកិលេស ដោយគិតថា ពួកអកុសលធម៌ដ៏លាមក កើតឡើងដល់អាត្មាអញហើយ កាលបើអាត្មាអញមិនបានលះបង់ចេញទេ គប្បីប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ធ្វើសេចក្តីព្យាយាមដុតកម្តៅកិលេស ដោយគិតថា ពួកកុសលធម៌ដែលមិនទាន់កើតឡើងដល់អាត្មាអញ កាលបើមិនទាន់កើតឡើង គប្បីប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ធ្វើសេចក្តីព្យាយាមដុតកម្តៅកិលេស ដោយគិតថា ពួកកុសលធម៌ដែលកើតឡើងដល់អាត្មាអញហើយ កាលបើរលត់ទៅវិញ គប្បីប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ។ ម្នាលអាវុសោ បុគ្គលជាអ្នកមានសេចក្តីព្យាយាមដុតកម្តៅកិលេស យ៉ាងនេះឯង ។

កស្សបសំយុត្តស្ស ទុតិយសុត្តេ ឱត្តាបិភាវោ

[១៣៧] កថញ្ចាវុសោ ឱត្តាបី ហោតិ ។ ឥធាវុសោ ភិក្ខុ អនុប្បន្នា មេ បាបកា អកុសលា ធម្មា ឧប្បជ្ជមានា អនត្ថាយ សំវត្តេយ្យុន្តិ ឱត្តប្បតិ ឧប្បន្នា មេ បាបកា អកុសលា ធម្មា អប្បហីយមានា អនត្ថាយ សំវត្តេយ្យុន្តិ ឱត្តប្បតិ អនុប្បន្នា មេ កុសលា ធម្មា អនុប្បជ្ជមានា អនត្ថាយ សំវត្តេយ្យុន្តិ ឱត្តប្បតិ ឧប្បន្នា មេ កុសលា ធម្មា និរុជ្ឈមានា អនត្ថាយ សំវត្តេយ្យុន្តិ ឱត្តប្បតិ ។ ឯវំ ខោ អាវុសោ ឱត្តាបី ហោតិ ។ ឯវំ ខោ អាវុសោ អាតាបី ឱត្តាបី ភព្វោ សម្ពោធាយ ភព្វោ និព្វានាយ ភព្វោ អនុត្តរស្ស យោគក្ខេមស្ស អធិគមាយាតិ ។ ទុតិយំ ។

កស្សបសំយុត្ត ទុតិយសូត្រ ភាពនៃបុគ្គលមានសេចក្តីខ្លាចបាប

[១៣៧] ម្នាលអាវុសោ ចុះបុគ្គលជាអ្នកមានសេចក្តីខ្លាចបាប តើដូចម្តេច ។ ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ រមែងខ្លាចបាប ដោយគិតថា ពួកអកុសលធម៌ដ៏លាមក ដែលមិនទាន់កើតឡើងដល់អាត្មាអញ កាលបើកើតឡើង គប្បីប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ រមែងខ្លាចបាប ដោយគិតថា ពួកអកុសលធម៌ដែលកើតឡើង ដល់អាត្មាអញហើយ កាលបើអាត្មាអញមិនបានលះបង់ចេញទេ គប្បីប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ រមែងខ្លាចបាប ដោយគិតថា ពួកកុសលធម៌ដែលមិនទាន់កើតឡើងដល់អាត្មាអញ កាលបើមិនទាន់កើតឡើង គប្បីប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ រមែងខ្លាចបាប ដោយគិតថា ពួកកុសលធម៌ដែលកើតឡើងដល់អាត្មាអញហើយ កាលបើរលត់ទៅវិញ គប្បីប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ។ ម្នាលអាវុសោ បុគ្គលជាអ្នកមានសេចក្តីខ្លាចបាបយ៉ាងនេះឯង ។ ម្នាលអាវុសោ បុគ្គលជាអ្នកមានសេចក្តីព្យាយាមដុតកម្តៅកិលេស ជាអ្នកមានសេចក្តីខ្លាចបាបយ៉ាងនេះ ទើបគួរដើម្បីត្រាស់ដឹង គួរដើម្បីព្រះនិព្វាន គួរដើម្បីបាននូវធម៌ដ៏ក្សេមចាកយោគដ៏ប្រសើរ ។ ចប់សូត្រទី ២ ។

[១៣៨] សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា ចន្ទូបមា ភិក្ខវេ កុលានិ ឧបសង្កមថ អបកស្សេវ កាយំ អបកស្ស ចិត្តំ និច្ចនវកា កុលេសុ អប្បគព្ភា ។ សេយ្យថាបិ ភិក្ខវេ បុរិសោ ជរុទបានំ វា ឱលោកេយ្យ បព្វតវិសមំ វា នទីវិទុគ្គំ វា អបកស្សេវ កាយំ អបកស្ស ចិត្តំ ឯវមេវ ខោ ភិក្ខវេ ចន្ទូបមា កុលានិ ឧបសង្កមថ អបកស្សេវ កាយំ អបកស្ស ចិត្តំ និច្ចនវកា កុលេសុ អប្បគព្ភា ។ កស្សបោ ភិក្ខវេ ចន្ទូបមោ កុលានិ ឧបសង្កមតិ អបកស្សេវ កាយំ អបកស្ស ចិត្តំ និច្ចនវកោ កុលេសុ អប្បគព្ភោ ។

[១៣៨] ព្រះមានព្រះភាគ គង់នៅទៀបក្រុងសាវត្ថី... ក្នុងទីនោះឯង ព្រះមានព្រះភាគ... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយមានឧបមាដូចជាព្រះចន្ទ[១] ត្រូវដកកាយដកចិត្តចេញ ធ្វើដូចជាអាគន្តុកភិក្ខុ មិនឃ្នើសឃ្នង ក្នុងត្រកូលទាំងឡាយ ចូលទៅកាន់ត្រកូលចុះ ។ ម្នាលភិក្ខុទាំងឡាយ បុរសក្រឡេកមើលរណ្តៅចាស់ក្តី ទីដែលមិនរាបស្មើក្នុងភ្នំក្តី ទីដែលឆ្លងបានដោយលំបាកក្នុងស្ទឹងក្តី គប្បីដកកាយដកចិត្តចេញ យ៉ាងណា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយមានឧបមាដូចជាព្រះចន្ទ ចូរដកកាយដកចិត្តចេញ ធ្វើដូចជាអាគន្តុកភិក្ខុ មិនឃ្នើសឃ្នង ក្នុងត្រកូលទាំងឡាយ ចូលទៅកាន់ត្រកូលចុះយ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ កស្សបៈមានឧបមាដូចព្រះចន្ទ ជាអ្នកដកកាយដកចិត្តចេញ ធ្វើដូចជាអាគន្តុកភិក្ខុ មិនឃ្នើសឃ្នង ក្នុងត្រកូលទាំងឡាយ ចូលទៅកាន់ត្រកូល ។

---

១ ភិក្ខុប្រព្រឹត្តខ្លួនដូចជាព្រះចន្ទហើយចូលទៅកាន់ត្រកូលនោះ គឺមិនរើសមុខថា ក្សត្រិយ៍ឬព្រាហ្មណ៍ជាដើម ដូចព្រះចន្ទដែលផ្សាយរស្មីមិនរើសមុខសត្វណាមួយឡើយ ។

កស្សបសំយុត្តស្ស តតិយសុត្តេ កុលូបកភាវោ

[១៣៩] តំ កឹ មញ្ញថ ភិក្ខវេ កថំរូបោ ភិក្ខុ អរហតិ កុលានិ ឧបសង្កមិតុន្តិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ភគវំនេត្តិកា ភគវំបដិសរណា សាធុ វត ភន្តេ ភគវន្តំយេវ បដិភាតុ ឯតស្ស ភាសិតស្ស អត្ថោ ភគវតោ សុត្វា ភិក្ខូ ធារេស្សន្តីតិ ។ អថខោ ភគវា អាកាសេ ចាណឹ ចាលេសិ សេយ្យថាបិ ភិក្ខវេ អយំ អាកាសេ ចាណិ ន សជ្ជតិ ន គយ្ហតិ ន ពជ្ឈតិ ឯវមេវ ខោ ភិក្ខវេ យស្ស កស្សចិ ភិក្ខុនោ កុលានិ ឧបសង្កមតោ កុលេសុ ចិត្តំ ន សជ្ជតិ ន គយ្ហតិ ន ពជ្ឈតិ លភន្តុ លាភកាមា បុញ្ញកាមា ករោន្តុ បុញ្ញានីតិ យថាសកេន លាភេន អត្តមនោ ហោតិ សុមនោ ឯវំ បរេសំ លាភេន អត្តមនោ ហោតិ សុមនោ ។ ឯវរូបោ ខោ ភិក្ខវេ ភិក្ខុ អរហតិ កុលានិ ឧបសង្កមិតុំ ។ កស្សបស្ស ភិក្ខវេ

កស្សបសំយុត្ត តតិយសូត្រ ភាពនៃភិក្ខុអ្នកចូលទៅកាន់ត្រកូល

[១៣៩] ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់ហេតុនោះដូចម្តេច ភិក្ខុមានសភាពដូចម្តេច ដែលគួរចូលទៅកាន់ត្រកូលទាំងឡាយបាន ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយរបស់ពួកខ្ញុំព្រះអង្គ សឹងមានព្រះមានព្រះភាគជាឫស មានព្រះមានព្រះភាគ ជាអ្នកណែនាំ មានព្រះមានព្រះភាគជាទីពឹងអាស្រ័យ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់ព្រះមេត្តាប្រោស បំភ្លឺសេចក្តីនៃភាសិតនុ៎ះ ឲ្យទាន ពួកភិក្ខុបានស្តាប់ព្រះមានព្រះភាគហើយ នឹងបានចាំទុក ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ធ្វើព្រះហស្តឲ្យញ័រទៅក្នុងអាកាសហើយ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បាតដៃនេះ មិនជាប់ មិនជំពាក់ មិនស្អិតទៅលើអាកាស យ៉ាងណា ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាមួយចូលទៅកាន់ត្រកូលទាំងឡាយហើយ មានចិត្តមិនជាប់ មិនជំពាក់ មិនស្អិតក្នុងត្រកូលទាំងឡាយ ដោយគិតថា ពួកជនដែលប្រាថ្នាលាភ ចូរឲ្យបាននូវលាភចុះ ពួកជនប្រាថ្នាបុណ្យ ចូរធ្វើបុណ្យនេះ យ៉ាងនោះឯងបុគ្គលជាអ្នកពេញចិត្ត មានចិត្តល្អដោយលាភរបស់ខ្លួន យ៉ាងណា បុគ្គលជាអ្នកពេញចិត្ត មានចិត្តល្អ ដោយលាភរបស់ពួកជនដទៃ យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបែបនេះ ទើបគួរចូលទៅកាន់ត្រកូលទាំងឡាយបាន ។ ម្នាលភិក្ខុទាំងឡាយ កាលកស្សបភិក្ខុ

កុលានិ ឧបសង្កមតោ កុលេសុ ចិត្តំ ន សជ្ជតិ ន គយ្ហតិ ន ពជ្ឈតិ លភន្តុ លាភកាមា បុញ្ញកាមា ករោន្តុ បុញ្ញានីតិ យថាសកេន លាភេន អត្តមនោ ហោតិ សុមនោ ឯវំ បរេសំ លាភេន អត្តមនោ ហោតិ សុមនោ ។

[១៤០] តំ កឹ មញ្ញថ ភិក្ខវេ កថំរូបស្ស ភិក្ខុនោ អបរិសុទ្ធា ធម្មទេសនា ហោតិ កថំរូបស្ស ភិក្ខុនោ បរិសុទ្ធា ធម្មទេសនា ហោតីតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ភគវំនេត្តិកា ភគវំបដិសរណា

ចូលទៅកាន់ត្រកូលទាំងឡាយ មានចិត្តមិនជាប់ មិនជំពាក់ មិនស្អិតក្នុងត្រកូលទាំងឡាយ ដោយគិតថា ពួកជនប្រាថ្នាលាភ ចូរបានលាភចុះ ពួកជនប្រាថ្នាបុណ្យ ចូរធ្វើនូវបុណ្យចុះ ជនជាអ្នកពេញចិត្ត មានចិត្តល្អដោយលាភរបស់ខ្លួន យ៉ាងណា បុគ្គលជាអ្នកពេញចិត្ត មានចិត្តល្អដោយលាភរបស់បុគ្គលទាំងឡាយដទៃ យ៉ាងនោះដែរ ។

[១៤០] ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់ហេតុនោះដូចម្តេច ធម្មទេសនារបស់ភិក្ខុបែបណា ដែលមិនបរិសុទ្ធ ធម្មទេសនារបស់ភិក្ខុបែបណា ដែលបរិសុទ្ធ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំង-ឡាយរបស់ពួកខ្ញុំព្រះអង្គ សឹងមានព្រះមានព្រះភាគជាឫស មានព្រះមានព្រះភាគជាអ្នកណែនាំ មានព្រះមានព្រះភាគ ជាទីពឹងអាស្រ័យ

១២៣

កស្សបសំយុត្តស្ស តតិយសុត្តេ កុលូបកភាវោ

សាធុ វត ភន្តេ ភគវន្តំយេវ បដិភាតុ ឯតស្ស ភាសិ-តស្ស អត្ថោ ភគវតោ សុត្វា ភិក្ខូ ធារេស្សន្តីតិ ។ តេនហិ ភិក្ខវេ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច យោ ហិ កោចិ ភិក្ខវេ ភិក្ខុ ឯវំចិត្តោ បរេសំ ធម្មំ ទេសេតិ អហោ វត មេ ធម្មំ សុណេយ្យុំ សុត្វា ច បន ធម្មំ បសីទេយ្យុំ បសន្នា វ មេ បសន្នាការំ ករេយ្យុន្តិ ។ ឯវរូបស្ស ខោ ភិក្ខវេ ភិក្ខុនោ អបរិសុទ្ធា ធម្មទេសនា ហោតិ ។ យោ ច ខោ ភិក្ខវេ ភិក្ខុ ឯវំចិត្តោ បរេសំ ធម្មំ ទេសេតិ ស្វាក្ខាតោ ភគ-វតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ អហោ វត មេ ធម្មំ សុណេយ្យុំ សុត្វា ច បន ធម្មំ អាជានេយ្យុំ

បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់ព្រះមេត្តាប្រោស សំដែងសេចក្ដីនៃភាសិតនុ៎ះឲ្យទាន ពួកភិក្ខុបានស្ដាប់ព្រះមានព្រះភាគហើយ នឹងបានចាំទុក ។ ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយ ចូរប្រុងស្ដាប់ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ ភិក្ខុទាំងនោះ ទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ភាសិតនេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុឯណានីមួយ តាំងចិត្តយ៉ាងនេះថា អើហ្ន៎ ពួកជនគប្បីស្ដាប់ធម៌របស់អាត្មាអញ លុះស្ដាប់រួចហើយ ជ្រះថ្លាចំពោះធម៌ លុះជ្រះថ្លាពិតហើយ គប្បីធ្វើនូវអាការៈជ្រះថ្លា ចំពោះអាត្មាអញទៀតហើយក៏សំដែងធម៌ដល់ពួកជនដទៃ ។ ម្នាលភិក្ខុទាំងឡាយ ធម្មទេសនារបស់ភិក្ខុបែបនេះ ឈ្មោះថា មិនបរិសុទ្ធទេ ។ ម្នាលភិក្ខុទាំងឡាយ លុះតែភិក្ខុឯណា តាំងចិត្តយ៉ាងនេះថា ព្រះធម៌ដែលព្រះមានព្រះភាគទ្រង់សំដែងហើយដោយប្រពៃ ជាធម៌ដែលអ្នកប្រាជ្ញ គប្បីឃើញច្បាស់ដោយខ្លួនឯង ជាធម៌ឲ្យផលមិនរង់ចាំកាល ជាធម៌មានអាការៈដូចជាហៅបុគ្គលដទៃឲ្យចូលមកមើលបាន ជាធម៌គួរបង្អោនចូលមកទុកក្នុងខ្លួន ជាធម៌ដែលអ្នកប្រាជ្ញទាំងឡាយ គប្បីដឹងចំពោះខ្លួន អើហ្ន៎ ពួកជនដទៃគប្បីស្ដាប់ធម៌របស់អាត្មាអញ លុះស្ដាប់រួចហើយ គប្បីដឹងច្បាស់នូវធម៌

អាជានិត្វា ច បន តថត្តាយ បដិបជ្ជេយ្យុន្តិ ឥតិ ធម្មសុ-ធម្មតំ បដិច្ច បរេសំ ធម្មំ ទេសេតិ ការុញ្ញំ បដិច្ច បរេ-សំ ធម្មំ ទេសេតិ អនុទយំ បដិច្ច បរេសំ ធម្មំ ទេសេតិ អនុកម្បំ ឧបាទាយ បរេសំ ធម្មំ ទេសេតិ ។ ឯវរូបស្ស ខោ ភិក្ខវេ ភិក្ខុនោ បរិសុទ្ធា ធម្មទេសនា ហោតិ ។

[១៤១] កស្សបោ ភិក្ខវេ ឯវំចិត្តោ បរេសំ ធម្មំ ទេ-សេតិ ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកា-លិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ អហោ វត មេ ធម្មំ សុណេយ្យុំ សុត្វា ច បន

លុះដឹងច្បាស់នូវធម៌ហើយ គប្បីប្រតិបត្តិតាមបែបនោះ ហើយក៏សំដែង ធម៌ដល់ពួកជនដទៃ ភិក្ខុសំដែងធម៌ដល់ពួកជនដទៃ ព្រោះអាស្រ័យ នូវភាពនៃធម៌ជាធម៌ល្អ សំដែងធម៌ដល់ពួកជនដទៃ ព្រោះអាស្រ័យ សេចក្តីករុណា សំដែងធម៌ដល់ពួកជនដទៃ ព្រោះអាស្រ័យសេចក្តីអនុគ្រោះ ដូចសំដែងមកនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ធម្មទេសនា របស់ភិក្ខុ បែបនេះ ទើបឈ្មោះថា បរិសុទ្ធ ។

[១៤១] ម្នាលភិក្ខុទាំងឡាយ កស្សបភិក្ខុតាំងចិត្តយ៉ាងនេះថា ព្រះ ធម៌ដែលព្រះមានព្រះភាគ ទ្រង់សំដែងហើយដោយប្រពៃ ជាធម៌ដែល អ្នកប្រាជ្ញា គប្បីឃើញច្បាស់ដោយខ្លួនឯង ជាធម៌ឲ្យផលមិនរង់ចាំកាល ជាធម៌មានអាការៈដូចជាហៅបុគ្គលដទៃឲ្យចូលមកមើលបាន ជាធម៌គួរ បង្អោនចូលមកទុកក្នុងខ្លួន ជាធម៌ដែលអ្នកប្រាជ្ញទាំងឡាយ គប្បីដឹងចំពោះ ខ្លួន អើហ្ន៎ ពួកជនដទៃគប្បីស្តាប់ធម៌របស់អាត្មាអញ លុះស្តាប់រួចហើយ

ជម្មំ អាជានេយ្យុំ អាជានិត្វា ច បន តថត្តាយ បដិបជ្ជេយ្យុន្តិ ឥតិ ជម្មសុជម្មតំ បដិច្ច បរេសំ ជម្មំ ទេសេតិ ការុញ្ញំ បដិច្ច បរេសំ ជម្មំ ទេសេតិ អនុទយំ បដិច្ច បរេសំ ជម្មំ ទេសេតិ អនុកម្បំ ឧចាទាយ បរេសំ ជម្មំ ទេសេតិ ។ កស្សបេន វា ហិ វោ ភិក្ខវេ ឱវទិស្សាមិ យោ វា បនស្ស កស្សបសទិសោ ឱវទិតេហិ ច បន វោ តថត្តាយ បដិបជ្ជិតព្វន្តិ ។

តតិយំ ។

[១៤២] សាវត្ថិយំ វិហរតិ... តំ កឹ មញ្ញថ ភិក្ខវេ កថំរូបោ ភិក្ខុ អរហតិ កុលូបកោ ហោតុំ កថំរូបោ ភិក្ខុ ន អរហតិ កុលូបកោ ហោតុន្តិ ។ ភគវំមូលកា នោ ភន្តេ ជម្មា ។ បេ ។

គប្បីដឹងច្បាស់នូវធម៌ លុះដឹងច្បាស់ហើយ គប្បីប្រតិបត្តិតាមបែបនោះ ហើយក៏សំដែងធម៌ដល់ពួកជនដទៃ កស្សបភិក្ខុ រមែងសំដែងធម៌ដល់ពួកជនដទៃ ព្រោះអាស្រ័យនូវភាវធម៌ជាធម៌ល្អ សំដែងធម៌ដល់ពួកជនដទៃ ព្រោះអាស្រ័យសេចក្តីករុណា សំដែងធម៌ដល់ពួកជនដទៃ ព្រោះអាស្រ័យសេចក្តីអាណិត សំដែងធម៌ដល់ពួកជនដទៃ ព្រោះអាស្រ័យសេចក្តីអនុគ្រោះ ដូចសំដែងមកនេះឯង ។ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងទូន្មានអ្នកទាំងឡាយ តាមបែបកស្សបភិក្ខុ ឬក៏តាមបែបភិក្ខុណាដែលប្រហែលនឹងកស្សបភិក្ខុ អ្នកទាំងឡាយ ដែលតថាគតទូន្មានហើយ គប្បីប្រតិបត្តិតាមបែបនោះចុះ ។ ចប់សូត្រទី ៣ ។

[១៤២] ព្រះមានព្រះភាគ គង់នៅទៀបក្រុងសាវត្ថី... ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់ហេតុនោះដូចម្តេច ភិក្ខុបែបណាគួរជាអ្នកចូលទៅកាន់ត្រកូលបាន ភិក្ខុបែបណាមិនគួរជាអ្នកចូលទៅកាន់ត្រកូលបាន ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយរបស់ពួកខ្ញុំព្រះអង្គ សឹងមានព្រះមានព្រះភាគជាឫស ។ បេ ។

[១៤៣] ភគវា ឯតទវោច យោ ហិ កោចិ ភិក្ខវេ ភិក្ខុ ឯវំចិត្តោ កុលានិ ឧបសង្កមតិ ទេន្តុយេវ មេ មា នាទំសុ ពហុកញ្ញេវ មេ ទេន្តុ មា ថោកំ បណីតញ្ញេវ មេ ទេន្តុ មា លូខំ សីឃញ្ញេវ មេ ទេន្តុ មា ទន្ធំ សក្កច្ចញ្ញេវ មេ ទេន្តុ មា អសក្កច្ចន្តិ ។ តស្ស ចេ ភិក្ខវេ ភិក្ខុនោ ឯវំចិត្តស្ស កុលានិ ឧបសង្កមតោ ន ទេន្តិ តេន ភិក្ខុ សន្ទិយតិ សោ តតោនិទានំ ទុក្ខំ ទោមនស្សំ បដិសំវេទយតិ ។ ថោកំ ទេន្តិ នោ ពហុកំ ។ បេ ។ លូខំ ទេន្តិ នោ បណីតំ ទន្ធំ ទេន្តិ នោ សីឃំ តេន ភិក្ខុ សន្ទិយតិ សោ តតោនិទានំ ទុក្ខំ ទោមនស្សំ បដិសំវេទយតិ ។ អសក្កច្ចំ ទេន្តិ នោ សក្កច្ចំ តេន ភិក្ខុ សន្ទិយតិ សោ តតោនិទានំ ទុក្ខំ ទោមនស្សំ បដិសំវេទយតិ ។ ឯវរូបោ ខោ ភិក្ខវេ ភិក្ខុ ន អរហតិ កុលូបកោ ហោតុំ ។

[១៤៣] ព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាមួយចូលទៅកាន់ត្រកូលដោយគិតថា ពួកជនចូរឲ្យតែអាត្មាអញ កុំមិនឲ្យដល់អាត្មាអញឡើយ ចូរឲ្យតែវត្ថុច្រើនដល់អាត្មាអញ កុំឲ្យនូវវត្ថុតិចឡើយ ចូរឲ្យតែវត្ថុថ្លៃថ្លាដល់អាត្មាអញ កុំឲ្យនូវវត្ថុសៅហ្មងឡើយ ចូរឲ្យដល់អាត្មាអញជាប្រញាប់ កុំឲ្យយឺតយូរឡើយ ចូរឲ្យដល់អាត្មាអញដោយការគោរព កុំឲ្យដោយសេចក្តីមិនគោរពឡើយ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះតាំងចិត្តយ៉ាងនេះហើយ ចូលទៅកាន់ត្រកូល ឯពួកជនក៏មិនបានឲ្យឡើយ ភិក្ខុក៏ឃ្នើសចិត្ត ព្រោះការមិនឲ្យនោះ ភិក្ខុនោះ ក៏ទទួលទុក្ខទោមនស្ស ព្រោះមានការមិនឲ្យនោះជាហេតុ ។ ពួកជនឲ្យវត្ថុតិច មិនឲ្យវត្ថុច្រើន ។ បេ ។ ឲ្យវត្ថុសៅហ្មង មិនឲ្យវត្ថុថ្លៃថ្លា ឲ្យយឺតយូរ មិនឲ្យប្រញាប់ប្រញាល់ ភិក្ខុក៏ឃ្នើសចិត្ត ព្រោះការឲ្យតិចជាដើមនោះ ភិក្ខុនោះ ក៏ទទួលទុក្ខទោមនស្ស ព្រោះមានការឲ្យតិចជាដើមនោះជាហេតុ ។ ពួកជនឲ្យដោយសេចក្តីមិនគោរព មិនឲ្យដោយសេចក្តីគោរព ភិក្ខុក៏ឃ្នើសចិត្ត ដោយការមិនគោរពនោះ ភិក្ខុនោះ ក៏ទទួលទុក្ខទោមនស្ស ព្រោះការមិនឲ្យដោយសេចក្តីគោរពនោះជាហេតុ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបែបនេះឯង មិនគួរដើម្បីជាអ្នកចូលទៅកាន់ត្រកូលទេ ។

កស្សបសំយុត្តស្ស ចតុត្ថសុត្តេ កុលូបកភាវោ

[១៤៤] យោ ច ខោ ភិក្ខវេ ភិក្ខុ ឯវំចិត្តោ កុ-លានិ ឧបសង្កមតិ តំ កុតេត្ថ លព្ភា បរកុលេសុ ទេន្តុយេវ មេ មា អទំសុ ពហុកញ្ញេវ មេ ទេន្តុ មា ថោកំ បណីតញ្ញេវ មេ ទេន្តុ មា លូខំ សីឃញ្ញេវ មេ ទេន្តុ មា ទន្ធំ សក្កច្ចញ្ញេវ មេ ទេន្តុ មា អសក្កច្ចន្តិ ។ តស្ស ចេ ភិក្ខវេ ភិក្ខុនោ ឯវំចិត្តស្ស កុលានិ ឧបសង្កមតោ ន ទេន្តិ តេន ភិក្ខុ ន សន្ទិយតិ សោ ន តតោនិទានំ ទុក្ខំ ទោមនស្សំ បដិសំវេទយតិ ។ ថោកំ ទេន្តិ នោ ពហុកំ តេន ភិក្ខុ ន សន្ទិយតិ សោ ន តតោនិទានំ ទុក្ខំ ទោមនស្សំ បដិសំវេទយតិ ។ លូខំ ទេន្តិ បណីតំ... ទន្ធំ ទេន្តិ នោ សីឃំ តេន ភិក្ខុ ន សន្ទិយតិ

[១៤៤] ម្នាលភិក្ខុទាំងឡាយ ភិក្ខុឯណា ចូលទៅកាន់ត្រកូល តាំងចិត្តយ៉ាងនេះថា អាត្មាអញគប្បីបានវត្ថុនោះអំពីណា ក្នុងពួកត្រកូលនៃបុគ្គលដទៃ ពួកជនដទៃចូរឲ្យដល់អាត្មាអញ កុំខានឲ្យឡើយ ចូរឲ្យតែវត្ថុដ៏ច្រើនមួយយ៉ាងដល់អាត្មាអញ កុំឲ្យវត្ថុតិចឡើយ ចូរឲ្យតែវត្ថុដ៏ថ្លៃថ្លាដល់អាត្មាអញ កុំឲ្យវត្ថុសៅហ្មងឡើយ ចូរឲ្យដល់អាត្មាអញជាប្រញាប់ កុំឲ្យយឺតយូរឡើយ ចូរឲ្យដល់អាត្មាអញដោយសេចក្ដីគោរព កុំឲ្យដោយសេចក្ដីមិនគោរពឡើយ ។ ម្នាលភិក្ខុទាំងឡាយ ថាបើភិក្ខុនោះចូលទៅកាន់ត្រកូលតាំងចិត្តយ៉ាងនេះហើយ (បើ) ពួកជនគេមិនឲ្យ ភិក្ខុក៏មិនឃ្លើសចិត្ត ព្រោះការមិនឲ្យនោះ ភិក្ខុនោះ ក៏មិនទទួលទុក្ខទោមនស្ស ព្រោះគេមិនឲ្យនោះជាហេតុឡើយ ។ ពួកជនឲ្យវត្ថុតិច មិនឲ្យវត្ថុច្រើន ភិក្ខុក៏មិនឃ្លើសចិត្ត ព្រោះការឲ្យតិចនោះឡើយ ភិក្ខុនោះ ក៏មិនទទួលទុក្ខទោមនស្ស ព្រោះការឲ្យតិចមិនឲ្យច្រើននោះជាហេតុឡើយ ។ ពួកជនឲ្យវត្ថុសៅហ្មង មិនឲ្យវត្ថុថ្លៃថ្លា... ពួកជនឲ្យយឺតយូរ មិនឲ្យប្រញាប់ប្រញាល់ ភិក្ខុក៏មិនឃ្លើសចិត្ត ព្រោះការមិនឲ្យប្រញាប់នោះ

សោ ច តតោនិទានំ ទុក្ខំ ទោមនស្សំ បដិសំវេទយតិ ។ អសក្កច្ចំ ទេន្តិ ជោ សក្កច្ចំ តេន ភិក្ខុ ច សន្តិយតិ សោ ច តតោនិទានំ ទុក្ខំ ទោមនស្សំ បដិសំវេទ-យតិ ។ ឯវរូបោ ខោ ភិក្ខវេ ភិក្ខុ អរហតិ កុលូបកោ ហោតុំ ។

[១៤៥] កស្សបោ ភិក្ខវេ ឯវំចិត្តោ កុលានិ ឧបសង្កមតិ តំ កុតេត្ថ លព្ភា បរកុលេសុ ទេន្តុយេវ មេ មា ជាទំសុ ពហុកញ្ញេវ មេ ទេន្តុ មា ថោកំ ។ បេ ។ ច ទេន្តិ តេន កស្សបោ ច សន្តិយតិ សោ ច តតោនិទានំ ទុក្ខំ ទោមនស្សំ បដិវេទយតិ ។ ថោកំ ទេន្តិ ជោ ពហុកំ តេន កស្សបោ ច សន្តិយតិ សោ ច តតោនិទានំ ទុក្ខំ ទោមនស្សំ បដិសំវេទយតិ ។ លូខំ ទេន្តិ ជោ បណីតំ តេន កស្សបោ ច សន្តិយតិ

ភិក្ខុនោះ ក៏មិនទទួលទុក្ខទោមនស្ស ព្រោះការឲ្យយឺតយូរ មិនឲ្យប្រញាប់ប្រញាល់នោះជាហេតុឡើយ ។ ពួកជនឲ្យដោយសេចក្តីមិនគោរព មិនឲ្យដោយសេចក្តីគោរព ភិក្ខុក៏មិនឃ្នើសចិត្ត ព្រោះការឲ្យដោយសេចក្តីមិនគោរពនោះ ភិក្ខុនោះ មិនទទួលទុក្ខទោមនស្ស ព្រោះគេឲ្យមិនគោរព មិនឲ្យដោយសេចក្តីគោរពនោះជាហេតុឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុយ៉ាងនេះឯង ទើបគួរដើម្បីចូលទៅកាន់ត្រកូលបាន ។

]១៤៥] ម្នាលភិក្ខុទាំងឡាយ កស្សបចូលទៅកាន់ត្រកូលតាំងចិត្តយ៉ាងនេះថា អាត្មាអញគប្បីបាននូវវត្ថុនោះអំពីណា ក្នុងពួកត្រកូលនៃបុគ្គលដទៃ ពួកជនដទៃ ចូរឲ្យដល់អាត្មាអញ កុំខានឲ្យឡើយ ចូរឲ្យតែវត្ថុច្រើនដល់អាត្មាអញ កុំឲ្យវត្ថុតិចឡើយ ។ បេ ។ បើពួកជនគេមិនឲ្យ កស្សបក៏មិនឃ្នើសចិត្ត ព្រោះគេមិនឲ្យនោះឡើយ កស្សបនោះ ក៏មិនទទួលទុក្ខទោមនស្ស ព្រោះគេមិនឲ្យនោះជាហេតុឡើយ ។ ពួកជនឲ្យវត្ថុតិច មិនឲ្យវត្ថុច្រើន កស្សបក៏មិនឃ្នើសចិត្ត ព្រោះគេមិនឲ្យវត្ថុច្រើននោះឡើយ កស្សបនោះ ក៏មិនទទួលទុក្ខទោមនស្ស ព្រោះគេឲ្យតិច មិនឲ្យច្រើននោះជាហេតុឡើយ ។ ពួកជនឲ្យវត្ថុសៅហ្មង មិនឲ្យវត្ថុថ្លៃថ្លា កស្សបក៏មិនឃ្នើសចិត្ត ព្រោះគេមិនឲ្យវត្ថុថ្លៃថ្លានោះឡើយ

សោ ន តតោនិទានំ ទុក្ខំ ទោមនស្សំ បដិសំវេទ-យតិ ។ ទន្ធំ ទេន្តិ នោ សីឃំ តេន កស្សបោ ន សន្ទិយតិ សោ ន តតោនិទានំ ទុក្ខំ ទោមនស្សំ បដិសំវេទយតិ ។ អសក្កច្ចំ ទេន្តិ នោ សក្កច្ចំ តេន កស្សបោ ន សន្ទិយតិ សោ ន តតោនិទានំ ទុក្ខំ ទោមនស្សំ បដិសំវេទយតិ ។ កស្សបេន វា ហិ វោ ភិក្ខវេ ឱវទិស្សាមិ យោ វា បនស្ស កស្សបាទិសោ ឱវទិតេហិ ច បន វោ តថត្តាយ បដិបជ្ជិតព្វន្តិ ។ ចតុត្ថំ ។

[១៤៦] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ ។ បេ ។ អថខោ អាយស្មា មហាកស្សបោ យេន ភគវា តេនុបសង្កមិ ឧបសង្ក-មិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។

កស្សបនោះ មិនទទួលទុក្ខទោមនស្ស ព្រោះគេឲ្យវត្ថុសៅហ្មង មិនឲ្យវត្ថុថ្លៃថ្លានោះជាហេតុឡើយ ។ ពួកជនឲ្យយឺតយូរ មិនឲ្យប្រញាប់ប្រញាល់ កស្សបក៏មិនឃ្នើសចិត្ត ព្រោះគេមិនឲ្យដោយប្រញាប់ប្រញាល់នោះឡើយ កស្សបនោះ មិនទទួលទុក្ខទោមនស្ស ព្រោះគេឲ្យយឺតយូរ មិនឲ្យប្រញាប់ប្រញាល់នោះជាហេតុឡើយ ។ ពួកជនឲ្យដោយសេចក្តីមិនគោរព មិនឲ្យដោយសេចក្តីគោរព កស្សបក៏មិនឃ្នើសចិត្ត ព្រោះគេឲ្យដោយសេចក្តីមិនគោរពនោះ កស្សបនោះ មិនទទួលទុក្ខទោមនស្ស ព្រោះគេឲ្យមិនគោរព មិនឲ្យដោយសេចក្តីគោរពនោះជាហេតុឡើយ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងទូន្មានអ្នកទាំងឡាយ តាមបែបកស្សប ឬក៏តាមបែបភិក្ខុណាដែលប្រហែលនឹងកស្សប អ្នកទាំងឡាយ ដែលតថាគតទូន្មានហើយ គប្បីប្រតិបត្តិតាមបែបនោះចុះ ។ ចប់សូត្រទី ៤ ។

[១៤៦] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវន ទៀបក្រុងរាជគ្រឹះ ។ បេ ។ គ្រានោះឯង ព្រះមហាកស្សបមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។

[១៤៧] ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ មហាកស្សបំ ភគវា ឯតទវោច ជិណ្ណាសិទានិ ត្វំ កស្សប គរុកានិ ច តេ ឥមានិ សាណានិ បំសុកូលានិ និព្វសនានិ តស្មាតិហ ត្វំ កស្សប គហបតានិ ចេវ ចីវរានិ ធារេហិ និមន្តនានិ ច ភុញ្ជាហិ មម សន្តិកេ វិហរាហីតិ ។ អហំ ខោ ភន្តេ ទីឃរត្តំ អារញ្ញិកោ ចេវ អារញ្ញិកត្តស្ស ច វណ្ណវាទី បិណ្ឌបាតិកោ ចេវ បិណ្ឌបាតិកត្តស្ស ច វណ្ណវាទី បំសុកូលិកោ ចេវ បំសុកូលិកត្តស្ស ច វណ្ណវាទី តេចីវរិកោ ចេវ តេចីវរិកត្តស្ស ច វណ្ណវាទី អប្បិច្ឆោ ចេវ អប្បិច្ឆតាយ ច វណ្ណវាទី សន្តុដ្ឋោ ចេវ សន្តុដ្ឋិយា ច វណ្ណវាទី បវិវិត្តោ ចេវ បវិវេកស្ស ច វណ្ណវាទី អសំសដ្ឋោ ចេវ អសំសគ្គស្ស ច វណ្ណវាទី អារទ្ធវីរិយោ ចេវ វីរិយារម្ភស្ស ច វណ្ណវាទីតិ ។

[១៤៧] លុះព្រះមហាកស្សបមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះថា ម្នាលកស្សប ឥឡូវនេះ អ្នកក៏កាន់តែចាស់ហើយ ទាំងសំពត់សំបកធ្មៃនេះរបស់អ្នកក៏ធ្ងន់ ជាសំពត់បង្សុកូលដែលតថាគតឈប់ស្លៀកដណ្តប់ ម្នាលកស្សប ហេតុដូច្នោះ អ្នកចូរស្លៀកដណ្តប់គហបតីចីវរ ចូរបរិភោគនិមន្តនភត្ត ចូរនៅជិតតថាគតចុះ ។ បពិត្រព្រះអង្គដ៏ចម្រើន យូរអង្វែងមកហើយ ខ្ញុំព្រះអង្គជាអ្នកប្រព្រឹត្តនៅក្នុងព្រៃផង ជាអ្នកពោលសរសើរគុណនៃការនៅក្នុងព្រៃផង ជាអ្នកប្រព្រឹត្តបិណ្ឌបាតផង ជាអ្នកពោលសរសើរគុណនៃការប្រព្រឹត្តបិណ្ឌបាតផង ជាអ្នកស្លៀកដណ្តប់សំពត់បង្សុកូលផង ជាអ្នកពោលសរសើរគុណនៃការស្លៀកដណ្តប់សំពត់បង្សុកូលផង ជាអ្នកទ្រទ្រង់ចីវរបីផង ជាអ្នកពោលសរសើរគុណនៃការទ្រទ្រង់ចីវរបីផង ជាអ្នកប្រាថ្នាតិចផង ជាអ្នកពោលសរសើរនៃសេចក្តីប្រាថ្នាតិចផង ជាអ្នកសន្តោសផង ជាអ្នកពោលសរសើរគុណនៃសេចក្តីសន្តោសផង ជាអ្នកស្ងប់ស្ងាត់ផង ជាអ្នកពោលសរសើរគុណនៃសេចក្តីស្ងប់ស្ងាត់ផង ជាអ្នកមិនច្រឡូកច្រឡំ (ដោយពួក) ផង ជាអ្នកពោលសរសើរគុណនៃការមិនច្រឡូកច្រឡំផង ជាអ្នកប្រារព្ធសេចក្តីព្យាយាមផង ជាអ្នកពោលសរសើរគុណនៃសេចក្តីប្រារព្ធព្យាយាមផង ។

កស្សបសំយុត្តស្ស បញ្ចមសុត្តេ អត្ថវសសម្បស្សនំ

[១៤៨] កិម្បន ត្វំ កស្សប អត្ថវសំ សម្បស្ស-
មានោ ទីឃរត្តំ អារញ្ញិកោ ចេវ អារញ្ញិកត្តស្ស ច
វណ្ណវាទី ។

(ឯវំ បេយ្យាលោ)

បិណ្ឌបាតិកោ ចេវ... បំសុកូលិកោ ចេវ... តេចីវរិ-
កោ ចេវ... អប្បិច្ឆោ ចេវ... សន្តុដ្ឋោ ចេវ... បវិវិត្តោ
ចេវ... អសំសដ្ឋោ ចេវ... អារទ្ធវិរិយោ ចេវ វិរិយារម្ភស្ស
ច វណ្ណវាទីតិ ។

[១៤៩] ទ្វេ ខ្វាហំ ភន្តេ អត្ថវសេ សម្បស្ស-
មានោ ទីឃរត្តំ អារញ្ញិកោ ចេវ អារញ្ញិកត្តស្ស ច
វណ្ណវាទី ។ បេ ។ បិណ្ឌបាតិកោ ចេវ... បំសុកូលិ-
កោ ចេវ... តេចីវរិកោ ចេវ... អប្បិច្ឆោ ចេវ... សន្តុដ្ឋោ
ចេវ... បវិវិត្តោ ចេវ... អសំសដ្ឋោ ចេវ... អារទ្ធវិរិយោ ចេវ

[១៤៨] ម្នាលកស្សប ចុះអ្នកឃើញអំណាចប្រយោជន៍ដូចម្តេច បានជាអ្នកប្រព្រឹត្តនៅក្នុងព្រៃ នឹងពោលសរសើរគុណនៃការនៅក្នុងព្រៃ អស់រាត្រីយូរអង្វែងម៉្លេះ ។

(បេយ្យាលៈ យ៉ាងនេះ)

ជាអ្នកប្រព្រឹត្តបិណ្ឌបាតផង... ជាអ្នកស្លៀកដណ្តប់សំពត់បង្សុកូលផង... ជាអ្នកទ្រទ្រង់ចីវរបីផង... ជាអ្នកប្រាថ្នាតិចផង... ជាអ្នកសន្តោសផង... ជាអ្នកស្ងប់ស្ងាត់ផង... ជាអ្នកមិនច្រឡូកច្រឡំផង... ជាអ្នកប្រារព្ធសេចក្តីព្យាយាមផង ពោលសរសើរគុណនៃការប្រារព្ធសេចក្តីព្យាយាមផង ។

[១៤៩] បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញអំណាចប្រយោជន៍ទាំងពីរ បានជាយូរអង្វែងមកហើយ ជាអ្នកប្រព្រឹត្តនៅក្នុងព្រៃផង ពោលសរសើរគុណនៃការនៅក្នុងព្រៃផង ។ បេ ។ ជាអ្នកប្រព្រឹត្តបិណ្ឌបាតផង... ជាអ្នកទ្រទ្រង់សំពត់បង្សុកូលផង... ជាអ្នកទ្រទ្រង់ចីវរបីផង... ជាអ្នកប្រាថ្នាតិចផង... ជាអ្នកសន្តោសផង... ជាអ្នកស្ងប់ស្ងាត់ផង... ជាអ្នកមិនច្រឡូកច្រឡំផង... ជាអ្នកប្រារព្ធសេចក្តីព្យាយាមផង

វីរិយារម្ភស្ស ច វណ្ណវាទី អត្តនោ ច ទិដ្ឋធម្មសុខវិហារំ សម្បស្សមានោ បច្ឆិមញ្ច ជនតំ អនុកម្បមានោ អប្បេវនាម បច្ឆិមា ជនតា ទិដ្ឋានុគតឹ អាបជ្ជេយ្យ យេ កិរ តេ អហេសុំ ពុទ្ធានុពុទ្ធសាវកា តេ ទីឃរត្តំ អារញ្ញិកា ចេវ អហេសុំ អារញ្ញិកត្តស្ស ច វណ្ណវាទិនោ ។ បេ ។ បិណ្ឌបាតិកា ចេវ អហេសុំ... បំសុកូលិកា ចេវ អហេសុំ... តេចីវរិកា ចេវ អហេសុំ... អប្បិច្ឆា ចេវ... អហេសុំ... សន្តុដ្ឋា ចេវ អហេសុំ... បវិវិត្តា ចេវ អហេសុំ... អសំសដ្ឋា ចេវ អហេសុំ... អារទ្ធវីរិយា ចេវ អហេសុំ វីរិយារម្ភស្ស ច វណ្ណវាទិនោតិ តេ តថត្តាយ បដិបជ្ជិស្សន្តិ តេសន្តំ ភវិស្សតិ ទីឃរត្តំ ហិតាយ សុខាយាតិ ឥមេ ខោ អហំ ភន្តេ ទ្វេ អត្ថវសេ សម្បស្សមានោ ទីឃរត្តំ អារញ្ញិកោ ចេវ អារញ្ញិកត្តស្ស ច វណ្ណវាទី បិណ្ឌបាតិកោ ចេវ... បំសុកូលិកោ ចេវ... តេចីវរិកោ ចេវ... អប្បិច្ឆោ ចេវ...

ពោលសរសើរគុណនៃការប្រារព្ធសេចក្តីព្យាយាមផង គឺឃើញនូវធម៌ជាគ្រឿងនៅជាសុខស្រួលក្នុងបច្ចុប្បន្នរបស់ខ្លួន ១ ជាអ្នកអនុគ្រោះប្រជុំជនខាងក្រោយ ១ ដោយគិតថា ធ្វើដូចម្តេចហ្ន៎ នឹងប្រជុំជនខាងក្រោយគប្បីយកតម្រាប់ផងបាន បានឮថា ព្រះពុទ្ធ និងសាវ័កជាអនុពុទ្ធ យូរអង្វែងមកហើយ ជាអ្នកប្រព្រឹត្តនៅក្នុងព្រៃផង ជាអ្នកពោលសរសើរគុណនៃការនៅក្នុងព្រៃផង ជាធម្មតា ។ បេ ។ ជាអ្នកប្រព្រឹត្តបិណ្ឌបាតផង... ជាអ្នកស្លៀកដណ្តប់សំពត់បង្សុកូលផង... ជាអ្នកស្ងប់ស្ងាត់ផង... ជាអ្នកមិនច្រឡូកច្រឡំផង... ជាអ្នកប្រារព្ធសេចក្តីព្យាយាមផង ពោលសរសើរគុណ នៃការប្រារព្ធសេចក្តីព្យាយាមផង ជនទាំងនោះ មុខជាប្រតិបត្តិដោយប្រការដូច្នោះ សេចក្តីប្រតិបត្តិនោះ នឹងបានជាប្រយោជន៍ និងមានសេចក្តីសុខដល់ជនទាំងនោះ អស់កាលយូរអង្វែង បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គប្រព្រឹត្តនៅក្នុងព្រៃផង ពោលសរសើរគុណនៃការនៅក្នុងព្រៃផង ជាអ្នកប្រព្រឹត្តបិណ្ឌបាតផង... ជាអ្នកស្លៀកដណ្តប់សំពត់បង្សុកូលផង... ជាអ្នកទ្រទ្រង់ចីវរបីផង... ជាអ្នកប្រាថ្នាតិចផង...

សន្តុដ្ឋោ ចេវ... បវិវិត្តោ ចេវ... អសំសដ្ឋោ ចេវ... អារទ្ធវិរិយោ ចេវ វិរិយារម្ភស្ស ច វណ្ណវាទីតិ ។

[១៨០] សាធុ សាធុ កស្សប ពហុជនហិតាយ កិរ ត្វំ កស្សប បដិបន្នោ ពហុជនសុខាយ លោកា-នុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ តស្មាតិហ ត្វំ កស្សប សាណានិ ចេវ បំសុកូលានិ ធារេហិ និព្វសនានិ បិណ្ឌាយ ចរាហិ អរញ្ញេ វិហ-រាហីតិ ។ បញ្ចមំ ។

[១៨១] រាជគហេ វិហរតិ វេឡុវនេ... អថខោ អាយស្មា មហាកស្សបោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ មហាកស្សបំ

ជាអ្នកសន្តោសផង... ជាអ្នកស្ងប់ស្ងាត់ផង... ជាអ្នកមិនច្រឡូកច្រឡំផង... ជាអ្នកប្រារព្ធសេចក្តីព្យាយាមផង ពោលសរសើរគុណនៃការប្រារព្ធសេចក្តីព្យាយាមផង ។

[១៥០] ម្នាលកស្សប ប្រពៃហើយ ៗ ម្នាលកស្សប ព្ធថា អ្នកប្រតិបត្តិដើម្បីជាប្រយោជន៍ដល់ជនច្រើន ដើម្បីជាសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ពួកទេវតានិងមនុស្ស ម្នាលកស្សប ហេតុដូច្នោះ អ្នកចូរទ្រទ្រង់សំពត់សម្បកធ្មៃ ជាសំពត់បង្សុកូលដែលតថាគតឈប់ស្លៀកដណ្តាប់ចុះ ចូរប្រព្រឹត្តបិណ្ឌបាតចុះ ចូរនៅក្នុងព្រៃចុះ ។ ចប់សូត្រទី ៥ ។

[១៥១] ទ្រង់គង់នៅក្នុងវត្តវេឡុវន ទៀបក្រុងរាជគ្រឹះ... គ្រានោះឯង ព្រះមហាកស្សបមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះព្រះមហាកស្សបមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ

ភគវា ឯតទវោច ឱវទ កស្សប ភិក្ខូ ករោហិ កស្សប ភិក្ខូនំ ធម្មឹ កថំ អហំ វា កស្សប ភិក្ខូ ឱវទេយ្យំ ត្វំ វា អហំ វា ភិក្ខូនំ ធម្មឹ កថំ ករេយ្យំ ត្វំ វាតិ ។

[១៨២] ទុព្វចា ខោ ភន្តេ ភគវា ឯតរហិ ភិក្ខូ ទោវចស្សករណេហិ ធម្មេហិ សមន្នាគតា អក្ខមា អប្បទក្ខិណគ្គាហិនោ អនុសាសនឹ ។ ឥធាហំ ភន្តេ អទ្ទសំ ភណ្ឌញ្ច នាម ភិក្ខុំ អានន្ទស្ស សទ្ធិវិហារឹ អាភិជ្ជិកញ្ច នាម ភិក្ខុំ អនុរុទ្ធស្ស សទ្ធិវិហារឹ អញ្ញមញ្ញំ សុតេន អច្ចាវទន្តេ ឯហិ ភិក្ខុ កោ ពហុតរំ ភាសិស្សតិ កោ សុន្ទរតរំ ភាសិស្សតិ កោ ចិរតរំ ភាសិស្សតីតិ ។

[១៨៣] អថខោ ភគវា អញ្ញតរំ ភិក្ខុំ អាមន្តេសិ ឯហិ ត្វំ ភិក្ខុ មម វចនេន ភណ្ឌញ្ច ភិក្ខុំ អាមន្តេសិ សទ្ធិវិហារឹ អាភិជ្ជិកញ្ច ភិក្ខុំ អនុរុទ្ធស្ស សទ្ធិវិហា-រឹ អាមន្តេហិ សត្ថា អាយស្មន្តេ អាមន្តេតីតិ ។ ឯវំ ភន្តេតិ ខោ សោ ភិក្ខុ ភគវតោ បដិស្សុណិត្វា

ទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលកស្សប អ្នកចូរទូន្មានភិក្ខុទាំងឡាយ ម្នាលកស្សប អ្នកចូរធ្វើធម្មីកថាដល់ភិក្ខុទាំងឡាយចុះ ម្នាលកស្សប តថាគត ឬអ្នក ត្រូវទូន្មានពួកភិក្ខុ តថាគត ឬអ្នក ត្រូវធ្វើធម្មីកថាដល់ពួកភិក្ខុ ។

[១៥២] បពិត្រព្រះមានព្រះភាគ ឥឡូវនេះ ពួកភិក្ខុសុទ្ធតែជាអ្នកប្រដៅក្រ ប្រកបដោយធម៌ដែលធ្វើឲ្យជាអ្នកប្រដៅក្រ ជាអ្នកមិនអត់សង្កត់ មិនកាន់យកពាក្យប្រដៅដោយចំណែកស្តាំឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះ ខ្ញុំព្រះអង្គបានឃើញភិក្ខុឈ្មោះភណ្ឌៈជាសទ្ធិវិហារិករបស់អានន្ទ ១ ភិក្ខុឈ្មោះអាភិជ្ជិកៈជាសទ្ធិវិហារិករបស់អនុរុទ្ធ ១ កំពុងតែនិយាយជជែកគ្នាដោយពុទ្ធវចនៈថា ម្នាលភិក្ខុ អ្នកចូរមក អ្នកណានឹងពោលពុទ្ធវចនៈបានច្រើនជាង អ្នកណានឹងពោលពុទ្ធវចនៈពីរោះជាង អ្នកណានឹងពោលពុទ្ធវចនៈបានយូរជាង ។

[១៥៣] គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុ ១ រូបមកថា ម្នាលភិក្ខុ អ្នកចូរមក អ្នកចូរទៅហៅភណ្ឌភិក្ខុជាសទ្ធិវិហារិករបស់អានន្ទ ១ អាភិជ្ជិកភិក្ខុជាសទ្ធិវិហារិករបស់អនុរុទ្ធ ១ តាមពាក្យតថាគតថា ព្រះសាស្តាត្រាស់ហៅលោកមានអាយុទាំងឡាយ ។ ភិក្ខុនោះ ទទួលព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ

យេន តេ ភិក្ខូ តេនុបសង្កមិ ឧបសង្កមិត្វា តេ ភិក្ខូ ឯតទវោច សត្ថា អាយស្មន្តេ អាមន្តេតីតិ ។ ឯវមា-វុសោតិ ខោ តេ ភិក្ខូ តស្ស ភិក្ខុនោ បដិស្សុណិត្វា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។

[១៥៤] ឯកមន្តំ និសិន្នេ ខោ តេ ភិក្ខូ ភគវា ឯតទវោច សច្ចំ កិរ តុម្ហេ ភិក្ខវេ អញ្ញមញ្ញំ សុតេន អច្ចាវទថ ឯហិ ភិក្ខុ កោ ពហុតរំ ភាសិស្សតិ កោ សុន្ទរតរំ ភាសិស្សតិ កោ ចិរតរំ ភាសិស្សតិ ។ ឯវំ ភន្តេតិ ។ កិន្នុ[1] មេ តុម្ហេ ភិក្ខវេ ឯវំ ធម្មំ ទេសិតំ អាជានាថ ឯវំ តុម្ហេ ភិក្ខវេ អញ្ញមញ្ញំ សុតេន អច្ចាវទថ ឯហិ ភិក្ខុ កោ ពហុតរំ ភាសិស្សតិ កោ សុន្ទរតរំ ភាសិស្សតិ កោ ចិរតរំ ភាសិស្សតិ ។ នោ ហេតំ ភន្តេ ។ នោ ចេ កិរ មេ តុម្ហេ ភិក្ខវេ

១ ឱ. កិន្នុ ខោ ។

ហើយក៏ចូលទៅរកភិក្ខុទាំងនោះ លុះចូលទៅដល់ហើយ បានពោលនឹងភិក្ខុទាំងនោះដូច្នេះថា ព្រះសាស្តាទ្រង់ត្រាស់ហៅលោកមានអាយុទាំងឡាយ ។ ភិក្ខុទាំងនោះក៏ទទួលពាក្យភិក្ខុនោះថា អើលោកដ៏មានអាយុ ហើយក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។

[១៥២] លុះភិក្ខុទាំងនោះ អង្គុយក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ បានឮថា អ្នកទាំងឡាយ និយាយជជែកគ្នាដោយពុទ្ធវចនៈថា ម្នាលភិក្ខុ អ្នកចូរមក អ្នកណានឹងពោលពុទ្ធវចនៈបានច្រើនជាង អ្នកណានឹងពោលពុទ្ធវចនៈពីរោះជាង អ្នកណានឹងពោលពុទ្ធវចនៈបានយូរជាង ពិតមែនឬ ។ សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ដឹងធម៌ដែលតថាគតសំដែងហើយយ៉ាងនេះឬហ្ន៎ ម្នាលភិក្ខុទាំងឡាយ បានជាអ្នកទាំងឡាយ ហ៊ាននិយាយជជែកគ្នា ដោយពុទ្ធវចនៈយ៉ាងនេះថា ម្នាលភិក្ខុ អ្នកចូរមក អ្នកណានឹងពោលពុទ្ធវចនៈបានច្រើនជាង អ្នកណានឹងពោលពុទ្ធវចនៈពីរោះជាង អ្នកណានឹងពោលពុទ្ធវចនៈបានយូរជាង ។ សូមទ្រង់ព្រះមេត្តាប្រោស មិនបានដឹងដូច្នោះទេ ។ ម្នាលភិក្ខុទាំងឡាយ បានឮថា បើអ្នកទាំងឡាយ មិន

ឯវំ ធម្មំ ទេសិតំ អាជានាថ អថ កិញ្ចរហិ តុម្ហេ មោឃបុរិសា កឹ ជានន្តា កឹ បស្សន្តា ឯវំ ស្វាក្ខាតេ ធម្មវិនយេ បព្វជិតា សមានា អញ្ញមញ្ញំ សុតេន អច្ចាវទេថ ឯហិ ភិក្ខុ កោ ពហុតរំ ភាសិស្សតិ កោ សុន្ទរតរំ ភាសិស្សតិ កោ ចិរតរំ ភាសិស្សតីតិ ។

[១៥៥] អថខោ តេ ភិក្ខូ ភគវតោ បាទេសុ សិរសា និបតិត្វា ភគវន្តំ ឯតទវោចុំ អច្ចយោ នោ ភន្តេ អច្ចគមា យថាពាលេ យថាមូឡ្ហេ យថា អកុសលេ យេ មយំ ឯវំ ស្វាក្ខាតេ ធម្មវិនយេ បព្វជិតា សមានា អញ្ញមញ្ញំ សុតេន អច្ចាវទិម្ហា ឯហិ ភិក្ខុ កោ ពហុតរំ ភាសិស្សតិ កោ សុន្ទរតរំ ភាសិស្សតិ កោ ចិរតរំ ភាសិស្សតីតិ តេសំ នោ ភន្តេ ភគវា អច្ចយំ អច្ចយតោ បដិគ្គណ្ហាតុ អាយតឹ សំវរាយាតិ ។

ដឹងធម៌ដែលតថាគតសំដែងយ៉ាងនេះទេ ចុះអ្នកទាំងឡាយជាមោឃបុរស ដឹងដូចម្តេច ឃើញដូចម្តេច បានជាមកបួសក្នុងធម្មវិន័យដែលតថាគត សំដែងទុកដោយប្រពៃយ៉ាងនេះ ហើយនិយាយជជែកគ្នាដោយពុទ្ធវចនៈ ថា ម្នាលភិក្ខុ អ្នកចូរមក អ្នកណានឹងពោលពុទ្ធវចនៈបានច្រើនជាង អ្នកណានឹងពោលពុទ្ធវចនៈពីរោះជាង អ្នកណានឹងពោលពុទ្ធវចនៈបាន យូរជាង ។

[១៥៥] គ្រានោះឯង ភិក្ខុទាំងនោះ ក៏ក្រាបចុះដោយសិរសា ទៀបបាទាព្រះមានព្រះភាគ ក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះ ថា បពិត្រព្រះអង្គដ៏ចម្រើន ទោសខុសគ្របសង្កត់នូវខ្ញុំព្រះអង្គទាំងឡាយ តាមដោយខ្ញុំព្រះអង្គទាំងឡាយជាមនុស្សពាល ជាមនុស្សវង្វេង ជា មនុស្សមិនឈ្លាស ព្រោះថា ខ្ញុំព្រះអង្គទាំងឡាយបានបួសក្នុងធម្មវិន័យ ដែលព្រះមានព្រះភាគសំដែងទុកដោយប្រពៃយ៉ាងនេះ ហើយនិយាយ ជជែកគ្នាដោយពុទ្ធវចនៈថា ម្នាលភិក្ខុ អ្នកចូរមក អ្នកណានឹងពោល ពុទ្ធវចនៈបានច្រើនជាង អ្នកណានឹងពោលពុទ្ធវចនៈពីរោះជាង អ្នក ណានឹងពោលពុទ្ធវចនៈបានយូរជាង បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះ ដ៏មានបុណ្យអត់ទោស តាមទោស ដល់យើងខ្ញុំព្រះអង្គ ដើម្បីនឹង បានសង្រួមតទៅ ។

កស្សបសំយុត្តស្ស ឆដ្ឋសុត្តេ អច្ចយប្បដិគ្គហណំ

[១៨៦] តគ្ឃ តុម្ហេ ភិក្ខវេ អច្ចយោ អច្ចគមា យថាពាលេ យថាមូឡ្ហេ យថា អកុសលេ យេ តុម្ហេ ឯវំ ស្វាក្ខាតេ ធម្មវិនយេ បព្វជិតា សមានា អញ្ញមញ្ញំ សុតេន អច្ចាវទថ ឯកហិ ភិក្ខុ កោ ពហុតរំ ភាសិស្សតិ កោ សុន្ទរតរំ ភាសិស្សតិ កោ ចិរតរំ ភាសិស្សតីតិ យតោ ច ខោ តុម្ហេ ភិក្ខវេ អច្ចយំ អច្ចយតោ ទិស្វា យថាធម្មំ បដិករោថ តំ វោ មយំ អច្ចយំ បដិគ្គណ្ហាម វុឌ្ឍិហេសា ភិក្ខវេ អរិយស្ស វិនយេ យោ អច្ចយំ អច្ចយតោ ទិស្វា យថាធម្មំ បដិករោតិ អាយតឹ ច សំវរំ អាបជ្ជតីតិ ។ ឆដ្ឋំ ។

កស្សបសំយុត្ត ឆដ្ឋសូត្រ ការទ្រង់ទទួលអត់ទោស

[១៥៦] ម្នាលភិក្ខុទាំងឡាយ បើយ៉ាងហ្នឹងហើយ ទោសខុសក៏គ្របសង្កត់នូវអ្នកទាំងឡាយ តាមដែលអ្នកទាំងឡាយជាមនុស្សពាល ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស ព្រោះថា អ្នកទាំងឡាយ បានបួសក្នុងធម្មវិន័យ ដែលតថាគតពោលទុកប្រពៃយ៉ាងនេះ ហើយនិយាយជជែកគ្នាដោយពុទ្ធវចនៈថា ម្នាលភិក្ខុ អ្នកចូរមក អ្នកណានឹងពោលទុកវចនៈបានច្រើនជាង អ្នកណានឹងពោលពុទ្ធវចនៈពីរោះជាង អ្នកណានឹងពោលពុទ្ធវចនៈបានយូរជាង ម្នាលភិក្ខុទាំងឡាយ កាលណាបើអ្នកទាំងឡាយឃើញទោសតាមទោសហើយ ធ្វើឲ្យសមតាមធម៌ គឺសំដែងអាបត្តិចេញ ទើបតថាគតអត់ទោសនោះ ដល់អ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ បុគ្គលណាឃើញទោសតាមទោស (របស់ខ្លួន) ហើយធ្វើឲ្យសមតាមធម៌ គឺសំដែងអាបត្តិចេញផង ដល់នូវការសង្រួមតទៅផង នេះជាសេចក្ដីចម្រើនរបស់បុគ្គលនោះ ក្នុងវិន័យរបស់ព្រះអរិយបុគ្គលបាន ។ ចប់សូត្រទី ៦ ។

[១៨៧] រាជគហេ វិហរតិ វេឡុវនេ... អថខោ អាយស្មា មហាកស្សបោ យេន ភគវា តេនុបសង្កមិ... ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ មហាកស្សបំ ភគវា ឯតទវោច ឱវទ កស្សប ភិក្ខូ ករោហិ កស្សប ភិក្ខូនំ ធម្មឹ កថំ អហំ វា កស្សប ភិក្ខូ ឱវទេយ្យំ ត្វំ វា អហំ វា ភិក្ខូនំ ធម្មឹ កថំ ករេយ្យំ ត្វំ វាតិ ។

[១៨៨] ទុព្វចា ខោ ភន្តេ ភគវា ឯតរហិ ភិក្ខូ ទោវចស្សករណេហិ ធម្មេហិ សមន្នាគតា អក្ខ-មា អប្បទក្ខិណគ្គាហិនោ អនុសាសនឹ ។ យស្ស កស្សចិ ភន្តេ សទ្ធា នត្ថិ កុសលេសុ ធម្មេសុ ហិរិ នត្ថិ កុសលេសុ ធម្មេសុ ឱត្តប្បំ នត្ថិ កុស-លេសុ ធម្មេសុ វីរិយំ នត្ថិ កុសលេសុ ធម្មេសុ បញ្ញា នត្ថិ កុសលេសុ ធម្មេសុ តស្ស យា រត្តិ

[១៥៧] ព្រះមានព្រះភាគ ទ្រង់គង់នៅវត្តវេឡុវន ទៀបក្រុងរាជគ្រឹះ... គ្រានោះឯង ព្រះមហាកស្សបមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ... លុះព្រះមហាកស្សបមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ទើបព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះថា ម្នាលកស្សប អ្នកចូរទូន្មានពួកភិក្ខុ ម្នាលកស្សប អ្នកចូរធ្វើធម្មីកថាដល់ពួកភិក្ខុ ម្នាលកស្សប តថាគត ឬអ្នក គប្បីទូន្មានពួកភិក្ខុ តថាគត ឬអ្នក គប្បីធ្វើធម្មីកថាដល់ពួកភិក្ខុ ។

[១៥៨] បពិត្រព្រះមានព្រះភាគដ៏ចម្រើន ឥឡូវនេះ ពួកភិក្ខុសុទ្ធតែជាអ្នកប្រដៅក្រ ជាអ្នកប្រកបដោយធម៌ដែលធ្វើឲ្យជាអ្នកប្រដៅក្រ ជាអ្នកមិនអត់សង្កត់ មិនកាន់យកពាក្យប្រដៅដោយចំណែកស្តាំឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលណាមួយមិនមានសទ្ធាក្នុងកុសលធម៌ មិនមានហិរិក្នុងកុសលធម៌ មិនមានឱត្តប្បៈក្នុងកុសលធម៌ មិនមានវីរិយៈក្នុងកុសលធម៌ មិនមានបញ្ញាក្នុងកុសលធម៌ វេលាយប់

១៣៩

កស្សបសំយុត្តស្ស សត្តមសុត្តេ បរិហានភាវោ

វា ទិវសោ វា អាគច្ឆតិ ហានិយេវ បាដិកង្ខា កុសលេសុ ធម្មេសុ នោ វុឌ្ឍិ ។ សេយ្យថាបិ ភន្តេ កាឡបក្ខេ ចន្ទស្ស យា រត្តិ វា ទិវសោ វា អាគច្ឆតិ ហាយតេវ ច វណ្ណេន ហាយតិ មណ្ឌលេន ហាយតិ អាភាយ ហាយតិ អារោហបរិណាហេន ឯវមេវ ខោ ភន្តេ យស្ស កស្សចិ សទ្ធា នត្ថិ កុសលេសុ ធម្មេសុ ហិរិ នត្ថិ... ឱត្តប្បំ នត្ថិ... វីរិយំ នត្ថិ... បញ្ញា នត្ថិ កុសលេសុ ធម្មេសុ តស្ស យា រត្តិ វា ទិវសោ វា អាគច្ឆតិ ហានិយេវ បាដិកង្ខា កុសលេសុ ធម្មេសុ នោ វុឌ្ឍិ ។ អស្ស-ទ្ធោ ខោ បុរិសបុគ្គលោតិ ភន្តេ បរិហានមេតំ អហិរិកោ បុរិសបុគ្គលោតិ ភន្តេ បរិហានមេតំ អនោត្តាបី បុរិស-បុគ្គលោតិ ភន្តេ បរិហានមេតំ កុសីតោ បុរិសបុគ្គលោតិ ភន្តេ បរិហានមេតំ ទុប្បញ្ញោ បុរិសបុគ្គលោតិ ភន្តេ

ឬថ្ងៃរបស់បុគ្គលនោះមកដល់ហើយ ក៏មានតែសេចក្ដីសាបសូន្យប្រាកដក្នុងកុសលធម៌ ឥតមានសេចក្ដីចម្រើនឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន យប់ឬថ្ងៃរបស់ព្រះចន្ទ ក្នុងកាឡបក្ខតែងមកដល់ (ព្រះចន្ទក្នុងកាឡបក្ខនោះ) ក៏ចេះតែសាបសូន្យចាកទ្រង់ទ្រាយ សូន្យចាកមណ្ឌល សូន្យចាកពន្លឺ សូន្យចាកកំពស់និងទំហំ យ៉ាងណា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលណាមួយ មិនមានសទ្ធាក្នុងកុសលធម៌ មិនមានហិរិ... មិនមានឱត្តប្ប... មិនមានវិរិយ... មិនមានបញ្ញាក្នុងកុសលធម៌ វេលាយប់ឬថ្ងៃរបស់បុគ្គលនោះមកដល់ហើយ ក៏មានតែសេចក្ដីសាបសូន្យប្រាកដក្នុងកុសលធម៌ ឥតមានសេចក្ដីចម្រើនឡើយ យ៉ាងនោះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន ត្រង់ពាក្យថា បុរសបុគ្គលមិនមានសទ្ធា នេះជាសេចក្ដីសាបសូន្យ ១ បពិត្រព្រះអង្គដ៏ចម្រើន ត្រង់ពាក្យថា បុរសបុគ្គលមិនមានហិរិ នេះជាសេចក្ដីសាបសូន្យ ១ បពិត្រព្រះអង្គដ៏ចម្រើន ត្រង់ពាក្យថា បុរសបុគ្គលមិនមានឱត្តប្បៈ នេះជាសេចក្ដីសាបសូន្យ ១ បពិត្រព្រះអង្គដ៏ចម្រើន ត្រង់ពាក្យថា បុរសបុគ្គលខ្ជិលច្រអូស នេះជាសេចក្ដីសាបសូន្យ ១ បពិត្រព្រះអង្គដ៏ចម្រើន ត្រង់ពាក្យថា បុរសបុគ្គលមិនមានបញ្ញា

បរិហានមេតំ កោធនោ បុរិសបុគ្គលោតិ ភន្តេ បរិហានមេតំ ឧបនាហី បុរិសបុគ្គលោតិ ភន្តេ បរិហានមេតំ ន សន្តិ ភិក្ខូ ឱវាទកាតិ ភន្តេ បរិហានមេតំ ។

[១៨៩] យស្ស កស្សចិ ភន្តេ សទ្ធា អត្ថិ កុសលេសុ ធម្មេសុ ហិរិ អត្ថិ កុសលេសុ ធម្មេសុ ឱត្តប្បំ អត្ថិ កុសលេសុ ធម្មេសុ វីរិយំ អត្ថិ កុសលេសុ ធម្មេសុ បញ្ញា អត្ថិ កុសលេសុ ធម្មេសុ តស្ស យា រត្តិ វា ទិវសោ វា អាគច្ឆតិ វុឌ្ឍិយេវ បាដិកង្ខា កុសលេសុ ធម្មេសុ នោ បរិហានិ ។ សេយ្យថាបិ ភន្តេ ជុណ្ហបក្ខេ ចន្ទស្ស យា រត្តិ វា ទិវសោ វា អាគច្ឆតិ វឌ្ឍតេវ ច វណ្ណេន វឌ្ឍតិ មណ្ឌលេន វឌ្ឍតិ អាភាយ វឌ្ឍតិ អារោហបរិណាហេន ឯវមេវ ខោ ភន្តេ យស្ស កស្សចិ សទ្ធា អត្ថិ កុសលេសុ ធម្មេសុ ហិរិ អត្ថិ... ឱត្តប្បំ អត្ថិ... វីរិយំ អត្ថិ... បញ្ញា អត្ថិ កុសលេសុ ធម្មេសុ តស្ស យា រត្តិ វា ទិវសោ វា អាគច្ឆតិ វុឌ្ឍិយេវ បាដិកង្ខា កុសលេសុ ធម្មេសុ

នេះជាសេចក្តីសាបសូន្យ ១ បពិត្រព្រះអង្គដ៏ចម្រើន ត្រង់ពាក្យថា បុរសបុគ្គលមានសេចក្តីក្រោធ នេះជាសេចក្តីសាបសូន្យ ១ បពិត្រព្រះអង្គដ៏ចម្រើន ត្រង់ពាក្យថា បុរសបុគ្គលមានការចងគំនុំ នេះជាសេចក្តីសាបសូន្យ ១ បពិត្រព្រះអង្គដ៏ចម្រើន ត្រង់ពាក្យថា មិនមានពួកភិក្ខុជាអ្នកទូន្មាន នេះជាសេចក្តីសាបសូន្យ ១ ។

[១៥៩] បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលណាមួយមានសទ្ធាក្នុងកុសលធម៌ មានហិរិក្នុងកុសលធម៌ មានឱត្តប្បៈក្នុងកុសលធម៌ មានវិរិយៈក្នុងកុសលធម៌ មានបញ្ញាក្នុងកុសលធម៌ យប់ឬថ្ងៃរបស់បុគ្គលនោះមកដល់ហើយ ក៏មានតែសេចក្តីចម្រើនប្រាកដក្នុងកុសលធម៌ មិនសាបសូន្យឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន យប់ឬថ្ងៃរបស់ព្រះចន្ទក្នុងជុណ្ហបក្ខគឺខាងខ្នើតមកដល់ (ព្រះចន្ទនោះ) តែងចម្រើនដោយទ្រង់ទ្រាយចម្រើនដោយមណ្ឌល ចម្រើនដោយពន្លឺ ចម្រើនដោយកំពស់និងទំហំ យ៉ាងណា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលណាមួយមានសទ្ធាក្នុងកុសលធម៌ មានហិរិ... មានឱត្តប្បៈ... មានវិរិយៈ... មានបញ្ញាក្នុងកុសលធម៌ យប់ឬថ្ងៃនៃបុគ្គលនោះមកដល់ សេចក្តីចម្រើនក៏ប្រាកដក្នុងកុសលធម៌ទាំងឡាយ

១៤១



នោ បរិហានិ ។ សទ្ធោ បុរិសបុគ្គលោតិ ភន្តេ អបរិហានមេតំ ហិរិមា បុរិសបុគ្គលោតិ ភន្តេ អបរិហានមេតំ ឱត្តាបី បុរិសបុគ្គលោតិ ភន្តេ អបរិហានមេតំ អារទ្ធវីរិយោ បុរិសបុគ្គលោតិ ភន្តេ អបរិហានមេតំ បញ្ញវា បុរិសបុគ្គលោតិ ភន្តេ អបរិហានមេតំ អកោធនោ បុរិសបុគ្គលោតិ ភន្តេ អបរិហានមេតំ អនុបនាហី បុរិសបុគ្គលោតិ ភន្តេ អបរិហានមេតំ សន្តិ ភិក្ខូ ឱវាទកាតិ ភន្តេ អបរិហានមេតន្តិ ។

មិនសាបសូន្យឡើយ យ៉ាងនោះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន ត្រង់ពាក្យថា បុរសបុគ្គលមានសទ្ធា នេះជាសេចក្តីមិនសាបសូន្យ ១ បពិត្រព្រះអង្គដ៏ចម្រើន ត្រង់ពាក្យថា បុរសបុគ្គលមានហិរិ នេះជាសេចក្តីមិនសាបសូន្យ ១ បពិត្រព្រះអង្គដ៏ចម្រើន ត្រង់ពាក្យថា បុរសបុគ្គលមានឱត្តប្បៈ នេះជាសេចក្តីមិនសាបសូន្យ ១ បពិត្រព្រះអង្គដ៏ចម្រើន ត្រង់ពាក្យថា បុរសបុគ្គលមានវីរិយៈប្រារព្ធហើយ នេះជាសេចក្តីមិនសាបសូន្យ ១ បពិត្រព្រះអង្គដ៏ចម្រើន ត្រង់ពាក្យថា បុរសបុគ្គលមានបញ្ញា នេះជាសេចក្តីមិនសាបសូន្យ ១ បពិត្រព្រះអង្គដ៏ចម្រើន ត្រង់ពាក្យថា បុរសបុគ្គលមិនមានសេចក្តីក្រោធ នេះជាសេចក្តីមិនសាបសូន្យ ១ បពិត្រព្រះអង្គដ៏ចម្រើន ត្រង់ពាក្យថា បុរសបុគ្គលមិនមានការចងគំនុំ នេះជាសេចក្តីមិនសាបសូន្យ ១ បពិត្រព្រះអង្គដ៏ចម្រើន ត្រង់ពាក្យថា មានពួកភិក្ខុជាអ្នកទូន្មាន នេះជាសេចក្តីមិនសាបសូន្យ ១ ។

[១៦០] សាធុ សាធុ កស្សប យស្ស កស្សបចិ សទ្ធា នត្ថិ កុសលេសុ ធម្មេសុ ហិរិ នត្ថិ... ឱត្តប្បំ នត្ថិ... វីរិយំ នត្ថិ... បញ្ញា នត្ថិ កុសលេសុ ធម្មេសុ តស្ស យា រត្តិំ វា ទិវសោ វា អាគច្ឆតិ ហានិយេវ បាដិកង្ខា កុសលេសុ ធម្មេសុ នោ វុឌ្ឍិ ។ សេយ្យថាបិ កស្សប កាឡបក្ខេ ចន្ទស្ស យា រត្តិ វា ទិវសោ វា អាគច្ឆតិ ហាយតេវ ច វណ្ណេន ហាយតិ មណ្ឌលេន ហាយតិ អាភាយ ហាយតិ អារោហបរិណាហេន ឯវមេវ ខោ កស្សប យស្ស កស្សចិ សទ្ធា នត្ថិ កុសលេសុ ធម្មេសុ ហិរិ នត្ថិ... ឱត្តប្បំ នត្ថិ... វីរិយំ នត្ថិ... បញ្ញា នត្ថិ កុសលេសុ ធម្មេសុ តស្ស យា រត្តិ វា ទិវសោ វា អាគច្ឆតិ

[១៦០] ម្នាលកស្សប ត្រូវណាស់ហើយ ៗ បុគ្គលណាមួយមិនមានសទ្ធា ក្នុងកុសលធម៌ទាំងឡាយ មិនមានហិរិ... មិនមានឱត្តប្បៈ... មិនមានវីរិយៈ... មិនមានបញ្ញា ក្នុងកុសលធម៌ទាំងឡាយ យប់ឬថ្ងៃនៃបុគ្គលនោះមកដល់ សេចក្តីសាបសូន្យក៏ប្រាកដក្នុងកុសលធម៌ទាំងឡាយ មិនមានសេចក្តីចម្រើនឡើយ ។ ម្នាលកស្សប យប់ឬថ្ងៃនៃព្រះចន្ទក្នុងចំណែករនោចមកដល់ (ព្រះចន្ទនោះ) តែងសាបសូន្យចាកទ្រង់ទ្រាយ សាបសូន្យចាកមណ្ឌល សាបសូន្យចាកពន្លឺ សាបសូន្យចាកកំពស់ និងទំហំ យ៉ាងណា ម្នាលកស្សប បុគ្គលណាមួយមិនមានសទ្ធា ក្នុងកុសលធម៌ទាំងឡាយ មិនមានហិរិ... មិនមានឱត្តប្បៈ... មិនមានវីរិយៈ... មិនមានបញ្ញា ក្នុងកុសលធម៌ទាំងឡាយ យប់ឬថ្ងៃនៃបុគ្គលនោះមកដល់

ហានិយេវ ចាដិកង្ខា កុសលេសុ ធម្មេសុ នោ វុឌ្ឍិ ។ អស្សទ្ធោ បុរិសបុគ្គលោតិ កស្សប បរិហានមេតំ អហិរិកោ ។ បេ ។ អនោត្តាបី ។ បេ ។ កុសីតោ ។ បេ ។ ទុប្បញ្ញោ ។ បេ ។ កោធនោ ។ បេ ។ ឧបនាហី បុរិសបុគ្គលោតិ កស្សប បរិហានមេតំ ន សន្តិ ភិក្ខូ ឱវាទកាតិ កស្សប បរិហានមេតំ ។

[១៦១] យស្ស កស្សចិ កស្សប សទ្ធា អត្ថិ កុសលេសុ ធម្មេសុ ហិរិ អត្ថិ... ឱត្តប្បំ អត្ថិ... វីរិយំ អត្ថិ... បញ្ញា អត្ថិ កុសលេសុ ធម្មេសុ តស្ស យា រត្តិ វា ទិវសោ វា អាគច្ឆតិ វុឌ្ឍិយេវ ចាដិកង្ខា កុសលេសុ ធម្មេសុ នោ បរិហានិ ។ សេយ្យថាបិ កស្សប ជណ្ហាបក្ខេ ចន្ទស្ស យា រត្តិ វា ទិវសោ វា អាគច្ឆតិ វឌ្ឍតេវ វណ្ណេន វឌ្ឍតិ មណ្ឌលេន វឌ្ឍតិ អាភាយ វឌ្ឍតិ អារោហបរិណាហេន ឯវមេវ ខោ កស្សប យស្ស កស្សចិ សទ្ធា អត្ថិ កុសលេសុ ធម្មេសុ ហិរិ អត្ថិ... ឱត្តប្បំ អត្ថិ... វីរិយំ អត្ថិ... បញ្ញា អត្ថិ កុសលេសុ ធម្មេសុ តស្ស យា រត្តិ វា ទិវសោ វា

សេចក្តីសាបសូន្យក៏ប្រាកដក្នុងកុសលធម៌ទាំងឡាយ មិនមានសេចក្តីចម្រើនឡើយ យ៉ាងនេះឯង ។ ម្នាលកស្សប ត្រង់ពាក្យថា បុរសបុគ្គលមិនមានសទ្ធា នេះជាសេចក្តីសាបសូន្យ ១ ។ បេ ។ មិនមានហិរិ ។ បេ ។ មិនមានឱត្តប្បៈ ។ បេ ។ ជាអ្នកខ្ជិលច្រអូស ។ បេ ។ មិនមានបញ្ញា ។ បេ ។ មានសេចក្តីក្រោធ ។ បេ ។ ម្នាលកស្សប ត្រង់ពាក្យថា បុរសបុគ្គលជាអ្នកមានការចងគំនុំ នេះជាសេចក្តីសាបសូន្យ ១ ម្នាលកស្សប ត្រង់ពាក្យថា មិនមានពួកភិក្ខុជាអ្នកទូន្មាន នេះជាសេចក្តីសាបសូន្យ ១ ។

[១៦១] ម្នាលកស្សប បុគ្គលណាមួយមានសទ្ធា ក្នុងកុសលធម៌ទាំងឡាយ មានហិរិ... មានឱត្តប្បៈ... មានវីរិយៈ... មានបញ្ញា ក្នុងកុសលធម៌ទាំងឡាយ យប់ឬថ្ងៃនៃបុគ្គលនោះមកដល់ សេចក្តីចម្រើនក៏ប្រាកដក្នុងកុសលធម៌ទាំងឡាយ មិនមានសេចក្តីសាបសូន្យឡើយ ។ ម្នាលកស្សប យប់ឬថ្ងៃនៃព្រះចន្ទក្នុងចំណែកខ្នើតមកដល់ (ព្រះចន្ទនោះ) តែងចម្រើនដោយទ្រង់ទ្រាយ ចម្រើនដោយមណ្ឌល ចម្រើនដោយពន្លឺ ចម្រើនដោយកំពស់និងទំហំ យ៉ាងណា ម្នាលកស្សប បុគ្គលណាមួយមានសទ្ធា ក្នុងកុសលធម៌ទាំងឡាយ មានហិរិ... មានឱត្តប្បៈ... មានវីរិយៈ... មានបញ្ញា ក្នុងកុសលធម៌ទាំងឡាយ យប់ឬថ្ងៃនៃបុគ្គលនោះ

អាគច្ឆតិ វុឌ្ឍិយេវ ចាដិកង្ខា កុសលេសុ ធម្មេសុ នោ បរិហានិ ។ សទ្ធោ បុរិសបុគ្គលោតិ កស្សប អបរិហានមេតំ ហិរិមា ។ បេ ។ ឱត្តាបី ។ បេ ។ អារទ្ធវីរិយោ ។ បេ ។ បញ្ញា ។ បេ ។ អកោធនោ ។ បេ ។ អនុបនាហី បុរិសបុគ្គលោតិ កស្សប អបរិហានមេតំ សន្តិ ភិក្ខូ ឱវាទកាតិ កស្សប អបរិហានមេតំ ។ សត្តមំ ។

[១៦២] រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ អថខោ អាយស្មា មហាកស្សបោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ មហាកស្សបំ ភគវា ឯតទវោច ឱវទ កស្សប ភិក្ខូ ករោហិ កស្សប ភិក្ខូនំ ធម្មិំ កថំ អហំ វា កស្សប ភិក្ខូ ឱវទេយ្យំ ត្វំ វា អហំ វា ភិក្ខូនំ ធម្មិំ កថំ ករេយ្យំ ត្វំ វាតិ ។ ទុព្វចា ខោ ភន្តេ ភគវា ឯតរហិ ភិក្ខូ

មកដល់ សេចក្តីចម្រើនក៏ប្រាកដក្នុងកុសលធម៌ទាំងឡាយ មិនមានសេចក្តីសាបសូន្យឡើយ យ៉ាងនោះឯង ។ ម្នាលកស្សប ត្រង់ពាក្យថា បុរសបុគ្គលមានសទ្ធា នេះជាសេចក្តីមិនសាបសូន្យ ១ មានហិរិ ។ បេ ។ មានឱត្តប្បៈ ។ បេ ។ មានព្យាយាមប្រារព្ធហើយ ។ បេ ។ មានបញ្ញា ។ បេ ។ មិនមានសេក្តីក្រោធ ។ បេ ។ ម្នាលកស្សប ត្រង់ពាក្យថា បុរសបុគ្គលជាអ្នកមិនមានការចងគំនុំ នេះជាសេចក្តីមិនសាបសូន្យ ១ ម្នាលកស្សប ត្រង់ពាក្យថា មានពួកភិក្ខុជាអ្នកទូន្មាន នេះជាសេចក្តីមិនសាបសូន្យ ១ ។ ចប់សូត្រទី ៧ ។

[១៦២] ព្រះមានព្រះភាគ ទ្រង់គង់នៅវត្តវេឡុវនជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ គ្រានោះ ព្រះមហាកស្សបដ៏មានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ទើបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះមហាកស្សបមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ទើបព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះថា ម្នាលកស្សប អ្នកចូរទូន្មានពួកភិក្ខុ ម្នាលកស្សប អ្នកចូរធ្វើធម្មីកថាចំពោះពួកភិក្ខុចុះ ម្នាលកស្សប តថាគតឬអ្នក គប្បីទូន្មានពួកភិក្ខុ តថាគតឬអ្នក គប្បីធ្វើធម្មីកថាដល់ពួកភិក្ខុ ។ បពិត្រព្រះមានព្រះភាគដ៏ចម្រើន ឥឡូវនេះ ពួកភិក្ខុជាអ្នកប្រដៅក្រ

ទោវចស្សករណេហិ ធម្មេហិ សមន្នាគតា អក្ខមា អប្បទក្ខិណគ្គាហិនោ អនុសាសនិន្តិ ។

[១៦៣] តថា ហិ បន កស្សប បុព្វេ ថេរា ភិក្ខូ អារញ្ញិកា ចេវ អហេសុំ អារញ្ញិកត្តស្ស ច វណ្ណវាទិនោ បិណ្ឌបាតិកា ចេវ អហេសុំ បិណ្ឌបាតិ-កត្តស្ស ច វណ្ណវាទិនោ បំសុកូលិកា ចេវ អហេសុំ បំសុកូលិកត្តស្ស ច វណ្ណវាទិនោ តេចីវរិកា ចេវ អ-ហេសុំ តេចីវរិកត្តស្ស ច វណ្ណវាទិនោ អប្បិច្ឆា ចេវ អហេសុំ អប្បិច្ឆតាយ ច វណ្ណវាទិនោ សន្តុដ្ឋា ចេវ អ-ហេសុំ សន្តុដ្ឋិយា ច វណ្ណវាទិនោ បវិវិត្តា ចេវ អហេ-សុំ បវិវេកស្ស ច វណ្ណវាទិនោ អសំសដ្ឋា ចេវ អហេសុំ អសំសគ្គស្ស ច វណ្ណវាទិនោ អារទ្ធវីរិយា ចេវ អហេសុំ វីរិយារម្ភស្ស ច វណ្ណវាទិនោ ។ តត្រ យោ ហោតិ ភិក្ខុ អារញ្ញិកោ ចេវ អារញ្ញិកត្តស្ស ច វណ្ណវាទី បិណ្ឌបាតិកោ ចេវ បិណ្ឌបាតិកត្តស្ស ច វណ្ណវាទី

ប្រកបដោយធម៌ដែលធ្វើឲ្យជាអ្នកប្រដៅក្រ ជាអ្នកមិនអត់សង្កត់ មិនកាន់យកពាក្យប្រដៅដោយចំណែកស្តាំឡើយ ។

[១៦៣] ម្នាលកស្សប ហេតុដូច្នោះហើយ បានជាក្នុងកាលពីមុន មានពួកភិក្ខុជាថេរៈ ជាអ្នកប្រព្រឹត្តនៅក្នុងព្រៃផង់ ពោលសរសើរគុណនៃការនៅក្នុងព្រៃផង់ ជាអ្នកប្រព្រឹត្តបិណ្ឌបាតផង់ ពោលសរសើរគុណនៃការប្រព្រឹត្តបិណ្ឌបាតផង់ ជាអ្នកស្លៀកដណ្តប់សំពត់បង្សុកូលផង់ ពោលសរសើរគុណនៃការស្លៀកដណ្តប់សំពត់បង្សុកូលផង់ ជាអ្នកទ្រទ្រង់ចីវរបីផង់ ពោលសរសើរគុណនៃការទ្រទ្រង់ចីវរបីផង់ ជាអ្នកប្រាថ្នាតិចផង់ ពោលសរសើរគុណនៃសេចក្តីប្រាថ្នាតិចផង់ ជាអ្នកមានសេចក្តីសន្តោសផង់ ពោលសរសើរគុណនៃសេចក្តីសន្តោសផង់ ជាអ្នកស្ងប់ស្ងាត់ផង់ ពោលសរសើរគុណនៃការស្ងប់ស្ងាត់ផង់ ជាអ្នកមិនច្រឡូកច្រឡំផង់ ពោលសរសើរគុណនៃការមិនច្រឡូកច្រឡំផង់ ជាអ្នកប្រារព្ធសេចក្តីព្យាយាមផង់ ពោលសរសើរគុណនៃការប្រារព្ធសេចក្តីព្យាយាមផង់ ។ បណ្តាភិក្ខុទាំងនោះ ភិក្ខុណាជាអ្នកប្រព្រឹត្តនៅក្នុងព្រៃផង់ ពោលសរសើរគុណនៃការនៅក្នុងព្រៃផង់ ជាអ្នកប្រព្រឹត្តបិណ្ឌបាតផង់ ពោលសរសើរគុណនៃការប្រព្រឹត្តបិណ្ឌបាតផង់

បំសុកូលិកោ ចេវ បំសុកូលិកត្តស្ស ច វណ្ណវាទី តេចីវរិកោ ចេវ តេចីវរិកត្តស្ស ច វណ្ណវាទី អប្បិច្ឆោ ចេវ អប្បិច្ឆតាយ ច វណ្ណវាទី សន្តុដ្ឋោ ចេវ សន្តុដ្ឋិយា ច វណ្ណវាទី បវិវិត្តោ ចេវ បវិវេកស្ស ច វណ្ណវាទី អសំសដ្ឋោ ចេវ អសំសគ្គស្ស ច វណ្ណវាទី អារទ្ធវីរិយោ ចេវ វីរិយារម្ភស្ស ច វណ្ណវាទី តំ ថេរា ភិក្ខូ អាសនេន និមន្តេន្តិ ឯហិ ភិក្ខុ កោ នាមាយំ ភិក្ខុ ភទ្ទកោ វតាយំ ភិក្ខុ សិក្ខាកាមោ វតាយំ ភិក្ខុ ឯហិ ភិក្ខុ ឥទំ អាសនំ និសីទាហីតិ ។ តត្រ កស្សប នវានំ ភិក្ខូនំ ឯវំ ហោតិ យោ កិរ សោ ហោតិ ភិក្ខុ អារញ្ញិកោ ចេវ អារញ្ញិកត្តស្ស ច វណ្ណវាទី បិណ្ឌបាតិកោ ចេវ... បំសុកូលិកោ ចេវ... តេចីវរិកោ... អប្បិច្ឆោ ចេវ... សន្តុដ្ឋោ ចេវ... បវិវិត្តោ ចេវ... អសំសដ្ឋោ ចេវ... អារទ្ធវីរិយោ ចេវ វីរិយារម្ភស្ស ច វណ្ណវាទី

ជាអ្នកស្មៀកដណ្ដប់សំពត់បង្សុកូលផង ពោលសរសើរគុណនៃការស្មៀកដណ្ដប់សំពត់បង្សុកូលផង ជាអ្នកទ្រទ្រង់ចីវរបីផង ពោលសរសើរគុណនៃការទ្រទ្រង់ចីវរបីផង ជាអ្នកប្រាថ្នាតិចផង ពោលសរសើរគុណនៃសេចក្ដីប្រាថ្នាតិចផង ជាអ្នកមានសេចក្ដីសន្ដោសផង ពោលសរសើរគុណនៃសេចក្ដីសន្ដោសផង ជាអ្នកស្ងប់ស្ងាត់ផង ពោលសរសើរគុណនៃការស្ងប់ស្ងាត់ផង ជាអ្នកមិនច្រឡូកច្រឡំផង ពោលសរសើរគុណនៃការមិនច្រឡូកច្រឡំផង ជាអ្នកប្រារព្ធសេចក្ដីព្យាយាមផង ពោលសរសើរគុណនៃការប្រារព្ធសេចក្ដីព្យាយាមផង ពួកភិក្ខុជាថេរៈតែងនិមន្ដភិក្ខុនោះដោយអាសនៈថា ម្នាលភិក្ខុ អ្នកចូរមក ភិក្ខុនេះឈ្មោះអ្វី ភិក្ខុនេះជាអ្នកចម្រើន ភិក្ខុនេះប្រាថ្នានូវសិក្ខា ម្នាលភិក្ខុ អ្នកចូរមកអង្គុយលើអាសនៈនេះចុះ ។ ម្នាលកស្សប បណ្ដាភិក្ខុទាំងនោះ ពួកភិក្ខុថ្មី មានសេចក្ដីត្រិះរិះយ៉ាងនេះថា បានឮថា ភិក្ខុណាជាអ្នកប្រព្រឹត្តនៅក្នុងព្រៃផង ពោលសរសើរគុណនៃការនៅក្នុងព្រៃផង ជាអ្នកប្រព្រឹត្តបិណ្ឌបាតផង... ជាអ្នកស្មៀកដណ្ដប់សំពត់បង្សុកូលផង... ជាអ្នកទ្រទ្រង់ចីវរបីផង... ជាអ្នកប្រាថ្នាតិចផង... ជាអ្នកមានសេចក្ដីសន្ដោសផង... ជាអ្នកស្ងប់ស្ងាត់ផង... ជាអ្នកមិនច្រឡូកច្រឡំផង... ជាអ្នកប្រារព្ធសេចក្ដីព្យាយាមផង ពោលសរសើរគុណនៃការប្រារព្ធសេចក្ដីព្យាយាមផង

តំ ថេរា ភិក្ខូ អាសនេន និមន្តេន្តិ ឯហិ ភិក្ខុ កោ នាមាយំ ភិក្ខុ ភទ្ទកោ វតាយំ ភិក្ខុ សិក្ខាកាមោ វតាយំ ភិក្ខុ ឯហិ ភិក្ខុ ឥទំ អាសនំ និសីទាហីតិ តេ តថត្តាយ បដិបជ្ជន្តិ តេសន្តំ ហោតិ ទីឃរត្តំ ហិតាយ សុខាយ ។

[១៦៤] ឯតរហិ បន កស្សប ថេរា ភិក្ខូ ន ចេវ អារញ្ញិកា ន ច អារញ្ញិកត្តស្ស វណ្ណវាទិនោ ន ចេវ បិណ្ឌបាតិកា ន ច បិណ្ឌបាតិកត្តស្ស វណ្ណវាទិនោ ន ចេវ បំសុកូលិកា ន ច បំសុកូលិកត្តស្ស វណ្ណវាទិ-នោ ន ចេវ តេចីវរិកា ន ច តេចីវរិកត្តស្ស វណ្ណវាទិ-នោ ន ចេវ អប្បិច្ឆា ន ច អប្បិច្ឆតាយ វណ្ណវាទិនោ ន ចេវ សន្តុដ្ឋា ន ច សន្តុដ្ឋិយា វណ្ណវាទិនោ ន ចេវ បវិវិត្តា ន ច បវិវេកស្ស វណ្ណវាទិនោ ន ចេវ អសំសដ្ឋា ន ច អសំសគ្គស្ស វណ្ណវាទិនោ ន ចេវ អារទ្ធវីរិយា

ពួកភិក្ខុជាថេរៈតែងនិមន្តភិក្ខុនោះដោយអាសនៈថា ម្នាលភិក្ខុ អ្នកចូរមក ភិក្ខុនេះឈ្មោះអ្វី ភិក្ខុនេះជាអ្នកចម្រើន ភិក្ខុនេះជាអ្នកប្រាថ្នាសិក្ខា ម្នាលភិក្ខុ អ្នកចូរមកអង្គុយលើអាសនៈនេះចុះ ដូច្នេះហើយ ភិក្ខុទាំងនោះ រមែងប្រតិបត្តិតាមបែបនោះ សេចក្ដីប្រតិបត្តិនោះ របស់ភិក្ខុទាំងនោះ រមែងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ និងសេចក្ដីសុខ អស់រាត្រីយូរអង្វែង ។

[១៦៤] ម្នាលកស្សប ក៏ក្នុងកាលឥឡូវនេះ ពួកភិក្ខុជាថេរៈ មិនប្រព្រឹត្តនៅក្នុងព្រៃផង មិនពោលសរសើរគុណនៃការនៅក្នុងព្រៃផង មិនជាអ្នកប្រតិបត្តិបិណ្ឌបាតផង មិនពោលសរសើរគុណនៃការប្រព្រឹត្តបិណ្ឌបាតផង មិនជាអ្នកស្លៀកដណ្ដប់សំពត់បង្សុកូលផង មិនពោលសរសើរគុណនៃការស្លៀកដណ្ដប់សំពត់បង្សុកូលផង មិនជាអ្នកទ្រទ្រង់ចីវរបីផង មិនពោលសរសើរគុណនៃការទ្រទ្រង់ចីវរបីផង មិនជាអ្នកមានសេចក្ដីប្រាថ្នាតិចផង មិនពោលសរសើរគុណនៃសេចក្ដីប្រាថ្នាតិចផង មិនជាអ្នកមានសេចក្ដីសន្ដោសផង មិនពោលសរសើរគុណនៃសេចក្ដីសន្ដោសផង មិនជាអ្នកស្ងប់ស្ងាត់ផង មិនពោលសរសើរគុណនៃសេចក្ដីស្ងប់ស្ងាត់ផង មិនជាអ្នកច្រឡូកច្រឡំផង ពោលសរសើរគុណនៃការមិនច្រឡូកច្រឡំផង ជាអ្នកមិនប្រារព្ធសេចក្ដីព្យាយាមផង

ន ច វីរិយារម្ភស្ស វណ្ណភាណិនោ ។ តត្រ យោ ហោតិ ភិក្ខុ ញាតោ យសស្សី លាភី ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ តំ ថេរា ភិក្ខូ អាសនេន និមន្តេន្តិ ឯហិ ភិក្ខុ កោ នាមាយំ ភិក្ខុ ភទ្ទកោ វតាយំ ភិក្ខុ សព្រហ្មចារិកាមោ វតាយំ ភិក្ខុ ឯហិ ភិក្ខុ ឥទំ អាសនំ និសីទាហីតិ ។ តត្រ កស្សប នវានំ ភិក្ខូនំ ឯវំ ហោតិ យោ កិរ សោ ហោតិ ភិក្ខុ ញាតោ យសស្សី លាភី ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ តំ ថេរា ភិក្ខូ អាសនេន និមន្តេន្តិ ឯហិ ភិក្ខុ កោ នាមាយំ ភិក្ខុ ភទ្ទកោ វតាយំ ភិក្ខុ សព្រហ្មចារិកាមោ វតាយំ ភិក្ខុ ឯហិ ភិក្ខុ ឥទំ អាសនំ និសីទាហីតិ តេ តថត្តាយ បដិបជ្ជន្តិ តេសន្តំ ហោតិ ទីឃរត្តំ អហិតាយ ទុក្ខាយ ។

មិនពោលសរសើរគុណនៃការប្រារព្ធសេចក្តីព្យាយាមផង ។ បណ្តាភិក្ខុទាំងនោះ ភិក្ខុណាជាអ្នកល្បីល្បាញ មានយស តែងបានចីវរ បិណ្ឌ-បាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារទាំងឡាយ ទើបពួកភិក្ខុជាថេរៈនិមន្តភិក្ខុនោះដោយអាសនៈថា ម្នាលភិក្ខុ អ្នកចូរមក ភិក្ខុនេះឈ្មោះអ្វី ភិក្ខុនេះជាអ្នកចម្រើនហ្ន៎ ភិក្ខុនេះជាអ្នកស្រឡាញ់សព្រហ្មចារី ម្នាលភិក្ខុ អ្នកចូរមកអង្គុយលើអាសនៈនេះចុះ ។ ម្នាលកស្សប បណ្តាភិក្ខុទាំងនោះ ពួកភិក្ខុថ្មី មានសេចក្តីត្រិះរិះយ៉ាងនេះថា ឮថាភិក្ខុណាជាអ្នកល្បីល្បាញ មានយស តែងបាននូវចីវរ បិណ្ឌបាត សេនា-សនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារទាំងឡាយ ទើបពួកភិក្ខុជាថេរៈនិមន្តភិក្ខុនោះដោយអាសនៈថា ម្នាលភិក្ខុ អ្នកចូរមក ភិក្ខុនេះឈ្មោះអ្វី ភិក្ខុនេះជាអ្នកចម្រើនភិក្ខុនេះជាអ្នកស្រឡាញ់សព្រហ្មចារី ម្នាលភិក្ខុ អ្នកចូរមកអង្គុយលើអាសនៈនេះចុះ ដូច្នេះហើយ ភិក្ខុទាំងនោះរមែងប្រតិបត្តិតាមបែបនោះ ការប្រតិបត្តិនោះ របស់ភិក្ខុនោះ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ អស់រាត្រីយូរអង្វែង ។

យញ្ហិតំ កស្សប សម្មា វទមានោ វទេយ្យំ ឧបទ្ទុតា ព្រហ្មចារី ព្រហ្មចារូបទ្ទវេន អភិភវនា[១] ព្រហ្មចារី ព្រហ្មចារាភិភវនេនាតិ[២] ។ ឯតរហិ[៣] តំ កស្សប សម្មា វទមានោ វទេយ្យ ឧបទ្ទុតា ព្រហ្មចារី ព្រហ្មចារូបទ្ទវេន អភិភវនា ព្រហ្មចារី ព្រហ្មចារាភិភវនេនាតិ ។ អដ្ឋមំ ។

[១៦៤] សាវត្ថិយំ វិហរតិ... អហំ ភិក្ខវេ យាវទេវ អាកង្ខាមិ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរាមិ ។ កស្សបោបិ ភិក្ខវេ យាវទេវ អាកង្ខតិ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ។

១ ឱ. អភិភវនា ។ ម. អភិបត្ថនា ។ ២ ព្រហ្មចារូបព្ពវេន ។ ម. ព្រហ្មចារិបត្ថនេន ។ ៣ ឯវំ ហិ ។

ម្នាលកស្សប រឿងនោះ មានទំនង់គួរឲ្យអ្នកផង គេនិយាយបានថា ព្រហ្មចារីបុគ្គល ត្រូវឧបទ្រពរបស់ព្រហ្មចារីបុគ្គលបៀតបៀនហើយ ព្រហ្មចារីបុគ្គលត្រូវសេចក្តីប្រាថ្នាលើសលុប របស់ព្រហ្មចារីបុគ្គលរួបរឹតហើយ ។ ម្នាលកស្សប ឥឡូវនេះ ពាក្យនោះ មានទំនង់គួរឲ្យអ្នកផងគេនិយាយបានថា ព្រហ្មចារីបុគ្គល ត្រូវឧបទ្រពរបស់ព្រហ្មចារីបុគ្គល បៀតបៀនហើយ ព្រហ្មចារីបុគ្គល ត្រូវសេចក្តីប្រាថ្នាលើសលុប របស់ព្រហ្មចារីបុគ្គលរួបរឹតហើយ ។ ចប់សូត្រទី ៨ ។

[១៦៥] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ម្នាលភិក្ខុទាំងឡាយ តថាគតប្រាថ្នា ដរាបណា ក៏ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្កៈ វិចារៈ មានបីតិនិងសុខៈ ដែលកើតអំពីសេចក្តីស្ងាត់នោះ ដរាបនោះ ។ ម្នាលភិក្ខុទាំងឡាយ ចំណែកកស្សបប្រាថ្នា ដរាបណា ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្កៈ វិចារៈ មានបីតិនិងសុខៈ ដែលកើតអំពីសេចក្តីស្ងាត់នោះ ដរាបនោះដែរ ។

[១៦៦] អហំ ភិក្ខវេ យាវទេវ អាកង្ខាមិ វិតក្ក-
វិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ
ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ
ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរាមិ ។ កស្សបោបិ
ភិក្ខវេ យាវទេវ អាកង្ខតិ វិតក្កវិចារានំ វូបសមា ។ បេ ។
ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ។

[១៦៧] អហំ ភិក្ខវេ យាវទេវ អាកង្ខាមិ បី-
តិយា ច វិរាគា ឧបេក្ខកោ ច វិហរតិ សតោ ច
សម្បជានោ សុខញ្ច កាយេន បដិសំវេទេមិ យន្តំ
អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ
តតិយំ ឈានំ ឧបសម្បជ្ជ វិហរាមិ ។ កស្សបោបិ
ភិក្ខវេ យាវទេវ អាកង្ខតិ បីតិយា ច វិរាគា ឧ-
បេក្ខកោ ច វិហរតិ សតោ ច សម្បជានោ

[១៦៦] ម្នាលភិក្ខុទាំងឡាយ តថាគតប្រាថ្នា ដរាបណា ក៏បាន រម្ងាប់នូវវិតក្កៈនិងវិចារៈអស់ហើយ ក៏ចូលកាន់ទុតិយជ្ឈាន ជាធម្មជាត កើតមានក្នុងសន្តាននៃខ្លួន ប្រកបដោយសេចក្តីជ្រះថ្លាគឺសទ្ធា មាន សភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារៈទេ មានតែបីតិនិង សុខ ដែលកើតអំពីសមាធិគឺបឋមជ្ឈានប៉ុណ្ណោះ ដរាបនោះ ។ ម្នាល ភិក្ខុទាំងឡាយ ចំណែកខាងកស្សបប្រាថ្នា ដរាបណា ក៏បានរម្ងាប់នូវ វិតក្កៈនិងវិចារៈអស់ហើយ ។ បេ ។ ចូលទុតិយជ្ឈាន ដរាបនោះដែរ ។

[១៦៧] ម្នាលភិក្ខុទាំងឡាយ តថាគតប្រាថ្នា ដរាបណា ក៏ នឿយណាយចាកបីតិផង ប្រកបដោយឧបេក្ខាផង មានសតិនិង សម្បជញ្ញៈផង សោយនូវសេចក្តីសុខដោយនាមកាយផង ព្រះអរិយៈ ទាំងឡាយ តែងសរសើរនូវបុគ្គលដែលប្រកបដោយតតិយជ្ឈាននោះថា ជាអ្នកមានឧបេក្ខា មានសតិ មានធម៌ជាគ្រឿងនៅជាសុខដូច្នេះ ព្រោះ តតិយជ្ឈានឯណា ក៏ចូលតតិយជ្ឈាននោះ ដរាបនោះ ។ ម្នាល ភិក្ខុទាំងឡាយ ចំណែកខាងកស្សបប្រាថ្នា ដរាបណា ក៏នឿយណាយ ចាកបីតិផង ប្រកបដោយឧបេក្ខាផង មានសតិនិងសម្បជញ្ញៈផង

សុខញ្ច កាយេន បដិសំវេទេតិ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ។

[១៦៨] អហំ ភិក្ខវេ យាវទេវ អាកង្ខាមិ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្ស-ទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបា-រិសុទ្ធឹ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរាមិ ។ កស្សបោបិ ភិក្ខវេ យាវទេវ អាកង្ខតិ សុខស្ស ច បហានា ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។

[១៦៩] អហំ ភិក្ខវេ យាវទេវ អាកង្ខាមិ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរាមិ ។ កស្ស-បោបិ ភិក្ខវេ យាវទេវ អាកង្ខតិ សព្វសោ រូបសញ្ញានំ សមតិក្កមា ។ បេ ។ អាកាសានញ្ចាយតនំ ឧប-សម្បជ្ជ វិហរតិ ។

សោយនូវសេចក្ដីសុខដោយនាមកាយផង ព្រះអរិយៈទាំងឡាយ តែង សរសើរបុគ្គលដែលប្រកបដោយតតិយជ្ឈាននោះថា ជាអ្នកមានឧបេក្ខា មានស្មារតី មានធម៌ជាគ្រឿងនៅជាសុខដូច្នេះ ព្រោះតតិយជ្ឈានឯណា ក៏ចូលតតិយជ្ឈាននោះ ដរាបនោះដែរ ។

[១៦៨] ម្នាលភិក្ខុទាំងឡាយ តថាគតប្រាថ្នា ដរាបណា ក៏ លះបង់នូវសេចក្ដីសុខផង លះបង់នូវសេចក្ដីទុក្ខផង មានសោមនស្ស និងទោមនស្សអស់ទៅក្នុងកាលមុន ក៏ចូលចតុត្ថជ្ឈាន ដែលមិនជាទុក្ខ មិនជាសុខ មានសតិដ៏បរិសុទ្ធដោយឧបេក្ខា ដរាបនោះ ។ ម្នាលភិក្ខុ ទាំងឡាយ ចំណែកខាងកស្សបប្រាថ្នា ដរាបណា ក៏លះបង់នូវ សេចក្ដីសុខផង ។ បេ ។ ចូលចតុត្ថជ្ឈាន ដរាបនោះដែរ ។

[១៦៩] ម្នាលភិក្ខុទាំងឡាយ តថាគតប្រាថ្នា ដរាបណា ក៏ប្រព្រឹត្តកន្លងនូវរូបសញ្ញា ដោយប្រការទាំងពួង ដល់នូវការអស់ទៅ នៃបដិឃសញ្ញា លែងធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ហើយចូលអាកា-សានញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុត ដូច្នេះ ដរាបនោះ ។ ម្នាលភិក្ខុទាំងឡាយ ចំណែកខាងកស្សបប្រាថ្នា ដរាបណា ក៏ប្រព្រឹត្តកន្លងនូវរូបសញ្ញាដោយប្រការទាំងពួង ។ បេ ។ ហើយចូលអាកាសានញ្ចាយតនជ្ឈាន ដរាបនោះដែរ ។

[១៧០] អហំ ភិក្ខវេ យាវទេវ អាកង្ខាមិ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរាមិ ។ កស្សបោបិ ភិក្ខវេ យាវទេវ អាកង្ខតិ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ ។

[១៧១] អហំ ភិក្ខវេ យាវទេវ អាកង្ខាមិ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរាមិ ។ កស្សបោបិ ភិក្ខវេ យាវទេវ អាកង្ខតិ ។ បេ ។ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ ។

[១៧២] អហំ ភិក្ខវេ យាវទេវ អាកង្ខាមិ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្មម នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរាមិ ។ កស្សបោបិ ភិក្ខវេ យាវទេវ អាកង្ខតិ ។ បេ ។ នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ ។

[១៧០] ម្នាលភិក្ខុទាំងឡាយ តថាគតប្រាថ្នា ដរាបណា ក៏ប្រព្រឹត្តកន្លងនូវអាកាសានញ្ចាយតនៈ ដោយប្រការទាំងពួង ហើយចូលវិញ្ញាណញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុតដូច្នេះ ដរាបនោះ ។ ម្នាលភិក្ខុទាំងឡាយ ចំណែកខាងកស្សបប្រាថ្នា ដរាបណា ក៏ប្រព្រឹត្តកន្លងនូវអាកាសានញ្ចាយតនៈ ដោយប្រការទាំងពួង ហើយចូលវិញ្ញាណញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុតដូច្នេះ ដរាបនោះដែរ ។

[១៧១] ម្នាលភិក្ខុទាំងឡាយ តថាគតប្រាថ្នា ដរាបណា ក៏ប្រព្រឹត្តកន្លងនូវវិញ្ញាណញ្ចាយតនៈ ដោយប្រការទាំងពួង ហើយចូលអាកិញ្ចញ្ញាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា អ្វីបន្តិចបន្តួចមិនមានដូច្នេះ ដរាបនោះ ។ ម្នាលភិក្ខុទាំងឡាយ ចំណែកខាងកស្សបប្រាថ្នា ដរាបណា ។ បេ ។ ក៏ចូលអាកិញ្ចញ្ញាយតនជ្ឈាន ដរាបនោះដែរ ។

[១៧២] ម្នាលភិក្ខុទាំងឡាយ តថាគតប្រាថ្នា ដរាបណា ក៏ប្រព្រឹត្តកន្លងនូវអាកិញ្ចញ្ញាយតនៈ ដោយប្រការទាំងពួង ហើយចូលនេវសញ្ញានាសញ្ញាយតនជ្ឈាន ដរាបនោះ ។ ម្នាលភិក្ខុទាំងឡាយ ចំណែកខាងកស្សបប្រាថ្នា ដរាបណា ។ បេ ។ ក៏ចូលនេវសញ្ញានាសញ្ញាយតនជ្ឈាន ដរាបនោះដែរ ។

កស្សបសំយុត្តស្ស នវមសុត្តំ ឥទ្ធិវិធំ

[១៧៣] អហំ ភិក្ខវេ យាវទេវ អាកង្ខាមិ សព្វសោ នេវសញ្ញានាសញ្ញាយតនំ សមតិក្កម្ម សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ វិហរាមិ ។ កស្សបោបិ ភិក្ខវេ ។ បេ ។ សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ វិហរតិ ។

[១៧៤] អហំ ភិក្ខវេ យាវទេវ អាកង្ខាមិ អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោមិ ឯកោបិ ហុត្វា ពហុធា ហោមិ ពហុធាបិ ហុត្វា ឯកោ ហោមិ អាវិភាវំ តិរោភាវំ តិរោកុឌ្ឌំ តិរោបាការំ តិរោបព្វតំ អសជ្ជមានោ គច្ឆាមិ សេយ្យថាបិ អាកាសេ បឋវិយាបិ ឧម្មុជ្ជនិម្មុជ្ជំ ករោមិ សេយ្យថាបិ ឧទកេ ឧទកេបិ អភិជ្ជមានេ គច្ឆាមិ សេយ្យថាបិ បឋវិយំ អាកាសេបិ បល្លង្កេន ចង្កមាមិ សេយ្យថាបិ បក្ខី សកុណោ ឥមេបិ ចន្ទិមសុរិយេ ឯវំមហិទ្ធិកេ ឯវំមហានុភាវេ បាណិនា បរិមសាមិ បរិមជ្ជាមិ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេមិ ។ កស្សបោបិ ភិក្ខវេ

[១៧៣] ម្នាលភិក្ខុទាំងឡាយ តថាគតប្រាថ្នា ដរាបណា ក៏ប្រព្រឹត្តកន្លងនេវសញ្ញានាសញ្ញាយតនៈ ដោយប្រការទាំងពួង ហើយចូលសញ្ញាវេទយិតនិរោធ (សេចក្ដីរលត់នៃសញ្ញានិងវេទនា) ដរាបនោះ ។ ម្នាលភិក្ខុទាំងឡាយ ចំណែកខាងកស្សប ។ បេ ។ ក៏ចូលសញ្ញាវេទយិតនិរោធ ដរាបនោះដែរ ។

[១៧៤] ម្នាលភិក្ខុទាំងឡាយ តថាគតប្រាថ្នា ដរាបណា ក៏បាននូវឥទ្ធិវិធៈច្រើនបែប គឺតថាគតមានកាយតែមួយ ធ្វើឲ្យជាកាយមានចំណែកច្រើនក៏បាន ឬកាយមានចំណែកច្រើន ធ្វើឲ្យជាកាយមួយក៏បាន នៅក្នុងទីកំបាំង ដើរចេញទៅទីវាលក៏បាន នៅខាងក្នុង ដើរចេញទៅខាងក្រៅ គឺក្រៅជញ្ជាំង ក្រៅកំពែង ក្រៅភ្នំ ក៏បាន មិនជាប់ចំពាក់ដូចជាដើរទៅក្នុងអាកាស ធ្វើនូវការមុជងើបក្នុងផែនដី ដូចជាមុជងើបក្នុងទឹក ដើរទៅលើទឹកមិនធ្លាយធ្លុះ ដូចជាដើរទៅលើផែនដី ទៅទាំងភ្នែនក្នុងអាកាស ដូចជាសត្វស្លាបហើរទៅក្នុងអាកាស ស្ទាបអង្អែលព្រះចន្ទព្រះអាទិត្យ ដែលមានឥទ្ធិឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ដោយដៃក៏បាន ធ្វើអំណាចឲ្យប្រព្រឹត្តដោយកាយរហូតដល់ព្រហ្មលោកនាយ ដរាបនោះ ។ ម្នាលភិក្ខុទាំងឡាយ ចំណែកកស្សប

យាវទេវ អាកង្ខតិ អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោតិ ។ បេ ។ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេតិ ។

[១៧៥] អហំ ភិក្ខវេ យាវទេវ អាកង្ខាមិ ទិព្វាយ សោតធាតុយា ។ បេ ។ យេ ទូរេ សន្តិកេ ច ។ កស្សបោបិ ភិក្ខវេ... សន្តិកេ ច ។

[១៧៦] អហំ ភិក្ខវេ យាវទេវ អាកង្ខាមិ បរសត្តានំ បរបុគ្គលានំ ចេតសា ចេតោ បរិច្ច ជានាមិ សរាគំ វា ចិត្តំ សរាគំ ចិត្តន្តិ បជានាមិ វីតរាគំ វា ចិត្តំ វីតរាគំ ចិត្តន្តិ បជានាមិ សទោសំ វា ចិត្តំ ។ បេ ។ វីតទោសំ វា ចិត្តំ... សមោហំ វា ចិត្តំ... វីតមោហំ វា ចិត្តំ... សង្ខិត្តំ វា ចិត្តំ... វិក្ខិត្តំ វា ចិត្តំ... មហគ្គតំ វា ចិត្តំ... អមហគ្គតំ វា ចិត្តំ... សឧត្តរំ វា ចិត្តំ... អនុត្តរំ វា ចិត្តំ... សមាហិតំ វា ចិត្តំ... អសមាហិតំ វា ចិត្តំ... វិមុត្តំ វា ចិត្តំ អវិមុត្តំ វា ចិត្តំ អវិមុត្តំ ចិត្តន្តិ បជានាមិ ។ កស្សបោបិ ភិក្ខវេ យាវទេវ អាកង្ខតិ

ប្រាថ្នា ដរាបណា ក៏បាននូវឥទ្ធិវិធៈជាច្រើនបែប ។ បេ ។ ធ្វើអំណាច ឲ្យប្រព្រឹត្តដោយកាយរហូតដល់ព្រហ្មលោកនាយ ដរាបនោះដែរ ។

[១៧៥] ម្នាលភិក្ខុទាំងឡាយ តថាគតប្រាថ្នា ដរាបណា ក៏ស្តាប់សំឡេងឮដោយសោតធាតុជាទិព្វ ។ បេ ។ ទោះឆ្ងាយក្តី ជិតក្តី ម្នាលភិក្ខុទាំងឡាយ ចំណែកកស្សប... ទោះជិតក្តី ។

[១៧៦] ម្នាលភិក្ខុទាំងឡាយ តថាគតប្រាថ្នា ដរាបណា ក៏កំណត់ដឹងនូវចិត្តពួកសត្វដទៃ ពួកបុគ្គលដទៃ ដោយចិត្តរបស់តថាគត ចិត្តប្រកបដោយរាគៈក្តី ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយរាគៈ ចិត្តប្រាសចាករាគៈក្តី ក៏ដឹងច្បាស់ថា ចិត្តប្រាសចាករាគៈ ចិត្តប្រកបដោយទោសៈក្តី ។ បេ ។ ចិត្តប្រាសចាកទោសៈក្តី... ចិត្តប្រកបដោយមោហៈក្តី... ចិត្តប្រាសចាកមោហៈក្តី ចិត្តរួញរាក្តី... ចិត្តអណ្តែតអណ្តូងក្តី... ចិត្តដល់នូវភាវៈជាធំក្តី... ចិត្តមិនដល់នូវភាវៈជាធំក្តី... ចិត្តផុតស្រឡះក្តី... ចិត្តជាអនុត្តរៈក្តី... ចិត្តតាំងមាំក្តី... ចិត្តមិនតាំងមាំក្តី... ចិត្តផុតស្រឡះក្តី... ចិត្តមិនទាន់ផុតស្រឡះក្តី ក៏ដឹងច្បាស់ថា ចិត្តមិនទាន់ផុតស្រឡះ ដរាបនោះ ។ ម្នាលភិក្ខុទាំងឡាយ ចំណែកខាងកស្សបប្រាថ្នា ដរាបណា

បរសត្តានំ បរបុគ្គលានំ ចេតសា ចេតោ បរិច្ច ជានាតិ សរាគំ វា ចិត្តំ សរាគំ ចិត្តន្តិ បជានាតិ ។ បេ ។ អវិមុត្តំ វា ចិត្តំ អវិមុត្តំ ចិត្តន្តិ បជានាតិ ។

[១៧៧] អហំ ភិក្ខវេ យាវទេវ អាកង្ខាមិ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរាមិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ តិស្សោបិ ជាតិយោ ចតស្សោបិ ជាតិយោ បញ្ចបិ ជាតិយោ ទសបិ ជាតិយោ វីសម្បិ ជាតិយោ តឹសម្បិ ជាតិយោ ចត្តាឡីសម្បិ ជាតិយោ បញ្ញាសម្បិ ជាតិយោ ជាតិសតម្បិ ជាតិសហស្សម្បិ ជាតិសតសហស្សម្បិ អនេកេបិ សំវដ្ដកប្បេ អនេកេបិ វិវដ្ដកប្បេ អនេកេបិ សំវដ្ដវិវដ្ដកប្បេ អមុត្រាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ អមុត្រ ឧទបាទឹ តត្រាបាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ

ក៏កំណត់ដឹងចិត្តពួកសត្វដទៃ ពួកបុគ្គលដទៃ ដោយចិត្តរបស់ខ្លួន ចិត្តប្រកបដោយរាគៈក្តី ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយរាគៈ ។ បេ ។ ចិត្តមិនទាន់ផុតស្រឡះក្តី ក៏ដឹងច្បាស់ថា ចិត្តមិនទាន់ផុតស្រឡះ ដរាបនោះដែរ ។

[១៧៧] ម្នាលភិក្ខុទាំងឡាយ តថាគតប្រាថ្នា ដរាបណា ក៏រឭកឃើញនូវបុព្វេនិវាសច្រើនប្រការ គឺរឭកបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ៣ ជាតិខ្លះ ៤ ជាតិខ្លះ ៥ ជាតិខ្លះ ១០ ជាតិខ្លះ ២០ ជាតិខ្លះ ៣០ ជាតិខ្លះ ៤០ ជាតិខ្លះ ៥០ ជាតិខ្លះ ១ រយជាតិខ្លះ ១ ពាន់ជាតិខ្លះ ១ សែនជាតិខ្លះ ច្រើនសំវដ្តកប្បខ្លះ ច្រើនវិវដ្តកប្បខ្លះ ច្រើនសំវដ្តវិវដ្តកប្បខ្លះថា អាត្មាអញកើតក្នុងទីឯណោះ មាននាមយ៉ាងនេះ មានគោត្រយ៉ាងនេះ មានវណ្ណៈយ៉ាងនេះ មានអាហារយ៉ាងនេះ បានសោយសុខទុក្ខយ៉ាងនេះ មានអាយុកំណត់ត្រឹមប៉ុណ្ណេះ លុះអាត្មាអញនោះច្យុតអំពីទីនោះហើយ ទៅកើតក្នុងទីឯណោះទៀត ដែលកើតក្នុងទីឯណោះ អាត្មាអញមាននាមយ៉ាងនេះ មានគោត្រយ៉ាងនេះ មានវណ្ណៈយ៉ាងនេះ

ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ ឥធូបបន្នោតិ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរាមិ ។ កស្សបោបិ ភិក្ខវេ យាវទេវ អាកង្ខតិ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកម្បិ ជាតឹ ។ បេ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ។

[១៧៨] អហំ ភិក្ខវេ យាវទេវ អាកង្ខាមិ ទិព្វេ-ន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សាមិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាមិ ឥមេ វត ភោន្តោ សត្តា កាយ-ទុច្ចរិតេន សមន្នាគតា វចីទុច្ចរិតេន សមន្នាគតា មនោទុច្ចរិតេន សមន្នាគតា អរិយានំ ឧបវាទកា

មានអាហារយ៉ាងនេះ បានសោយសុខទុក្ខយ៉ាងនេះ មានអាយុកំណត់ត្រឹមប៉ុណ្ណេះ អាត្មាអញច្យុតចាកទីនោះ បានមកកើតក្នុងទីនេះដូច្នេះ តថាគតរមែងរឭកឃើញនូវបុព្វេនិវាសច្រើនប្រការ ព្រមទាំងអាការៈព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះឯង ដរាបនោះ ។ ម្នាលភិក្ខុទាំងឡាយ ចំណែកខាងកស្សបប្រាថ្នា ដរាបណា ក៏រឭកឃើញនូវបុព្វេ-និវាសច្រើនប្រការ គឺរឭកបាន ១ ជាតិខ្លះ ។ បេ ។ រឭកឃើញនូវបុព្វេនិ-វាសច្រើនប្រការ ព្រមទាំងអាការៈ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះឯង ដរាបនោះដែរ ។

[១៧៨] ម្នាលភិក្ខុទាំងឡាយ តថាគតប្រាថ្នា ដរាបណា ក៏មានទិព្វចក្ខុដ៏បរិសុទ្ធ កន្លងនូវចក្ខុរបស់មនុស្សធម្មតា បានឃើញពួកសត្វដែលច្យុត កើត ថោកទាប ឧត្តម មានសម្បុរល្អ មានសម្បុរអាក្រក់មានគតិល្អ មានគតិអាក្រក់ ដឹងច្បាស់នូវពពួកសត្វដែលអន្ទោលទៅតាមកម្មថា អើហ្ន៎ ពួកសត្វទាំងនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលពួកព្រះអរិយៈ

១៨៧

កស្សបសំយុត្តស្ស នវមសុត្តេ ទិព្វចក្ខុ

មិច្ឆាទិដ្ឋិកា មិច្ឆាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នា ឥមេ វា បន ភោន្តោ សត្តា កាយសុចរិតេន សមន្នាគតា វចីសុចរិតេន សមន្នាគតា មនោសុចរិតេន សមន្នាគតា អរិយានំ អនុបវាទកា សម្មាទិដ្ឋិកា សម្មាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបន្នាតិ ឥតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សាមិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាមិ ។ កស្សបោបិ ភិក្ខវេ យាវទេ អាកង្ខតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ។ បេ ។ យថាកម្មូបគេ សត្តេ បជានាតិ ។

ជាមិច្ឆាទិដ្ឋិ កាន់អំពើជាមិច្ឆាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយរាងកាយបន្ទាប់អំពីមរណៈទៅ ក៏ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរកអើហ្ន៎ ចំណែកពួកសត្វទាំងនេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាអ្នកមិនតិះដៀលពួកព្រះអរិយៈ ជាសម្មាទិដ្ឋិ កាន់អំពើជាសម្មាទិដ្ឋិ ពួកសត្វទាំងនោះ លុះបែកធ្លាយរាងកាយបន្ទាប់អំពីមរណៈទៅ ក៏ទៅកើតក្នុងសុគតិសួគ៌ទេវលោក តថាគតមានទិព្វចក្ខុដ៏បរិសុទ្ធ កន្លងនូវចក្ខុរបស់មនុស្សធម្មតា បានឃើញនូវពួកសត្វដែលច្យុត កើត ថោកទាប ឧត្តម មានវណ្ណល្អ មានវណ្ណអាក្រក់ មានគតិល្អ មានគតិអាក្រក់ ដឹងច្បាស់នូវពួកសត្វដែលអន្ទោលទៅតាមកម្ម ដោយប្រការដូច្នេះឯង ដរាបនោះ ។ ម្នាលភិក្ខុទាំងឡាយ ចំណែកខាងកស្សបប្រាថ្នា ដរាបណា ក៏មានទិព្វចក្ខុដ៏បរិសុទ្ធ កន្លងនូវចក្ខុរបស់មនុស្សធម្មតា បានឃើញពួកសត្វដែលច្យុត ។ បេ ។ ដឹងច្បាស់នូវពួកសត្វដែលអន្ទោលទៅតាមកម្មដរាបនោះដែរ ។

[១៧៩] អហំ ភិក្ខវេ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរាមិ ។ កស្សបោបិ ភិក្ខវេ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតីតិ ។ នវមំ ។

[១៨០] ឯវម្មេ សុតំ ។ ឯកំ សមយំ អាយស្មា មហាកស្សបោ សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ អាយស្មា អានន្ទោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេនាយស្មា មហាកស្សបោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ មហាកស្សបំ ឯតទវោច អាយាម ភន្តេ កស្សប យេន អញ្ញតរោ ភិក្ខុនុបស្សយោ តេនុបសង្កមិស្សាមាតិ ។ គច្ឆ ត្វំ អាវុសោ

[១៧៩] ម្នាលភិក្ខុទាំងឡាយ តថាគតបានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈ ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ ចំណែកកស្សបសោត ក៏ធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈ ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្នដែរ ។ ចប់សូត្រទី ៩ ។

[១៨០] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមហាកស្សបមានអាយុ គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ព្រះអានន្ទមានអាយុ ស្លៀកស្បង់ ប្រដាប់បាត្រនិងចីវរ ក្នុងពេលព្រឹកព្រហាម ហើយចូលទៅរកព្រះមហាកស្សបមានអាយុ លុះចូលទៅដល់ហើយ បានពោលពាក្យនេះនឹងមហាកស្សបមានអាយុថា បពិត្រព្រះកស្សបដ៏ចម្រើន មកយើងនឹងចូលទៅកាន់លំនៅរបស់ភិក្ខុនីមួយរូប ។ ព្រះមហាកស្សបតបថា ម្នាលអាវុសោ

អានន្ទ ពហុកិច្ចោ ត្វំ ពហុករណីយោតិ ។ ទុតិយម្បិ ខោ អាយស្មា អានន្ទោ អាយស្មន្តំ មហាកស្សបំ ឯតទវោច អាយាម ភន្តេ កស្សប យេន អញ្ញតរោ ភិក្ខុនូបស្សយោ តេនុបសង្កមិស្សាមាតិ ។ គច្ឆ ត្វំ អាវុសោ អានន្ទ ពហុកិច្ចោ ត្វំ ពហុករណីយោតិ ។ តតិយម្បិ ខោ អាយស្មា អានន្ទោ អាយស្មន្តំ មហា-កស្សបំ ឯតទវោច អាយាម ភន្តេ កស្សប យេន អញ្ញតរោ ភិក្ខុនូបស្សយោ តេនុបសង្កមិស្សាមាតិ ។

[១៨១] អថខោ អាយស្មា មហាកស្សបោ បុព្វ-ណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ អាយស្មតា អានន្ទេន បច្ឆាសមណេន យេន អញ្ញតរោ ភិក្ខុ-នូបស្សយោ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ អថខោ សម្ពហុលា ភិក្ខុនិ-យោ យេនាយស្មា មហាកស្សបោ តេនុបសង្កមឹសុ

អានន្ទ ចូរអ្នកទៅចុះ អ្នកមានកិច្ចច្រើន មានការដែលត្រូវធ្វើច្រើន ។ ព្រះអានន្ទមានអាយុ បានពោលពាក្យនេះ នឹងព្រះមហាកស្សបដ៏មានអាយុ ជាគម្រប់ ២ ដងថា បពិត្រព្រះកស្សបដ៏ចម្រើន មកយើងនឹងចូលទៅកាន់លំនៅរបស់ភិក្ខុនីមួយរូប ។ ម្នាលអាវុសោអានន្ទ ចូរអ្នកទៅចុះ អ្នកមានកិច្ចច្រើន មានការដែលត្រូវធ្វើច្រើន ។ ព្រះអានន្ទមានអាយុ បានពោលពាក្យនេះ នឹងព្រះមហាកស្សបមានអាយុ ជាគម្រប់ ៣ ដងថា បពិត្រព្រះកស្សបដ៏ចម្រើន មកយើងនឹងចូលទៅកាន់លំនៅរបស់ភិក្ខុនីមួយរូប ។

[១៨១] គ្រានោះឯង ព្រះមហាកស្សបមានអាយុ ស្លៀកស្បង់ ប្រដាប់បាត្រនិងចីវរ ក្នុងពេលព្រឹកព្រហាម មានព្រះអានន្ទដ៏មានអាយុ ជាបច្ឆាសមណៈ ក៏ចូលទៅកាន់លំនៅភិក្ខុនីមួយរូប លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈ ដែលគេក្រាលទុក ។ វេលានោះឯង ភិក្ខុនីច្រើនរូប នាំគ្នាចូលទៅរកព្រះមហាកស្សបមានអាយុ

ឧបសង្កមិត្វា អាយស្មន្តំ មហាកស្សបំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តា ភិក្ខុនិយោ អាយស្មា មហាកស្សបោ ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។ អថខោ អាយស្មា មហាកស្សបោ តា ភិក្ខុនិយោ ធម្មិយា កថាយ សន្ទស្សេត្វា សមាទបេត្វា សមុត្តេជេត្វា សម្បហំសេត្វា ឧដ្ឋាយាសនា បក្កាមិ ។

[១៨២] អថខោ ថុល្លតិស្សា ភិក្ខុនី អនត្តមនា អនត្តមនវាចំ និច្ឆារេសិ កឹ បន អយ្យោ មហាកស្សបោ

លុះចូលទៅដល់ហើយ ទើបថ្វាយបង្គំព្រះមហាកស្សបមានអាយុ ហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ លុះភិក្ខុនីទាំងនោះ អង្គុយក្នុងទីដ៏សមគួរហើយ ទើបព្រះមហាកស្សបមានអាយុ ពន្យល់ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ។ លុះព្រះមហាកស្សបមានអាយុ បានញុំាងភិក្ខុនីនោះ ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក្រោកចាកអាសនៈចៀសចេញទៅ ។

[១៨២] គ្រានោះឯង ថុល្លតិស្សាភិក្ខុនី មិនពេញចិត្ត ក៏បញ្ចេញនូវវាចាមិនពេញចិត្តថា ដូចម្ដេច ក៏ព្រះមហាកស្សបជាម្ចាស់

១៦១



អយ្យស្ស អានន្ទស្ស វេទេហមុនិនោ សម្មុខា ធម្មំ ភាសិតព្វំ មញ្ញតិ សេយ្យថាបិ នាម សូចិពាណិជកោ សុខុមសូចិការស្ស[១] សន្តិកេ សូចឹ វិក្កេតព្វំ មញ្ញេយ្យ ឯវមេវ អយ្យោ មហាកស្សបោ អយ្យស្ស អានន្ទស្ស វេទេហមុនិនោ សម្មុខា ធម្មំ ភាសិតព្វំ មញ្ញតីតិ ។ អស្សោសិ ខោ អាយស្មា មហាកស្សបោ ថុល្លតិស្សាយ ភិក្ខុនិយា ឥមំ វាចំ ភាសមានាយ ។ អថខោ អាយស្មា មហាកស្សបោ អាយស្មន្តំ អានន្ទំ ឯតទវោច កឹ នុ ខោ អាវុសោ អានន្ទ អហំ សូចិពាណិជកោ ត្វំ សូចិការោ ឧទាហុ អហំ សូចិការោ ត្វំ សូចិពាណិជកោតិ ។ ខមថ ភន្តេ កស្សប ពាលោ មាតុគាមោតិ ។

---

១ ឱ. ម. សូចិការស្ស ។ សុខុមាតិ បទំ នត្ថិ ។

សម្គាល់នូវធម៌ដែលខ្លួនគប្បីពោលក្នុងទីចំពោះមុខព្រះអានន្ទជាម្ចាស់ ជាអ្នកប្រាជ្ញអាចសម្រេចកិច្ចដោយបញ្ញាបាន ឈ្មួញម្ជុល គប្បីសម្គាល់នូវម្ជុលដែលខ្លួនត្រូវលក់ក្នុងសំណាក់នៃជាងម្ជុលដ៏ល្អិតល្អ យ៉ាងណា ព្រះមហាកស្សបជាម្ចាស់ ក៏សម្គាល់នូវធម៌ដែលខ្លួនគប្បីពោលក្នុងទីចំពោះមុខនៃព្រះអានន្ទជាម្ចាស់ ជាអ្នកប្រាជ្ញអាចសម្រេចកិច្ចដោយបញ្ញាបាន យ៉ាងនោះដែរ ។ ព្រះមហាកស្សបមានអាយុ បានឮវាចារបស់ថុល្លតិស្សាភិក្ខុនីពោលយ៉ាងនេះហើយ ។ ទើបព្រះមហាកស្សបមានអាយុ បានពោលពាក្យនេះនឹងព្រះអានន្ទមានអាយុថា ម្នាលអាវុសោអានន្ទ ខ្ញុំទុកដូចឈ្មួញម្ជុល លោកទុកដូចជាជាងម្ជុល ឬថាខ្ញុំទុកដូចជាជាងម្ជុល លោកទុកដូចជាឈ្មួញម្ជុលវិញ ។ បពិត្រព្រះកស្សបដ៏ចម្រើន សូមលោកអត់ទោសចុះ (ដ្បិត) មាតុគ្រាមជាអ្នកល្ងង់ ។

[១៨៣] អាគមេហិ ត្វំ អាវុសោ អានន្ទ មា តេ សង្ឃោ ឧត្តរឹ ឧបបរិក្ខិ តំ កឹ មញ្ញសិ អាវុសោ អានន្ទ អបិ នុ ត្វំ ភគវតោ សម្មុខា ភិក្ខុសង្ឃេ ឧបនីតោ អហំ ភិក្ខវេ យាវទេវ អាកង្ខាមិ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរាមិ អានន្ទោតិ ភិក្ខវេ យាវទេវ អាកង្ខតិ វិវិច្ចេវ កាមេហិ វិវិច្ច កុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតីតិ ។ នោ ហេតំ ភន្តេ ។ អហំ ខោ អាវុសោ ភគវតោ សម្មុខា ភិក្ខុសង្ឃេ ឧបនីតោ អហំ ភិក្ខវេ យាវទេវ អាកង្ខាមិ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរាមិ កស្សបោបិ ភិក្ខវេ យាវទេវ អាកង្ខតិ

[១៨៣] ម្នាលអាវុសោអានន្ទ លោកចូរបង្អង់សិន កុំឲ្យសង្ឃត្រិះរិះតទៅទៀតដល់លោកឡើយ ម្នាលអាវុសោអានន្ទ លោកសម្គាល់នូវហេតុនោះដូចម្តេច លោក ក្រែងព្រះមានព្រះភាគ បានសរសើរ ក្នុងកណ្តាលជំនុំភិក្ខុសង្ឃ ចំពោះព្រះភក្ត្រថា ម្នាលភិក្ខុទាំងឡាយ តថាគតប្រាថ្នា ដរាបណា ក៏ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្កៈ វិចារៈ មានបីតិនិងសុខៈដ៏កើតអំពីសេចក្តីស្ងាត់នោះ ដរាបនោះ ម្នាលភិក្ខុទាំងឡាយចំណែកអានន្ទប្រាថ្នា ដរាបណា ក៏ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្កៈវិចារៈ មានបីតិនិងសុខៈដ៏កើត អំពីសេចក្តីស្ងប់ស្ងាត់នោះ ដរាបនោះដែរ ដូច្នេះឬ ។ បពិត្រលោកដ៏ចម្រើន សេចក្តីនោះមិនដូច្នោះទេ ។ ម្នាលអាវុសោ ឯខ្ញុំព្រះមានព្រះភាគ ទ្រង់សរសើរក្នុងកណ្តាលជំនុំសង្ឃ ចំពោះព្រះភក្ត្រថា ម្នាលភិក្ខុទាំងឡាយ តថាគតប្រាថ្នា ដរាបណា ក៏ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្កៈ វិចារៈ មានបីតិនិងសុខៈ ដ៏កើតអំពីសេចក្តីស្ងាត់នោះ ដរាបនោះ ម្នាលភិក្ខុទាំងឡាយ ចំណែកខាងកស្សបប្រាថ្នា ដរាបណា

វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតីតិ ។

(នវន្នំ អនុបុព្វវិហារសមាបត្តីនំ បញ្ចន្នញ្ច អភិញ្ញានំ ឯវំ បេយ្យាលោ) ។

[១៨៤] តំ កឹ មញ្ញសិ អាវុសោ អានន្ទ អបិ នុ ត្វំ ភគវតោ សម្មុខា ភិក្ខុសង្ឃេ ឧបនីតោ អហំ ភិក្ខវេ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរាមិ អានន្ទោបិ ភិក្ខវេ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតីតិ ។ នោ ហេតំ ភន្តេ ។ អហំ ខោ អាវុសោ ភគវ-តោ សម្មុខា ភិក្ខុសង្ឃេ ឧបនីតោ អហំ ភិក្ខវេ

ក៏ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ។ បេ ។ ចូលកាន់បឋមជ្ឈាន ដរាបនោះដែរ ។

( បេយ្យាលនៃអនុបុព្វវិហារសមាបត្តិ ៩ និងអភិញ្ញា ៥ យ៉ាងនេះ ) ។

[១៨៤] ម្នាលអាវុសោអានន្ទ លោកសម្គាល់ហេតុនោះដូចម្តេចលោក ព្រះមានព្រះភាគបានសរសើរក្នុងកណ្តាលជំនុំភិក្ខុសង្ឃចំពោះព្រះភក្ត្រថា ម្នាលភិក្ខុទាំងឡាយ តថាគតបានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ម្នាលភិក្ខុទាំងឡាយ ចំណែកអានន្ទ បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្នដូច្នេះដែរឬ ។ បពិត្រលោកដ៏ចម្រើន សេចក្តីនោះ មិនដូច្នោះទេ ។ ម្នាលអាវុសោ ឯខ្លួនខ្ញុំ ព្រះមានព្រះភាគទ្រង់សរសើរក្នុងកណ្តាលជំនុំភិក្ខុសង្ឃ ក្នុងទីចំពោះព្រះភក្ត្រថា ម្នាលភិក្ខុទាំងឡាយ តថាគតធ្វើឲ្យ

អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរាមិ កស្សបោបិ ភិក្ខវេ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតីតិ ។

[១៨៥] សត្តរតនំ វា សោ អាវុសោ នាគំ អឌ្ឍដ្ឋមរតនំ វា តាលបត្តិកាយ ឆាទេតព្វំ មញ្ញេយ្យ យោ មំ[១] ឆហិ អភិញ្ញាហិ ឆាទេតព្វំ មញ្ញេយ្យាតិ ។ ចវិត្ថ ច បន ថុល្លតិស្សា ភិក្ខុនី ព្រហ្មចរិយម្ហាតិ ។ ឆដ្ឋំ ។

[១៨៦] ឯកំ សមយំ អាយស្មា មហាកស្សបោ រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន អាយស្មា អានន្ទោ ទក្ខិណាគិរិស្មឹ ចារិកំ ចរតិ មហតា ភិក្ខុសង្ឃេន សទ្ធឹ ។ តេន ខោ បន សមយេន អាយស្មតោ អានន្ទស្ស តឹសមត្តា សទ្ធិវិហារិនោ ភិក្ខូ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តា ភវន្តិ យេភុយ្យេន កុមារភូតា ។

១ ឱ. ម. យោ មេ ឆ អភិញ្ញា ។

ជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ម្នាលភិក្ខុទាំងឡាយ ចំណែកខាងកស្សប ក៏បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្នដែរ ។

[១៨៥] ម្នាលអាវុសោ អ្នកណាសម្គាល់នូវខ្លួនខ្ញុំថា គួរបិទបាំងដោយអភិញ្ញាទាំង ៦ បាន អ្នកនោះដូចជាសម្គាល់នូវដំរីមានកំពស់ ៧ ហត្ថ ឬ ៧ ហត្ថកន្លះ ថាគួរបិទបាំងដោយស្លឹកត្នោតបាន ។ ចំណែកថុល្លតិស្សាភិក្ខុនី ក៏ឃ្លាតចាកព្រហ្មចរិយធម៌ហើយ ។ ចប់សូត្រទី ១០ ។

[១៨៦] សម័យមួយ ព្រះមហាកស្សបមានអាយុ នៅក្នុងវត្តវេឡុវនជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ ក៏សម័យនោះឯង ព្រះអានន្ទមានអាយុ ត្រាច់ទៅកាន់ផ្លូវក្នុងទក្ខិណាគិរិជនបទ ជាមួយនឹងភិក្ខុសង្ឃច្រើនរូប ។ សម័យនោះ ពួកសទ្ធិវិហារិកភិក្ខុ ៣០ រូប របស់ព្រះអានន្ទមានអាយុច្រើនតែក្មេង ៗ តែងលះបង់នូវសិក្ខា ត្រឡប់ទៅកាន់ភេទថោកទាប ។

[១៨៧] អថខោ អាយស្មា អានន្ទោ ទក្ខិណាគិរិស្មឹ យថាភិរន្តំ ចារិកំ ចរិត្វា យេន រាជគហំ វេឡុវនំ កលន្ទកនិវាបំ[១] យេនាយស្មា មហាកស្សបោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ មហាកស្សបំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ អានន្ទំ អាយស្មា មហាកស្សបោ ឯតទវោច កតិ នុ ខោ អាវុសោ អានន្ទ អត្ថវសេ បដិច្ច ភគវតា កុលេសុ តិកភោជនំ បញ្ញត្តន្តិ ។

[១៨៨] តយោ ខោ ភន្តេ កស្សប អត្ថវសេ បដិច្ច ភគវតា កុលេសុ តិកភោជនំ បញ្ញត្តំ ទុម្មង្កូនំ បុគ្គលានំ និគ្គហាយ បេសលានំ ភិក្ខូនំ ផាសុវិហារ-រាយ មា ចាបិច្ឆា បក្ខំ និស្សាយ សង្ឃំ ភិន្ទេយ្យុំ កុលានុទយតាយ ច ឥមេ ខោ ភន្តេ កស្សប

១ ឱ. ម. កលន្ទកនិវាបោ ។

[១៨៧] គ្រានោះឯង ព្រះអានន្ទមានអាយុ ត្រាច់ទៅកាន់ផ្លូវក្នុងទក្ខិណាគិរិជនបទ គួរតាមអធ្យាស្រ័យ ហើយក៏ចូលទៅរកព្រះមហាកស្សបមានអាយុ ដែលគង់នៅក្នុងវត្តវេឡុវន ជាកលន្ទនិវាបស្ថាន ជិតក្រុងរាជគ្រឹះ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមហាកស្សបមានអាយុ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ព្រះមហាកស្សបមានអាយុមានថេរវាចាដូច្នេះថា ម្នាលអាវុសោអានន្ទ ព្រះមានព្រះភាគទ្រង់បញ្ញត្តតិកភោជន[១] ក្នុងត្រកូលទាំងឡាយ ព្រោះអាស្រ័យនូវអំណាចប្រយោជន៍ប៉ុន្មានយ៉ាង ។

[១៨៨] បពិត្រព្រះកស្សបដ៏ចម្រើន ព្រះមានព្រះភាគទ្រង់បញ្ញត្តតិកភោជន ក្នុងត្រកូលទាំងឡាយ ព្រោះអាស្រ័យអំណាចប្រយោជន៍ ៣ យ៉ាងគឺ ដើម្បីសង្កត់សង្កិននូវបុគ្គលទាំងឡាយ ដែលជាអ្នកទ្រុស្តសីល ១ ដើម្បីនៅសប្បាយនៃភិក្ខុទាំងឡាយ ដែលមានសីលជាទីស្រឡាញ់ ១ ដើម្បីអនុគ្រោះដល់ត្រកូល កុំឲ្យបុគ្គលដែលប្រាថ្នាលាមក ស្វែងរកនូវពួកមកបំបែកសង្ឃ ១ បពិត្រព្រះកស្សបដ៏ចម្រើន

---

១ គឺភោជនដែលគេនិមន្តដោយពាក្យមិនគួរ ហើយភិក្ខុ ៣ រូបទទួលនិមន្តទៅឆាន់ក្នុងទីនោះជាមួយគ្នា មិនត្រូវអាបត្តិឡើយ ។ អដ្ឋកថា ។

តយោ អត្ថវសេ បដិច្ច ភគវតា កុលេសុ តិកភោ-
ជនំ បញ្ញត្តន្តិ ។

[១៨៩] អថ កិញ្ចរហិ ត្វំ អាវុសោ អានន្ទ ឥមេហិ នវេហិ ភិក្ខូហិ ឥន្ទ្រិយេសុ អគុត្តទ្វារេហិ ភោជនេ អមត្តញ្ញូហិ ជាគរិយំ អននុយុត្តេហិ សទ្ធឹ ចារិកំ ចរសិ សស្សឃាតំ មញ្ញេ ចរសិ កុលូប-ឃាតំ មញ្ញេ ចរសិ ឱលុជ្ជតិ ខោ តេ អាវុសោ អានន្ទ បរិសា បលុជ្ជន្តិ ខោ តេ អាវុសោ អានន្ទ នវប្បាយា ន វាយំ កុមារកោ មត្តមញ្ញាសីតិ ។ អបិ មេ ភន្តេ កស្សប សិរស្មឹ បលិតានិ ជាតានិ អថ ច បន មយំ អជ្ជាបិ អាយស្មតោ មហា-កស្សបស្ស កុមារកវាទា ន មុច្ចាមាតិ[១] ។ តថា ហិ បន ត្វំ អាវុសោ អានន្ទ ឥមេហិ នវេហិ ភិក្ខូហិ ឥន្ទ្រិយេសុ អគុត្តទ្វារេហិ ភោជន អម-ត្តញ្ញូហិ ជាគរិយំ អននុយុត្តេហិ សទ្ធឹ ចារិកំ ចរសិ

១ ឱ. ម. ន មុញ្ចាម ។

ព្រះមានព្រះភាគទ្រង់បញ្ញត្តតិកភោជន ក្នុងត្រកូលទាំងឡាយ ព្រោះអាស្រ័យអំណាចប្រយោជន៍ទាំង ៣ នេះឯង ។

[១៨៩] ម្នាលអាវុសោអានន្ទ លោកត្រាច់ទៅកាន់ផ្លូវជាមួយពួកភិក្ខុថ្មីទាំងនេះ ជាអ្នកមានទ្វារមិនបានគ្រប់គ្រងក្នុងឥន្ទ្រិយ៍ទាំងឡាយ មិនដឹងប្រមាណក្នុងភោជន មិនប្រកបរឿយ ៗ ក្នុងការភ្ញាក់រឭក ដូចជាត្រាច់ទៅបៀតបៀនសំទូងគេ ដូចជាត្រាច់ទៅសម្លាប់ត្រកូលគេ ម្នាលអាវុសោអានន្ទ បរិសទ្យរបស់អ្នកបាក់បែកអស់ហើយ ម្នាលអាវុសោអានន្ទ បរិសទ្យទាំងនោះ ច្រើនតែបួសថ្មី រមែងបាក់បែកទៅ ព្រះអានន្ទនេះនៅក្មេងមិនដឹងប្រមាណឡើយ ។ បពិត្រព្រះកស្សបដ៏ចម្រើន ចំណែកក្បាលរបស់ខ្ញុំមានសក់ស្កូវអស់ហើយ តែថាខ្ញុំនៅមិនរួចចាកកុមារកវាទ (ពាក្យតិះដៀលថាក្មេង) របស់ព្រះមហាកស្សបមានអាយុក្នុងថ្ងៃនេះឯង ។ ម្នាលអាវុសោអានន្ទ ព្រោះតែលោកត្រាច់ទៅកាន់ផ្លូវជាមួយពួកភិក្ខុថ្មីទាំងនេះ ជាអ្នកមានទ្វារមិនគ្រប់គ្រងក្នុងឥន្ទ្រិយ៍ទាំង-ឡាយ មិនដឹងប្រមាណក្នុងភោជន មិនប្រកបរឿយៗ នូវការភ្ញាក់រឭក

សស្សយាតំ មញ្ញេ ចរសិ កុលប្បយាតំ មញ្ញេ ចរសិ ឱលុជ្ជតិ ខោ តេ អាវុសោ អានន្ទ បរិសា បលុជ្ជន្តិ ខោ តេ អាវុសោ នវប្បាយ ន វាយំ កុមារកោ មត្តមញ្ញាសីតិ ។

[១៩០] អស្សោសិ ខោ ថុល្លនន្ទា ភិក្ខុនី អយ្យេ-ន កិរ មហាកស្សបេន អយ្យោ អានន្ទោ វេទេហ-មុនិ កុមារកវាទេន អបសាទិតោតិ ។ អថខោ ថុល្ល-នន្ទា ភិក្ខុនី អនត្តមនា អនត្តមនវាចំ និច្ឆារេសិ កឹ បន អយ្យោ មហាកស្សបោ អញ្ញតិត្ថិយបុព្វោ សមានោ អយ្យំ អានន្ទំ វេទេហមុនឹ កុមារកវាទេន អបសាទេតព្វំ មញ្ញតីតិ ។ អស្សោសិ ខោ អាយស្មា មហាកស្សបោ ថុល្លនន្ទាយ ភិក្ខុនិយា ឥមំ វាចំ ភាសមានាយ ។

ដូចជាត្រាច់ទៅបៀតបៀនសំទូងគេ ដូចជាត្រាច់ទៅសម្លាប់ត្រកូលគេ ដូច្នោះ ម្នាលអាវុសោអានន្ទ បានជាឥឡូវនេះ ពួកបរិសទ្យរបស់អ្នកបាក់បែកអស់ ម្នាលអាវុសោអានន្ទ បរិសទ្យទាំងនោះ ច្រើនតែបួសថ្មីរមែងបាក់បែកទៅ ព្រះអានន្ទនេះនៅក្មេងមិនដឹងប្រមាណឡើយ ។

[១៩០] ថុល្លនន្ទាភិក្ខុនី បានឮដំណឹងថា ព្រះមហាកស្សបជាម្ចាស់ បន្ទោសព្រះអានន្ទជាម្ចាស់ ដែលជាអ្នកប្រាជ្ញអាចសម្រេចកិច្ចដោយបញ្ញាបាន ដោយកុមារកវាទហើយ ។ ទើបថុល្លនន្ទាភិក្ខុនីមិនពេញចិត្ត ក៏បញ្ចេញនូវវាចាមិនពេញចិត្តថា ព្រះមហាកស្សបជាម្ចាស់ធ្លាប់ជាអន្យតិរ្ថិយទេដឹង បានជាសម្គាល់នូវព្រះអានន្ទជាម្ចាស់ ដែលជាអ្នកប្រាជ្ញអាចសម្រេចកិច្ចដោយបញ្ញាបានថា គួរបន្ទោសដោយកុមារ-កវាទដូច្នេះ ។ ព្រោះមហាកស្សបមានអាយុ បានឮវាចាដែលថុល្លនន្ទាភិក្ខុនីពោលនេះហើយ ។

[១៩១] អថខោ អាយស្មា មហាកស្សបោ អាយស្មន្តំ អានន្ទំ ឯតទវោច តគ្ឃាវុសោ អានន្ទ ថុល្លនន្ទាយ ភិក្ខុនិយា សហសា អប្បដិសង្ខា វាចា ភាសិតា យតោហំ[១] អាវុសោ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិតោ នាភិជានាមិ អញ្ញំ សត្ថារំ ឧទ្ទិសិត្វា[២] អញ្ញត្រ តេន ភគវតា អរហតា សម្មាសម្ពុទ្ធេន ។ បុព្វេ មេ អាវុសោ អាគារិកភូតស្ស សតោ ឯតទហោសិ សម្ពាធោ ឃរាវាសោ រជាបថោ អព្ភោកាសោ បព្វជ្ជា នយិទំ សុករំ អគារំ អជ្ឈាវសតា ឯកន្តបរិបុណ្ណំ ឯកន្តបរិសុទ្ធំ សង្ខលិខិតំ ព្រហ្មចរិយំ ចរិតុំ យន្នូនាហំ

១ ម. យស្មា ។ ២ ឱ. ម. ឧទ្ទិសិតុំ ។

[១៩១] គ្រានោះឯង ព្រះមហាកស្សបមានអាយុ បានពោលពាក្យនេះ នឹងព្រះអានន្ទមានអាយុថា ម្នាលអាវុសោអានន្ទ ខ្ញុំសូមរំឭកលោក ចុល្លនន្ទាភិក្ខុនីមិនបានពិចារណាហើយពោលវាចាដោយរហ័ស ម្នាលអាវុសោ តាំងពីកាលដែលខ្ញុំកោរសក់និងពុកមាត់ ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះចូលមកកាន់ផ្នួស មិនដែលឧទ្ទិសចំពោះគ្រូដទៃ ក្រៅអំពីព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះសោះ ។ ម្នាលអាវុសោ កាលមុនដែលខ្ញុំនៅជាគ្រហស្ថ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា ឃរាវាសជាទីចង្អៀត ជាផ្លូវនៃធូលីគឺកិលេស ឯបព្វជ្ជាទើបមានឱកាសទំនេរ ព្រោះបុគ្គលដែលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយៈ ឲ្យពេញដោយចំណែកមួយ ឲ្យបរិសុទ្ធដោយចំណែកមួយ ដូចជាសង្ខ៍ដែលគេខាត់បានឡើយ បើដូច្នោះមានតែ

កស្សបសំយុត្តស្ស ឯកាទសមសុត្តេ មហាកស្សបវាចា

កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជេយ្យន្តិ ។ សោ ខ្វាហំ អាវុសោ អបរេន សមយេន បដបិលោតិកានំ សង្ឃាដឹ ការិត្វា យេ លោកេ អរហន្តោ ឧទ្ទិស កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជឹ សោ ឯវំ បព្វជិតោ សមានោ អទ្ធា-នមគ្គំ បដិបន្នោ អទ្ទសំ ភគវន្តំ អន្តរា ច រាជគហំ អន្តរា ច នាឡន្ទំ ពហុបុត្តចេតិយេ និសិន្នំ ទិស្វាន មេ ឯតទហោសិ សត្ថារញ្ច វតាហំ បស្សេយ្យំ ភគវន្តមេវ បស្សេយ្យំ សុគតញ្ច វតាហំ បស្សេយ្យំ ភគវន្តមេវ បស្សេយ្យំ សម្មាសម្ពុទ្ធញ្ច វតាហំ បស្សេយ្យំ ភគវន្តមេវ បស្សេយ្យន្តិ ។ សោ ខ្វាហំ អាវុសោ តត្ថេវ ភគវតោ បាទេសុ សិរសា និបតិត្វា ភគវន្តំ ឯតទវោចំ សត្ថា មេ ភន្តេ ភគវា សាវកោហមស្មិ សត្ថា មេ ភន្តេ ភគវា សាវកោហមស្មីតិ ។

អាត្មាអញកោរសក់ ពុកមាត់ ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះចូលមកកាន់ផ្នួស ។ ម្នាលអាវុសោ សម័យតមក ខ្លួនខ្ញុំក៏ធ្វើសង្ឃាដិដោយសំពត់ចាស់ ហើយកោរសក់និងពុកមាត់ ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះចូលមកកាន់ផ្នួស ឧទ្ទិសចំពោះព្រះអរហន្តក្នុងលោក លុះខ្ញុំបួសយ៉ាងនេះហើយ ក៏ដើរទៅកាន់ផ្លូវដាច់ស្រយាល បានឃើញព្រះមានព្រះភាគគង់នៅក្នុងពហុបុត្តចេតិយ ដាច់ចន្លោះនគររាជគ្រឹះ និងចន្លោះស្រុកនាឡន្ទា លុះឃើញហើយ ខ្ញុំក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា អើហ្ន៎ ប្រសិនបើអាត្មាអញចួបនឹងបុគ្គលដែលជាគ្រូ ក៏សូមឲ្យចួបតែនឹងព្រះមានព្រះភាគ អើហ្ន៎ ប្រសិនបើអាត្មាអញបានចួបនឹងបុគ្គលដែលមានគតិល្អ ក៏សូមឲ្យចួបតែនឹងព្រះមានព្រះភាគ អើហ្ន៎ ប្រសិនបើអាត្មាអញបានចួបនឹងបុគ្គលដែលត្រាស់ដឹងធម៌ ក៏សូមឲ្យចួបតែនឹងព្រះមានព្រះភាគ ។ ម្នាលអាវុសោ ខ្លួនខ្ញុំក៏ក្រាបទៀបបាទាព្រះមានព្រះភាគ ក្នុងទីនោះឯង ដោយសិរសា ក្រាបទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគជាគ្រូរបស់ខ្ញុំ ខ្ញុំជាសាវ័ករបស់ព្រះអង្គ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគជាគ្រូនៃខ្ញុំ ខ្ញុំជាសាវ័ករបស់ព្រះអង្គ ដូច្នេះ ។

[១៩២] ឯវំ វុត្តេ មំ អាវុសោ ភគវា ឯតទ-វោច យោ ខោ កស្សប ឯវំ សព្វចេតសោ ស-មន្នាកហាតំ[១] សាវកំ អជានញ្ញេវ វទេយ្យ ជានាមីតិ អបស្សញ្ញេវ វទេយ្យ បស្សាមីតិ មុទ្ធាបិ តស្ស វិប-តេយ្យ ។ អហំ ខោ បន កស្សប ជានញ្ញេវ វទាមិ ជានាមីតិ បស្សញ្ញេវ វទាមិ បស្សាមីតិ ។ តស្មាតិហ តេ កស្សប ឯវំ សិក្ខិតព្វំ តិព្វំ មេ ហិរោត្តប្បំ បច្ចុបដ្ឋិតំ ភវិស្សតិ ថេរេសុ នវេសុ មជ្ឈិមេសូតិ ឯវញ្ហិ តេ កស្សប សិក្ខិតព្វំ ។ តស្មាតិហ តេ កស្សប ឯវំ សិក្ខិតព្វំ យំ កិញ្ចិ ធម្មំ សុណិស្សាមិ កុសលូបសញ្ហិតំ សព្វន្តំ អដ្ឋិកត្វា មនសិការិត្វា

---

១ ឱ. ម. សព្វំ ចេតនា សមន្នាគតំ ។

[១៩២] ម្នាលអាវុសោ កាលបើខ្ញុំក្រាបទូលយ៉ាងនេះហើយ ព្រះមានព្រះភាគទ្រង់ត្រាស់នឹងខ្ញុំដូច្នេះថា ម្នាលកស្សប បុគ្គលឯណា មិនដឹង ហើយពោលថា អាត្មាអញដឹង មិនឃើញ ហើយពោលថា អាត្មាអញឃើញ ចំពោះសាវ័កដែលផ្ចង់ចិត្តទាំងពួង យ៉ាងនេះហើយ ក្បាលបុគ្គលនោះឯងនឹងបែកពុំខាន ។ ម្នាលកស្សប តថាគតដឹង ទើបពោលថាដឹង តថាគតឃើញ ទើបពោលថាឃើញ ។ ម្នាលកស្សប ហេតុដូច្នោះ ក្នុងសាសនានេះ អ្នកគប្បីសិក្សាយ៉ាងនេះថា ហិរិនិង ឱត្តប្បៈដ៏ក្លៀវក្លា អាត្មាអញបានតម្កល់ទុកក្នុងភិក្ខុចាស់ទាំងឡាយ ក្នុងភិក្ខុថ្មីទាំងឡាយ ក្នុងភិក្ខុកណ្តាលទាំងឡាយ ម្នាលកស្សប អ្នកគួរសិក្សាយ៉ាងនេះឯង ។ ម្នាលកស្សប ហេតុដូច្នោះ ក្នុងសាសនានេះ អ្នកគប្បីសិក្សាយ៉ាងនេះថា អាត្មាអញនឹងស្តាប់នូវធម៌ដែលប្រកបដោយកុសលឯ-ណានីមួយ ហើយធ្វើនូវធម៌ទាំងអស់នោះឲ្យជាប្រយោជន៍ ធ្វើទុកក្នុងចិត្ត

សព្វចេតសោ សមន្នាហរិត្វា ឱហិតសោតោ ធម្មំ សុណិស្សាមីតិ ឯវញ្ហិ តេ កស្សប សិក្ខិតព្វំ ។ តស្មាតិហ តេ កស្សប ឯវំ សិក្ខិតព្វំ សាតសហ-គតា ច មេ កាយគតាសតិ ន វិជហិស្សតីតិ ឯវញ្ហិ តេ កស្សប សិក្ខិតព្វន្តិ ។ អថខោ មំ អាវុសោ ភគវា ឥមិនា ឱវាទេន ឱវទិត្វា ឧដ្ឋា-យាសនា បក្កាមិ ។ សត្តាហមេវ ខោហំ អាវុសោ សាណោ រដ្ឋបិណ្ឌំ ភុញ្ជឹ អថ អដ្ឋមិយា អញ្ញា ឧទបាទិ ។ អថខោ អាវុសោ ភគវា មគ្គា ឱក្កម្ម យេន អញ្ញតរំ រុក្ខមូលំ តេនុបសង្កមិ ។ អថខ្វាហំ អាវុសោ បដបិលោតិកានំ សង្ឃាដឹ ចតុគ្គុណំ បញ្ញ-បេត្វា ភគវន្តំ ឯតទវោចំ ឥធ ភន្តេ ភគវា និសីទតុ យំ មមស្ស ទីឃរត្តំ ហិតាយ សុខាយាតិ ។ និសីទិ ខោ អាវុសោ ភគវា បញ្ញត្តេ អាសនេ ។ និសជ្ជ ខោ មំ អាវុសោ ភគវា ឯតទវោច

ផ្ចង់នូវចិត្តទាំងពួង ផ្ទៀងត្រចៀកចាំស្តាប់ធម៌ ម្នាលកស្សប អ្នកគប្បីសិក្សាយ៉ាងនេះចុះ ។ ម្នាលកស្សប ហេតុដូច្នោះ ក្នុងសាសនានេះ អ្នកគប្បីសិក្សាយ៉ាងនេះថា កាយគតាសតិរបស់អាត្មាអញ ប្រកបដោយសេចក្តីសុខ មិនទាន់សាបសូន្យនៅឡើយ ម្នាលកស្សប អ្នកគប្បីសិក្សាយ៉ាងនេះឯង ។ ម្នាលអាវុសោ គ្រានោះ ព្រះមានព្រះភាគទូន្មានខ្ញុំដោយឱវាទនេះហើយ ក៏ទ្រង់ក្រោកចាកអាសនៈចៀសចេញទៅ ។ ម្នាលអាវុសោ ខ្ញុំនៅប្រកបដោយបំណុល បរិភោគនូវដុំបាយ របស់អ្នកនៅក្នុងដែនអស់ ៧ ថ្ងៃគត់ លុះដល់ថ្ងៃទី ៨ ក៏បានអរហត្តផល ។ ម្នាលអាវុសោ គ្រានោះ ព្រះមានព្រះភាគ ក៏ស្តេចចុះចាកផ្លូវចូលទៅរកម្លប់ឈើមួយ ។ ម្នាលអាវុសោ គ្រានោះឯង ខ្ញុំក៏ក្រាលនូវសង្ឃាដិ ៤ ជាន់ ដែលធ្វើដោយសំពត់ចាស់ ហើយក្រាបទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគគង់លើសង្ឃាដិនេះ ដើម្បីជាប្រយោជន៍ និងសេចក្តីសុខ ដល់ខ្ញុំព្រះអង្គ អស់កាលជាយូរអង្វែង ។ ម្នាលអាវុសោ ព្រះមានព្រះភាគ ក៏គង់លើអាសនៈដែលខ្ញុំក្រាលថ្វាយហើយ ។ ម្នាលអាវុសោ លុះព្រះមានព្រះភាគគង់រួចហើយ ក៏មានព្រះពុទ្ធដីកានឹងខ្ញុំយ៉ាងនេះថា

មុទុកា ខោ ត្យាយំ កស្សប បដបិលោតិកានំ សង្ឃាដីតិ ។ បដិគ្គណ្ហាតុ មេ ភន្តេ ភគវា បដបិ-លោតិកានំ សង្ឃាដឹ អនុកម្បំ ឧបាទាយាតិ ។ ធារេស្សសិ បន មេ ត្វំ កស្សប សាណានិ បំសុកូ-លានិ និព្វសនានីតិ ។ ធារេស្សាមហំ ភន្តេ ភគវតោ សាណានិ បំសុកូលានិ និព្វសនានីតិ ។

[១៩៣] សោ ខ្វាហំ អាវុសោ បដបិលោតិកានំ សង្ឃាដឹ ភគវតោ បាទាសឹ អហំ បនស្ស ភគវតោ សាណានិ បំសុកូលានិ និព្វសនានិ បដិបជ្ជឹ ។ យញ្ហិ តំ អាវុសោ សម្មា វទមានោ វទេយ្យ ភគវតោ បុត្តោ ឱរសោ មុខតោ ជាតោ ធម្មជោ ធម្មនិម្មិតោ ធម្ម-ទាយាទោ បដិគ្គហិតានិ សាណានិ បំសុកូលានិ និព្វសនានីតិ មមំ តំ សម្មា វទមានោ វទេយ្យ ភគវតោ បុត្តោ ឱរសោ មុខតោ ជាតោ ធម្មជោ

ម្នាលកស្សប សង្ឃាដីដែលធ្វើដោយសំពត់ចាស់របស់អ្នកនេះ មានសាច់ទន់ល្អណាស់ ។ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគទទួលនូវសង្ឃាដីដែលធ្វើដោយសំពត់ចាស់ ដើម្បីអនុគ្រោះដល់ខ្ញុំព្រះអង្គឲ្យទាន ។ ម្នាលកស្សប អ្នកនឹងស្លៀកដណ្តប់សំពត់សម្បកធ្មៃជារបស់បង្សុកូលរបស់តថាគត ដែលតថាគតលែងប្រើប្រាស់ឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងប្រើប្រាស់សំពត់សម្បកធ្មៃជារបស់បង្សុកូលរបស់ព្រះមានព្រះភាគ ដែលទ្រង់លែងប្រើប្រាស់ ។

[១៩៣] ម្នាលអាវុសោ ខ្ញុំក៏បានថ្វាយសង្ឃាដី ដែលធ្វើដោយសំពត់ចាស់ ចំពោះព្រះមានព្រះភាគដែរ ខ្លួនខ្ញុំក៏ប្រើប្រាស់នូវសំពត់សម្បកធ្មៃជារបស់បង្សុកូលរបស់ព្រះមានព្រះភាគ ដែលទ្រង់លែងប្រើប្រាស់វិញ ។ ម្នាលអាវុសោ បុគ្គលគប្បីពោលដោយប្រពៃនូវពាក្យឯណាថា បុត្តរបស់ព្រះមានព្រះភាគ កើតចេញពីទ្រូង កើតអំពីព្រះឱស្ឋ កើតអំពីធម៌ ព្រះធម៌បានតាក់តែងមក ជាអ្នកមានធម៌ជាមត៌ក បុត្តនោះបានទទួលសំពត់សម្បកធ្មៃជារបស់បង្សុកូល ដែលព្រះមានព្រះភាគទ្រង់លែងប្រើប្រាស់ បុគ្គលពោលពាក្យនោះថា បុត្តរបស់ព្រះមានព្រះភាគ កើតចេញពីទ្រូង កើតអំពីព្រះឱស្ឋ កើតអំពីធម៌

ជម្មនិម្មិតោ ជម្មបាយាតោ បដិគ្គហិតានិ សាណានិ បំសុកូលានិ និព្វសនានីតិ ។

[១៩៤] អហំ ខោ អាវុសោ យាវទេវ អាកង្ខាមិ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិ-តក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧប-សម្បជ្ជ វិហរាមិ ។ អហំ ខោ អាវុសោ យាវទេវ អាកង្ខាមិ ។ បេ ។

(នវន្នំ អនុបុព្វវិហារសមាបត្តីនំ បញ្ចន្នញ្ច អភិញ្ញានំ ឯវំ បេយ្យាលោ) ។

[១៩៥] អហំ ខោ អាវុសោ អាសវានំ ខយា អ-នាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អ-ភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរាមិ ។ សត្តរតនំ វា សោ អាវុសោ នាគំ អឌ្ឍដ្ឋមរតនំ វា តាល-បត្តិកាយ ឆាទេតព្វំ មញ្ញេយ្យ យោ មំ ឆហិ អ-ភិញ្ញាហិ ឆាទេតព្វំ មញ្ញេយ្យាតិ ។ ចវិត្ថ ច បន ថុល្លនន្ទា ភិក្ខុនី ព្រហ្មចរិយម្ហាតិ ។ ឯកាទសមំ ។

ព្រះធម៌បានតាក់តែងមក មានធម៌ជាមត៌ក បុត្តនោះបានទទួលសំពត់សម្បកធ្មៃជារបស់បង្សុកូល ដែលព្រះមានព្រះភាគ ទ្រង់លែងប្រើប្រាស់ដូច្នេះ គឺពោលចំពោះខ្លួនខ្ញុំ ។

[១៩៤] ម្នាលអាវុសោ ខ្ញុំប្រាថ្នា ដរាបណា ក៏ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្កៈនិងវិចារៈ មានបីតិនិងសុខៈដ៏កើតអំពីសេចក្តីស្ងាត់នោះ ដរាបនោះ ។ ម្នាលអាវុសោ ខ្ញុំប្រាថ្នា ដរាបណា ។ បេ ។

(បេយ្យាលនៃអនុបុព្វវិហារសមាបត្តិ ៩ និងអភិញ្ញា ៥ យ៉ាងនេះ) ។

[១៩៥] ម្នាលអាវុសោ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ។ ម្នាលអាវុសោ អ្នកឯណា សម្គាល់នូវខ្លួនខ្ញុំថា គួរបិទបាំងដោយអភិញ្ញាទាំង ៦ បាន អ្នកនោះ ដូចជាសម្គាល់នូវដំរីមានកំពស់ ៧ ហត្ថ ឬ ៧ ហត្ថកន្លះថា គួរបិទបាំងដោយស្លឹកត្នោតបាន ។ ឯថុល្លនន្ទាភិក្ខុនី ឃ្លាតចាកព្រហ្មចរិយៈហើយ ។ ចប់សូត្រទី ១១ ។

[១៩៦] ឯកំ សមយំ អាយស្មា ច មហាកស្សបោ អាយស្មា ច សារីបុត្តោ ពារាណសិយំ វិហរន្តិ ឥសិបតនេ មិគទាយេ ។ អថខោ អាយស្មា សារីបុត្តោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេនាយស្មា មហាកស្សបោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា មហាកស្សបេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។

[១៩៧] ឯកមន្តំ និសិន្នោ ខោ អាយស្មា សារីបុត្តោ អាយស្មន្តំ មហាកស្សបំ ឯតទវោច កិន្នុ ខោ អាវុសោ កស្សប ហោតិ តថាគតោ បរម្មរណាតិ ។ អព្យាកតំ ខោ ឯតំ អាវុសោ ភគវតា ហោតិ តថាគតោ បរម្មរណាតិ ។ កឹ បនាវុសោ ន ហោតិ តថាគតោ បរម្មរណាតិ ។ ឯតម្បិ[១] ខោ អាវុសោ អព្យាកតំ ភគវតា ន ហោតិ តថាគតោ បរម្មរណាតិ ។ កឹ នុ ខោ អាវុសោ ហោតិ ច

---

១ ឱ. ម. ឯវម្បិ ខោ ។

[១៩៦] សម័យមួយ ព្រះមហាកស្សបមានអាយុ និង ព្រះសារីបុត្តមានអាយុ គង់នៅក្នុងឥសិបតនមិគទាយវន ទៀបក្រុងពារាណសី ។ គ្រានោះឯង ព្រះសារីបុត្តមានអាយុ ចេញអំពីទីសម្ងំក្នុងវេលាថ្ងៃរសៀល ហើយចូលទៅរកព្រះមហាកស្សបមានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះមហាកស្សបដ៏មានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏គង់ក្នុងទីដ៏សមគួរ ។

[១៩៧] លុះព្រះសារីបុត្តមានអាយុ គង់ក្នុងទីដ៏សមគួរហើយ បានពោលពាក្យនេះនឹងព្រះមហាកស្សបមានអាយុថា ម្នាលអាវុសោកស្សប សត្វស្លាប់ហើយកើតវិញឬទេ ។ ម្នាលអាវុសោ ពាក្យថា សត្វស្លាប់ហើយកើតវិញនេះ ព្រះមានព្រះភាគមិនបានព្យាករទេ ។ ម្នាលអាវុសោ បើដូច្នោះ មានតែសត្វស្លាប់ហើយមិនកើតទៀតឬ ។ ម្នាលអាវុសោ ពាក្យថា សត្វស្លាប់ហើយមិនកើតទៀតនេះ ក៏ព្រះមានព្រះភាគមិនដែលព្យាករដែរ ។ ម្នាលអាវុសោ ចុះសត្វស្លាប់ហើយកើត

ន ច ហោតិ តថាគតោ បរម្មរណាតិ ។ អព្យាកតំ ខោ ឯតំ អាវុសោ ភគវតា ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណាតិ ។ កឹ បនាវុសោ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ ។ ឯតម្បិ ខោ អាវុសោ អព្យាកតំ ភគវតា នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ ។ កស្មា ចេតំ អាវុសោ អព្យាកតំ ភគវតាតិ ។ ន ហេតំ អាវុសោ អត្ថសញ្ហិតំ នាទិព្រហ្មចរិយកំ ន និព្វិទាយ ន វិរាគាយ ន និរោធាយ ន ឧបសមាយ ន អភិញ្ញាយ ន សម្ពោធាយ ន និព្វានាយ សំវត្តតិ តស្មា តំ អព្យាកតំ ភគវតាតិ ។

ទៀតក៏មាន មិនកើតក៏មានឬ ។ ម្នាលអាវុសោ ពាក្យថា សត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មាននេះ ព្រះមានព្រះភាគមិនដែលព្យាករទេ ។ ម្នាលអាវុសោ បើដូច្នោះ សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនឬ ។ ម្នាលអាវុសោ ពាក្យថា សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែននេះ ព្រះមានព្រះភាគមិនដែលព្យាករទេ ។ ម្នាលអាវុសោ ចុះហេតុដូចម្ដេចបានជាព្រះមានព្រះភាគមិនដែលព្យាករពាក្យនេះ ។ ម្នាលអាវុសោ ព្រោះពាក្យនេះមិនប្រកបដោយប្រយោជន៍ មិនជាខាងដើមនៃព្រហ្មចរិយៈ មិនប្រព្រឹត្តទៅដើម្បីសេចក្ដីនឿយណាយ មិនប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេក មិនប្រព្រឹត្តទៅដើម្បីសេចក្ដីរំលត់ មិនប្រព្រឹត្តទៅដើម្បីស្ងប់រម្ងាប់ មិនប្រព្រឹត្តទៅដើម្បីសេចក្ដីដឹងច្បាស់ មិនប្រព្រឹត្តទៅដើម្បីសេចក្ដីត្រាស់ដឹង មិនប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ព្រោះហេតុនោះ បានជាព្រះមានព្រះភាគ មិនដែលព្យាករពាក្យនោះ ។

[១៩៨] អថ ភិញ្ញូវហារុសោ ព្យាកតំ ភគវ-តាតិ ។ ឥទំ ទុក្ខន្តិ ខោ អាវុសោ ព្យាកតំ ភគវតា អយំ ទុក្ខសមុទយោតិ ព្យាកតំ ភគវតា អយំ ទុក្ខនិរោធោតិ ព្យាកតំ ភគវតា អយំ ទុក្ខនិរោធ-គាមិនី បដិបទាតិ ព្យាកតំ ភគវតាតិ ។ កស្មា ចេតំ អាវុសោ ព្យាកតំ ភគវតាតិ ។ ឯតញ្ហិ អាវុសោ អត្ថសញ្ហិតំ ឯតំ អាទិព្រហ្មចរិយកំ ឯតំ និព្វិទាយ វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោធា-យ និព្វានាយ សំវត្តតិ តស្មា តំ ព្យាកតំ ភគវ-តាតិ ។ ទ្វាទសមំ ។

[១៩៩] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរ-តិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ អាយស្មា មហាកស្សបោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។

[១៩៨] ម្នាលអាវុសោ ចុះព្រះមានព្រះភាគ ទ្រង់ព្យាករថា ដូចម្តេចវិញ ។ ម្នាលអាវុសោ ព្រះមានព្រះភាគទ្រង់ព្យាករថា នេះជាទុក្ខ ព្រះមានព្រះភាគទ្រង់ព្យាករថា នេះជាហេតុនាំឲ្យកើតទុក្ខ ព្រះមានព្រះភាគទ្រង់ព្យាករថា នេះជាសេចក្តីរំលត់ទុក្ខ ព្រះមានព្រះភាគទ្រង់ព្យាករថា នេះជាផ្លូវប្រតិបត្តិជាដំណើរទៅកាន់សេចក្តីរំលត់ទុក្ខ ។ ម្នាលអាវុសោ ចុះហេតុដូចម្តេច បានជាព្រះមានព្រះភាគទ្រង់ព្យាករពាក្យនេះ ។ ម្នាលអាវុសោ ព្រោះថា ពាក្យនេះប្រកបដោយប្រយោជន៍ ជាខាងដើមនៃព្រហ្មចរិយៈ ប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីសេចក្តីរំលត់ ដើម្បីស្ងប់រម្ងាប់ ដើម្បីសេចក្តីដឹងច្បាស់ ដើម្បីសេចក្តីត្រាស់ដឹង ដើម្បីព្រះនិព្វាន ព្រោះហេតុនោះ បានជាព្រះមានព្រះភាគទ្រង់ព្យាករពាក្យនោះ ។ ចប់សូត្រទី ១២ ។

[១៩៩] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ព្រះមហាកស្សបមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។

ឯកមន្តំ និសិន្នោ ខោ អាយស្មា មហាកស្សបោ ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេន បុព្វេ អប្បតរានិ ចេវ សិក្ខាបទានិ អហេសុំ ពហុតរា ច ភិក្ខូ អញ្ញាយ សណ្ឋហឹសុ កោ បន ភន្តេ ហេតុ កោ បច្ចយោ យេនេតរហិ ព-ហុតរានិ ចេវ សិក្ខាបទានិ អប្បតរា ច ភិក្ខូ អញ្ញា-យ សណ្ឋហន្តីតិ ។

[២០០] ឯវញ្ចេតំ កស្សប ហោតិ សត្តេសុ ហា-យមានេសុ សទ្ធម្មេ អន្តរធាយមានេ ពហុតរានិ ចេវ សិក្ខាបទានិ ហោន្តិ អប្បតរា ច ភិក្ខុ អញ្ញាយ សណ្ឋហន្តិ ន តាវ កស្សប សទ្ធម្មស្ស អន្តរធានំ ហោតិ យាវ ន សទ្ធម្មប្បដិរូបកំ លោកេ ឧប្បជ្ជតិ យតោ ច ខោ កស្សប សទ្ធម្មប្បដិរូបកំ លោកេ ឧប្បជ្ជតិ អថ សទ្ធម្មស្ស អន្តរធានំ ហោតិ ។ សេយ្យ-ថាបិ កស្សប ន តាវ ជាតរូបស្ស អន្តរធានំ ហោតិ យាវ ន ជាតរូបប្បដិរូបកំ លោកេ ឧប្បជ្ជតិ យតោ ច ខោ កស្សប ជាតរូបប្បដិរូបកំ លោកេ ឧប្បជ្ជតិ

លុះព្រះមហាកស្សបមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលសួរព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ចុះហេតុដូចម្ដេច បច្ច័យដូចម្ដេច បានជាក្នុងកាលពីដើម មានសិក្ខាបទតិច តែមានភិក្ខុបានសម្រេចព្រះអរហន្តច្រើន បពិត្រព្រះអង្គដ៏ចម្រើន ហេតុដូចម្ដេច បច្ច័យដូចម្ដេច បានជាឥឡូវនេះ មានសិក្ខាបទច្រើន តែមានភិក្ខុបានសម្រេចព្រះអរហន្តតិច ។

[២០១] ម្នាលកស្សប ហេតុនេះ តែងមានយ៉ាងនេះឯង កាលបើពួកសត្វសាបសូន្យទៅ ព្រះសទ្ធម្មក៏អន្តរធានទៅដែរ បានជាមានសិក្ខាបទច្រើន មានពួកភិក្ខុបានសម្រេចព្រះអរហន្តតិច ម្នាលកស្សប សទ្ធម្មប្បដិរូប គឺធម៌ដែលស្រដៀងគ្នានឹងព្រះសទ្ធម្ម មិនបានកើតឡើងក្នុងលោក ដរាបណា ការអន្តរធាននៃព្រះសទ្ធម្ម ក៏មិនមាន ដរាបនោះ ម្នាលកស្សប សទ្ធម្មប្បដិរូបកើតឡើងក្នុងលោក កាលណា ការអន្តរធាននៃព្រះសទ្ធម្ម ក៏មានកាលនោះ ។ ម្នាលកស្សប ជាតរូបប្បដិរូប គឺរបស់ដែលស្រដៀងនឹងមាស មិនទាន់កើតឡើងក្នុងលោក ដរាបណា ការអន្តរធាននៃមាស ក៏មិនមាន ដរាបនោះ ម្នាលកស្សប ជាតរូបប្បដិរូប គឺរបស់ដែលស្រដៀងនឹងមាស កើតឡើងក្នុងលោក កាលណា

អថ ជាតរូបស្ស អន្តរធានំ ហោតិ ។ ឯវមេវ ខោ កស្សប ន តាវ សទ្ធម្មស្ស អន្តរធានំ ហោតិ យាវ ន សទ្ធម្មប្បដិរូបកំ លោកេ ឧប្បជ្ជតិ យតោ ច ខោ កស្សប សទ្ធម្មប្បដិរូបកំ លោកេ ឧប្បជ្ជតិ អថ សទ្ធម្មស្ស អន្តរធានំ ហោតិ ។

[២០១] ន ខោ កស្សប បឋវីធាតុ សទ្ធម្មំ អន្តរធាបេតិ ន អាបោធាតុ សទ្ធម្មំ អន្តរធាបេតិ ន តេជោធាតុ សទ្ធម្មំ អន្តរធាបេតិ ន វាយោធាតុ សទ្ធម្មំ អន្តរធាបេតិ អថខោ ឥធេវ តេ ឧប្បជ្ជតិ មោឃបុរិសា យេ ឥមំ សទ្ធម្មំ អន្តរធាបេន្តិ សេយ្យថាបិ កស្សប នាវា អាទិកេនេវ ឱបិលាវតិ ។ ន ខោ កស្សប ឯវំ សទ្ធម្មស្ស អន្តរធានំ ហោតិ ។

ការអន្តរធាននៃមាស ក៏មានក្នុងកាលនោះ យ៉ាងណាមិញ ។ ម្នាលកស្សប សទ្ធម្មប្បដិរូបមិនកើតឡើងក្នុងលោក ដរាបណា ការអន្តរធាននៃព្រះសទ្ធម្ម ក៏មិនមាន ដរាបនោះ ម្នាលកស្សប សទ្ធម្មប្បដិរូបកើតឡើងក្នុងលោក កាលណា ការអន្តរធាននៃព្រះសទ្ធម្ម ក៏មានក្នុងកាលនោះ យ៉ាងនោះឯង ។

[២០១] ម្នាលកស្សប បឋវីធាតុ ធ្វើព្រះសទ្ធម្មឲ្យអន្តរធានទៅក៏ទេ អាបោធាតុ ធ្វើព្រះសទ្ធម្មឲ្យអន្តរធានទៅក៏ទេ តេជោធាតុ ធ្វើព្រះសទ្ធម្មឲ្យអន្តរធានទៅក៏ទេ វាយោធាតុ ធ្វើព្រះសទ្ធម្មឲ្យអន្តរធានទៅក៏ទេ មានតែពួកមោឃបុរស ដែលកើតឡើងក្នុងលោកនេះ ទើបធ្វើព្រះសទ្ធម្មនេះឲ្យអន្តរធានទៅបាន ម្នាលកស្សប ដូចទូកលិចចុះដោយការផ្ទុករបស់ យ៉ាងណា ។ ម្នាលកស្សប ការអន្តរធាននៃព្រះសទ្ធម្ម ក៏មាន យ៉ាងនោះដែរ ។

១៧៩

កស្សបសំយុត្តស្ស តេរសមសុត្តេ សទ្ធម្មានន្តរធានំ

[២០២] បញ្ច ខោមេ កស្សប ឱក្កមនិយា ធម្មា សទ្ធម្មស្ស សម្មោសាយ អន្តរធានាយ សំវត្តន្តិ ។ កតមេ បញ្ច ។ ឥធ កស្សប ភិក្ខូ ភិក្ខុនិយោ ឧបាសកា ឧបាសិកាយោ សត្ថរិ អគារវា វិហរន្តិ អប្បតិស្សា ធម្មេ អគារវា វិហរន្តិ អប្បតិស្សា សង្ឃេ អគារវា វិហរន្តិ អប្បតិស្សា សិក្ខាយ អគារវា វិហរន្តិ អប្បតិស្សា សមាធិស្មឹ អគារវា វិហរន្តិ អប្បតិស្សា ។ ឥមេ ខោ កស្សប បញ្ច ឱក្កមនិយា ធម្មា សទ្ធម្មស្ស សម្មោសាយ អន្តរធានាយ សំវត្តន្តិ ។

[២០៣] បញ្ច ខោមេ កស្សប ធម្មា សទ្ធម្មស្ស ឋិតិយា អសម្មោសាយ អនន្តរធានាយ សំវត្តន្តិ ។ កតមេ បញ្ច ។ ឥធ កស្សប ភិក្ខូ ភិក្ខុនិយោ ឧបាសកា ឧបាសិកាយោ សត្ថរិ សគារវា វិហរន្តិ សប្បតិស្សា ធម្មេ សគារវា វិហរន្តិ សប្បតិស្សា សង្ឃេ សគារវា វិហរន្តិ សប្បតិស្សា សិក្ខាយ សគារវា វិហរន្តិ សប្បតិស្សា សមាធិស្មឹ សគារវា វិហរន្តិ សប្បតិស្សា ។ ឥមេ ខោ កស្សប បញ្ច ធម្មា

កស្សបសំយុត្ត តេរសមសូត្រ សេចក្តីមិនសាបសូន្យទៅនៃព្រះសទ្ធម្ម

[២០២] ម្នាលកស្សប ធម៌ ៥ ប្រការនេះថយចុះ តែងប្រព្រឹត្តទៅដើម្បីវិនាស សាបសូន្យនៃព្រះសទ្ធម្ម ។ ធម៌ ៥ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលកស្សប ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ក្នុងសាសនានេះ ជាអ្នកមិនគោរព មិនកោតក្រែង ក្នុងព្រះសាស្តា ១ ជាអ្នកមិនគោរព មិនកោតក្រែង ក្នុងព្រះធម៌ ១ ជាអ្នកមិនគោរព មិនកោតក្រែង ក្នុងព្រះសង្ឃ ១ ជាអ្នកមិនគោរព មិនកោតក្រែង ក្នុងសិក្ខា ១ ជាអ្នកមិនគោរព មិនកោតក្រែង ក្នុងសមាធិ ១ ។ ម្នាលកស្សប ធម៌ទាំង ៥ ប្រការនេះឯងថយចុះ តែងប្រព្រឹត្តទៅដើម្បីវិនាស សាបសូន្យនៃព្រះសទ្ធម្ម ។

[២០៣] ម្នាលកស្សប ធម៌ទាំង ៥ ប្រការនេះ តែងប្រព្រឹត្តទៅដើម្បីតាំងនៅ ដើម្បីមិនវិនាស មិនសាបសូន្យនៃព្រះសទ្ធម្ម ។ ធម៌ទាំង ៥ ប្រការតើដូចម្តេចខ្លះ ។ ម្នាលកស្សប ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ក្នុងសាសនានេះ ជាអ្នកគោរព កោតក្រែង ក្នុងព្រះសាស្តា ១ ជាអ្នកគោរព កោតក្រែង ក្នុងព្រះធម៌ ១ ជាអ្នកគោរព កោតក្រែង ក្នុងព្រះសង្ឃ ១ ជាអ្នកគោរព កោតក្រែង ក្នុងសិក្ខា ១ ជាអ្នកគោរព កោតក្រែង ក្នុងសមាធិ ១ ។ ម្នាលកស្សប ធម៌ទាំង ៥ ប្រការនេះឯង

សទ្ធម្មស្ស ឋិតិយា អសម្មោសាយ អនន្តរធានាយ សំវត្តន្តីតិ ។ តេរសមំ ។

កស្សបសំយុត្តំ ចតុត្ថំ និដ្ឋិតំ ។

## តស្ស ឧទ្ទានំ

សន្តុដ្ឋញ្ច អនោត្តាបី
ចន្ទូបមំ កុលូបកំ
ជិណ្ណំ តយោ ច ឱវាទា
ឈានាភិញ្ញា ឧបស្សយំ
ចីវរំ បរម្មរណំ
សទ្ធម្មប្បដិរូបកាន្តិ ។

---

តែងប្រព្រឹត្តទៅដើម្បីតាំងនៅ ដើម្បីមិនវិនាស មិនសាបសូន្យនៃព្រះសទ្ធម្ម ។ ចប់សូត្រទី ១៣ ។

ចប់ កស្សបសំយុត្ត ទី ៥ ។

## ឧទ្ទាននៃកស្សបសំយុត្តនោះគឺ

ពោលអំពីបុគ្គលសន្តោស បុគ្គលមិនខ្លាចបាប បុគ្គលមានឧបមាដូចជាព្រះចន្ទ បុគ្គលចូលទៅកាន់ត្រកូល បុគ្គលចាស់ ឱវាទបី ឈាននិងអភិញ្ញា លំនៅភិក្ខុនី ចីវរ សត្វស្លាប់ហើយកើតទៀតឬមិនកើតទៀត សទ្ធម្មប្បដិរូប ។

# លាភសក្ការសំយុត្តំ

## សុទ្ធកវគ្គោ

[២០៤] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

[២០៥] ភគវា ឯតទវោច ទារុណោ ភិក្ខវេ លាភសក្ការសិលោកោ កដុកោ ផរុណោ អន្តរាយិកោ អនុត្តរស្ស យោគក្ខេមស្ស អធិគមាយ តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ ឧប្បន្នំ លាភសក្ការសិលោកំ បជហិស្សាម ន ច នោ ឧប្បន្នោ លាភសក្ការសិលោកោ ចិត្តំ បរិយាទាយ ឋស្សតីតិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។ បឋមំ ។

# លាភសក្ការសំយុត្ត

## សុទ្ធកវគ្គ

[២០៤] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ព្រះមានព្រះភាគត្រាស់នឹងភិក្ខុទាំងឡាយក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[២០៥] ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្តីសរសើរ ជារបស់អាក្រក់ នាំឲ្យក្តៅផ្សា គ្រោតគ្រាត ធ្វើនូវសេចក្តីអន្តរាយដល់ការត្រាស់ដឹងនូវព្រះនិព្វាន ជាទីក្សេមចាកយោគៈ រកគុណជាតដទៃក្រៃលែងជាងគ្មាន ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយគប្បីសិក្សាក្នុងសាសនានេះយ៉ាងនេះថា យើងទាំងឡាយ នឹងលះបង់នូវលាភសក្ការៈនិងសេចក្តីសរសើរដែលកើតឡើងហើយ ទាំងលាភសក្ការៈនិងសេចក្តីសរសើរដែលកើតឡើងហើយ ក៏កុំឲ្យគ្របសង្កត់ចិត្តយើងបានឡើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។ ចប់សូត្រទី ១ ។

[២០៦] សាវត្ថិយំ វិហរតិ... ទារុណោ ភិក្ខវេ លាភសក្ការសិលោកោ កដុកោ ផរុសោ អន្តរាយិកោ អនុត្តរស្ស យោគក្ខេមស្ស អធិគមាយ ។

[២០៧] សេយ្យថាបិ ភិក្ខវេ ពាឡិសិកោ អាមិសគតំ ពឡិសំ គម្ភីរេ ឧទករហទេ បក្ខិបេយ្យ តមេនំ អញ្ញតរោ អាមិសចក្ខុ មច្ឆោ គិលេយ្យ ឯវញ្ហិ សោ ភិក្ខវេ មច្ឆោ គិលពឡិសោ[១] ពាឡិសិកស្ស អនយំ អាបន្នោ ព្យសនំ អាបន្នោ យថាកាមករណីយោ ពាឡិសិកស្ស ។

[២០៨] ពាឡិសិកោតិ ខោ ភិក្ខវេ មារស្សេតំ ធាបិមតោ អធិវចនំ ។ ពឡិសន្តិ ខោ ភិក្ខវេ លាភសក្ការសិលោកស្សេតំ អធិវចនំ ។ យោ ហិ កោចិ ភិក្ខវេ ភិក្ខុ ឧប្បន្នំ លាភសក្ការសិលោកំ អស្សាទេតិ និកាមេតិ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ គិលពឡិសោ

១ ឱ. ម. គិលិតពឡិសោ ។

[២០៦] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្តីសរសើរ ជារបស់អាក្រក់ នាំឲ្យក្តៅផ្សា គ្រោតគ្រាត ធ្វើនូវសេចក្តីអន្តរាយដល់ការត្រាស់ដឹងនូវព្រះនិព្វាន ជាទីក្សេមចាកយោគៈ រកគុណជាតដទៃក្រៃលែងជាងគ្មាន ។

[២០៧] ម្នាលភិក្ខុទាំងឡាយ ដូចព្រានសន្ទូច បោះនូវសន្ទូចដែលបិទដោយនុយទៅក្នុងអន្លង់ទឹកដ៏ជ្រៅ ត្រីណាមួយសំឡឹងឃើញនុយ ក៏លេបសន្ទូចនោះ ម្នាលភិក្ខុទាំងឡាយ ត្រីនោះឯង លុះបានលេបសន្ទូចរបស់ព្រានសន្ទូចយ៉ាងនេះហើយ ក៏ដល់នូវសេចក្តីទុក្ខ ដល់នូវសេចក្តីវិនាស ត្រូវតាមអំពើដោយបំណងរបស់ព្រានសន្ទូច មានឧបមាយ៉ាងណា ។

[២០៨] ម្នាលភិក្ខុទាំងឡាយ ពាក្យថា ព្រានសន្ទូចនេះ ជាឈ្មោះនៃមារចិត្តបាប ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា សន្ទូចនេះ ជាឈ្មោះនៃលាភសក្ការៈនិងសេចក្តីសរសើរ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុឯណានីមួយ ត្រេកអរ ត្រូវការនូវលាភសក្ការៈនិងសេចក្តីសរសើរដែលកើតឡើងហើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះហៅថា លេបសន្ទូច

មារស្ស អនយំ អាបន្នោ ព្យសនំ អាបន្នោ យថាកាមករណីយោ ចាបិមតោ ។ ឯវំ ទារុណោ ខោ ភិក្ខវេ លាភសក្ការសិលោកោ កដុកោ ផរុសោ អន្តរាយិកោ អនុត្តរស្ស យោគក្ខេមស្ស អធិគមាយ ។

[២០៩] តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ ឧប្បន្នំ លាភសក្ការសិលោកំ បជហិស្សាម ន ច នោ ឧប្បន្នោ លាភសក្ការសិលោកោ ចិត្តំ បរិយាទាយ ឋស្សតីតិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។ ទុតិយំ ។

[២១០] សាវត្ថិយំ វិហរតិ... ទារុណោ ភិក្ខវេ លាភសក្ការសិលោកោ ។ បេ ។ អធិគមាយ ។

របស់មារ រមែងដល់នូវសេចក្តីទុក្ខ ដល់នូវសេចក្តីវិនាស ត្រូវតាមអំពើ ដោយបំណងរបស់មារចិត្តបាបមិនខាន ។ ម្នាលភិក្ខុទាំងឡាយ លាភ-សក្ការៈនិងសេចក្តីសរសើរ ជារបស់អាក្រក់ នាំឲ្យក្តៅផ្សា គ្រោតគ្រាត ធ្វើនូវសេចក្តីអន្តរាយដល់ការ ត្រាស់ដឹងនូវព្រះនិព្វានជាទីក្សេមចាកយោគៈ រកគុណជាតដទៃក្រៃលែងជាងគ្មាន ក៏មានឧបមេយ្យយ៉ាងនោះដែរ ។

[២០៩] ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយ គប្បីសិក្សាក្នុងសាសនានេះ យ៉ាងនេះថា យើងទាំងឡាយ នឹងលះបង់នូវលាភសក្ការៈនិងសេចក្តីសរសើរដែលកើតឡើងហើយ ទាំងលាភ-សក្ការៈនិងសេចក្តីសរសើរដែលកើតឡើងហើយ ក៏កុំឲ្យគ្របសង្កត់ចិត្តយើងបានឡើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។ ចប់សូត្រទី ២ ។

[២១០] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្តីសរសើរជារបស់អាក្រក់ ។ បេ ។ ធ្វើនូវសេចក្តីអន្តរាយដល់ការត្រាស់ដឹង ។

[២១១] ភូតបុព្វំ ភិក្ខវេ អញ្ញតរស្មឹ ឧឧការហានេ មហាកុម្ភកុលំ ចិរនិវាសិ អហោសិ ។ អថខោ ភិក្ខវេ អញ្ញតរោ កុម្ភោ យេន អញ្ញតរោ កុម្ភោ តេនុបសង្កមិ អញ្ញតរំ កុម្ភំ ឯតទវោច មា ខោ ត្វំ តាត កុម្ភ ឯតំ បទេសំ អគមាសីតិ ។ អគមសិ ខោ ភិក្ខវេ សោ កុម្ភោ តំ បទេសំ តមេនំ លុទ្ទោ បបតាយ វិជ្ឈិ ។ អថខោ ភិក្ខវេ សោ កុម្ភោ យេន សោ កុម្ភោ តេនុបសង្កមិ ។ អទ្ទសា ខោ ភិក្ខវេ សោ កុម្ភោ តំ កុម្ភំ ទូរតោ វ អាគច្ឆន្តំ ទិស្វាន តំ កុម្ភំ ឯតទវោច កច្ចិ ត្វំ តាត កុម្ភ ន តំ បទេសំ អគមាសីតិ ។ អគមាសឹ[១] ខ្វាហំ តាត កុម្ភ

១ ម. អគមាមិ ខ្វាហំ ។

[២១១] ម្នាលភិក្ខុទាំងឡាយ រឿងធ្លាប់មានមកហើយថា មានត្រកូលនៃសត្វអណ្តើកធំ អាស្រ័យនៅជាយូរអង្វែងមកហើយក្នុងអន្លង់ទឹកមួយ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ អណ្តើកមួយ ចូលទៅរកអណ្តើកមួយទៀត ហើយក៏ពោលទៅនឹងអណ្តើកមួយ (នោះ) ដូច្នេះថា នែបងអណ្តើក បងឯងកុំទៅកាន់ប្រទេសនុ៎ះឡើយ ។ ម្នាលភិក្ខុទាំងឡាយ អណ្តើកនោះ បានទៅកាន់ប្រទេសនោះ ព្រានក៏ចាក់អណ្តើកនោះដោយមូល[១] ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ អណ្តើកនោះចូលទៅរកអណ្តើក (ដែលឃាត់) នោះ ។ ម្នាលភិក្ខុទាំងឡាយ អណ្តើកនោះ បានឃើញអណ្តើកនោះ មកអំពីចម្ងាយ លុះឃើញហើយ ក៏ពោលទៅនឹងអណ្តើកនោះដូច្នេះថា នែបងអណ្តើក បងឯងមិនបានទៅកាន់ប្រទេសនោះទេឬ ។ អណ្តើកនោះ ឆ្លើយថា នែបងអណ្តើក ខ្ញុំបានទៅ

១ ជាឈ្មោះគ្រឿងប្រហារសត្វមួយយ៉ាង ផ្លែវាធ្វើដោយដែកស្រួច បញ្ចូលដងទៅក្នុងមៀនសម្រាប់កាន់ពួយ មានខ្សែ ១ វែងចងផ្លែ កាលបើចាក់សត្វទៅហើយ ដងនោះរបូតចេញអំពីផ្លែទៅ នៅជាប់តែខ្សែជាមួយនឹងផ្លែ (អដ្ឋកថា) ។

តំ បនេសន្តិ ។ កច្ចិ បនាបិ[១] តាត កុម្ម អក្ខតោ អនុបហតោតិ ។ អក្ខតោ ខោម្ហិ តាត កុម្ម អនុបហតោ អត្ថិ បន មេ ឥទំ សុត្តកំ បិដ្ឋិតោ បិដ្ឋិតោ អនុពន្ធន្តិ ។ តគ្ឃ ហិ[២] តាត កុម្ម ខតោ តគ្ឃ ឧបហតោ ឯតេន ហិ តេ តាត កុម្ម សុត្តកេន[៣] បិតរោ ច បិតាមហា ច អនយំ អាបន្នា ព្យសនំ អាបន្នា គច្ឆទានិ ត្វំ តាត កុម្ម នទានិ ត្វំ អម្ហាកន្តិ ។

[២១២] លុទ្ទោតិ ខោ ភិក្ខវេ មារស្សេតំ ចាបិមតោ អធិវចនំ ។ បបតាយាតិ ខោ ភិក្ខវេ លាភសក្ការសិលោកស្សេតំ អធិវចនំ ។ សុត្តកន្តិ ខោ ភិក្ខវេ នន្ទិរាគស្សេតំ អធិវចនំ ។ យោ ហិ កោចិ ភិក្ខវេ ភិក្ខុ ឧប្បន្នំ លាភសក្ការសិលោកំ អស្សាទេតិ និកាមេតិ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ[៤] បបតាយ អនយំ អាបន្នោ ព្យសនំ អាបន្នោ យថាកាមករណីយោ ចាបិមតោ ។

---

១ កច្ចិ បនាសិ ។ ២ តគ្ឃសិ ។ ៣ ឱ. លុទ្ទកេន ។ ម. សុតេន ។ ៤ ឱ. ម. ភិក្ខុ គិទ្ធោ ។

កាន់ប្រទេសនោះហើយ ។ នែបងអណ្តើក បងឯងមិនត្រូវគេបៀតបៀន មិនត្រូវគេប្រហារទេឬ ។ នែបងអណ្តើក ខ្ញុំមិនត្រូវគេបៀតបៀន មិនត្រូវគេប្រហារទេ គ្រាន់តែមានខ្សែនេះជាប់តាមអំពីក្រោយខ្នងខ្ញុំប៉ុណ្ណោះ ។ នែបងណ្តើក អើនោះហើយហៅថា ត្រូវគេបៀតបៀន អើនោះហើយហៅថា ត្រូវគេប្រហារ នែបងអណ្តើក មាតាបិតាក្តី ជីដូនជីតាក្តី របស់បងឯង ដល់នូវសេចក្តីទុក្ខ ដល់នូវសេចក្តីវិនាស ដោយខ្សែនេះឯង នែបងអណ្តើក ឥឡូវនេះ បងឯងចូរទៅចុះ ឥឡូវនេះ បងឯងមិនមែនជារបស់យើងទេ ។

[២១២] ម្នាលភិក្ខុទាំងឡាយ ពាក្យថា ព្រាននេះ ជាឈ្មោះនៃមារចិត្តបាប ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា មូលនេះ ជាឈ្មោះនៃលាភសក្ការៈ និងសេចក្តីសរសើរ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ខ្សែនេះ ជាឈ្មោះនៃនន្ទិរាគ (តម្រេកដោយសេចក្តីភ្លើតភ្លើន) ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុឯណានីមួយ ត្រេកអរ ត្រូវការនូវលាភសក្ការៈ និងសេចក្តីសរសើរ ដែលកើតឡើងហើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះហៅថា អ្នកដល់នូវសេចក្តីទុក្ខ ដល់នូវសេចក្តីវិនាស ត្រូវតាមអំពើដោយបំណងរបស់មារចិត្តបាប ។

ឯវំ ទារុណោ ខោ ភិក្ខវេ លាភសក្ការសិលោកោ ។ បេ ។ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។ តតិយំ ។

[២១៣] សាវត្ថិយំ វិហរតិ... ទារុណោ ភិក្ខវេ លាភសក្ការសិលោកោ ។ បេ ។ អធិគមាយ ។

[២១៤] សេយ្យថាបិ ភិក្ខវេ ទីឃលោមិកា ឯឡ-កា កណ្ដកគហនំ បវិសេយ្យ សា តត្រ តត្រ សជ្ជេយ្យ តត្រ តត្រ គណ្ហេយ្យ តត្រ តត្រ ពជ្ឈេយ្យ តត្រ តត្រ អនយព្យសនំ អាបជ្ជេយ្យ ឯវមេវ ខោ ភិក្ខវេ ឥធេកច្ចោ ភិក្ខុ លាភសក្ការសិលោកេន អភិភូតោ បរិយាទិន្នចិត្តោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ គាមំ វា និគមំ វា បិណ្ឌាយ បវិ-សតិ សោ តត្រ តត្រ សជ្ជតិ តត្រ តត្រ គយ្ហតិ តត្រ តត្រ ពជ្ឈតិ តត្រ តត្រ អនយព្យសនំ អាបជ្ជតិ ។

ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្តីសរសើរ ជារបស់អាក្រក់ យ៉ាងនេះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាង នេះចុះ ។ ចប់សូត្រទី ៣ ។

[២១៣] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្តីសរសើរ ជារបស់អាក្រក់ ។ បេ ។ ធ្វើនូវសេចក្តីអន្តរាយដល់ការត្រាស់ដឹង ។

[២១៤] ម្នាលភិក្ខុទាំងឡាយ ដូចមេចៀមមានរោមវែង ចូលទៅកាន់ព្រៃស្បាតដែលមានបន្លា មេចៀមនោះ ក៏ជាប់នៅក្នុងទីនោះ ៗ ទាក់នៅក្នុងទីនោះ ៗ ជំពាក់នៅក្នុងទីនោះ ៗ ដល់នូវសេចក្តីទុក្ខនិងសេចក្តីវិនាសក្នុងទីនោះ ៗ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពួកខ្លះក្នុងសាសនានេះ ត្រូវលាភសក្ការៈនិងសេចក្តីសរសើរគ្របសង្កត់ រួបរឹតចិត្ត ក៏ស្លៀកស្បង់ប្រដាប់បាត្រចីវរ ក្នុងវេលាបុព្វណ្ហសម័យ ហើយចូលទៅកាន់ស្រុកក្តី និគមក្តី ដើម្បីបិណ្ឌបាត ភិក្ខុនោះ រមែងជាប់នៅក្នុងទីនោះ ៗ រមែងទាក់នៅក្នុងទីនោះ ៗ រមែងជំពាក់នៅក្នុងទីនោះ ៗ រមែងដល់នូវសេចក្តីទុក្ខ និងសេចក្តីវិនាសក្នុងទីនោះ ៗ យ៉ាងនេះឯង ។

ឯវំ ទារុណោ ខោ ភិក្ខវេ លាភសក្ការសិលោកោ ។ បេ ។ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។ ចតុត្ថំ ។

[២១៥] សាវត្ថិយំ វិហរតិ... ទារុណោ ភិក្ខវេ លាភសក្ការសិលោកោ ។ បេ ។ អធិគមាយ ។

[២១៦] សេយ្យថាបិ ភិក្ខវេ កាំសឡ្បកា(១) គូថាទី គូថបូរា បុណ្ណា គូថស្ស បូរតោ ចស្ស(២) មហាគូថបុញ្ជោ សា តេន អញ្ញា កាំសឡ្បកា អតិមញ្ញេយ្យ អហម្ហិ គូថាទី គូថបូរា បុណ្ណា គូថស្ស បូរតោ ច ម្យាយំ មហាគូថបុញ្ជោតិ ។ ឯវមេវ ខោ ភិក្ខវេ ឥធេកច្ចោ ភិក្ខុ លាភសក្ការសិលោកេនាភិភូតោ

---

១ ឱ. បិឡ្ហកា ។ ម. មិឡ្ហកា ។ ២ ចស្សា ឥតិ បាឋោ យុត្តតរោ ។

ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្ដីសរសើរ ជារបស់អាក្រក់យ៉ាងនេះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។ ចប់សូត្រទី ៤ ។

[២១៥] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្ដីសរសើរ ជារបស់អាក្រក់ ។ បេ ។ ធ្វើនូវសេចក្ដីអន្តរាយដល់ការត្រាស់ដឹង ។

[២១៦] ម្នាលភិក្ខុទាំងឡាយ ដូចសត្វកំពោង[១] ទំពាស៊ីនូវលាមក ខាងក្នុងពេញដោយលាមក បរិបូណ៌ដោយលាមក មានគំនរនៃលាមកធំពីខាងក្នុង សត្វកំពោងនោះ ក៏មើលងាយសត្វកំពោងដទៃ ដោយហេតុនោះថា អាត្មាអញទំពាស៊ីលាមក ខាងក្នុងពេញដោយលាមក បរិបូណ៌ដោយលាមក នេះជាគំនរនៃលាមកដ៏ធំពីខាងមុខអាត្មាអញ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពួកខ្លះ ក្នុងសាសនានេះ ត្រូវលាភសក្ការៈនិងសេចក្ដីសរសើរគ្របសង្កត់

---

១ ឈ្មោះសត្វតូចមួយយ៉ាងស្រដៀងគ្នានឹងកញ្ចែ មានស្លាបពីរជាន់ ច្រើនត្បុលលុញលាមក។

បរិយាទិន្នចិត្តោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ គាមំ វា និគមំ វា បិណ្ឌាយ បវិសតិ សោ តត្ថ កុត្តាវី ច ហោតិ យាវទត្ថោ និមន្តិតោ ច ស្វាតនាយ បិណ្ឌបាតោបស្ស បូរោ សោ អារាមំ គន្ត្វា ភិក្ខុគណស្ស មជ្ឈេ វិកថេតិ កុត្តាវី ចម្ហិ យាវទត្ថោ និមន្តិតោ ចម្ហិ ស្វាតនាយ បិណ្ឌបាតោ ច ម្យាយំ បូរោ លាភី ចម្ហិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ ឥមេ បន អញ្ញេ ភិក្ខូ អប្បបុញ្ញា អប្បេសក្ខា ន លាភិនោ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានន្តិ ។ សោ តេន លាភសក្ការសិលោកេន អភិភូតោ បរិយាទិន្នចិត្តោ អញ្ញេ បេសលេ ភិក្ខូ អតិមញ្ញតិ ។ តញ្ហិ តស្ស ភិក្ខវេ មោឃបុរិសស្ស ហោតិ ទីឃរត្តំ អហិតាយ ទុក្ខាយ ។ ឯវំ ទារុណោ ខោ ភិក្ខវេ លាភសក្ការសិលោកោ ។ បេ ។ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។ បញ្ចមំ ។

រូបរឹតចិត្ត ក៏ស្លៀកស្បង់ប្រដាប់បាត្រចីវរ ក្នុងវេលាបុព្វណ្ហសម័យ ហើយចូលទៅកាន់ស្រុកក្តី និគមក្តី ដើម្បីបិណ្ឌបាត ភិក្ខុនោះក៏បរិភោគភត្តក្នុងទីនោះដរាបដល់ឆ្អែតផង មានគេនិមន្តដើម្បីឆាន់ក្នុងថ្ងៃស្អែកផង ចង្ហាន់បិណ្ឌបាតក៏មានពោរពេញ ភិក្ខុនោះទៅកាន់អារាមវិញ ពោលអួតកណ្តាលពពួកនៃភិក្ខុថា ខ្ញុំបានបរិភោគភត្តដរាបដល់ឆ្អែតផង មានគេនិមន្តដើម្បីឆាន់ក្នុងថ្ងៃស្អែកផង នេះជាចង្ហាន់បិណ្ឌបាតដ៏ពោរពេញរបស់ខ្ញុំផង ខ្ញុំជាបុគ្គលបាននូវចីវរ បិណ្ឌបាត សេនាសនៈ និងគ្រឿងបរិក្ខារ គឺថ្នាំជាបច្ច័យដល់អ្នកជំងឺផង ពួកភិក្ខុដទៃទាំងអម្បាលនេះមានបុណ្យតិច ស័ក្តិតូច មិនបាននូវចីវរ បិណ្ឌបាត សេនាសនៈ និងគ្រឿងបរិក្ខារ គឺថ្នាំជាបច្ច័យដល់អ្នកជំងឺទេ ។ ភិក្ខុនោះ ត្រូវលាភសក្ការៈនិងសេចក្តីសរសើរនោះគ្របសង្កត់ រូបរឹតចិត្ត តែងមើលងាយនូវពួកភិក្ខុឯទៀត ដែលមានសីលជាទីស្រឡាញ់ យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ អំពើនោះឯង ជាអំពើប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខអស់កាលដ៏វែង ដល់មោឃបុរសនោះ ។ ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្តីសរសើរ ជារបស់អាក្រក់យ៉ាងនេះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។

ចប់សូត្រទី ៥ ។

[២១៧] សាវត្ថិយំ វិហរតិ... ទារុណោ ភិក្ខវេ លាភសក្ការសិលោកោ ។ បេ ។ អធិគមាយ ។

[២១៨] កាំ ភិក្ខវេ អសនិវិចក្កំ ។ [១]សេក្ខំ អប្បត្តមានសំ លាភសក្ការសិលោកោ អនុចាបុណាតិ ។ អសនិវិចក្កន្តិ ខោ ភិក្ខវេ លាភសក្ការសិលោកស្សេតំ អធិវចនំ ។ ឯវំ ទារុណោ ខោ ភិក្ខវេ លាភសក្ការសិលោកោ ។ បេ ។ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។ ឆដ្ឋំ ។

[២១៩] សាវត្ថិយំ វិហរតិ... ទារុណោ ភិក្ខវេ លាភសក្ការសិលោកោ ។ បេ ។ អធិគមាយ ។

១ ឱ. ម. តំ សេក្ខំ ។

[២១៧] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្ដីសរសើរជារបស់អាក្រក់ ។ បេ ។ ធ្វើនូវសេចក្ដីអន្តរាយដល់ការត្រាស់ដឹង ។

[២១៨] ម្នាលភិក្ខុទាំងឡាយ កាំរន្ទះធ្លាក់ចំលើបុគ្គលណា ។ លាភសក្ការៈនិងសេចក្ដីសរសើរ តែងដល់ដោយលំដាប់ ចំពោះសេក្ខ-បុគ្គលដែលមិនទាន់បានសម្រេចព្រះអរហត្តផល ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា កាំរន្ទះនេះ ជាឈ្មោះនៃលាភសក្ការៈនិងសេចក្ដីសរសើរ ។ ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្ដីសរសើរ ជារបស់អាក្រក់យ៉ាងនេះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។ ចប់សូត្រទី ៦ ។

[២១៩] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្ដីសរសើរជារបស់អាក្រក់ ។ បេ ។ ធ្វើនូវសេចក្ដីអន្តរាយដល់ការត្រាស់ដឹង ។

[២២០] កាំ ភិក្ខវេ សល្លេន វិជ្ឈតិ ។ សេក្ខំ អប្បត្តមានសំ លាភសក្ការសិលោកោ អនុបាបុណាតិ ។ សល្លន្តិ ខោ ភិក្ខវេ លាភសក្ការសិលោកស្សេតំ អធិវចនំ ។ ឯវំ ទារុណោ ខោ ភិក្ខវេ លាភសក្ការសិលោកោ ។ បេ ។ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។ សត្តមំ ។

[២២១] សាវត្ថិយំ វិហរតិ... ទារុណោ ភិក្ខវេ លាភសក្ការសិលោកោ ។ បេ ។ អធិគមាយ ។

[២២២] បស្សថ នោ តុម្ហេ ភិក្ខវេ រត្តិយា បច្ចូសសមយំ ជរសិគាលស្ស វស្សមានស្សាតិ ។ ឯវំ ភន្តេ ។ សោ ខោ ភិក្ខវេ ជរសិគាលោ ឧក្កណ្ណកេន នាម រោគជាតេន ផុដ្ឋោ នេវ ពលគតោ រមតិ ន រុក្ខមូលគតោ រមតិ ន អព្ភោកាសគតោ

[២២០] ម្នាលភិក្ខុទាំងឡាយ បុគ្គលចាក់នូវបុគ្គលណាដោយសរ ។ លាភសក្ការៈនិងសេចក្ដីសរសើរ រមែងដល់ដោយលំដាប់ចំពោះសេក្ខបុគ្គលដែលមិនទាន់បានសម្រេចអរហត្តផល ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា សរនេះ ជាឈ្មោះនៃលាភសក្ការៈនិងសេចក្ដីសរសើរ ។ ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្ដីសរសើរ ជារបស់អាក្រក់យ៉ាងនេះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។ ចប់សូត្រទី ៧ ។

[២២១] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្ដីសរសើរជារបស់អាក្រក់ ។ បេ ។ ធ្វើនូវសេចក្ដីអន្តរាយដល់ការត្រាស់ដឹង ។

[២២២] ម្នាលភិក្ខុទាំងឡាយ កាលសត្វចចកចាស់ នៅក្នុងវេលាបច្ចូសសម័យនៃរាត្រី អ្នកទាំងឡាយបានឃើញដែរឬទេ ។ ភិក្ខុទាំងឡាយទូលថា ព្រះករុណា ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ សត្វចចកចាស់នោះ កើតរោគអង្គែ[១] ហើយរមែងទៅកាន់ទីគោក ក៏មិនស្រួល ទៅនៅក្រោមម្លប់ឈើ ក៏មិនស្រួល ទៅនៅក្នុងទីវាល

១ រោគនេះច្រើនកើតក្នុងរដូវត្រជាក់ កាលបើកើតឡើងរហ័ស រមែងជ្រុះរោមអស់ ហើយមានកមពងខ្ទុះដាសពាសពេញសរីរៈ (អដ្ឋកថា) ។

រមតិ យេន យេន គច្ឆតិ យត្ថ យត្ថ តិដ្ឋតិ យត្ថ យត្ថ និសីទតិ យត្ថ យត្ថ និបជ្ជតិ តត្ថ តត្ថ អនយព្យសនំ អាបជ្ជតិ ។ ឯវមេវ ខោ ភិក្ខវេ ឥធេកច្ចោ ភិក្ខុ លាភសក្ការសិលោកេន អភិភូតោ បរិយាទិន្នចិត្តោ នេវ សុញ្ញាគារគតោ រមតិ ន រុក្ខមូលគតោ រមតិ ន អព្ភោកាសគតោ រមតិ យេន យេន គច្ឆតិ យត្ថ យត្ថ តិដ្ឋតិ យត្ថ យត្ថ និសីទតិ យត្ថ យត្ថ និបជ្ជតិ តត្ថ តត្ថ អនយព្យសនំ អាបជ្ជតិ ។ ឯវំ ទារុណោ ខោ ភិក្ខវេ លាភសក្ការសិលោកោ ។ បេ ។ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។ អដ្ឋមំ ។

[២២៣] សាវត្ថិយំ វិហរតិ... ទារុណោ ភិក្ខវេ លាភសក្ការសិលោកោ ។ បេ ។ អធិគមាយ ។

ក៏មិនស្រួល ទុកជាដើរទៅក្នុងទីឯណា ៗ ឈរនៅក្នុងទីឯណា ៗ អង្គុយនៅក្នុងទីឯណា ៗ ដេកក្នុងទីឯណា ៗ ក៏រមែងដល់នូវសេចក្តីទុក្ខនិងសេចក្តីវិនាសក្នុងទីនោះ ៗ (យ៉ាងណាមិញ) ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពួកខ្លះ ក្នុងសាសនានេះ ត្រូវលាភសក្ការៈនិងសេចក្តីសរសើរគ្របសង្កត់ រួបរឹតចិត្ត ទៅកាន់ផ្ទះស្ងាត់ ក៏មិនស្រួល ទៅនៅក្រោមម្លប់ឈើ ក៏មិនស្រួល ទៅនៅក្នុងទីវាល ក៏មិនស្រួល ទុកជាដើរទៅក្នុងទីឯណា ៗ ឈរនៅក្នុងទីឯណា ៗ អង្គុយនៅក្នុងទីឯណា ៗ ដេកនៅក្នុងទីឯណា ៗ ក៏រមែងដល់នូវសេចក្តីទុក្ខនិងសេចក្តីវិនាសក្នុងទីនោះ ៗ យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្តីសរសើរ ជារបស់អាក្រក់ យ៉ាងនេះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។ ចប់សូត្រទី ៨ ។

[២២៣] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្តីសរសើរ ជារបស់អាក្រក់ ។ បេ ។ ធ្វើនូវសេចក្តីអន្តរាយដល់ការត្រាស់ដឹង ។

[២២៤] ឧបរិ ភិក្ខវេ អាកាសេ វេរម្ភា នាម វាតា វាយន្តិ តត្ថ យោ បក្ខី គច្ឆតិ តមេនំ វេរម្ភា វាតា ខិបន្តិ តស្ស វេរម្ភវាតក្ខិត្តស្ស អញ្ញេនេវ បាទា គច្ឆន្តិ អញ្ញេន បក្ខា គច្ឆន្តិ អញ្ញេន សីសំ គច្ឆតិ អញ្ញេន កាយោ គច្ឆន្តិ ។ ឯវមេវ ខោ ភិក្ខវេ ឥធេកច្ចោ ភិក្ខុ លាភសក្ការសិលោកេន អភិភូតោ បរិយាទិន្នចិត្តោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមា-ទាយ គាមំ វា និគមំ វា បិណ្ឌាយ បវិសតិ អរក្ខិ-តេនេវ កាយេន អរក្ខិតាយ វាចាយ អរក្ខិតេន ចិត្តេន អនុបដ្ឋិតាយ សតិយា អសំវុតេហិ ឥន្ទ្រិ-យេហិ សោ តត្ថ បស្សតិ មាតុគ្គាមំ ទុន្និវត្ថំ វា ទុប្បារុតំ វា តស្ស មាតុគ្គាមិ ទិស្វាន ទុន្និវត្ថំ វា ទុប្បារុតំ វា រាគោ ចិត្តំ អនុទ្ធំសេតិ សោ រាគា-នុទ្ធំសេន ចិត្តេន សិក្ខំ បច្ចក្ខាយ ហីនាយា-វត្តតិ តស្ស អញ្ញេ ចីវរំ ហរន្តិ អញ្ញេ បត្តំ ហរន្តិ

[២២៤] ម្នាលភិក្ខុទាំងឡាយ វេរម្ភវាត (ខ្យល់ព្យុះ) បក់ទៅលើអាកាស សត្វស្លាបឯណា ហើរទៅលើអាកាសនោះ វេរម្ភវាតក៏បក់ផាត់សត្វស្លាបនោះ សត្វស្លាបនោះ លុះត្រូវវេរម្ភវាតផាត់ឡើងហើយ ជើងក៏រសាត់ទៅដោយឡែក ស្លាបក៏រសាត់ទៅដោយឡែក ក្បាលក៏រសាត់ទៅដោយឡែក ដងខ្លួនក៏រសាត់ទៅដោយឡែក (យ៉ាងណាមិញ) ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុខ្វះក្នុងសាសនានេះ ត្រូវលាភសក្ការៈនិងសេចក្តីសរសើរគ្របសង្កត់ រួបរឹតចិត្ត ក៏ស្លៀកស្បង់ប្រដាប់បាត្រនិងចីវរក្នុងវេលាបុព្វណ្ហសម័យ ហើយចូលទៅកាន់ស្រុកក្តី និគមក្តី ដើម្បីបិណ្ឌបាតដោយមិនបានរក្សាកាយ មិនបានរក្សាវាចា មិនបានរក្សាចិត្ត មិនបានប្រុងប្រៀបស្មារតី មិនបានសង្រួមឥន្ទ្រិយ ភិក្ខុនោះក៏ឃើញមាតុគ្រាមក្នុងទីនោះ ស្លៀកសំពត់មិនស្រួលក្តី ដណ្តប់សំពត់មិនស្រួលក្តី ភិក្ខុនោះ លុះបានឃើញមាតុគ្រាម ដែលស្លៀកសំពត់មិនស្រួលក្តី ដណ្តប់សំពត់មិនស្រួលក្តីហើយ រាគៈក៏កម្ចាត់ចិត្ត ភិក្ខុនោះ លុះត្រូវរាគៈគ្របសង្កត់ចិត្តហើយ ក៏ពោលលាសិក្ខា ត្រឡប់ទៅកាន់ហីនភេទវិញ ពួកភិក្ខុឯទៀតក៏យកចីវរ ពួកភិក្ខុឯទៀតយកបាត្រ

អញ្ញោ និសីទនំ ហរន្តិ អញ្ញោ សូចិឃរំ ហរន្តិ វេរម្ភ-
វាតុក្ខិតស្សេវ សកុណស្ស ។ ឯវំ ទារុណោ ខោ ភិក្ខវេ
លាភសក្ការសិលោកោ ។ បេ ។ ឯវញ្ហិ វោ ភិក្ខវេ
សិក្ខិតព្វន្តិ ។ ទវមំ ។

[២២៥] សាវត្ថិយំ វិហរតិ... ទារុណោ ភិក្ខវេ
លាភសក្ការសិលោកោ ។ បេ ។ អធិគមាយ ។

[២២៦] ឥធាហំ ភិក្ខវេ ឯកច្ចំ បុគ្គលំ ប-
ស្សាមិ សក្ការេន អភិភូតំ បរិយាទិន្នចិត្តំ កាយស្ស
ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ
ឧបបន្នំ ។ ឥធ បនាហំ ភិក្ខវេ ឯកច្ចំ បុគ្គលំ
បស្សាមិ អសក្ការេន អភិភូតំ បរិយាទិន្នចិត្តំ កា-
យស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ
និរយំ ឧបបន្នំ ។ ឥធ បនាហំ ភិក្ខវេ ឯកច្ចំ
បុគ្គលំ បស្សាមិ សក្ការេន ច អសក្ការេន ច

ពួកភិក្ខុឯទៀតយកនិសីទនៈ ពួកភិក្ខុទៀតយកបំពង់ម្ជុលរបស់ភិក្ខុនោះ ដូចគ្នានឹងសត្វស្វាបដែលត្រូវវេរម្ភ៍វាតបក់ផាត់ ក៏យ៉ាងនោះឯង ។ ម្នាល ភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្ដីសរសើរ ជារបស់អាក្រក់យ៉ាង នេះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាង នេះចុះ ។ ចប់សូត្រទី ៩ ។

[២២៥] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្ដីសរសើរ ជារបស់អាក្រក់ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងលោកនេះ តថាគតឃើញ បុគ្គលពួកខ្លះ ត្រូវគ្រឿងសក្ការៈគ្របសង្កត់ រួបរឹតចិត្ត លុះបែកធ្លាយ រាងកាយខាងមុខអំពីមរណៈ តែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នរក ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ក្នុងលោក នេះ តថាគតឃើញបុគ្គលពួកខ្លះ ត្រូវអសក្ការៈ[១]គ្រប់សង្កត់ រួបរឹត ចិត្ត លុះបែកធ្លាយរាងកាយខាងមុខអំពីមរណៈ តែងទៅកើតក្នុងកំណើត តិរច្ឆាន ប្រេត អសុរកាយ នរក ។ ម្នាលភិក្ខុទាំងឡាយ ក្នុងលោក នេះ តថាគតឃើញបុគ្គលពួកខ្លះ ត្រូវគ្រឿងសក្ការៈផង អសក្ការៈផង

---

១ មិនមានគ្រឿងសក្ការបូជា ។

តេនុភយេន អភិភូតំ បរិយាទិន្នចិត្តំ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជំ ។ ឯវំ ទារុណោ ខោ ភិក្ខវេ លាភសក្ការសិលោកោ ។ បេ ។ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។

[២២៧] ឥទមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា

យស្ស សក្ករិយមានស្ស
អសក្ការេន ចូភយំ
សមាធិ ន វិកម្បតិ
អប្បមាណវិហារិនោ[១]
តំ ឈាយិនំ សាតតិកំ
សុខុមទិដ្ឋិវិបស្សកំ
ឧបាទានក្ខយារាមំ
អាហុ សប្បុរិសោ ឥតីតិ ។ ទសមំ ។

សុទ្ធកវគ្គោ បឋមោ ។

---

១ ឱ. ម. អប្បមាទវិហារិនោ ។

ទាំងពីរនោះគ្របសង្កត់ រួបរឹតចិត្ត លុះបែកធ្លាយរាងកាយខាងមុខអំពីមរណៈ តែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នរក ។ ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្ដីសរសើរ ជារបស់អាក្រក់យ៉ាងនេះឯង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។

[២២៧] ព្រះមានព្រះភាគ បានត្រាស់សំដែងនូវសូត្រនេះ លុះព្រះសុគតជាសាស្ដា បានសំដែងនូវសូត្រនេះចប់ហើយ ក៏ទ្រង់ពោលនូវគាថាពន្ធដូច្នេះ តទៅទៀតថា

សមាធិរបស់បុគ្គលឯណា ដែលមានប្រក្រតីនៅដោយផល-
សមាធិ ប្រមាណមិនបាន រមែងមិនញាប់ញ័រដោយសក្ការៈ
ផង ដោយអសក្ការៈផង ដោយសក្ការៈនិងអសក្ការៈទាំងពីរ
ផង អ្នកប្រាជ្ញទាំងឡាយរមែងពោលនូវបុគ្គលនោះដែលជា
អ្នកពិនិត្យ មានព្យាយាមជាប់តគ្នា ជាអ្នកឃើញច្បាស់
ដោយទិដ្ឋិដ៏សុខុម ត្រេកអរចំពោះព្រះនិព្វាន ជាទីក្ស័យ
នៃឧបាទាន ថាជាសប្បុរសដូច្នេះ ។ ចប់សូត្រទី ១០ ។

ចប់ សុទ្ធកវគ្គ ទី ១ ។

១៩៨

លាភសក្ការសំយុត្តស្ស សុទ្ធកវគ្គេ ឧទ្ទានំ

# តស្ស ឧទ្ទានំ

សុទ្ធកំ ពឡិសំ កុម្មំ
ជីឃលោមំ បុដេឡកំ
អសនិ សរំ សិគាលំ
វេរម្ភេន សកយ្ហកាឌ្ឌិ ។

# ឧទ្ទាននៃសុទ្ធកវគ្គនោះគឺ

*និយាយអំពីលាភសក្ការៈនិងសេចក្តីសរសើរសុទ្ធ ១ និយាយអំពីលាភសក្ការៈ និងសេចក្តីសរសើរប្រៀបដោយផ្ទៃសន្ធូច ១ ប្រៀបដោយមូលចាក់សត្វអណ្តើក ១ ប្រៀបដោយមេចៀមមានរោមវែង (ប្រៀបដោយសត្វកំពោងបានដុំលាមក[១] ១) ប្រៀបដោយកាំរន្ទះ ១ ប្រៀបដោយសរ ១ ប្រៀបដោយសត្វចចកចាស់ ១ ប្រៀបដោយវេរម្ភវាត ១ និយាយអំពីបុគ្គលមានចិត្តត្រូវសក្ការៈជាដើមគ្របសង្កត់ ១ ។*

---

១ ពាក្យក្នុងវង់ក្រចកនេះ ប្រែតាមសេចក្តីក្នុងសូត្រទី៥ ព្រោះសូត្រនេះមិនមានស្រង់បាលីទុកក្នុងឧទ្ទានគាថានេះ ។

# បាតិវគ្គោ

[២២៨] សាវត្ថិយំ វិហរតិ... ទារុណោ ភិក្ខវេ លាភសក្ការសិលោកោ ។ បេ ។ អធិគមាយ ។

[២២៩] ឥធាហំ ភិក្ខវេ ឯកច្ចំ បុគ្គលំ ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ ន វាយមាយស្មា សុវណ្ណបាតិយាបិ រូបិយចុណ្ណបរិបូរាយ ហេតុ សម្បជានមុសា ភាសេយ្យាតិ តមេនំ បស្សាមិ អបរេន សមយេន លាភសក្ការសិលោកេន អភិភូតំ បរិយាទិន្នចិត្តំ សម្បជានមុសា ភាសន្តំ ។ ឯវំ ទារុណោ ខោ ភិក្ខវេ លាភសក្ការសិលោកោ ។ បេ ។ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។ បឋមំ ។

[២៣០] សាវត្ថិយំ វិហរតិ... ទារុណោ ភិក្ខវេ លាភសក្ការសិលោកោ ។ បេ ។ អធិគមាយ ។

# បាតិវគ្គ

[២២៨] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្ដីសរសើរ ជារបស់អាក្រក់ ។ បេ ។ ធ្វើនូវសេចក្ដីអន្តរាយដល់ការត្រាស់ដឹង ។

[២២៩] ម្នាលភិក្ខុទាំងឡាយ ក្នុងលោកនេះ តថាគតកំណត់ដឹងច្បាស់នូវចិត្តបុគ្គលពួកខ្លះ ដោយចិត្តរបស់តថាគតយ៉ាងនេះថា អ្នកនេះមិនគប្បីពោលសម្បជានមុសា (និយាយកុហកទាំងដឹងខ្លួន) ព្រោះហេតុនៃភាជនៈមាស ដ៏ពេញដោយលំអិតនៃប្រាក់ទេ លុះសម័យខាងក្រោយមក តថាគតឃើញបុគ្គលនោះ ត្រូវលាភសក្ការៈនិងសេចក្ដីសរ-សើរគ្របសង្កត់ រួបរឹតចិត្ត ក៏ពោលនូវសម្បជានមុសា ។ ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្ដីសរសើរ ជារបស់អាក្រក់យ៉ាងនេះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។ ចប់សូត្រទី ១ ។

[២៣០] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្ដីសរសើរ ជារបស់អាក្រក់ ។ បេ ។ ធ្វើនូវសេចក្ដីអន្តរាយដល់ការត្រាស់ដឹង ។

[២៣១] ឥធាហំ ភិក្ខវេ ឯកច្ចំ បុគ្គលំ ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ ន វាយមាយស្មា រូបិយចាតិយាបិ សុវណ្ណចុណ្ណបរិបូរាយ ហេតុ សម្បជានមុសា ភាសេយ្យាតិ តមេនំ បស្សាមិ អបរេន សមយេន លាភសក្ការសិលោកេន អភិភូតំ បរិយាទិន្នចិត្តំ សម្បជានមុសា ភាសន្តំ ។ ឯវំ ទារុណោ ខោ ភិក្ខវេ លាភសក្ការសិលោកោ ។ បេ ។ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។ ទុតិយំ ។

[២៣២] សាវត្ថិយំ វិហរតិ... ឥធាហំ ភិក្ខវេ ឯកច្ចំ បុគ្គលំ ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ ន វាយមាយស្មា សុវណ្ណនិក្ខស្សាបិ ហេតុ... សុវណ្ណនិក្ខសតស្សាបិ ហេតុ... សិង្គីនិក្ខស្សាបិ ហេតុ... សិង្គីនិក្ខសតស្សាបិ ហេតុ... បឋវិយាបិ ជាតរូបបរិបូរាយ ហេតុ... អាមិសកិញ្ចិក្ខហេតុបិ... ជីវិតហេតុបិ... ជនបទកល្យាណិយាបិ ហេតុ សម្បជានមុសា ភាសេយ្យាតិ តមេនំ បស្សាមិ អបរេន សមយេន លាភសក្ការសិលោកេន អភិភូតំ បរិយាទិន្នចិត្តំ

[២៣១] ម្នាលភិក្ខុទាំងឡាយ ក្នុងលោកនេះ តថាគតកំណត់ដឹងច្បាស់នូវចិត្តបុគ្គលពួកខ្លះ ដោយចិត្តរបស់តថាគតយ៉ាងនេះថា អ្នកនេះមិនគប្បីពោលសម្បជានមុសា ព្រោះហេតុនៃភាជនៈប្រាក់ដ៏ពេញដោយលំអិតនៃមាសទេ លុះសម័យខាងក្រោយមក តថាគតឃើញបុគ្គលនោះ ត្រូវលាភសក្ការៈនិងសេចក្ដីសរសើរគ្របសង្កត់ រួបរឹតចិត្តក៏ពោលនូវសម្បជានមុសា ។ ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្ដីសរសើរ ជារបស់អាក្រក់យ៉ាងនេះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។ ចប់សូត្រទី ២ ។

[២៣២] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងលោកនេះ តថាគតកំណត់ដឹងច្បាស់នូវចិត្តបុគ្គលពួកខ្លះ ដោយចិត្តរបស់តថាគតយ៉ាងនេះថា អ្នកនេះ មិនគប្បីពោលសម្បជានមុសា ព្រោះហេតុនៃដុំមាស ១... ព្រោះហេតុនៃដុំមាស ១០០... ព្រោះហេតុនៃដុំមាសសិង្គិ ១... ព្រោះហេតុនៃដុំមាសសិង្គិ ១០០... ព្រោះហេតុនៃផែនដីដ៏ពេញដោយមាស... ព្រោះហេតុតែអាមិសបន្តិចបន្តួច... ព្រោះហេតុតែជីវិត... ព្រោះហេតុនៃស្រីមានលម្អក្នុងជនបទ លុះសម័យខាងក្រោយមក តថាគតឃើញបុគ្គលនោះ ត្រូវលាភសក្ការៈនិងសេចក្ដីសរសើរគ្របសង្កត់ រួបរឹតចិត្ត

សម្បជានមុសា ភាសន្តំ ។ ឯវំ ទារុណោ ខោ ភិក្ខវេ លាភសក្ការសិលោកោ ។ បេ ។ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។ ទសមំ ។

បាតិវគ្គោ ទុតិយោ ។

## តស្ស ឧទ្ទានំ

ទ្វេ ចាតី ទ្វេ សុវណ្ណា
សិង្គីហិ អបរេ ទុវេ
បឋវី កិញ្ចិក្ខជីវិត-
ជនបទកល្យាណិយា ទសាតិ ។

---

កំពោលនូវសម្បជានមុសា ។ ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិង សេចក្តីសរសើរ ជារបស់អាក្រក់យ៉ាងនេះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។ ចប់សូត្រទី ១០ ។

ចប់ បាតិវគ្គទី ២ ។

## ឧទ្ទាននៃបាតិវគ្គនោះគឺ

និយាយអំពីភាជនៈពីរលើក និយាយអំពីមាសពីរលើក និ- យាយអំពីមាសសិង្គីពីរលើក និយាយអំពីផែនដី ១ និយាយ អំពីអាមិសបន្តិចបន្តួច ១ និយាយអំពីជីវិត ១ និយាយអំពី ស្រីមានលម្អក្នុងជនបទ ១ ជា ១០ ។

# មាតុគ្គាមវគ្គោ

[២៣៣] សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា... ទារុណោ ភិក្ខវេ លាភសក្ការសិលោកោ ។ បេ ។ អធិគមាយ ។

[២៣៤] ន តស្ស ភិក្ខវេ មាតុគ្គាមោ ឯកោ ឯកស្ស ចិត្តំ បរិយាទាយ តិដ្ឋតិ យស្ស លាភសក្ការសិលោកោ ចិត្តំ បរិយាទាយ តិដ្ឋតិ ។ បេ ។ ឯវំ ទារុណោ ខោ ភិក្ខវេ លាភសក្ការសិលោកោ ។ បេ ។ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។ បឋមំ ។

[២៣៥] សាវត្ថិយំ វិហរតិ... ទារុណោ ភិក្ខវេ លាភសក្ការសិលោកោ ។ បេ ។ អធិគមាយ ។

# មាតុគ្គាមវគ្គ

[២៣៣] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ក្នុងទីនោះឯង ព្រះមានព្រះភាគ... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្ដីសរសើរ ជារបស់អាក្រក់ ។ បេ ។ ធ្វើនូវសេចក្ដីអន្តរាយដល់ការត្រាស់ដឹង ។

[២៣៤] ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្ដីសរសើរ រមែងគ្របសង្កត់ចិត្តនៃបុគ្គលឯណាបាន ឯមាតុគ្រាមម្នាក់ មិនអាចគ្របសង្កត់ចិត្តនៃបុគ្គលនោះតែម្នាក់ឯងបានទេ ។ បេ ។ ម្នាលភិក្ខុទាំង-ឡាយ លាភសក្ការៈនិងសេចក្ដីសរសើរ ជារបស់អាក្រក់យ៉ាងនេះឯង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។ ចប់សូត្រទី ១ ។

[២៣៥] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្ដីសរសើរ ជារបស់អាក្រក់ ។ បេ ។ ធ្វើនូវសេចក្ដីអន្តរាយដល់ការត្រាស់ដឹង ។

[២៣៦] ន តស្ស ភិក្ខវេ ជនបទកល្យាណី ឯកា ឯកស្ស ចិត្តំ បរិយាទាយ តិដ្ឋតិ យស្ស លាភសក្ការសិលោកោ ចិត្តំ បរិយាទាយ តិដ្ឋតិ ។ បេ ។ ឯវំ ទារុណោ ខោ ភិក្ខវេ លាភសក្ការសិលោកោ ។ បេ ។ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។ ទុតិយំ ។

[២៣៧] សាវត្ថិយំ វិហរតិ... ទារុណោ ភិក្ខវេ លាភសក្ការសិលោកោ ។ បេ ។ អធិគមាយ ។

[២៣៨] សទ្ធា ភិក្ខវេ ឧបាសិកា ឯកំ បុត្តកំ បិយំ មនាបំ ឯវំ សម្មា អាយាចមានា អាយាចេយ្យ តាទិសោ តាត ភវាហិ យាទិសោ ចិត្តោ ច គហបតិ ហត្ថកោ ច អាឡវកោតិ ។ ឯសា ភិក្ខវេ តុលា ឯតំ បមាណំ មម សាវកានំ ឧបាសកានំ យទិទំ

[២៣៦] ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្តីសរសើរ រមែងគ្របសង្កត់ចិត្តនៃបុគ្គលឯណាបាន ឯស្រីមានលម្អក្នុងជនបទម្នាក់ មិនអាចគ្របសង្កត់ចិត្តនៃបុគ្គលនោះតែម្នាក់ឯងបានទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្តីសរសើរ ជារបស់អាក្រក់យ៉ាងនេះឯង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។ ចប់សូត្រទី ២ ។

[២៣៧] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្តីសរសើរ ជារបស់អាក្រក់ ។ បេ ។ ធ្វើនូវសេចក្តីអន្តរាយដល់ការត្រាស់ដឹង ។

[២៣៨] ម្នាលភិក្ខុទាំងឡាយ ប្រសិនបើឧបាសិកាមានសទ្ធា កាលនិយាយអង្វរដោយប្រពៃ ក៏និយាយអង្វរ ចំពោះកូនប្រុសតូចម្នាក់ ដែលជាទីស្រឡាញ់ ជាទីពេញចិត្តយ៉ាងនេះថា នៃកូន ចូរបាមានគុណសម្បត្តិប្រាកដដូចចិត្តគហបតី និងហត្ថកឧបាសកអ្នកស្រុកអាឡវីចុះ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាពួកឧបាសកជាសាវករបស់តថាគត

ចិត្តោ ច គហបតិ ហត្ថកោ ច អាឡវកោ ។ សចេ ខោ ត្វំ តាត អគារស្មា អនគារិយំ បព្វជសិ តាទិសោ តាត ភវាហិ យាទិសា សារីបុត្តមោគ្គល្លានាតិ ។ ឯសា ភិក្ខវេ តុលា ឯតំ បមាណំ មម សាវកានំ ភិក្ខូនំ យទិទំ សារីបុត្តមោគ្គល្លានា ។ មា ច ខោ តំ តាត សេក្ខំ អប្បត្តមានសំ លាភសក្ការសិលោកោ អនុបាបុណា-តីតិ[១] ។ តញ្ចេ ភិក្ខវេ ភិក្ខុំ សេក្ខំ អប្បត្តមានសំ លាភសក្ការសិលោកោ អនុបាបុណាតិ សោ តស្ស ហោតិ អន្តរាយាយ ។ ឯវំ ទារុណោ ខោ ភិក្ខវេ លាភសក្ការសិលោកោ ។ បេ ។ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។ តតិយំ ។

១ ឱ. ម. អនុបាបុណាតូតិ ។

មានតែចិត្តគហបតី ១ ហត្ថកឧបាសកអ្នកស្រុកអាឡវី ១ នុ៎ះជាជញ្ជីង នុ៎ះជាខ្នាត ។ (ឧបាសិកាគប្បីនិយាយអង្វរ) ថា នែកូន បើឯងចេញចាកផ្ទះហើយចូលទៅកាន់ផ្នួស នែកូន ចូរបាមានគុណសម្បត្តិប្រាកដដូចជាព្រះសារីបុត្តនិងព្រះមោគ្គល្លានចុះ ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកភិក្ខុជាសាវករបស់តថាគត មានតែសារីបុត្តនិងមោគ្គល្លាន នុ៎ះជាជញ្ជីង នុ៎ះជាខ្នាត ។ (ឧបាសិកាគប្បីនិយាយអង្វរ) ថា នែកូន លាភសក្ការៈនិងសេចក្ដីសរសើរ កុំបីជិតដល់កូនឯង ដែលនៅជាសេក្ខបុគ្គលមិនទាន់បានសម្រេចព្រះអរហត្តផលនៅឡើយ ។ ម្នាលភិក្ខុទាំងឡាយ បើលាភសក្ការៈនិងសេចក្ដីសរសើរមកជិតដល់ភិក្ខុនោះ ដែលនៅជាសេក្ខបុគ្គល មិនទាន់បានសម្រេចព្រះអរហត្តផល លាភសក្ការៈនិងសេចក្ដីសរសើរនោះ នាំឲ្យកើតសេចក្ដីអន្តរាយដល់ភិក្ខុនោះ ។ ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្ដីសរសើរ ជារបស់អាក្រក់យ៉ាងនេះឯង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។ ចប់សូត្រទី ៣ ។

[២៣៩] សាវត្ថិយំ វិហរតិ... ទារុណោ ភិក្ខវេ លាភសក្ការសិលោកោ ។ បេ ។ អធិគមាយ ។

[២៤០] សទ្ធា ភិក្ខវេ ឧបាសិកា ឯកំ ធីតរំ បិយំ មនាបំ ឯវំ សម្មា អាយាចមានា អាយាចេយ្យ តាទិសា អយ្យេ ភវាហិ យាទិសា ខុជ្ជុត្តរា ច ឧបាសិកា វេឡុកណ្ដកិយា ច នន្ទមាតាតិ ។ ឯសា ភិក្ខវេ តុលា ឯតំ បមាណំ មម សាវិកានំ ឧបាសិកានំ យទិទំ ខុជ្ជុត្តរា ច ឧបាសិកា វេឡុកណ្ដកិយា ច នន្ទមាតា ។ សចេ ខោ ត្វំ អយ្យេ អគារស្មា អនគារិយំ បព្វជសិ តាទិសា អយ្យេ ភវាហិ យាទិសា ខេមា ច ភិក្ខុនី ឧប្បលវណ្ណា ចាតិ ។ ឯសា ភិក្ខវេ តុលា ឯតំ បមាណំ មម សាវិកានំ ភិក្ខុនីនំ យទិទំ ខេមា ច ភិក្ខុនី ឧប្បលវណ្ណា ច ។ មា ច ខោ តំ អយ្យេ សេក្ខំ អប្បត្តមានសំ លាភសក្ការសិលោកោ អនុបាបុណាតីតិ ។

[២៣៩] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្តីសរសើរ ជារបស់អាក្រក់ ។ បេ ។ ធ្វើនូវសេចក្តីអន្តរាយដល់ការត្រាស់ដឹង ។

[២៤០] ម្នាលភិក្ខុទាំងឡាយ ឧបាសិកាមានសទ្ធា កាលបើនិយាយអង្វរដោយប្រពៃ ក៏និយាយអង្វរចំពោះកូនស្រីម្នាក់ ដែលជាទីស្រឡាញ់ ជាទីពេញចិត្តយ៉ាងនេះថា នែនាង ចូរនាងមានគុណសម្បត្តិប្រាកដដូចជាឧបាសិកាឈ្មោះខុជ្ជុត្តរា និងឧបាសិកាឈ្មោះវេឡុកណ្ឌកិយានន្ទមាតា ។ ម្នាលភិក្ខុទាំងឡាយ បណ្តាពួកឧបាសិកាជាសាវិការបស់តថាគត មានតែនាងខុជ្ជុត្តរាឧបាសិកា ១ នាងវេឡុកណ្ឌកិយានន្ទមាតា ១ នុ៎ះជាជញ្ជីង នុ៎ះជាខ្នាត ។ (ប្រសិនបើឧបាសិកានិយាយអង្វរ) ថា នែនាង បើឯងចេញចាកផ្ទះហើយចូលទៅកាន់ផ្នួស នែនាង ចូរនាងមានគុណសម្បត្តិប្រាកដដូចជានាងខេមាភិក្ខុនីនិងនាងឧប្បលវណ្ណាភិក្ខុនីចុះ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុនីជាសាវិការបស់តថាគត មានតែនាងខេមាភិក្ខុនី ១ ឧប្បលវណ្ណាភិក្ខុនី ១ នុ៎ះជាជញ្ជីង នុ៎ះជាខ្នាត ។ (ប្រសិនបើឧបាសិកានិយាយអង្វរ ) ថា នែនាង លាភសក្ការៈនិងសេចក្តីសរសើរ កុំបីមកដិតដល់នាងឯង ដែលនៅជាសេក្ខបុគ្គល មិនទាន់បានសម្រេចព្រះអរហត្តផលនៅឡើយ ។

តញ្ច ភិក្ខវេ ភិក្ខុំ ឆេកំ អប្បត្តមានសំ លាភសក្ការសិលោកោ អនុធាបុណាតិ សោ តស្ស ហោតិ អន្តរាយាយ ។ ឯវំ ទារុណោ ខោ ភិក្ខវេ លាភសក្ការសិលោកោ ។ បេ ។ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។ ចតុត្ថំ ។

[២៤១] សាវត្ថិយំ វិហរតិ... យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា លាភសក្ការសិលោកស្ស អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ នប្បជានន្តិ (ឯវំ កាតព្វំ) បជានន្តិ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តីតិ ។ បញ្ចមំ ។

ម្នាលភិក្ខុទាំងឡាយ បើលាភសក្ការៈនិងសេចក្តីសរសើរមកដិតដល់ភិក្ខុនីនោះ ដែលនៅជាសេក្ខបុគ្គល មិនទាន់បានសម្រេចព្រះអរហត្តផលនៅឡើយ លាភសក្ការៈនិងសេចក្តីសរសើរនោះ នាំឲ្យកើតសេចក្តីអន្តរាយដល់ភិក្ខុនីនោះ ។ ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្តីសរសើរ ជារបស់អាក្រក់យ៉ាងនេះឯង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។ ចប់សូត្រទី ៤ ។

[២៤១] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ឯណានីមួយ មិនដឹងច្បាស់តាមពិត នូវអានិសង្សផង នូវទោសផង នៃលាភសក្ការៈនិងសេចក្តីសរសើរ នូវឧបាយជាគ្រឿងរលាស់ចោលនូវលាភសក្ការៈនិងសេចក្តីសរសើរផង (គប្បីធ្វើយ៉ាងនេះចុះ) ដឹងច្បាស់ ធ្វើឲ្យជាក់ច្បាស់ សម្រេចដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ។ ចប់សូត្រទី ៥ ។

[២៤២] សាវត្ថិយំ វិហរតិ... យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា លាភសក្ការសិលោកស្ស សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្ស-រណញ្ច យថាភូតំ នប្បជានន្តិ (ឯវំ កាតព្វំ) ។

[២៤៣] យេ ច ខោ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា លាភសក្ការសិលោកស្ស សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យ-ថាភូតំ បជានន្តិ (ឯវំ កាតព្វំ) វិហរន្តីតិ ។ ឆដ្ឋំ ។

[២៤៤] សាវត្ថិយំ វិហរតិ... យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា លាភសក្ការសិ-លោកំ នប្បជានន្តិ លាភសក្ការសិលោកសមុទយំ នប្បជានន្តិ លាភសក្ការសិលោកនិរោធំ នប្បជានន្តិ

[២៨២] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ឯណានីមួយ មិនដឹងច្បាស់តាមពិត នូវហេតុជាទីកើតឡើងផង នូវសេចក្ដីវិនាសផង នូវអា-និសង្សផង នូវទោសផង នៃលាភសក្ការៈនិងសេចក្ដីសរសើរ នូវឧបាយជាគ្រឿងរលាស់ចោល នូវលាភសក្ការៈនិងសេចក្ដីសរសើរផង (គប្បីធ្វើយ៉ាងនេះចុះ) ។

[២៨៣] ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ឯណានីមួយ ដឹងច្បាស់តាមពិត នូវហេតុជាទីកើតឡើងផង នូវសេចក្ដីវិនាសផង នូវអានិសង្សផង នូវទោសផង នៃលាភសក្ការៈនិងសេចក្ដីសរសើរ នូវឧបាយជាគ្រឿងរលាស់ចោល នូវលាភសក្ការៈនិងសេចក្ដីសរសើរផង (គប្បីធ្វើយ៉ាងនេះចុះ) ។ ចប់សូត្រទី ៦ ។

២៨៤ ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ឯណានីមួយ មិនដឹងច្បាស់នូវលាភសក្ការៈនិងសេចក្ដីសរសើរ មិនដឹងច្បាស់នូវហេតុជាទីកើតឡើងនៃលាភសក្ការៈនិងសេចក្ដីសរសើរ មិនដឹងច្បាស់នូវការរលត់នៃលាភសក្ការៈ

លាភសក្ការសិលោកនិរោធគាមិនី បដិបទំ នប្បជា-នន្តិ (ឯវំ កាតព្វំ) បជានន្តិ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តីតិ ។ សត្តមំ ។

[២៤៨] សាវត្ថិយំ វិហរតិ... ទារុណោ ភិក្ខវេ លា-ភសក្ការសិលោកោ ។ លាភសក្ការសិលោកោ ភិក្ខវេ ឆវឹ ឆិន្ទតិ ឆវឹ ឆេត្វា ចម្មំ ឆិន្ទតិ ចម្មំ ឆេត្វា មំសំ ឆិន្ទតិ មំសំ ឆេត្វា ន្ហារុំ ឆិន្ទតិ ន្ហារុំ ឆេត្វា អដ្ឋឹ ឆិន្ទតិ អដ្ឋឹ ឆេត្វា អដ្ឋិមិញ្ជំ អាហច្ច តិដ្ឋតិ ។ ឯវំ ទារុណោ ខោ ភិក្ខវេ លាភសក្ការសិលោកោ ។ បេ ។ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។ អដ្ឋមំ ។

និងសេចក្ដីសរសើរ មិនដឹងច្បាស់នូវបដិបទា ជាដំណើរទៅកាន់ហេតុជាទីរលត់នៃលាភសក្ការៈនិងសេចក្ដីសរសើរ (គប្បីធ្វើយ៉ាងនេះចុះ) ដឹងច្បាស់ ធ្វើឲ្យជាក់ច្បាស់ សម្រេចដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯង ។ ចប់សូត្រទី ៧ ។

[២៤៥] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្ដីសរសើរ ជារបស់អាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្ដីសរសើរ តែងកាត់នូវស្បែកក្រៅ លុះកាត់ស្បែកក្រៅហើយ តែងកាត់ស្បែកក្នុង លុះកាត់ស្បែកក្នុងហើយ តែងកាត់នូវសាច់ លុះកាត់សាច់ហើយ តែងកាត់នូវសរសៃ លុះកាត់សរសៃហើយ តែងកាត់នូវឆ្អឹង លុះកាត់ឆ្អឹងហើយ តែងចាក់ចុចដល់ខួរក្នុងឆ្អឹង ទើបតាំងនៅ ។ ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្ដីសរសើរ ជារបស់អាក្រក់យ៉ាងនេះឯង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។ ចប់សូត្រទី ៨ ។

[២៤៦] សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា ទារុណោ ភិក្ខវេ លាភសក្ការសិលោកោ ។ លាភសក្ការសិលោកោ ភិក្ខវេ ឆវឹ ឆិន្ទតិ ឆវឹ ឆេត្វា ចម្មំ ឆិន្ទតិ ចម្មំ ឆេត្វា មំសំ ឆិន្ទតិ មំសំ ឆេត្វា ន្ហារុំ ឆិន្ទតិ ន្ហារុំ ឆេត្វា អដ្ឋឹ ឆិន្ទតិ អដ្ឋឹ ឆេត្វា អដ្ឋិមិញ្ជំ អាហច្ច តិដ្ឋតិ ។

[២៤៧] សេយ្យថាបិ ភិក្ខវេ ពលវា បុរិសោ ទឡ្ហាយ វាលរជ្ជុយា ជង្ឃំ វេឋេត្វា ឃំសេយ្យ សា ឆវឹ ឆិន្ទេយ្យ ឆវឹ ឆេត្វា ចម្មំ ឆិន្ទេយ្យ ចម្មំ ឆេត្វា មំសំ ឆិន្ទេយ្យ មំសំ ឆេត្វា ន្ហារុំ ឆិន្ទេយ្យ ន្ហារុំ ឆេត្វា អដ្ឋឹ ឆិន្ទេយ្យ អដ្ឋឹ ឆេត្វា អដ្ឋិមិញ្ជំ អាហច្ចច តិដ្ឋេយ្យ ។ ឯវមេវ ខោ ភិក្ខវេ លាភសក្ការសិលោកោ ឆវឹ ឆិន្ទតិ ឆវឹ ឆេត្វា ចម្មំ ឆិន្ទតិ ចម្មំ ឆេត្វា មំសំ ឆន្ទតិ

[២៤៦] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ក្នុងទីនោះឯង ព្រះមានព្រះភាគ... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្តីសរសើរ ជារបស់អាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្តីសរសើរ តែងកាត់នូវស្បែកក្រៅ លុះកាត់ស្បែកក្រៅហើយ តែងកាត់ស្បែកក្នុង លុះកាត់ស្បែកក្នុងហើយ តែងកាត់នូវសាច់ លុះកាត់សាច់ហើយ តែងកាត់នូវសរសៃ លុះកាត់សរសៃហើយ តែងកាត់នូវឆ្អឹង លុះកាត់ឆ្អឹងហើយ តែងចាក់ចុចដល់ខួរក្នុងឆ្អឹង ទើបតាំងនៅ ។

[២៤៧] ម្នាលភិក្ខុទាំងឡាយ ដូចបុរសមានកម្លាំង រុំស្នងហើយ ពួតដោយខ្សែរោមកន្ទុយសត្វដ៏មាំ ខ្សែនោះគប្បីកាត់នូវស្បែកក្រៅ លុះកាត់ស្បែកក្រៅហើយ គប្បីកាត់នូវស្បែកក្នុង លុះកាត់ស្បែកក្នុងហើយ គប្បីកាត់នូវសាច់ លុះកាត់សាច់ហើយ គប្បីកាត់នូវសរសៃ លុះកាត់សរសៃហើយ គប្បីកាត់នូវឆ្អឹង លុះកាត់ឆ្អឹងហើយ គប្បីចាក់ចុចដល់ខួរក្នុងឆ្អឹង ទើបតាំងនៅ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ លាភ-សក្ការៈនិងសេចក្តីសរសើរ តែងកាត់នូវស្បែកក្រៅ លុះកាត់ស្បែកក្រៅហើយ តែងកាត់នូវស្បែកក្នុង លុះកាត់ស្បែកក្នុងហើយ តែងកាត់នូវសាច់

មំសំ ឆេត្វា នហារុំ ឆិន្ទតិ នហារុំ ឆេត្វា អដ្ឋឹ ឆិន្ទតិ អដ្ឋឹ ឆេត្វា អដ្ឋិមិញ្ជំ អាហច្ច តិដ្ឋតិ ។ ឯវំ ទារុណោ ខោ ភិក្ខវេ លាភសក្ការសិលោកោ ។ បេ ។ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។ នវមំ ។

[២៤៨] សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា... យោបិ សោ ភិក្ខវេ ភិក្ខុ អរហំ ខីណាសវោ តស្សបហំ លា-ភសក្ការសិលោកំ អន្តរាយាយ វទាមីតិ ។ ឯវំ វុត្តេ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច កិស្ស បន ភន្តេ ខីណាសវស្ស ភិក្ខុនោ លាភសក្ការសិលោកោ អន្ត-រាយាយាតិ ។

លុះកាត់សាច់ហើយ តែងកាត់នូវសរសៃ លុះកាត់សរសៃហើយ តែងកាត់នូវឆ្អឹង លុះកាត់ឆ្អឹងហើយ តែងចាក់ចុចដល់ខួរក្នុងឆ្អឹង ទើបតាំងនៅ ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្តីសរសើរ ជារបស់អាក្រក់យ៉ាងនេះឯង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។ ចប់សូត្រទី ៩ ។

[២៤៨] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ក្នុងទីនោះឯង ព្រះមានព្រះភាគ... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សូម្បីភិក្ខុឯណាជាអរហន្តខីណាស្រព តថាគតពោលថា លាភសក្ការៈនិងសេចក្តីសរសើរ ប្រព្រឹត្តទៅដើម្បីសេចក្តីអន្តរាយដល់ភិក្ខុនោះដែរ ។ កាលបើព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះអានន្ទដ៏មានអាយុ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ចុះលាភសក្ការៈនិងសេចក្តីសរសើរ ប្រព្រឹត្តទៅដើម្បីសេចក្តីអន្តរាយដល់ភិក្ខុជាព្រះខីណាស្រព ដូចម្តេច ។

[២៤៩] យា ហិស្ស សា អានន្ទ អកុប្បា ចេតោ-វិមុត្តិ តាហំ តស្សា លាភសក្ការសិលោកំ អន្តរាយាយ វទាមិ ។ យេ ច ខ្វស្ស តេ អានន្ទ អប្បមត្តស្ស អាតា-បិនោ បហិតត្តស្ស វិហរតោ ទិដ្ឋធម្មសុខវិហារា អធិគ-តា តេសាហមស្ស លាភសក្ការសិលោកំ អន្តរាយាយ វទាមិ ។ ឯវំ ទារុណោ ខោ អានន្ទ លាភសក្ការសិ-លោកោ កដុកោ ផរុសោ អន្តរាយិកោ អនុត្តរស្ស យោគក្ខេមស្ស អធិគមាយ ។ តស្មាតិហ អានន្ទ ឯវំ សិក្ខិតព្វំ ឧប្បន្នំ លាភសក្ការសិលោកំ បជហិស្សាម ន ច នោ ឧប្បន្នោ លាភសក្ការសិលោកោ ចិត្តំ ប-រិយាទាយ ឋស្សតីតិ ។ ឯវញ្ហិ វោ អានន្ទ សិក្ខិតព្វន្តិ ។ ទសមំ ។

មាតុគ្គាមវគ្គោ តតិយោ ។

[២៤៩] ព្រះអង្គត្រាស់ថា ម្នាលអានន្ទ ចេតោវិមុត្តិឯណា មិនបានកម្រើក តថាគតមិនពោលថា លាភសក្ការៈនិងសេចក្តីសរសើរ ប្រព្រឹត្តទៅដើម្បីសេចក្តីអន្តរាយដល់ចេតោវិមុត្តិនោះទេ ។ ម្នាលអានន្ទ ប៉ុន្តែភិក្ខុដែលមិនប្រមាទ ជាអ្នកដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន បានសម្រេចធម៌ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន (សុខក្នុងផលសមាបត្តិ) ឯណា តថាគតពោលថា លាភសក្ការៈនិងសេចក្តីសរសើររបស់ភិក្ខុនោះ ប្រព្រឹត្តទៅដើម្បីសេចក្តីអន្តរាយដល់ធម៌ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្នទាំងនោះ ។ ម្នាលអានន្ទ លាភសក្ការៈនិងសេចក្តីសរសើរ ជារបស់អាក្រក់ នាំឲ្យក្តៅផ្សា គ្រោតគ្រាត ធ្វើនូវសេចក្តីអន្តរាយដល់ការត្រាស់ដឹងនូវព្រះនិព្វានជាទីក្សេមចាកយោគៈ រកគុណជាតដទៃក្រៃលែងជាងគ្មាន យ៉ាងនេះឯង ។ ម្នាលអានន្ទ ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះថា យើងទាំងឡាយ នឹងលះបង់នូវលាភសក្ការៈនិងសេកចក្តីសរសើរ ដែលកើតឡើងហើយ ទាំងលាភសក្ការៈនិងសេចក្តីសរសើរ ដែលកើតឡើងហើយ ក៏កុំឲ្យគ្របសង្កត់ចិត្តយើងបានឡើយ ។ ម្នាលអានន្ទ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។ ចប់សូត្រទី ១០ ។

ចប់ មាតុគ្គាមវគ្គ ទី ៣ ។

២០៩

លាភសក្ការសំយុត្តស្ស មាតុគ្គាមវគ្គេ ឧទ្ទានំ

## តស្ស ឧទ្ទានំ

មាតុគ្គាមោ ច កល្យាណី
បុត្តោ ច ឯកធីតុយា
សមណព្រាហ្មណា តីណិ
ឆវិ រជ្ជុ ច ភិក្ខុជាតិ ។

---

## ឧទ្ទាននៃមាតុគ្គាមវគ្គនោះគឺ

*និយាយអំពីមាតុគ្រាម ១ និយាយអំពីស្រីមានលម្អក្នុងជនបទ ១ និយាយអំពីកូនប្រុស ១ និយាយអំពីកូនស្រីម្នាក់ ១ និយាយអំពីសមណព្រាហ្មណ៍មាន ៣ លើក និយាយអំពីស្បែកក្រៅ ១ និយាយអំពីខ្សែ ១ និយាយអំពីភិក្ខុ ១ ។*

---

# ភេទវគ្គោ

[២៤០] សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា... ទារុណោ ភិក្ខវេ លាភសក្ការសិលោកោ ។ បេ ។ លាភសក្ការសិលោកេន អភិភូតោ បរិយាទិន្នចិត្តោ ភិក្ខវេ ទេវទត្តោ សង្ឃំ ភិន្ទតិ ។ ឯវំ ទារុណោ ខោ ភិក្ខវេ លាភសក្ការសិលោកោ ។ បេ ។ សិក្ខិតព្វន្តិ ។ បឋមំ ។

[២៤១] សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា... ទារុណោ ភិក្ខវេ លាភសក្ការសិលោកោ ។ បេ ។ លា-ភសក្ការសិលោកេន អភិភូតស្ស បរិយាទិន្នចិត្តស្ស ភិក្ខវេ ទេវទត្តស្ស កុសលមូលំ សមុច្ឆេទមគមា ។ ឯវំ ទារុណោ ខោ ភិក្ខវេ លាភសក្ការសិលោកោ ។ បេ ។ សិក្ខិតព្វន្តិ ។ ទុតិយំ ។

# ភេទវគ្គ

[២៥០] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ក្នុងទីនោះឯង ព្រះមានព្រះភាគ... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្ដីសរសើរ ជារបស់អាក្រក់ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ទេវទត្តត្រូវលាភសក្ការៈនិងសេចក្ដីសរសើរគ្របសង្កត់រួបរឹតចិត្ត ទើបបំបែកសង្ឃ ។ ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្ដីសរសើរ ជារបស់អាក្រក់យ៉ាងនេះឯង ។ បេ ។ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។ ចប់សូត្រទី ១ ។

[២៥១] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ក្នុងទីនោះឯង ព្រះមានព្រះភាគ... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្ដីសរសើរ ជារបស់អាក្រក់ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ទេវទត្តត្រូវលាភសក្ការៈនិងសេចក្ដីសរសើរគ្របសង្កត់រួបរឹតចិត្ត ទើបកុសលមូលដល់នូវកិរិយាបើកឡើង ។ ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្ដីសរសើរ ជារបស់អាក្រក់យ៉ាងនេះឯង ។ បេ ។ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។ ចប់សូត្រទី ២ ។

[២៤២] សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា... ទារុណោ ភិក្ខវេ លាភសក្ការសិលោកោ ។ បេ ។ លាភសក្ការសិលោកេន អភិភូតស្ស បរិយាទិន្នចិត្តស្ស ភិក្ខវេ ទេវទត្តស្ស កុសលោ ធម្មោ សមុច្ឆេទមគមា ។ ឯវំ ទារុណោ ខោ ភិក្ខវេ លាភសក្ការសិលោកោ ។ បេ ។ សិក្ខិតព្វន្តិ ។ តតិយំ ។

[២៤៣] សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា... ទារុណោ ភិក្ខវេ លាភសក្ការសិលោកោ ។ បេ ។ លាភសក្ការសិលោកេន អភិភូតស្ស បរិយាទិន្នចិត្តស្ស ភិក្ខវេ ទេវទត្តស្ស សុក្កោ ធម្មោ សមុច្ឆេទមគមា ។ ឯវំ ទារុណោ ខោ ភិក្ខវេ លាភសក្ការសិលោកោ ។ បេ ។ សិក្ខិតព្វន្តិ ។ ចតុត្ថំ ។

[២៩២] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ក្នុងទីនោះឯង ព្រះមានព្រះភាគ... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្ដីសរសើរ ជារបស់អាក្រក់ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ទេវទត្តត្រូវលាភសក្ការៈនិងសេចក្ដីសរសើរគ្របសង្កត់ រួបរឹតចិត្ត ទើបកុសលធម៌ដល់នូវកិរិយាបើកឡើង ។ ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្ដីសរសើរ ជារបស់អាក្រក់យ៉ាងនេះឯង ។ បេ ។ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។ ចប់សូត្រទី ៣ ។

[២៩៣] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ក្នុងទីនោះឯង ព្រះមានព្រះភាគ... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្ដីសរសើរ ជារបស់អាក្រក់ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ទេវទត្តត្រូវលាភសក្ការៈនិងសេចក្ដីសរសើរគ្របសង្កត់ រួបរឹតចិត្ត ទើបសុក្កធម៌ (ធម៌ស) ដល់នូវកិរិយាបើកឡើង ។ ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្ដីសរសើរ ជារបស់អាក្រក់យ៉ាងនេះឯង ។ បេ ។ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។ ចប់សូត្រទី ៤ ។

[២៨៤] ឯកំ សមយំ ភគវា រាជគហេ វិហរតិ គិជ្ឈកូដេ បព្វតេ ។ អចិរបក្កន្តេ ទេវទត្តេ តត្រ ខោ ភគវា ទេវទត្តំ អារព្ភ ភិក្ខូ អាមន្តេសិ អត្តវធាយ ភិក្ខវេ ទេវទត្តស្ស លាភសក្ការសិលោកោ ឧទបាទិ បរាភវាយ ទេវទត្តស្ស លាភសក្ការសិលោកោ ឧទ-បាទិ ។

[២៨៥] សេយ្យថាបិ ភិក្ខវេ កទលី អត្តវធាយ ផលំ ទេតិ បរាភវាយ ផលំ ទេតិ ។ ឯវមេវ ខោ ភិក្ខវេ អត្តវធាយ ទេវទត្តស្ស លាភសក្ការសិលោកោ ឧទបាទិ បរាភវាយ ទេវទត្តស្ស លាភសក្ការសិលោ-កោ ឧទបាទិ ។

[២៨៦] សេយ្យថាបិ ភិក្ខវេ វេឡុ អត្តវធាយ ផលំ ទេតិ បរាភវាយ ផលំ ទេតិ ។ ឯវមេវ ខោ ភិក្ខវេ អត្តវធាយ ទេវទត្តស្ស លាភសក្ការសិលោកោ ឧទបាទិ បរាភវាយ ទេវទត្តស្ស លាភសក្ការសិលោ-កោ ឧទបាទិ ។

[២៥៤] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ នាភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ ។ កាលដែលទេវទត្តចៀសចេញទៅមិនយូរប៉ុន្មាន ព្រះមានព្រះភាគ ក៏ប្រារព្ធចំពោះទេវទត្ត ហើយត្រាស់នឹងភិក្ខុទាំងឡាយក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្តីសរសើរកើតឡើងដល់ទេវទត្ត ដើម្បីសម្លាប់ខ្លួន លាភសក្ការៈនិងសេចក្តីសរសើរកើតឡើងដល់ទេវទត្ត ដើម្បីសេចក្តីវិនាស ។

[២៥៥] ម្នាលភិក្ខុទាំងឡាយ ដូចដើមចេក បញ្ចេញផ្លែមកដើម្បីសម្លាប់ខ្លួន បញ្ចេញផ្លែមកដើម្បីសេចក្តីវិនាស យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្តីសរសើរ កើតឡើងដល់ទេវទត្ត ដើម្បីសម្លាប់ខ្លួន លាភសក្ការៈនិងសេចក្តីសរសើរកើតឡើងដល់ទេវទត្ត ដើម្បីសេចក្តីវិនាស ក៏យ៉ាងនោះឯង ។

[២៥៦] ម្នាលភិក្ខុទាំងឡាយ ដូចដើមឫស្សី បញ្ចេញផ្លែមកដើម្បីសម្លាប់ខ្លួន បញ្ចេញផ្លែមកដើម្បីសេចក្តីវិនាស យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្តីសរសើរ កើតឡើងដល់ទេវទត្ត ដើម្បីសម្លាប់ខ្លួន លាភសក្ការៈនិងសេចក្តីសរសើរកើតឡើងដល់ទេវទត្ត ដើម្បីសេចក្តីវិនាស ក៏យ៉ាងនោះឯង ។

[២៨៧] សេយ្យថាបិ ភិក្ខវេ នឡោ អត្តវធាយ ផលំ ទេតិ បរាភវាយ ផលំ ទេតិ ។ ឯវមេវ ខោ ភិក្ខវេ អត្តវធាយ ទេវទត្តស្ស លាភសក្ការសិលោកោ ឧទបាទិ បរាភវាយ ទេវទត្តស្ស លាភសក្ការសិលោកោ ឧទបាទិ ។

[២៨៨] សេយ្យថាបិ ភិក្ខវេ អស្សតរី អត្តវធាយ គព្ភំ គណ្ហាតិ បរាភវាយ គព្ភំ គណ្ហាតិ ។ ឯវមេវ ខោ ភិក្ខវេ អត្តវធាយ ទេវទត្តស្ស លាភសក្ការសិលោកោ ឧទបាទិ បរាភវាយ ទេវទត្តស្ស លាភសក្ការសិលោកោ ឧទបាទិ ។ ឯវំ ទារុណោ ខោ ភិក្ខវេ លាភសក្ការសិលោកោ ។ បេ ។ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។

[២៨៩] ឥទមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា

[២៥៧] ម្នាលភិក្ខុទាំងឡាយ ដូចដើមបបុស បញ្ចេញផ្លែមក ដើម្បីសម្លាប់ខ្លួន បញ្ចេញផ្លែមកដើម្បីសេចក្តីវិនាស យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្តីសរសើរកើតឡើងដល់ទេវ-ទត្ត ដើម្បីសម្លាប់ខ្លួន លាភសក្ការៈនិងសេចក្តីសរសើរកើតឡើងដល់ទេវទត្ត ដើម្បីសេចក្តីវិនាស ក៏យ៉ាងនោះឯង ។

[២៥៨] ម្នាលភិក្ខុទាំងឡាយ ដូចមេសេះអស្សតរ មានគភ៌ ដើម្បីសម្លាប់ខ្លួន មានគភ៌ដើម្បីសេចក្តីវិនាស យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្តីសរសើរ កើតឡើងដល់ទេវទត្ត ដើម្បីសម្លាប់ខ្លួន លាភសក្ការៈនិងសេចក្តីសរសើរ កើតឡើងដល់ទេវទត្ត ដើម្បីសេចក្តីវិនាស ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ លាភ-សក្ការៈនិងសេចក្តីសរសើរ ជារបស់អាក្រក់យ៉ាងនេះឯង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។

[២៥៩] ព្រះមានព្រះភាគ ទ្រង់ត្រាស់នូវព្រះសូត្រនេះចប់ហើយ លុះព្រះសុគតជាសាស្តា ទ្រង់ត្រាស់នូវព្រះសូត្រនេះរួចហើយ ទើបទ្រង់ត្រាស់នូវគាថាពន្ធជាលំដាប់តទៅទៀតថា

ផលំ វេ កទលឹ ហន្តិ

ផលំ វេឡុំ ផលំ នឡំ

សក្ការោ កាបុរិសំ ហន្តិ

គព្ភោ អស្សតរឹ យថាតិ ។ បញ្ចមំ ។

[២៦០] រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវា-
បេ ។ តេន ខោ បន សមយេន ទេវទត្តស្ស អជាត-
សត្តុកុមារោ បញ្ចហិ រថសតេហិ សាយំ បាតំ ឧបដ្ឋា-
នំ គច្ឆតិ បញ្ច ច ថាលិបាកសតានិ ភត្តាភិហារោ
អភិហារិយតិ ។ អថខោ សម្ពហុលា ភិក្ខូ យេន ភគ-
វា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា
ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នោ ខោ តេ
ភិក្ខូ ភគវន្តំ ឯតទវោចុំ ទេវទត្តស្ស ភន្តេ អាជាតសត្តុ-
កុមារោ បញ្ចហិ រថសតេហិ សាយំ បាតំ ឧបដ្ឋានំ
គមិស្សតិ បញ្ច ច ថាលិបាកសតានិ ភត្តាភិហារោ
អភិហារិយិស្សតីតិ ។

ផ្លែចេក តែងសម្លាប់ដើមចេក ផ្លែឫស្សី តែងសម្លាប់ដើមឫស្សី ផ្លែបបុស តែងសម្លាប់ដើមបបុស ឯសក្ការៈតែងសម្លាប់បុរសអាក្រក់ ដូចជាគភ៌សម្លាប់មេសេះអស្សតរ ។

ចប់សូត្រទី ៥ ។

[២៦០] ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តវេឡុវន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង អជាតសត្តុកុមារ តែងទៅកាន់ទីបម្រើនៃទេវទត្ត ទាំងល្ងាចទាំងព្រឹក ដោយព្រះរាជរថចំនួន ៥០០ ផង ទ្រង់ឲ្យនាំចង្ហាន់ចំនួន ៥០០ ថាសទៅប្រគេនផង ។ លំដាប់នោះ ពួកភិក្ខុច្រើនរូបនាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អជាតសត្តុកុមារ តែងទៅកាន់ទីបម្រើនៃទេវទត្ត ទាំងល្ងាចទាំងព្រឹក ដោយព្រះរាជរថចំនួន ៥០០ ផង ទ្រង់ឲ្យនាំចង្ហាន់ចំនួន ៥០០ ថាសទៅប្រគេនផង ។

[២៦១] មា ភិក្ខវេ ទេវទត្តស្ស លាភសក្ការសិ-លោកំ បិហាយិត្ថ ។ យាវកិវញ្ច ភិក្ខវេ ទេវទត្តស្ស អជាតសត្តុកុមារោ បញ្ចហិ រថសតេហិ សាយំ បាតំ ឧបដ្ឋានំ គមិស្សតិ បញ្ច ច ថាលិបាកសតានិ ភត្តា-ភិហារោ អភិហរិយិស្សតិ ។ ហានិយេវ ភិក្ខវេ ទេវ-ទត្តស្ស បាដិកង្ខា កុសលេសុ ធម្មេសុ នោ វុឌ្ឍិ ។

[២៦២] សេយ្យថាបិ ភិក្ខវេ ចណ្ឌស្ស កុក្កុរស្ស នាសាយ បិត្តំ ភិន្ទេយ្យុំ ឯវញ្ហិ សោ ភិក្ខវេ កុក្កុរោ ភិយ្យោសោ មត្តាយ ចណ្ឌតរោ អស្ស ។ ឯវមេវ ខោ ភិក្ខវេ យាវកិវញ្ច ទេវទត្តស្ស អជាតសត្តុកុមារោ បញ្ចហិ រថសតេហិ សាយំ បាតំ ឧបដ្ឋានំ គមិស្សតិ បញ្ច ច ថាលិបាកសតានិ ភត្តាភិហារោ អភិហរិយិស្សតិ

លាភសក្ការសំយុត្ត ភេទវគ្គ ឧបមាដោយឆ្កែកាច

[២៦១] ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំស្រឡាញ់លាភសក្ការៈនិងសេចក្ដីសរសើរ របស់ទេវទត្តឡើយ ។ ម្នាលភិក្ខុទាំងឡាយ អជាតសត្តុកុមារនឹងទៅកាន់ទីបម្រើនៃទេវទត្ត ទាំងល្ងាចទាំងព្រឹក ដោយព្រះរាជរថចំនួន ៥០០ ផង ទ្រង់ឲ្យនាំចង្ហាន់ចំនួន ៥០០ ថាសទៅប្រគេនផង អស់កំណត់កាលត្រឹមណា ។ ម្នាលភិក្ខុទាំងឡាយ ទេវទត្តត្រូវនឹកសង្ឃឹមតែសេចក្ដីសាបសូន្យមួយយ៉ាងប៉ុណ្ណោះ ឯសេចក្ដីចម្រើនក្នុងកុសលធម៌ទាំងឡាយ មិនត្រូវនឹកសង្ឃឹមឡើយ អស់កាលមានកំណត់ត្រឹមនោះ ។

[២៦២] ម្នាលភិក្ខុទាំងឡាយ ដូចជនទាំងឡាយច្របាច់ប្រមាត់ដាក់ច្រមុះនៃឆ្កែកាច ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាងនេះហើយ ឆ្កែនោះរឹងរឹតតែកាចដោយក្រៃលែងឡើង យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ អជាតសត្តុកុមារនឹងទៅកាន់ទីបម្រើ នៃទេវទត្តទាំងល្ងាចទាំងព្រឹក ដោយព្រះរាជរថចំនួន ៥០០ ផង ទ្រង់ឲ្យនាំចង្ហាន់ចំនួន ៥០០ ថាសទៅប្រគេនផង អស់កាលមានកំណត់ត្រឹមណា

ហានិយេវ ភិក្ខវេ ទេវទត្តស្ស ចាដិកង្ខា កុសលេសុ ធម្មេសុ នោ វុឌ្ឍិ ។ ឯវំ ទារុណោ ខោ ភិក្ខវេ លាភ-សក្ការសិលោកោ ។ បេ ។ សិក្ខិតព្វន្តិ ។ ឆដ្ឋំ ។

[២៦៣] សាវត្ថិយំ វិហរតិ... ទារុណោ ភិក្ខវេ លា-ភសក្ការសិលោកោ កដុកោ ផរុសោ អន្តរាយិកោ អនុត្តរស្ស យោគក្ខេមស្ស អធិគមាយ ។

[២៦៤] ឥធាហំ ភិក្ខវេ ឯកច្ចំ បុគ្គលំ ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ ន វាយមាយស្មា[១] មាតុបិ ហេតុ សម្បជានមុសា ភាសេយ្យាតិ តមេនំ បស្សាមិ អបរេន សមយេន លាភសក្ការសិលោកេន អភិភូតំ បរិយាទិន្នចិត្តំ សម្បជានមុសា ភាសន្តំ ។

---

១ ឱ. ម. ន បាយមាយស្មា ។

ម្នាលភិក្ខុទាំងឡាយ ទេវទត្តត្រូវនឹកសង្ឃឹមតែសេចក្តីសាបសូន្យមួយយ៉ាង ប៉ុណ្ណោះ ឯសេចក្តីចម្រើនក្នុងកុសលធម៌ទាំងឡាយ មិនត្រូវនឹកសង្ឃឹម ឡើយ អស់កាលមានកំណត់ត្រឹមនោះ ក៏យ៉ាងនោះឯង ។ ម្នាល ភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្តីសរសើរ ជារបស់អាក្រក់យ៉ាងនេះ ឯង ។ បេ ។ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។ ចប់សូត្រទី ៦ ។

[២៦៣] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្តីសរសើរ ជារបស់អាក្រក់ ក្តៅផ្សា គ្រោតគ្រាត ធ្វើនូវសេចក្តីអន្តរាយដល់ការត្រាស់ដឹងនូវព្រះ និព្វាន ជាទីក្សេមចាកយោគៈ រកគុណជាតដទៃក្រៃលែងជាងគ្មាន ។

[២៦៤] ម្នាលភិក្ខុទាំងឡាយ ក្នុងលោកនេះ តថាគតកំណត់ ដឹងច្បាស់ នូវចិត្តបុគ្គលពួកខ្លះ ដោយចិត្តរបស់តថាគតយ៉ាងនេះថា អ្នកនេះ មិនគប្បីពោលសម្បជានមុសា ព្រោះហេតុតែមាតាទេ លុះ សម័យខាងក្រោយមក តថាគតឃើញបុគ្គលនោះ ត្រូវលាភសក្ការៈ និងសេចក្តីសរសើរគ្របសង្កត់ រួបរឹតចិត្ត ក៏ពោលសម្បជានមុសា ។

ឯវំ ទារុណោ ខោ ភិក្ខវេ លាភសក្ការសិលោកោ កដុកោ ផរុសោ អន្តរាយិកោ អនុត្តរស្ស យោគក្ខេមស្ស អធិគមាយ ។ តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ ឧប្បន្នំ លាភសក្ការសិលោកំ បជហិស្សាម ន ច នោ ឧប្បន្នោ លាភសក្ការសិលោកោ ចិត្តំ បរិយាទាយ ឋស្សតីតិ ។ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។ សត្តមំ ។

[២៦៨] សាវត្ថិយំ វិហរតិ... ទារុណោ ភិក្ខវេ លាភសក្ការសិលោកោ កដុកោ ផរុសោ អន្តរាយិកោ អនុត្តរស្ស យោគក្ខេមស្ស អធិគមាយ ។

ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្តីសរសើរ ជារបស់អាក្រក់ ក្តៅផ្សា គ្រោតគ្រាត ធ្វើនូវសេចក្តីអន្តរាយដល់ការត្រាស់ដឹងនូវព្រះនិព្វានជាទីក្សេមចាកយោគៈ រកគុណជាតដទៃក្រៃលែងជាងគ្មានយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះថា យើងទាំងឡាយនឹងលះបង់នូវលាភសក្ការៈនិងសេចក្តីសរសើរ ដែលកើតឡើងហើយ ទាំងលាភ-សក្ការៈនិងសេចក្តីសរសើរ ដែលកើតឡើងហើយ ក៏កុំឲ្យគ្របសង្កត់ចិត្តយើងបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។ ចប់សូត្រទី ៧ ។

[២៦៥] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្តីសរសើរ ជារបស់អាក្រក់ ក្តៅផ្សា គ្រោតគ្រាត ធ្វើនូវសេចក្តីអន្តរាយ ដល់ការដឹងនូវព្រះនិព្វានជាទីក្សេមចាកយោគៈ រកគុណជាតដទៃក្រៃលែងជាងគ្មាន ។

[២៦៦] ឥធាហំ ភិក្ខវេ ឯកច្ចំ បុគ្គលំ ឯវំ ចេតសា ចេតោ បរិច្ច បជានាមិ ន វាយមាយស្មា បិតុបិ ហេតុ (វិត្ថារេតព្វំ) ភាតុបិ ហេតុ... ភគិនិយាបិ ហេតុ... បុត្តស្សបិ ហេតុ... ធីតុយាបិ ហេតុ... បជាបតិយាបិ ហេតុ សម្បជានមុសា ភាសេយ្យាតិ តមេនំ បស្សាមិ អបរេន សមយេន លាភសក្ការសិលោកេន អភិភូតំ បរិយាទិន្នចិត្តំ សម្បជានមុសា ភាសន្តំ ។ ឯវំ ទារុណោ ខោ ភិក្ខវេ លាភសក្ការសិលោកោ កដុកោ ផរុសោ អន្តរាយិកោ អនុត្តរស្ស យោគក្ខេមស្ស កដុកោ ផរុសោ តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ ឧប្បន្នំ លាភសក្ការសិលោកំ បជហិស្សាម ន ច នោ ឧប្បន្នោ លាភសក្ការសិលោកោ ចិត្តំ បរិយាទាយ ឋស្សតីតិ ។ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។ តេរស ។

ភេទវគ្គោ ចតុត្ថោ ។

[២៦៦] ម្នាលភិក្ខុទាំងឡាយ ក្នុងលោកនេះ តថាគតកំណត់ដឹងច្បាស់នូវចិត្តបុគ្គលពួកខ្លះ ដោយចិត្តរបស់តថាគតយ៉ាងនេះថា អ្នកនេះ មិនគប្បីពោលសម្បជានមុសា ព្រោះហេតុតែបិតាទេ (បណ្ឌិតគប្បីឲ្យពិស្តារផងចុះ) ព្រោះហេតុតែបងប្អូនប្រុសទេ... ព្រោះហេតុតែបងប្អូនស្រីទេ... ព្រោះហេតុតែកូនប្រុសទេ... ព្រោះហេតុតែកូនស្រីទេ... ព្រោះហេតុតែប្រពន្ធទេ លុះសម័យខាងក្រោយមក តថាគតឃើញបុគ្គលនោះ ត្រូវលាភសក្ការៈនិងសេចក្តីសរសើរគ្របសង្កត់ រួបរឹតចិត្ត ក៏ពោលនូវសម្បជានមុសា ។ ម្នាលភិក្ខុទាំងឡាយ លាភសក្ការៈនិងសេចក្តីសរសើរ ជារបស់អាក្រក់ ក្តៅផ្សា គ្រោតគ្រាត ធ្វើនូវសេចក្តីអន្តរាយដល់ការត្រាស់ដឹងនូវព្រះនិព្វានជាទីក្សេមចាកយោគៈ រកគុណជាតដទៃក្រៃលែងជាងគ្មាន យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះថា យើងទាំងឡាយនឹងលះបង់នូវលាភសក្ការៈនិងសេចក្តីសរសើរ ដែលកើតឡើងហើយ ទាំងលាភសក្ការៈនិងសេចក្តីសរសើរ ដែលកើតឡើងហើយ ក៏កុំឲ្យគ្របសង្កត់ចិត្តយើងបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។ ចប់សូត្រទី ១៣ ។

ចប់ ភេទវគ្គ ទី ៤ ។

២១៩



## តស្ស ឧទ្ទានំ

ភិន្ទិ មូលំ ទ្វិជម្មោ[១] ច
បក្កន្តំ រថមាតរិ
បិតា ច ភាតា ភគិនី
បុត្តោ ជីតា បជាបតីតិ ។

លាភសក្ការសំយុត្តំ បញ្ចមំ សមត្តំ ។

---

១ ឱ. ម. ឆិន្ទិ មូលំ ធម្មោសុក្កោ ។

# ឧទ្ទាននៃភេទវគ្គនោះគឺ

*និយាយអំពីទេវទត្តបំបែកសង្ឃ ១ កុសលមូល ១ ធម៌មាន ២ លើក កាលទេវទត្តចៀសចេញទៅ ១ អជាតសត្តុកុមារទៅកាន់ទីបម្រើនៃទេវទត្ត ដោយព្រះរាជរថ ១ មាតា ១ បិតា ១ បងប្អូនប្រុស ១ បងប្អូនស្រី ១ កូនប្រុស ១ កូនស្រី ១ ប្រពន្ធ ១ ។*

ចប់ លាភសក្ការសំយុត្ត ទី ៥ ។

# រាហុលសំយុត្តំ

## អប្បមាទវគ្គោ

[២៦៧] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ អាយស្មា រាហុលោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា រាហុលោ ភគវន្តំ ឯតទវោច សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ យមហំ ភគវតោ ធម្មំ សុត្វា ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរេយ្យន្តិ ។

# រាហុលសំយុត្ត

## អប្បមាទវគ្គ

[២៦៧] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ ព្រះរាហុលមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះរាហុលមានអាយុអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគទ្រង់សំដែងធម៌ដោយសង្ខេប ដល់ខ្ញុំព្រះអង្គ ព្រោះថាខ្ញុំព្រះអង្គបានស្តាប់ធម៌របស់ព្រះមានព្រះភាគ ហើយចៀសចេញទៅតែម្នាក់ឯង មិនប្រមាទ មានព្យាយាមជាគ្រឿងដុតនូវកិលេស មានចិត្តស្ទុង (ទៅកាន់ព្រះនិព្វាន) ។

[២៦៨] តំ កឹ មញ្ញសិ រាហុល ចក្ខុំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កាល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។

(ឯវំ បេយ្យាលោ)

សោតំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ... ឃានំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ... ជិវ្ហា និច្ចា វា អនិច្ចា វាតិ ។ អនិច្ចា ភន្តេ... កាយោ និច្ចោ វា អនិច្ចោ វាតិ ។ អនិច្ចោ ភន្តេ... មនោ និច្ចោ វា អនិច្ចោ វាតិ ។ អនិច្ចោ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កាល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោ ហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។

[២៦៨] ព្រះអង្គត្រាស់សួរថា ម្នាលរាហុល អ្នកសម្គាល់សេចក្តីនោះដូចម្តេច ចក្ខុទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ឯណាដែលមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះរបស់ឯណាដែលមិនទៀង ជាទុក្ខ មានកិរិយាប្រែប្រួលជាធម្មតា គួរនឹងពិចារណានូវរបស់នោះថា នុ៎ះជារបស់អាត្មាអញ នុ៎ះជាអាត្មាអញ នុ៎ះជាខ្លួនរបស់អាត្មាអញដែរឬ ។ ហេតុនុ៎ះ មិនគួរទេ ព្រះអង្គ ។

(បេយ្យាលៈយ៉ាងនេះ)

ព្រះអង្គត្រាស់សួរថា ត្រចៀកទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ... ច្រមុះទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ... អណ្តាតទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ... កាយទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ... ចិត្តទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ឯណាមិនទៀង ជាទុក្ខ មានកិរិយាប្រែប្រួលជាធម្មតា គួរនឹងពិចារណានូវរបស់នោះថា នុ៎ះជារបស់អាត្មាអញ នុ៎ះជាអាត្មាអញ នុ៎ះជាខ្លួនរបស់អាត្មាអញដែរឬ ។ ហេតុនុ៎ះ មិនគួរទេ ព្រះអង្គ ។

[២៦៩] ឯវំ បស្សំ រាហុល សុតវា អរិយសាវកោ ចក្ខុស្មិម្បិ និព្វិន្ទតិ សោតស្មិម្បិ និព្វិន្ទតិ ឃានស្មិម្បិ និព្វិន្ទតិ ជិវ្ហាយបិ និព្វិន្ទតិ កាយស្មិម្បិ និព្វិន្ទតិ មនស្មិម្បិ និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ ។ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ។ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។ បឋមំ ។

(ឯតេន បេយ្យាលេន ទស សុត្តន្តា កាតព្វា)

[២៧០] សាវត្ថិយំ វិហរតិ... តំ កឹ មញ្ញសិ រាហុល រូបា និច្ចា វា អនិច្ចា វាតិ ។ អនិច្ចា ភន្តេ... សទ្ទា ។ បេ ។ គន្ធា... រសា... ផោដ្ឋព្វា... ធម្មា និច្ចា វា អនិច្ចា វាតិ ។ អនិច្ចា ភន្តេ... ។

[២៦៩] ម្នាលរាហុល អរិយសាវកអ្នកចេះដឹង កាលបើឃើញយ៉ាងនេះ ក៏រមែងនឿយណាយចំពោះភ្នែកផង នឿយណាយចំពោះត្រចៀកផង នឿយណាយចំពោះច្រមុះផង នឿយណាយចំពោះអណ្តាតផង នឿយណាយចំពោះកាយផង នឿយណាយចំពោះចិត្តផង កាលបើនឿយណាយហើយ ក៏ធុញទ្រាន់ ព្រោះការធុញទ្រាន់ ទើបចិត្តរួចស្រឡះ ។ កាលបើចិត្តរួចស្រឡះហើយ សេចក្តីដឹងក៏កើតមានថា ចិត្តអាត្មាអញរួចស្រឡះហើយ ។ អរិយសាវកនោះ រមែងដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈអាត្មាអញបានប្រព្រឹត្តរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។ ចប់សូត្រទី ១ ។

(ព្រះសូត្រទាំង ១០ បណ្ឌិតគប្បីធ្វើតាមបេយ្យាលៈនេះចុះ)

[២៧០] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ទ្រង់ត្រាស់សួរថា ម្នាលរាហុល អ្នកសម្គាល់សេចក្តីនោះដូចម្តេច រូបទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ... សំឡេង ។ បេ ។ ក្លិន... រស... ផ្សព្វ... ធម៌ទាំងឡាយទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ... ។

២២៣



[២៧១] ឯវំ បស្សំ រាហុល សុតវា អរិយសាវកោ រូបេសុបិ និព្វិន្ទតិ សទ្ទេសុបិ និព្វិន្ទតិ គន្ធេសុបិ និព្វិន្ទតិ រសេសុបិ និព្វិន្ទតិ ផោដ្ឋព្វេសុបិ និព្វិន្ទតិ ធម្មេសុបិ និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ ។ បេ ។ បជានាតីតិ ។ ទុតិយំ ។

[២៧២] សាវត្ថិយំ វិហរតិ... តំ កឹ មញ្ញសិ រាហុ-ល ចក្ខុវិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ... សោតវិញ្ញាណំ ។ បេ ។ ឃានវិញ្ញាណំ... ជិវ្ហាវិញ្ញាណំ... កាយវិញ្ញាណំ... មនោវិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ... ។

[២៧៣] ឯវំ បស្សំ រាហុល សុតវា អរិយសាវ-កោ ចក្ខុវិញ្ញាណស្មិម្បិ និព្វិន្ទតិ សោតវិញ្ញាណស្មិម្បិ និព្វិន្ទតិ ឃានវិញ្ញាណស្មិម្បិ និព្វិន្ទតិ ជិវ្ហាវិញ្ញាណស្មិម្បិ និព្វិន្ទតិ កាយវិញ្ញាណស្មិម្បិ និព្វិន្ទិតិ មនោវិញ្ញាណ-ស្មិម្បិ និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ ។ បេ ។ បជានាតីតិ ។ តតិយំ ។

[២៧១] ម្នាលរាហុល អរិយសាវ័កអ្នកចេះដឹង កាលបើឃើញយ៉ាងនេះ ក៏រមែងនឿយណាយចំពោះរូបផង នឿយណាយចំពោះសំឡេងផង នឿយណាយចំពោះក្លិនផង នឿយណាយចំពោះរសផង នឿយណាយចំពោះផ្សព្វផង នឿយណាយចំពោះធម៌ទាំងឡាយផង កាលបើនឿយណាយហើយ ក៏ធុញទ្រាន់ ។ បេ ។ ចប់សូត្រទី ២ ។

[២៧២] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ទ្រង់ត្រាស់សួរថា ម្នាលរាហុល អ្នកសម្គាល់សេចក្ដីនោះដូចម្ដេច ចក្ខុ-វិញ្ញាណ (សេចក្ដីដឹងតាមផ្លូវភ្នែក) ទៀង ឬមិនទៀង ។ មិនទៀង ព្រះអង្គ... សោតវិញ្ញាណ ។ បេ ។ ឃានវិញ្ញាណ... ជិវ្ហាវិញ្ញាណ... មនោវិញ្ញាណទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ... ។

[២៧៣] ម្នាលរាហុល អរិយសាវ័កអ្នកចេះដឹង កាលបើឃើញយ៉ាងនេះ ក៏រមែងនឿយណាយចំពោះចក្ខុវិញ្ញាណផង នឿយណាយចំពោះសោតវិញ្ញាណផង នឿយណាយចំពោះឃានវិញ្ញាណផង នឿយណាយចំពោះជិវ្ហាវិញ្ញាណផង នឿយណាយចំពោះកាយវិញ្ញាណផង នឿយណាយចំពោះមនោវិញ្ញាណផង កាលបើនឿយណាយហើយ ក៏ធុញទ្រាន់ ។ បេ ។ ចប់សូត្រទី ៣ ។

[២៧៤] សាវត្ថិយំ វិហរតិ... តំ កឹ មញ្ញសិ រាហុល ចក្ខុសម្ផស្សោ និច្ចោ វា អនិច្ចោ វាតិ ។ អនិច្ចោ វាតិ ភន្តេ... សោតសម្ផស្សោ ។ បេ ។ ឃានសម្ផស្សោ... ជិវ្ហាសម្ផ-ស្សោ... កាយសម្ផស្សោ... មនោសម្ផស្សោ និច្ចោ វា អនិច្ចោ វាតិ ។ អនិច្ចា ភន្តេ... ។

[២៧៥] ឯវំ បស្សំ រាហុល សុតវា អរិយសាវ-កោ ចក្ខុសម្ផស្សស្មិម្បិ និព្វិន្ទតិ សោតសម្ផស្សស្មិម្បិ និព្វិន្ទតិ ឃានសម្ផស្សស្មិម្បិ និព្វិន្ទតិ ជិវ្ហាសម្ផស្សស្មិម្បិ និព្វិន្ទតិ កាយសម្ផស្សស្មិម្បិ និព្វិន្ទតិ មនោសម្ផស្ស-ស្មិម្បិ និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ ។ បេ ។ បជានាតីតិ ។ ចតុត្ថំ ។

[២៧៤] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ទ្រង់ត្រាស់សួរថា ម្នាលរាហុល អ្នកសម្គាល់សេចក្តីនោះ ដូចម្តេច ចក្ខុសម្ផស្ស (រូបារម្មណ៍ដែលប៉ះពាល់ដោយចក្ខុ) ទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ... សោតសម្ផស្ស ។ បេ ។ ឃានសម្ផស្ស... ជិវ្ហាសម្ផស្ស... កាយសម្ផស្ស... មនោសម្ផស្សទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ... ។

[២៧៥] ម្នាលរាហុល អរិយសាវកអ្នកចេះដឹង កាលបើឃើញយ៉ាងនេះ ក៏រមែងនឿយណាយចំពោះចក្ខុសម្ផស្សផង នឿយណាយចំពោះសោតសម្ផស្សផង នឿយណាយចំពោះឃានសម្ផស្សផង នឿយណាយចំពោះជិវ្ហាសម្ផស្សផង នឿយណាយចំពោះកាយសម្ផស្សផង នឿយណាយចំពោះមនោសម្ផស្សផង កាលបើនឿយណាយហើយ ក៏ធុញទ្រាន់ ។ បេ ។ ចប់សូត្រទី ៤ ។

[២៧៦] សាវត្ថិយំ វិហរតិ... តំ កឹ មញ្ញសិ រាហុល ចក្ខុសម្ផស្សជា វេទនា និច្ចា វា អនិច្ចា វាតិ ។ អនិច្ចា ភន្តេ... សោតសម្ផស្សជា វេទនា ។ បេ ។ ឃានសម្ផស្សជា វេទនា... ជិវ្ហាសម្ផស្សជា វេទនា... កាយសម្ផស្សជា វេទនា... មនោសម្ផស្សជា វេទនា និច្ចា វា អនិច្ចា វាតិ ។ អនិច្ចា ភន្តេ... ។

[២៧៧] ឯវំ បស្សំ រាហុល សុតវា អរិយសាវកោ ចក្ខុសម្ផស្សជាយ វេទនាយបិ និព្វិន្ទតិ សោតសម្ផស្សជាយ វេទនាយបិ និព្វិន្ទតិ ឃានសម្ផស្សជាយ វេទនាយបិ និព្វិន្ទតិ ជិវ្ហាសម្ផស្សជាយ វេទនាយបិ និព្វិន្ទតិ កាយសម្ផស្សជាយ វេទនាយបិ និព្វិន្ទតិ មនោសម្ផស្សជាយ វេទនាយបិ និព្វិន្ទតិ ។ បេ ។ បជានាតីតិ ។ បញ្ចមំ ។

[២៧៦] *ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ទ្រង់ត្រាស់សួរថា* ម្នាលរាហុល *អ្នកសម្គាល់សេចក្តីនោះដូចម្តេច ចក្ខុសម្ផស្សជា វេទនា (វេទនាកើតអំពីចក្ខុសម្ផស្ស) ទៀង ឬមិនទៀង ។* មិនទៀង*ទេ ព្រះអង្គ... សោតសម្ផស្សជា វេទនា ។ បេ ។ ឃានសម្ផស្សជា វេទនា... ជិវ្ហាសម្ផស្សជា វេទនា... កាយសម្ផស្សជា វេទនា...* មនោ-*សម្ផស្សជា វេទនា ទៀង ឬ*មិន*ទៀង ។* មិន*ទៀងទេ ព្រះអង្គ... ។*

[២៧៧] ម្នាលរាហុល *អរិយសាវ័កអ្នកចេះដឹង កាលបើឃើញយ៉ាងនេះ រមែងនឿយណាយចំពោះចក្ខុសម្ផស្សជា វេទនាផង នឿយណាយចំពោះសោតសម្ផស្សជា វេទនាផង នឿយណាយចំពោះឃាន-សម្ផស្សជា វេទនាផង នឿយណាយចំពោះជិវ្ហាសម្ផស្សជា វេទនាផង នឿយណាយចំពោះកាយសម្ផស្សជា វេទនាផង នឿយណាយចំពោះ* មនោ*សម្ផស្សជា វេទនាផង ។ បេ ។ ចប់សូត្រទី ៥ ។*

[២៧៨] សាវត្ថិយំ វិហរតិ... តំ កឹ មញ្ញសិ រាហុល រូបសញ្ញា និច្ចា វា អនិច្ចា វាតិ ។ អនិច្ចា ភន្តេ... សទ្ទសញ្ញា... គន្ធសញ្ញា... រសសញ្ញា... ផោដ្ឋព្វសញ្ញា... ធម្មសញ្ញា និច្ចា វា អនិច្ចា វាតិ ។ អនិច្ចា ភន្តេ... ។

[២៧៩] ឯវំ បស្សំ រាហុល សុតវា អរិយសាវកោ រូបសញ្ញាយបិ និព្វិន្ទតិ សទ្ទសញ្ញាយបិ និព្វិន្ទតិ គន្ធសញ្ញាយបិ និព្វិន្ទតិ រសសញ្ញាយបិ និព្វិន្ទតិ ផោដ្ឋព្វសញ្ញាយបិ និព្វិន្ទតិ ធម្មសញ្ញាយបិ និព្វិន្ទតិ ។ បេ ។ បជានាតីតិ ។ ឆដ្ឋំ ។

[២៨០] សាវត្ថិយំ វិហរតិ... តំ កឹ មញ្ញសិ រាហុល រូបសញ្ចេតនា និច្ចា វា អនិច្ចា វាតិ ។ អនិច្ចា ភន្តេ... សទ្ទសញ្ចេតនា... គន្ធសញ្ចេតនា... រសសញ្ចេតនា... ផោដ្ឋព្វសញ្ចេតនា... ធម្មសញ្ចេតនា និច្ចា វា អនិច្ចា វាតិ ។ អនិច្ចា ភន្តេ... ។

[២៧៨] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ទ្រង់ត្រាស់សួរថា ម្នាលរាហុល អ្នកសម្គាល់សេចក្តីនោះដូចម្តេច រូបសញ្ញា (សេចក្តីសម្គាល់ក្នុងរូប) ទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ... សទ្ទសញ្ញា... គន្ធសញ្ញា... រសសញ្ញា... ផោដ្ឋព្វសញ្ញា... ធម្មសញ្ញា ទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ... ។

[២៧៩] ម្នាលរាហុល អរិយសាវ័កអ្នកចេះដឹង កាលបើឃើញយ៉ាងនេះ ក៏រមែងនឿយណាយចំពោះរូបសញ្ញាផង នឿយណាយចំពោះសទ្ទសញ្ញាផង នឿយណាយចំពោះគន្ធសញ្ញាផង នឿយណាយចំពោះរសសញ្ញាផង នឿយណាយចំពោះផោដ្ឋព្វសញ្ញាផង នឿយណាយចំពោះធម្មសញ្ញាផង ។ បេ ។ ចប់សូត្រទី ៦ ។

[២៨០] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ទ្រង់ត្រាស់សួរថា ម្នាលរាហុល អ្នកសម្គាល់សេចក្តីនោះ ដូចម្តេច រូបសញ្ចេតនា (សេចក្តីគិតក្នុងរូប) ទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ... សទ្ទសញ្ចេតនា... គន្ធសញ្ចេតនា... រសសញ្ចេនា... ផោដ្ឋព្វសញ្ចេតនា... ធម្មសញ្ចេតនា ទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ... ។

[២៨១] ឯវំ បស្សំ រាហុល សុតវា អរិយសាវកោ រូបសញ្ចេតនាយបិ និព្វិន្ទតិ សទ្ទសញ្ចេតនាយបិ និព្វិ- ន្ទតិ គន្ធសញ្ចេតនាយបិ និព្វិន្ទតិ រសសញ្ចេតនាយបិ និព្វិន្ទតិ ផោដ្ឋព្វសញ្ចេតនាយបិ និព្វិន្ទតិ ធម្មសញ្ចេត- នាយបិ និព្វិន្ទតិ ។ បេ ។ បជានាតីតិ ។ សត្តមំ ។

[២៨២] សាវត្ថិយំ វិហរតិ... តំ កឹ មញ្ញសិ រាហុល រូបតណ្ហា និច្ចា វា អនិច្ចា វាតិ ។ អនិច្ចា ភន្តេ... សទ្ទតណ្ហា... គន្ធតណ្ហា... រសតណ្ហា... ផោដ្ឋព្វតណ្ហា... ធម្មតណ្ហា និច្ចា វា អនិច្ចា វាតិ ។ អនិច្ចា ភន្តេ... ។

[២៨៣] ឯវំ បស្សំ រាហុល សុតវា អរិយសា- វកោ រូបតណ្ហាយបិ និព្វិន្ទតិ សទ្ទតណ្ហាយបិ និព្វិន្ទតិ គន្ធតណ្ហាយបិ និព្វិន្ទតិ រសតណ្ហាយបិ និព្វិន្ទតិ ផោដ្ឋព្វតណ្ហាយបិ និព្វិន្ទតិ ធម្មតណ្ហាយបិ និព្វិន្ទតិ ។ បេ ។ បជានាតីតិ ។ អដ្ឋមំ ។

[២៨១] ម្នាលរាហុល អរិយសាវ័កអ្នកចេះដឹង កាលបើឃើញយ៉ាងនេះ ក៏រមែងនឿយណាយចំពោះរូបសញ្ចេតនាផង នឿយណាយចំពោះសទ្ទសញ្ចេតនាផង នឿយណាយចំពោះគន្ធសញ្ចេតនាផង នឿយណាយចំពោះរសសញ្ចេតនាផង នឿយណាយចំពោះផោដ្ឋព្វសញ្ចេតនាផង នឿយណាយចំពោះធម្មសញ្ចេតនាផង ។ បេ ។ ចប់សូត្រទី ៧ ។

[២៨២] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ទ្រង់ត្រាស់សួរថា ម្នាលរាហុល អ្នកសម្គាល់សេចក្តីនោះដូចម្តេច រូបតណ្ហា (សេចក្តីប្រាថ្នាក្នុងរូប) ទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ... សទ្ទតណ្ហា... គន្ធតណ្ហា... រសតណ្ហា... ផោដ្ឋព្វតណ្ហា... ធម្មតណ្ហា ទៀង ឬមិនទៀង ។ មិនទៀងទេ... ព្រះអង្គ... ។

[២៨៣] ម្នាលរាហុល អរិយសាវកអ្នកចេះដឹង កាលបើឃើញយ៉ាងនេះ ក៏រមែងនឿយណាយចំពោះរូបតណ្ហាផង នឿយណាយចំពោះសទ្ទតណ្ហាផង នឿយណាយចំពោះគន្ធតណ្ហាផង នឿយណាយចំពោះរសតណ្ហាផង នឿយណាយចំពោះផោដ្ឋព្វតណ្ហាផង នឿយណាយចំពោះធម្មតណ្ហាផង ។ បេ ។ ចប់សូត្រទី ៨ ។

[២៨៤] សាវត្ថិយំ វិហរតិ... តំ កឹ មញ្ញសិ រាហុល បឋវីធាតុ និច្ចា វា អនិច្ចា វាតិ ។ អនិច្ចា ភន្តេ... អាបោធាតុ... តេជោធាតុ... វាយោធាតុ... អាកាសធាតុ... វិញ្ញាណធាតុ និច្ចា វា អនិច្ចា វាតិ ។ អនិច្ចា ភន្តេ... ។

[២៨៥] ឯវំ បស្សំ រាហុល សុតវា អរិយសាវកោ បឋវីធាតុយាបិ និព្វិន្ទតិ អាបោធាតុយាបិ និព្វិន្ទតិ តេជោធាតុយាបិ និព្វិន្ទតិ វាយោធាតុយាបិ និព្វិន្ទតិ អាកាសធាតុយាបិ និព្វិន្ទតិ វិញ្ញាណធាតុយាបិ និព្វិន្ទតិ ។ បេ ។ បជានាតីតិ ។ ឆដ្ឋំ ។

[២៨៤] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ទ្រង់ត្រាស់សួរថា ម្នាលរាហុល អ្នកសម្គាល់សេចក្តីនោះដូចម្តេច បឋវីធាតុ ទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ... អាបោធាតុ... តេជោធាតុ... វាយោធាតុ... អាកាសធាតុ... វិញ្ញាណធាតុទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ... ។

[២៨៥] ម្នាលរាហុល អរិយសាវ័កអ្នកចេះដឹង កាលបើឃើញយ៉ាងនេះ ក៏រមែងនឿយណាយចំពោះបឋវីធាតុផង នឿយណាយចំពោះអាបោធាតុផង នឿយណាយចំពោះតេជោធាតុផង នឿយណាយចំពោះវាយោធាតុផង នឿយណាយចំពោះអាកាសធាតុផង នឿយណាយចំពោះវិញ្ញាណធាតុផង ។ បេ ។ ចប់សូត្រទី ៩ ។

[២៨៦] សាវត្ថិយំ វិហរតិ... តំ កឹ មញ្ញសិ រាហុល រូបំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ... វេទនា... សញ្ញា... សង្ខារា... វិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កាល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។

[២៨៧] ឯវំ បស្សំ រាហុល សុតវា អរិយសាវកោ រូបស្មិម្បិ និព្វិន្ទតិ វេទនាយបិ និព្វិន្ទតិ សញ្ញាយបិ និព្វិន្ទតិ សង្ខារេសុបិ និព្វិន្ទតិ វិញ្ញាណស្មិម្បិ និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ ។ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ។ ខីណា ជាតិ

[២៨៦] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ទ្រង់ត្រាស់សួរថា ម្នាលរាហុល អ្នកសម្គាល់សេចក្តីនោះ ដូចម្តេច រូបទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ... វេទនា... សញ្ញា... សង្ខារ... វិញ្ញាណ ទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ឯណាមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះរបស់ឯណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរពិចារណាឃើញនូវរបស់នោះថា នុ៎ះជារបស់អាត្មាអញ នុ៎ះជាអាត្មាអញ នុ៎ះជាខ្លួនរបស់អាត្មាអញដែរឬ ។ ហេតុនុ៎ះ មិនគួរទេ ព្រះអង្គ ។

[២៨៧] ម្នាលរាហុល អរិយសាវ័កអ្នកចេះដឹង កាលបើឃើញយ៉ាងនេះ ក៏រមែងនឿយណាយចំពោះរូបផង នឿយណាយចំពោះវេទ-នាផង នឿយណាយចំពោះសញ្ញាផង នឿយណាយចំពោះសង្ខារផង នឿយណាយចំពោះវិញ្ញាណផង កាលបើនឿយណាយហើយ ក៏ធុញទ្រាន់ ព្រោះការធុញទ្រាន់ ទើបចិត្តរួចស្រឡះ ។ កាលបើចិត្តរួចស្រឡះហើយ សេចក្តីដឹងក៏កើតមានថា ចិត្តអាត្មាអញរួចស្រឡះហើយ ។ អរិយសាវ័កនោះ រមែងដឹងច្បាស់ថា ជាតិអស់ហើយ

២៣០

សុត្តន្តបិដកេ សំយុត្តនិកាយស្ស និទានវគ្គោ

វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។ ទសមំ ។

អប្បមាទវគ្គោ បឋមោ ។

តស្ស ឧទ្ទានំ

ចក្ខុ រូបញ្ច វិញ្ញាណំ
សម្ផស្សោ វេទនាយ ច
សញ្ញាយ ច ចេតនា តណ្ហា
ធាតុ ខន្ធេន តេទសាតិ ។

---

មគ្គព្រហ្មចរិយៈ អាត្មាអញបានប្រព្រឹត្តរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ចប់សូត្រទី ១០ ។

ចប់ អប្បមាទវគ្គ ទី ១ ។

## ឧទ្ទាននៃអប្បមាទវគ្គនោះគឺ

ព្រះមានព្រះភាគទ្រង់សំដែងអំពីចក្ខុ ១ រូប ១ វិញ្ញាណ ១ សម្ផស្ស ១ វេទនា ១ សញ្ញា ១ ចេតនា ១ តណ្ហា ១ ធាតុ ១ ខន្ធ ១ ជា ១០ ។

# អនុសយវគ្គោ

[២៨៨] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អា-រាមេ ។ អថខោ អាយស្មា រាហុលោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯក-មន្តំ និសីទិ ។

[២៨៩] ឯកមន្តំ និសិន្នោ ខោ អាយស្មន្តំ រាហុលំ ភគវា ឯតទវោច តំ កឹ មញ្ញសិ រាហុល ចក្ខុំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ

# អនុសយវគ្គ

[២៨៨] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ព្រះរាហុលមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។

[២៨៩] លុះព្រះរាហុលមានអាយុ អង្គុយក្នុងទីសមគួរហើយ ទើបព្រះមានព្រះភាគមានព្រះពុទ្ធដីកាយ៉ាងនេះថា ម្នាលរាហុល អ្នកសម្គាល់ហេតុដូចម្តេច ភ្នែកទៀង ឬមិនទៀង ។ ព្រះរាហុលក្រាបបង្គំទូលថា មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ឯណាមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះរបស់ឯណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរដើម្បីឃើញរបស់នោះថា

ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ សោតំ... ឃានំ... ជិវ្ហា... កាយោ... មនោ និច្ចោ វា អនិច្ចោ វាតិ ។ អនិច្ចោ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កាល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។

[២៩០] ឯវំ បស្សំ រាហុល សុតវា អរិយសាវកោ ចក្ខុស្មិម្បិ និព្វិន្ទតិ សោតស្មិម្បិ និព្វិន្ទតិ ឃានស្មិម្បិ និព្វិន្ទតិ ជិវ្ហាយបិ និព្វិន្ទតិ កាយស្មិម្បិ និព្វិន្ទតិ មនស្មិម្បិ និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ ។ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ។ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។ បឋមំ ។

នុ៎ះជារបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញដែរឬទេ ។ មិនគួរឃើញយ៉ាងនុ៎ះទេ ព្រះអង្គ ។ ត្រចៀក... ច្រមុះ... អណ្តាត... កាយ... ចិត្ត ទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ ចុះរបស់ឯណាមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ ចុះរបស់ឯណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរដើម្បីឃើញរបស់នោះថា នុ៎ះជារបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញដែរឬទេ ។ មិនគួរឃើញយ៉ាងនុ៎ះទេ ព្រះអង្គ ។

[២៩០] ម្នាលរាហុល អរិយសាវ័កអ្នកចេះដឹង កាលឃើញយ៉ាងនេះ ក៏រមែងនឿយណាយក្នុងភ្នែកផង នឿយណាយក្នុងត្រចៀកផង នឿយណាយក្នុងច្រមុះផង នឿយណាយក្នុងអណ្តាតផង នឿយណាយក្នុងកាយផង នឿយណាយក្នុងចិត្តផង កាលបើនឿយណាយធុញទ្រាន់ ព្រោះការធុញទ្រាន់ ទើបចិត្តរួចស្រឡះ ។ កាលបើចិត្តរួចស្រឡះ ញាណក៏កើតឡើងថា ចិត្តរួចស្រឡះហើយ ។ អរិយសាវកនោះ ក៏ដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌អាត្មាអញបាននៅរួចហើយ សោឡសកិច្ចអាត្មាអញក៏បានធ្វើស្រេចហើយ កិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។ ចប់សូត្រទី ១ ។

(ឯតេន បេយ្យាលេន ទស សុត្តន្តា កាតព្វា)

[២៩១] តំ កឹ មញ្ញសិ រាហុល រូបា និច្ចា វា អនិច្ចា វាតិ ។ អនិច្ចា ភន្តេ... សទ្ទា... គន្ធា... រសា... ផោដ្ឋព្វា... ធម្មា... ។

[២៩២] ចក្ខុវិញ្ញាណំ... សោតវិញ្ញាណំ... ឃានវិញ្ញាណំ... ជិវ្ហាវិញ្ញាណំ... កាយវិញ្ញាណំ... មនោវិញ្ញាណំ... ។

[២៩៣] ចក្ខុសម្ផស្សោ... សោតសម្ផស្សោ... ឃានសម្ផស្សោ... ជិវ្ហាសម្ផស្សោ... កាយសម្ផស្សោ... មនោសម្ផស្សោ... ។

[២៩៤] ចក្ខុសម្ផស្សជា វេទនា... សោតសម្ផស្សជា វេទនា... ឃានសម្ផស្សជា វេទនា... ជិវ្ហាសម្ផស្សជា វេទនា... កាយសម្ផស្សជា វេទនា... មនោសម្ផស្សជា វេទនា... ។

[២៩៥] រូបសញ្ញា... សទ្ទសញ្ញា... គន្ធសញ្ញា... រសសញ្ញា... ផោដ្ឋព្វសញ្ញា... ធម្មសញ្ញា... ។

( សូត្រទាំង ១០ បណ្ឌិតគប្បីធ្វើតាមបេយ្យាលនុ៎ះចុះ )

[២៩១] ម្នាលរាហុល អ្នកសម្គាល់ហេតុនោះដូចម្តេច រូបទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ... សំឡេង... ក្លិន... រស... ផ្សព្វ... ធម្មារម្មណ៍... ។

[២៩២] ចក្ខុវិញ្ញាណ... សោតវិញ្ញាណ... ឃានវិញ្ញាណ... ជិវ្ហាវិញ្ញាណ... កាយវិញ្ញាណ... មនោវិញ្ញាណ... ។

[២៩៣] ចក្ខុសម្ផស្ស... សោតសម្ផស្ស... ឃានសម្ផស្ស... ជិវ្ហាសម្ផស្ស... កាយសម្ផស្ស... មនោសម្ផស្ស... ។

[២៩៤] វេទនាដែលកើតអំពីចក្ខុសម្ផស្ស... វេទនាដែលកើតអំពីសោតសម្ផស្ស... វេទនាដែលកើតអំពីឃានសម្ផស្ស... វេទនាដែលកើតអំពីជិវ្ហាសម្ផស្ស... វេទនាដែលកើតអំពីកាយសម្ផស្ស... វេទនាដែលកើតអំពីមនោសម្ផស្ស... ។

[២៩៥] សេចក្តីសម្គាល់ក្នុងរូប... សេចក្តីសម្គាល់ក្នុងសំឡេង... សេចក្តីសម្គាល់ក្នុងក្លិន... សេចក្តីសម្គាល់ក្នុងរស... សេចក្តីសម្គាល់ក្នុងផ្សព្វ... សេចក្តីសម្គាល់ក្នុងធម្មារម្មណ៍... ។

[២៨៦] រូបសញ្ចេតនា សទ្ទសញ្ចេតនា គន្ធសញ្ចេតនា រសសញ្ចេតនា ផោដ្ឋព្វសញ្ចេតនា ធម្មសញ្ចេតនា... ។

[២៩៧] រូបតណ្ហា... សទ្ទតណ្ហា... គន្ធតណ្ហា... រសតណ្ហា... ផោដ្ឋព្វតណ្ហា... ធម្មតណ្ហា... ។

[២៩៨] បឋវីធាតុ... អាបោធាតុ... តេជោធាតុ... វាយោធាតុ... អាកាសធាតុ... វិញ្ញាណធាតុ.... ។

[២៩៩] រូបំ... វេទនា... សញ្ញា... សង្ខារា... វិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ បេ ។ ឯវំ បស្សំ រាហុល ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។ ទសមំ ។

[២៩៦] សេចក្តីគិតក្នុងរូប... សេចក្តីគិតក្នុងសំឡេង... សេចក្តីគិតក្នុងក្លិន... សេចក្តីគិតក្នុងរស... សេចក្តីគិតក្នុងផ្សព្វ... សេចក្តីគិតក្នុងធម្មារម្មណ៍... ។

[២៩៧] រូបតណ្ហា... សទ្ទតណ្ហា... គន្ធតណ្ហា... រសតណ្ហា... ផោដ្ឋព្វតណ្ហា... ធម្មតណ្ហា... ។

២៩៨ បឋវីធាតុ... អាបោធាតុ... តេជោធាតុ... វាយោធាតុ... អាកាសធាតុ... វិញ្ញាណធាតុ... ។

[២៩៩] រូប... វេទនា... សញ្ញា... សង្ខារ... វិញ្ញាណ... ទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ បេ ។ ម្នាលរាហុល កាលបើ អរិយសាវកឃើញយ៉ាងនេះ ។ បេ ។ ដឹងច្បាស់ថា កិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។ ចប់សូត្រទី ១០ ។

[៣០០] សាវត្ថិយំ វិហរតិ... អថខោ អាយស្មា រាហុលោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា រាហុលោ ភគវន្តំ ឯតទវោច កថំ នុ ខោ ភន្តេ ជានតោ កថំ បស្សតោ ឥមស្មិញ្ច សវិញ្ញាណកេ កាយេ ពហិទ្ធា ច សព្វនិមិត្តេសុ អហង្ការមមង្ការមានានុសយា ន ហោន្តីតិ ។

[៣០១] យំ កិញ្ចិ រាហុល រូបំ អតីតានាគតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា សព្វំ រូបំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ បស្សតិ ។ យា កាចិ វេទនា... យា កាចិ សញ្ញា... យេ កេចិ សង្ខារា... យំ កិញ្ចិ វិញ្ញាណំ អតីតានាគតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា

រាហុលសំយុត្ត អនុសយវគ្គ ការសួររកចិត្ត

[៣០០] ព្រះសាស្តា ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... គ្រានោះឯង ព្រះរាហុលមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះរាហុលមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ក៏បានពោលពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលដឹងដូចម្តេចឃើញដូចម្តេច បានជាមិនមានអហង្ការមមង្ការ និងមានានុស័យ ក្នុងកាយប្រកបដោយវិញ្ញាណនេះផង ក្នុងនិមិត្តទាំងពួងជាខាងក្រៅផង ។

[៣០១] ម្នាលរាហុល រូបឯណានីមួយជាអតីត អនាគត បច្ចុប្បន្ន ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី រូបឯណាមានក្នុងទីឆ្ងាយក្តី មានក្នុងទីជិតក្តី រូបទាំងអស់នោះឈ្មោះថាជារូប បុគ្គលរមែងឃើញរូបនុ៎ះ ដោយបញ្ញាដ៏ប្រពៃតាមពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ វេទនាឯណានីមួយ... សញ្ញាឯណានីមួយ... សង្ខារទាំងឡាយឯណានីមួយ... វិញ្ញាណឯណានីមួយ ជាអតីត... អនាគត បច្ចុប្បន្ន ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី

បណីតំ វា យំ ទូរេ សន្តិកេ វា សព្វំ វិញ្ញាណំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ បស្សតិ ។ ឯវំ ខោ រាហុល ជានតោ ឯវំ បស្សតោ ឥមស្មិញ្ច សវិញ្ញាណកេ កាយេ ពហិទ្ធា ច សព្វនិមិត្តេសុ អហង្ការមមង្ការមានានុសយា ន ហោន្តីតិ ។ ឯកាទសមំ ។

[៣០២] សាវត្ថិយំ វិហរតិ... អថខោ អាយស្មា រាហុលោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា រាហុលោ ភគវន្តំ ឯតទវោច កថំ នុ ខោ ភន្តេ ជានតោ កថំ បស្សតោ ឥមស្មិញ្ច សវិញ្ញាណកេ កាយេ ពហិទ្ធា ច សព្វនិមិត្តេសុ អហង្ការមមង្ការមានាបគតំ មានសំ ហោតិ វិធា សមតិក្កន្តំ សន្តំ សុវិមុត្តន្តិ ។

ឧត្តមក្តី វិញ្ញាណឯណាដែលមានក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី វិញ្ញាណទាំងអស់នោះ ឈ្មោះថាជាវិញ្ញាណ បុគ្គលរមែងឃើញវិញ្ញាណនុ៎ះដោយបញ្ញាដ៏ប្រពៃតាមពិតយ៉ាងនេះថា នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ ម្នាលរាហុល កាលអរិយសាវ័កដឹងយ៉ាងនេះ ឃើញយ៉ាងនេះ បានជាមិនមានអហង្ការមមង្ការ និងមានានុស័យ ក្នុងកាយប្រកបដោយវិញ្ញាណនេះផង ក្នុងនិមិត្តទាំងពួកជាខាងក្រៅផង ។ ចប់សូត្រទី ១១ ។

[៣០២] ព្រះសាស្តា ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... គ្រានោះឯងព្រះរាហុលមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះរាហុលមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ បានពោលពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលដឹងដូចម្តេចឃើញដូចម្តេច បានជាមានចិត្តប្រាសចាកអហង្ការមមង្ការ និងមានះ ក្នុងកាយប្រកបដោយវិញ្ញាណនេះផង ក្នុងនិមិត្តទាំងពួងជាខាងក្រៅផង ជាចិត្តប្រព្រឹត្តកន្លងក្នុងចំណែកនៃមានះ និងស្ងប់រម្ងាប់រួចផុតចាកកិលេស ។

[៣០៣] យំ កិញ្ចិ រាហុល រូបំ អតីតានាគត-តប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា សព្វំ រូបំ នេតំ មម នេសោហមស្មិ នមេសោ អត្តាតិ ឯវ-មេតំ យថាភូតំ សម្មប្បញ្ញាយ ទិស្វា អនុបាទា វិមុត្តោ ហោតិ ។

(បញ្ចន្នំ ខន្ធានំ ឯវំ កាតព្វំ)

យា កាចិ វេទនា... យា កាចិ សញ្ញា... យេ កេចិ សង្ខារា... យំ កិញ្ចិ វិញ្ញាណំ អតីតានាគតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា សព្វំ វិញ្ញាណំ

រាហុលសំយុត្ត អនុសយវគ្គ ការព្យាករណ៍នូវចិត្ត

[៣០៣] ម្នាលរាហុល រូបឯណានីមួយ ជាអតីត អនាគត បច្ចុប្បន្ន ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី រូបឯណាដែលមានក្នុងទីឆ្ងាយក្តី មានក្នុងទីជិតក្តី រូបទាំងអស់នោះឈ្មោះថាជារូប អរិយសាវកឃើញនូវរូបនុ៎ះ ដោយបញ្ញាដ៏ប្រពៃតាមពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ដូច្នេះហើយ ទើបបានរួចស្រឡះចាកកិលេស ព្រោះមិនមានសេចក្តីប្រកាន់ ។

(បណ្ឌិតគប្បីធ្វើខន្ធទាំង ៥ ឲ្យដូចគ្នា)

វេទនាឯណានីមួយ... សញ្ញាឯណានីមួយ... សង្ខារទាំងឡាយឯណានីមួយ... វិញ្ញាណឯណានីមួយ ជាអតីត អនាគត បច្ចុប្បន្ន ជាខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី វិញ្ញាណឯណាដែលមានក្នុងទីឆ្ងាយក្តី មានក្នុងទីជិតក្តី វិញ្ញាណទាំងអស់នោះ

នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវ-
មេតំ យថាភូតំ សម្មប្បញ្ញាយ ទិស្វា អនុបាទា វិមុត្តោ
ហោតិ ។ ឯវំ ខោ រាហុល ជានតោ ពហិទ្ធា ច សព្វ-
និមិត្តេសុ អហង្ការមមង្ការមានាបគតំ មានសំ ហោតិ
វិធា សមតិក្កន្តំ សន្តំ សុវិមុត្តន្តិ ។ ទ្វាទសមំ ។

អនុសយវគ្គោ ទុតិយោ ។

## តស្ស ឧទ្ទានំ

ចក្ខុ រូបញ្ច វិញ្ញាណំ
សម្ផស្សោ វេទនាយ ច
សញ្ញា ច ចេតសា តណ្ហា
ធាតុ ខន្ធេន តេ ទស
អនុសយំ អបគតញ្ចេវ
វគ្គោ តេន បវុច្ចតីតិ ។

រាហុលសំយុត្តំ ឆដ្ឋំ សមត្តំ ។

ឈ្មោះថាជាវិញ្ញាណ អរិយសាវកឃើញនូវវិញ្ញាណនុ៎ះ ដោយបញ្ញាដ៏ប្រពៃតាមពិតយ៉ាងនេះថា នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ដូច្នេះហើយ ទើបបានរួចស្រឡះចាកកិលេស ព្រោះមិនមានសេចក្តីប្រកាន់ ។ ម្នាលរាហុល កាលអរិយសាវកដឹងយ៉ាងនេះ ឃើញយ៉ាងនេះ បានជាមានចិត្តប្រាសចាកអហង្ការមមង្ការ និងមានានុស័យ ក្នុងកាលដែលប្រកបដោយវិញ្ញាណនេះផង ក្នុងនិមិត្តទាំងពួងជាខាងក្រៅនេះ ជាចិត្តប្រព្រឹត្តកន្លងក្នុងចំណែកនៃមានះ និងស្ងប់រម្ងាប់រួចផុតចាកកិលេស ។ ចប់សូត្រទី ១២ ។

ចប់ អនុសយវគ្គ ទី ២ ។

## ឧទ្ទាននៃអនុសយវគ្គនោះគឺ

ចក្ខុ ១ រូប ១ វិញ្ញាណ ១ សម្ផស្ស ១ វេទនា ១ សញ្ញា ១ ចេតនា ១ តណ្ហា ១ ធាតុ ១ ខន្ធ ១ ត្រូវជា ១០ អនុសយ ១ ចិត្តដែលប្រាសចាកអហង្ការជាដើម ១ ជាវគ្គដែលព្រះមានព្រះភាគនោះទ្រង់ត្រាស់សំដែង ។

ចប់ រាហុលសំយុត្ត ទី ៦ ។

# លក្ខណសំយុត្តំ

## អដ្ឋិសង្ខលិកវគ្គោ

[៣០៤] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន អាយស្មា ច លក្ខណោ អាយស្មា ច មហាមោគ្គល្លានោ គិជ្ឈកូដេ បព្វតេ វិហរន្តិ ។

[៣០៥] អថខោ អាយស្មា មហាមោគ្គល្លានោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេនាយស្មា លក្ខណោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ លក្ខណំ ឯតទវោច ឯហិ អាវុសោ លក្ខណ រាជគហំ បិណ្ឌាយ បវិសិស្សាមាតិ ។ ឯវមាវុសោតិ ខោ អាយស្មា លក្ខណោ អាយស្មតោ មហាមោគ្គល្លានស្ស បច្ចស្សោសិ ។ អថខោ អាយស្មា មហាមោគ្គល្លានោ គិជ្ឈកូដា បព្វតា ឱរោហន្តោ អញ្ញតរស្មឹ បទេសេ សិតំ ចាត្វាកាសិ ។ អថខោ អាយស្មា លក្ខណោ អាយស្មន្តំ មហាមោគ្គល្លានំ ឯតទវោច

# លក្ខណសំយុត្ត

## អដ្ឋិសង្ខលិកវគ្គ

[៣០៤] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ ក៏ក្នុងសម័យនោះឯង ព្រះលក្ខណៈមានអាយុ ១ ព្រះមហាមោគ្គល្លានមានអាយុ ១ គង់នៅនាភ្នំគិជ្ឈកូដ ។

[៣០៥] គ្រានោះឯង ព្រះមហាមោគ្គល្លានមានអាយុ ស្លៀកស្បង់ប្រដាប់បាត្រចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅរកព្រះលក្ខណៈមានអាយុ លុះចូលទៅដល់ហើយ បានពោលពាក្យនេះនឹងព្រះលក្ខណៈមានអាយុថា ម្នាលអាវុសោលក្ខណៈ អ្នកចូរមក យើងនឹងចូលទៅក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាត ។ ព្រះលក្ខណៈមានអាយុទទួលពាក្យព្រះមហាមោគ្គល្លានមានអាយុថា អើអាវុសោ ។ គ្រានោះឯង ព្រះមហាមោគ្គល្លានមានអាយុ កាលនិមន្តចុះអំពីភ្នំគិជ្ឈកូដក៏ធ្វើនូវការញញឹមឲ្យប្រាកដក្នុងប្រទេសមួយ ។ គ្រានោះឯង ព្រះលក្ខណៈមានអាយុ បានសួរព្រះមហាមោគ្គល្លានមានអាយុដូច្នេះថា

កោ នុ ខោ អាវុសោ មោគ្គល្លាន ហេតុ កោ បច្ចយោ សិតស្ស បាតុកម្មាយាតិ ។ អកាលោ ខោ អាវុសោ លក្ខណ ឯតស្ស បញ្ហស្ស ភគវតោ មំ សន្តិកេ ឯតំ បញ្ហំ បុច្ឆាតិ ។

[៣០៦] អថខោ អាយស្មា ច លក្ខណោ អាយស្មា ច មហាមោគ្គល្លានោ រាជគហេ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា លក្ខណោ អាយស្មន្តំ មហាមោគ្គល្លានំ ឯតទវោច ឥធាយស្មា មហាមោគ្គល្លានោ គិជ្ឈកូដា បព្វតា ឱរោហន្តោ អញ្ញតរស្មឹ បទេសេ សិតំ បាត្វាកាសិ កោ នុ ខោ អាវុសោ មោគ្គល្លាន ហេតុ កោ បច្ចយោ សិតស្ស បាតុកម្មាយាតិ ។

ម្នាលអាវុសោមោគ្គល្លាន ហេតុដូចម្តេច បច្ច័យដូចម្តេច បានជាលោកធ្វើនូវការញញឹមឲ្យប្រាកដ ។ ម្នាលអាវុសោលក្ខណៈ កាលនេះជាកាលមិនគួរដើម្បីសួរប្រស្នានុ៎ះទេ អ្នកចូរសួរប្រស្នានុ៎ះនឹងខ្ញុំក្នុងសំណាក់ព្រះមានព្រះភាគចុះ ។

[៣០៦] គ្រានោះឯង ព្រះលក្ខណៈមានអាយុ និងព្រះមហាមោគ្គល្លានមានអាយុ ចូលទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ត្រឡប់មកអំពីបិណ្ឌបាតវិញក្នុងវេលាក្រោយភត្ត ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ លុះព្រះលក្ខណៈមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ បានសួរព្រះមហាមោគ្គល្លានមានអាយុដូច្នេះថា ក្នុងទីឯណោះមហាមោគ្គល្លានមានអាយុ កាលចុះមកអំពីភ្នំគិជ្ឈកូដ បានធ្វើនូវការញញឹមឲ្យប្រាកដក្នុងប្រទេសមួយ ម្នាលអាវុសោមោគ្គល្លាន ហេតុដូចម្តេច បច្ច័យដូចម្តេច បានជាលោកធ្វើនូវការញញឹមឲ្យប្រាកដ ។

[៣០៧] ឥធាហំ អាវុសោ គិជ្ឈកូដា បព្វតា ឱរោហន្តោ អទ្ទសំ អដ្ឋិសង្ខលិកំ វេហាសំ គច្ឆន្តឹ តមេនំ គិជ្ឈាបិ កាកាបិ កុលលាបិ អនុបតិត្វា អនុបតិត្វា វិតុទេន្តិ[១] វិតច្ឆេន្តិ វិរាជេន្តិ[២] សា សុទំ អដ្ដស្សរំ ករោតិ តស្ស មយ្ហំ អាវុសោ ឯតទហោសិ អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ ឯវរូបោបិ នាម សត្តោ ភវិស្សតិ ឯវរូបោបិ នាម យក្ខោ ភវិស្សតិ ឯវរូបោបិ នាម អត្តភាវប្បដិលាភោ ភវិស្សតីតិ ។

[៣០៨] អថខោ ភគវា ភិក្ខូ អាមន្តេសិ ចក្ខុភូតា វត ភិក្ខវេ សាវកា វិហរន្តិ ញាណភូតា វត ភិក្ខវេ សាវកា វិហរន្តិ យត្រ ហិ នាម សាវកោ ឯវរូបំ ញស្សតិ វា ទក្ខតិ វា សក្ខឹ វា ករិស្សតិ ។ បុព្វេវ មេ សោ ភិក្ខវេ សត្តោ ទិដ្ឋោ អហោសិ អបិចាហំ ន ព្យាកាសឹ អហញ្ចេតំ ព្យាករេយ្យុំ បរេបិ មេ ន សទ្ទហេយ្យុំ យេ មេ ន សទ្ទហេយ្យុំ តេសន្តំ អស្ស ទីឃរត្តំ អហិតាយ ទុក្ខាយ ។

---

១ ឱ. ម. ផាសុឡន្តរិកាហិ ។ ២ វិភជន្តិ ។

[៣០៧] ព្រះមហាមោគ្គល្លានថា ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីគិជ្ឈកូដ បានឃើញអដ្ឋិសង្ខលិក គឺរាងឆ្អឹង កំពុងអណ្តែតទៅលើអាកាស ពួកត្មាត ក្អែក រអាត ដេញតាមចាប ចោមចឹកចោះ ភើចជញ្ជែងនូវរាងឆ្អឹងនោះ រាងឆ្អឹងនោះក៏ចេះតែស្រែកថ្ងូរ ម្នាលអាវុសោ ទើបខ្ញុំនោះមានសេចក្តីបរិវិតក្កៈថា យីអើ អស្ចារ្យណាស់ យីអើ មិនធ្លាប់កើតមានសោះឡើយ យីអើ សត្វបែបនេះនឹងត្រឡប់ទៅជាមានខ្លះដែរ យក្ខបែបនេះនឹងត្រឡប់ទៅជាមានខ្លះដែរ កិរិយាបានអត្តភាពបែបនេះ នឹងត្រឡប់ទៅជាមានខ្លះដែរតើ ។

[៣០៨] គ្រានោះឯង ព្រះមានព្រះភាគ ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ពួកសាវ័កមានចក្ខុកើតពិតហើយ ម្នាលភិក្ខុទាំងឡាយ ពួកសាវ័កមានញាណកើតពិតហើយ ដ្បិតសាវ័កដឹង ឬឃើញសត្វបែបនេះ ឬថានឹងធ្វើសត្វបែបនេះឲ្យជាសាក្សី (ដល់តថាគតបាន) ។ ម្នាលភិក្ខុទាំងឡាយ សត្វនោះតថាគតធ្លាប់ឃើញមកអំពីមុនដែរ ប៉ុន្តែតថាគតមិនទាន់សំដែង បើតថាគតសំដែងអំពីរឿងសត្វនុ៎ះទៅ ជនទាំងឡាយដទៃ មិនជឿពាក្យតថាគតទេ ជនទាំងឡាយឯណាមិនជឿពាក្យតថាគត សេចក្តីមិនជឿនោះ របស់ជនទាំងនោះ នឹងនាំឲ្យខានបានប្រយោជន៍ នាំឲ្យបានតែសេចក្តីទុក្ខ អស់កាលជាយូរអង្វែង ។

ឯសោ ភិក្ខវេ សត្តោ ឥមស្មិញ្ញេវ រាជគហេ គោឃា-
តកោ អហោសិ សោ តស្ស កម្មស្ស វិបាកេន ពហូនិ
វស្សានិ ពហូនិ វស្សសតានិ ពហូនិ វស្សសហស្សានិ
ពហូនិ វស្សសតសហស្សានិ និរយេ បចិត្ត[១] តស្សេវ
កម្មស្ស វិបាកាវសេសេន ឯវរូបំ អត្តភាវប្បដិលាភំ
បដិសំវេទយតីតិ ។ បឋមំ ។

(សព្វេសំ សុត្តន្តានំ ឯសេវ បេយ្យាលោ)

[៣០៩] ឥធាហំ អាវុសោ គិជ្ឈកូដា បព្វតា
ឱរោហន្តោ អទ្ទសំ មំសបេសឹ វេហាសំ គច្ឆន្តឹ តមេនំ
គិជ្ឈាបិ កាកាបិ កុលលាបិ អនុបតិត្វា អនុបតិត្វា
វិតុទេន្តិ វិតច្ឆេន្តិ វិរាជេន្តិ សោ សុទំ អដ្ដស្សរំ ករោតិ ។
ឯសោ ភិក្ខវេ សត្តោ ឥមស្មិញ្ញេវ រាជគហេ គោឃា-
តកោ អហោសិ ។ ទុតិយំ ។

១ ឱ. ម. បចិត្វា ។

ម្នាលភិក្ខុទាំងឡាយ សត្វនោះ (ពីដើម) ជាគោឃាតកៈ គឺអ្នកសម្លាប់គោ ក្នុងក្រុងរាជគ្រឹះនេះឯង ដោយវិបាករបស់កម្មនោះ គោឃាតកៈបុរសនោះ ក៏ទៅឆេះក្នុងនរកអស់ឆ្នាំដ៏ច្រើន អស់រយឆ្នាំដ៏ច្រើន អស់ពាន់ឆ្នាំដ៏ច្រើន អស់សែនឆ្នាំដ៏ច្រើន ដោយសេសសល់វិបាកនៃកម្មនោះឯង ទើបបានត្រឡប់មកទទួលផល គឺត្រឡប់បានអត្តភាពបែបនេះឯង ។ ចប់សូត្រទី ១ ។

(នេះឯងជាបេយ្យាលនៃសូត្រទាំងអស់)

[៣០៩] ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈកូដ បានឃើញមំសបេសិ គឺចំរៀកសាច់ កំពុងអណ្តែតទៅលើអាកាស ពួកត្មាត ក្អែក រអាត ដេញតាមឆាប ចោមចឹកចោះភើចជញ្ជែងនូវចំរៀកសាច់នោះ ចំរៀកសាច់នោះ ក៏ចេះតែស្រែកថ្ងូរ ។ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះជាគោឃាតកៈ គឺអ្នកសម្លាប់គោ (ពីដើម) ក្នុងក្រុងរាជគ្រឹះនេះឯង ។ ចប់សូត្រទី ២ ។

[៣១០] ឥធាហំ អាវុសោ គិជ្ឈកូដា បព្វតា ឱរោហន្តោ អទ្ទសំ មំសបិណ្ឌំ វេហាសំ គច្ឆន្តំ តមេនំ គិជ្ឈាបិ កាកាបិ កុលលាបិ អនុបតិត្វា អនុបតិត្វា វិតុទេន្តិ វិតច្ឆេន្តិ វិរាជេន្តិ សោ អដ្ដស្សរំ ករោតិ ។ ឯសោ ភិក្ខវេ សត្តោ ឥមស្មិញ្ញេវ រាជគហេ សាកុ-ណិកោ អហោសិ ។ តតិយំ ។

[៣១១] ឥធាហំ អាវុសោ គិជ្ឈកូដា បព្វតា ឱរោហន្តោ អទ្ទសំ និច្ឆវឹ បុរិសំ វេហាសំ គច្ឆន្តំ តមេនំ គិជ្ឈាបិ កាកាបិ កុលលាបិ អនុបតិត្វា អនុបតិត្វា វិតុទេន្តិ វិតច្ឆេន្តិ វិរាជេន្តិ សោ សុទំ អដ្ដស្សរំ ករោតិ ។ ឯសោ ភិក្ខវេ សត្តោ ឥមស្មិញ្ញេវ រាជគហេ ឱរព្ភិកោ(១) អហោសិ ។ ចតុត្ថំ ។

[៣១២] ឥធាហំ អាវុសោ គិជ្ឈកូដា បព្វតា ឱរោហន្តោ អទ្ទសំ អសិលោមំ បុរិសំ វេហាសំ គច្ឆន្តំ តស្ស តេ អសី ឧប្បតិត្វា ឧប្បតិត្វា តស្សេវ កា-យេ និបតន្តិ សោ សុទំ អដ្ដស្សរំ ករោតិ ។

១ ឱរម្ភិកោតិប្បត្តិ ។

[៣១០] ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈកូដ បានឃើញមំសបិណ្ឌៈ គឺដុំសាច់ កំពុងអណ្តែតទៅលើអាកាស ពួកត្មាត ក្អែក រអាត ដេញតាមផាប ចោមចឹកចោះ កើចជញ្ជែងនូវដុំសាច់នោះ ដុំសាច់នោះក៏ចេះតែស្រែកថ្ងូរ ។ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះជាព្រាមបក្សី (អំពីដើម) ក្នុងក្រុងរាជគ្រឹះនេះឯង ។ ចប់សូត្រទី ៣ ។

[៣១១] ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈកូដ បានឃើញនិច្ឆវិបុរស គឺបុរសមិនមានស្បែកក្រៅ កំពុងអណ្តែតទៅលើអាកាស ពួកត្មាត ក្អែក រអាត ដេញតាមផាប ចោមចឹកចោះ កើចជញ្ជែងនូវនិច្ឆវិបុរសនោះ និច្ឆវិបុរសនោះក៏ចេះតែស្រែកថ្ងូរ ។ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះជាអ្នកសម្លាប់ចៀម (ពីដើម) ក្នុងក្រុងរាជគ្រឹះនេះឯង ។ ចប់សូត្រទី ៤ ។

[៣១២] ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈកូដ បានឃើញអសិលោមបុរស គឺបុរសមានរោមដូចដាវ កំពុងអណ្តែតទៅលើអាកាស ដាវទាំងនោះ របស់បុសនោះ អណ្តែតធ្លាក់ ៗ មកត្រូវកាយរបស់បុរសនោះឯង បុរសនោះក៏ចេះតែស្រែកថ្ងូរ ។

ឯសោ ភិក្ខវេ សត្តោ ឥមស្មិញ្ញេវ រាជគហេ សូករិ-
កោ អហោសិ ។ បញ្ចមំ ។

[៣១៣] ឥធាហំ អាវុសោ គិជ្ឈកូដា បព្វតា ឱ-
រោហន្តោ អទ្ទសំ សត្តិលោមំ បុរិសំ វេហាសំ គច្ឆន្តំ
តស្ស តា សត្តិយោ ឧប្បតិត្វា ឧប្បតិត្វា តស្សេវ កា-
យេ និបតន្តិ សោ សុទំ អដ្ដស្សរំ ករោតិ ។ ឯសោ
ភិក្ខវេ សត្តោ ឥមស្មិញ្ញេវ រាជគហេ មាគវិកោ អ-
ហោសិ ។ ឆដ្ឋំ ។

[៣១៤] ឥធាហំ អាវុសោ គិជ្ឈកូដា បព្វតា ឱ-
រោហន្តោ អទ្ទសំ ឧសុលោមំ បុរិសំ វេហាសំ គច្ឆន្តំ
តស្ស តេ ឧសូ ឧប្បតិត្វា ឧប្បតិត្វា តស្សេវ កាយេ
និបតន្តិ សោ សុទំ អដ្ដស្សរំ ករោតិ ។ ឯសោ ភិក្ខវេ
សត្តោ ឥមស្មិញ្ញេវ រាជគហេ ការណិកោ អហោសិ ។
សត្តមំ ។

ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះជាអ្នកសម្លាប់ជ្រូក (ពីដើម) ក្នុងក្រុងរាជ-គ្រឹះនេះឯង ។ ចប់សូត្រទី ៥ ។

[៣១៣] ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈកូដ បានឃើញសត្តិលោមបុរស គឺបុរសមានរោមដូចលំពែង កំពុងអណ្តែតទៅលើអាកាស លំពែងទាំងនោះ របស់បុរសនោះ អណ្តែតធ្លាក់ៗ មកត្រូវកាយរបស់បុរសនោះឯង បុរសនោះក៏ចេះតែស្រែកថ្ងូរ ។ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះជាព្រានម្រឹគ (ពីដើម) ក្នុងក្រុងរាជគ្រឹះនេះឯង ។ ចប់សូត្រទី ៦ ។

[៣១៤] ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈកូដ បានឃើញឧសុលោមបុរស គឺបុរសមានរោមដូចព្រួញ កំពុងអណ្តែតទៅលើអាកាស ព្រួញទាំងនោះ របស់បុរសនោះ អណ្តែតធ្លាក់ៗ មកត្រូវកាយរបស់បុរសនោះឯង បុរសនោះក៏ចេះតែស្រែកថ្ងូរ ។ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះជាពេជ្ឈឃាដ (ពីដើម) ក្នុងក្រុងរាជគ្រឹះនេះឯង ។ ចប់សូត្រទី ៧ ។

[៣១៥] ឥធាហំ អាវុសោ គិជ្ឈកូដា បព្វតា ឱរោហន្តោ អទ្ទសំ សូចិលោមំ បុរិសំ វេហាសំ គច្ឆន្តំ តស្ស តា សូចិយោ ឧប្បតិត្វា ឧប្បតិត្វា តស្សេវ កាយេ និបតន្តិ សោ សុទំ អដ្ដស្សរំ ករោតិ ។ ឯសោ ភិក្ខវេ សត្តោ ឥមស្មិញ្ញេវ រាជគហេ សូតោ[១] អហោសិ ។ អដ្ឋមំ ។

[៣១៦] ឥធាហំ អាវុសោ គិជ្ឈកូដា បព្វតា ឱរោហន្តោ អទ្ទសំ សូចិលោមំ បុរិសំ វេហាសំ គច្ឆន្តំ តស្ស តា សូចិយោ សីសេ បវិសេត្វា មុខតោ និក្ខមន្តិ មុខេ បវិសេត្វា ឧរតោ និក្ខមន្តិ ឧរេ បវិសេត្វា ឧទរតោ និក្ខមន្តិ ឧទរេ បវិសេត្វា ឩរូហិ និក្ខមន្តិ ឩរូសុ បវិសេត្វា ជង្ឃាហិ និក្ខមន្តិ ជង្ឃាសុ បវិសេត្វា បាទេហិ និក្ខមន្តិ សោ សុទំ អដ្ដស្សរំ ករោតិ ។ ឯសោ ភិក្ខវេ សត្តោ ឥមស្មិញ្ញេវ រាជគហេ សូចិកោ អហោសិ ។ នវមំ ។

---

១ ឱ. សូចកោ ។ ម. សារថិកោ ។

[៣១៥] ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈកូដ បានឃើញសូចិលោមបុរស គឺបុរសមានរោមដូចដែកស្រួច កំពុងអណ្តែតលើអាកាស ដែកស្រួចទាំងនោះ របស់បុរសនោះអណ្តែតធ្លាក់ៗ មកត្រូវកាយរបស់បុរសនោះវិញ បុរសនោះក៏ចេះតែស្រែកថ្ងូរ ។ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះជាអ្នកបរគោ (ពីដើម) ក្នុងក្រុងរាជគ្រឹះនេះឯង ។ ចប់សូត្រទី ៨ ។

[៣១៦] ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈកូដ បានឃើញសូចិលោមបុរស គឺបុរសមានរោមដូចដែកស្រួច កំពុងអណ្តែតទៅលើអាកាស ដែកស្រួចទាំងនោះ របស់បុរសនោះ ក៏ដោតចូលទៅក្នុងក្បាល ធ្លាយចេញមកតាមមាត់ ដោតចូលទៅក្នុងមាត់ ធ្លាយចេញមកតាមទ្រូង ដោតចូលទៅក្នុងទ្រូង ធ្លាយចេញមកតាមពោះ ដោតចូលទៅក្នុងពោះ ធ្លាយចេញមកតាមភ្លៅ ដោតចូលទៅក្នុងភ្លៅ ធ្លាយចេញមកតាមស្មង ដោតចូលទៅក្នុងស្មង ធ្លាយចេញមកតាមបាតជើង បុរសនោះក៏ចេះតែស្រែកថ្ងូរ ។ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះជាអ្នកចាក់ដោតគឺញុះញង់គេ (ពីដើម) ក្នុងក្រុងរាជគ្រឹះនេះឯង ។ ចប់សូត្រទី ៩ ។

[៣១៧] ឥធាហំ អាវុសោ គិជ្ឈកូដា បព្វតា ឱរោ-
ហន្តោ អទ្ទសំ កុម្ភណ្ឌំ បុរិសំ វេហាសំ គច្ឆន្តំ សោ
គច្ឆន្តោបិ តេ ច អណ្ឌា ខន្ធេ អារោបេត្វា គច្ឆតិ និ-
សីទន្តោបិ តេស្វេវ អណ្ឌាសុ និសីទតិ តមេនំ គិជ្ឈាបិ
កាកាបិ កុលលាបិ អនុបតិត្វា អនុបតិត្វា វិតុទេន្តិ
វិតច្ឆេន្តិ វិរាជេន្តិ សោ សុទំ អដ្ដស្សរំ ករោតិ ។ ឯ-
សោ ភិក្ខវេ សត្តោ ឥមស្មិញ្ញេវ រាជគហេ គាមកូដោ
អហោសិ ។ ចតុត្ថំ ។

អដ្ឋិសង្ខលិកវគ្គោ បឋមោ ។

[៣១៧] ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈកូដ បានឃើញកុម្ភណ្ឌបុរស គឺបុរសមានអណ្ឌៈប៉ុនក្អម[១] កំពុងអណ្តែតទៅលើអាកាស កាលបុរសនោះដើរទៅ លុះតែលើកអណ្ឌៈទាំងនោះដាក់ត្រង់ក (លី) ទើបដើរទៅបាន កាលអង្គុយក៏អង្គុយសង្កត់លើអណ្ឌៈទាំងនោះឯង ពួកត្មាត ក្អែក រអាត ដេញតាមចាប ចោមចឹកចោះ ភើចជញ្ជែងនូវបុរសនោះ បុរសនោះក៏ចេះតែស្រែកថ្ងូរ ។ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះជាអ្នកកាន់អំពើវៀចក្នុងស្រុក[២] (ពីដើម) ក្នុងស្រុករាជគ្រឹះនេះឯង ។ ចប់សូត្រទី ១០ ។

ចប់ អដ្ឋិសង្ខលិកវគ្គ ទី ១ ។

---

១ ពងល្វា ។ ២ ជាអមាត្យអ្នកវិនិច្ឆ័យក្តីដោយទុច្ចរិត ។

## ២៤៧



# តស្ស ឧទ្ទានំ

អដ្ឋិ បេសិ ឧភោ គាវីឃាតកា[1]
បិណ្ឌោ សាកុណិយោ[2] និច្ឆវោរព្ភិ
អសិ សូករិកោ សត្តិ មាគវី
ឧសុ ការណិកោ សូចិ សារថិ
យោ ច សិព្វិស្សតិ[3] សូចិតោ ហិ សោ
អណ្ឌភារី អហុ គាមកូដកោតិ ។

១ ឱ. ម. គាវឃាតកា ។ ២ បិណ្ឌសាកុណិយំ ។ ៣ ឱ. ម. សិព្វិយតិ ។

# ឧទ្ទាននៃអដ្ឋិសង្ខលិកវគ្គនោះគឺ

*អដ្ឋិសង្ខលិកប្រេត មំសបេសិប្រេត (ពីដើម) ជាអ្នកសម្លាប់គោទាំងពីរនាក់ មំសបិណ្ឌប្រេត (ពីដើម) ជាព្រានបក្សី និច្ឆវីប្រេត (ពីដើម) ជាអ្នកសម្លាប់ចៀម អសិលោមប្រេត (ពីដើម) ជាអ្នកសម្លាប់ជ្រូក សត្តិលោមប្រេត (ពីដើម) ជាព្រានម្រឹគ ឧសុលោមប្រេត (ពីដើម) ជាពេជ្ឈឃាដ សុចិ-លោមប្រេត (ពីដើម) ជានាយសារថី អ្នកឯណាញុះញង់គេ (ពីដើម) អ្នកនោះជាសូចិលោមប្រេតពិត កុម្ភណ្ឌប្រេតមានអណ្ឌៈធ្ងន់ (ពីដើម) ជាអ្នកកាន់អំពើវៀចក្នុងស្រុក ។*

---

# បារទារិកវគ្គោ

[៣១៨] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ ឥធាហំ អាវុសោ គិជ្ឈកូដា បព្វតា ឱរោហន្តោ អទ្ទសំ បុរិសំ គូថកូបេ សីសកោ និមុគ្គំ ។ ឯសោ ភិក្ខវេ សត្តោ ឥមស្មិញ្ញេវ រាជគហេ ចារទារិកោ អហោសិ ។ បឋមំ ។

(ឯវំ បេយ្យាលោ កាតព្វោ)

[៣១៩] ឥធាហំ អាវុសោ គិជ្ឈកូដា បព្វតា ឱរោហន្តោ អទ្ទសំ បុរិសំ គូថកូបេ និមុគ្គំ ឧភោហិ ហត្ថេហិ គូថំ ខាទន្តំ ។ ឯសោ ភិក្ខវេ សត្តោ ឥមស្មិញ្ញេវ រាជគហេ ព្រាហ្មណោ អហោសិ ។ សោ កស្សបស្ស សម្មាសម្ពុទ្ធស្ស បាវចនេ ភិក្ខុសង្ឃំ ភត្តេន និមន្តេត្វា

# បារទារិកវគ្គ

[៣១៨] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈកូដ បានឃើញបុរសម្នាក់ កំពុងមុជក្បាលចុះទៅក្នុងរណ្តៅលាមក ។ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះជាអ្នកប្រព្រឹត្តបរទារិកកម្មគឺលួចប្រពន្ធអ្នកដទៃ (ពីដើម) ក្នុងក្រុងរាជគ្រឹះនេះឯង ។ ចប់សូត្រទី ១ ។

(បេយ្យាល បណ្ឌិតគប្បីធ្វើយ៉ាងនេះ)

[៣១៩] ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈកូដ បានឃើញបុរសម្នាក់ កំពុងមុជក្នុងរណ្តៅលាមក ចាប់លាមកដោយដៃទាំងសងខាងស៊ី ។ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះពីដើមជាព្រាហ្មណ៍ ក្នុងក្រុងរាជគ្រឹះនេះឯង ។ ព្រាហ្មណ៍នោះ កាលក្នុងសាសនាព្រះកស្សបសម្មាសម្ពុទ្ធ បាននិមន្តភិក្ខុសង្ឃដោយកត្តហារ

ទោណិយា គូថស្ស បូរាបេត្វា កាលំ អារោចាបេត្វា ឯតទវោច អហោ ភោន្តោ យាវទត្ថំ ភុញ្ជន្តុ ចេវ ហរន្តុ ចាតិ ។ ទុតិយំ ។

[៣២០] ឥធាហំ អាវុសោ គិជ្ឈកូដា បព្វតា ឱ-រោហន្តោ អទ្ទសំ និច្ឆវឹ ឥត្ថឹ វេហាសំ គច្ឆន្តឹ តមេនំ គិជ្ឈាបិ កាកាបិ កុលលាបិ អនុបតិត្វា អនុបតិត្វា វិតុទេន្តិ វិតច្ឆេន្តិ វិរាជេន្តិ សា សុទំ អដ្ដស្សរំ ករោតិ ។ ឯសា ភិក្ខវេ ឥត្ថី ឥមស្មិញ្ញេវ រាជគហេ អតិចារិនី អហោសិ ។ តតិយំ ។

[៣២១] ឥធាហំ អាវុសោ គិជ្ឈកូដា បព្វតា ឱ-រោហន្តោ អទ្ទសំ ឥត្ថឹ ទុគ្គន្ធំ មង្គុលឹ វេហាសំ គច្ឆន្តឹ តមេនំ គិជ្ឈាបិ កាកាបិ កុលលាបិ អនុបតិត្វា អនុប-តិត្វា វិតុទេន្តិ វិតច្ឆេន្តិ វិរាជេន្តិ សា សុទំ អដ្ដស្សរំ ករោតិ ។ ឯសា ភិក្ខវេ ឥត្ថី ឥមស្មិញ្ញេវ រាជគហេ ឥក្ខណិកា អហោសិ ។ ចតុត្ថំ ។

ក៏ដាក់លាមកពេញក្នុងស្នូក រួចហើយប្រើគេឲ្យប្រាប់កត្តកាល ហើយពោលដូច្នេះថា សូមលោកម្ចាស់ទាំងឡាយនិមន្តឆាន់ដរាបដល់ឆ្អែតផង សូមនិមន្តយកទៅផង ។ ចប់សូត្រទី ២ ។

[៣២០] ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈកូដ បានឃើញស្រីនិច្ឆវី គឺស្រីមិនមានស្បែកក្រៅ កំពុងអណ្តែតទៅលើអាកាស ពួកត្មាត ក្អែក រអាត ដេញតាមឆាប ចោមចឹកចោះ គើចជញ្ជែង នូវស្រីនោះ ស្រីនោះក៏ចេះតែស្រែកថ្ងូរ ។ ម្នាលភិក្ខុទាំងឡាយ ស្រីនុ៎ះ (ពីដើម) ជាស្រីប្រព្រឹត្តកន្លងចិត្តប្តី ក្នុងក្រុងរាជគ្រឹះនេះឯង ។ ចប់សូត្រទី ៣ ។

[៣២១] ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈកូដ បានឃើញស្រីមង្គុឡី[១] មានក្លិនស្អុយ កំពុងអណ្តែតទៅលើអាកាស ពួកត្មាត ក្អែក រអាត ដេញតាមឆាប ចោមចឹកចោះ គើចជញ្ជែង នូវស្រីនោះ ស្រីនោះក៏ចេះតែស្រែកថ្ងូរ ។ ម្នាលភិក្ខុទាំងឡាយ ស្រីនុ៎ះ (ពីដើម) ជាស្រីមេមត់ ក្នុងក្រុងរាជគ្រឹះនេះឯង ។ ចប់សូត្រទី ៤ ។

---

១ ស្រីមានរូបអាក្រក់បុរសគប្បីខ្ពើម ។

[៣៦២] ឥធាហំ អាវុសោ គិជ្ឈកូដា បព្វតា ឱរោហន្តោ អទ្ទសំ ឥត្ថឹ ឧបក្កំ ឱកិលិនឹ ឱកិរិណឹ វេហាសំ គច្ឆន្តឹ សា សុទំ អដ្ដស្សរំ ករោតិ ។ ឯសា ភិក្ខវេ ឥត្ថី កលិង្គស្ស រញ្ញោ អគ្គមហេសី អហោសិ សា ឥស្សាបកតា សបត្តឹ អង្គារកដាហេន ឱកិរិ ។ បញ្ចមំ ។

[៣៦៣] ឥធាហំ អាវុសោ គិជ្ឈកូដា បព្វតា ឱរោហន្តោ អទ្ទសំ អសីសកពន្ធំ វេហាសំ គច្ឆន្តំ តស្ស ឧរេ អក្ខីនិ ចេវ ហោន្តិ មុខញ្ច តមេនំ គិជ្ឈាបិ កាកាបិ កុលលាបិ អនុបតិត្វា អនុបតិត្វា វិតុដេន្តិ វិតច្ឆេន្តិ វិភជេន្តិ សោ សុទំ អដ្ដស្សរំ ករោតិ ។ ឯសោ ភិក្ខវេ សត្តោ ឥមស្មិញ្ញេវ រាជគហេ ហារិកោ នាម ចោរឃាតកោ អហោសិ ។ ឆដ្ឋំ ។

[៣២២] ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈកូដ បានឃើញស្រីមានកាយឆេះរោលរាលដោយភ្លើង មានកាយសើមជោកជាំ មានកាយដេរដាសដោយរងើកភ្លើង កំពុងតែអណ្តែតទៅលើអាកាស ស្រីនោះក៏បេះតែស្រែកថ្ងូរ ។ ម្នាលភិក្ខុទាំងឡាយ ស្រីនុ៎ះ (ពីដើម) ជាអគ្គមហេសីនៃស្តេចក្នុងដែនកលិង្គ ស្រីនោះជាអ្នកមានសេចក្តីឫស្យាគ្របសង្កត់ បានចាក់រងើកភ្លើងមួយអំបែងលើស្រី[១] ជាមហេសីចុង ។ ចប់សូត្រទី ៥ ។

[៣២៣] ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈកូដ បានឃើញអសីសកពន្ធប្រេត កំពុងអណ្តែតទៅលើអាកាស ប្រេតនោះមានភ្នែកនិងមុខនៅត្រង់ទ្រូង ពួកត្មាត ក្អែក រអាត ដេញតាមចាប ចោមចឹកចោះ ភើចជញ្ជែង នូវប្រេតនោះ ប្រេតនោះក៏បេះតែស្រែកថ្ងូរ ។ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះ (ពីដើម) ឈ្មោះហារិកៈជាអ្នកពិឃាដចោរ ក្នុងក្រុងរាជគ្រឹះនេះឯង ។ ចប់សូត្រទី ៦ ។

១ ស្រីរួមប្តី ។

[៣២៤] ឥធាហំ អាវុសោ គិជ្ឈកូដា បព្វតា ឱរោហន្តោ អទ្ទសំ ភិក្ខុំ វេហាសំ គច្ឆន្តំ តស្ស សង្ឃាដិបិ អាទិត្តា សម្បជ្ជលិតា សញ្ជោតិភូតា បត្តោបិ អាទិត្តោ សម្បជ្ជលិតោ សញ្ជោតិភូតោ កាយពន្ធនម្បិ អាទិត្តំ សម្បជ្ជលិតំ សញ្ជោតិភូតំ កាយោបិ អាទិត្តោ សម្បជ្ជលិតោ សញ្ជោតិភូតោ សោ សុទំ អដ្ដស្សរំ ករោតិ ។ ឯសោ ភិក្ខវេ ភិក្ខុ កស្សបស្ស សម្មាសម្ពុទ្ធស្ស ចាវចនេ ចាបភិក្ខុ អហោសិ ។ សត្តមំ ។

[៣២៥] អទ្ទសំ ភិក្ខុនឹ វេហាសំ គច្ឆន្តឹ តស្សា សង្ឃាដិបិ អាទិត្តា ។ បេ ។ ចាបភិក្ខុនី អហោសិ ។ អដ្ឋមំ ។

[៣២៦] អទ្ទសំ សិក្ខមានំ វេហាសំ គច្ឆន្តឹ តស្សា សង្ឃាដិបិ អាទិត្តា ។ បេ ។ ចាបសិក្ខមានា អហោសិ ។ នវមំ ។

[៣២៧] អទ្ទសំ សាមណេរំ វេហាសំ គច្ឆន្តំ តស្ស សង្ឃាដិបិ អាទិត្តា ។ បេ ។ ចាបសាមណេរោ អហោសិ ។ ទសមំ ។

[៣២៤] ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមក អំពីភ្នំគិជ្ឈកូដ បានឃើញភិក្ខុ កំពុងអណ្តែតទៅលើអាកាស សង្ឃាដីរបស់ភិក្ខុនោះក្តី មានភ្លើងឆេះសន្ធោសន្ធៅ បាត្រក្តី រាងកាយក្តី សន្ធោសន្ធៅ វត្ថពន្ធចង្កេះក្តី ក៏មានភ្លើងឆេះសន្ធោសន្ធៅ រាងកាយក្តី ក៏មានភ្លើងឆេះសន្ធោសន្ធៅ ភិក្ខុនោះក៏ចេះតែស្រែកថ្ងូរ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនុ៎ះ (ពីដើម) ជាភិក្ខុលាមក ក្នុងសាសនាព្រះកស្សបសម្មាសម្ពុទ្ធ ។ ចប់សូត្រទី ៧ ។

[៣២៥] ខ្ញុំបានឃើញភិក្ខុនី កំពុងអណ្តែតទៅលើអាកាស សង្ឃាដីរបស់ភិក្ខុនោះក្តី មានភ្លើងឆេះ ។ បេ ។ ជាភិក្ខុនីលាមក ។ ចប់សូត្រទី ៨ ។

[៣២៦] ខ្ញុំបានឃើញសិក្ខមានា កំពុងអណ្តែតទៅលើអាកាស សង្ឃាដីរបស់សិក្ខមានានោះក្តី មានភ្លើងឆេះ ។ បេ ។ ជាសិក្ខមានាលាមក ។ ចប់សូត្រទី ៩ ។

[៣២៧] ខ្ញុំបានឃើញសាមណេរ កំពុងអណ្តែតទៅលើអាកាស សង្ឃាដីរបស់សាមណេរនោះក្តី មានភ្លើងឆេះ ។ បេ ។ ជាសាមណេរលាមក ។ ចប់សូត្រទី ១០ ។

[៣២៨] ឥធាហំ អាវុសោ គិជ្ឈកូដា បព្វតា ឱរោហន្តោ អទ្ទសំ សាមណេរឹ វេហាសំ គច្ឆន្តឹ តស្សា សង្ឃាដិបិ អាទិត្តា សម្បជ្ជលិតា សជោតិភូតា បត្តោបិ អាទិត្តោ សម្បជ្ជលិតោ សជោតិភូតោ កាយពន្ធនម្បិ អាទិត្តំ សម្បជ្ជលិតំ សជោតិភូតំ កាយោបិ អាទិត្តោ សម្បជ្ជលិតោ សជោតិភូតោ សា សុទំ អដ្ដស្សរំ ករោតិ ។ តស្ស មយ្ហំ អាវុសោ ឯតទហោសិ អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ ឯវរូបោបិ នាម សត្តោ ភវិស្សតិ ឯវរូបោបិ នាម យក្ខោ ភវិស្សតិ ឯវរូបោបិ នាម អត្តភាវប្បដិលាភោ ភវិស្សតីតិ ។

[៣២៩] អថខោ ភគវា ភិក្ខូ អាមន្តេសិ ចក្ខុភូតា វត ភិក្ខវេ សាវកា វិហរន្តិ ញាណភូតា វត ភិក្ខវេ សាវកា វិហរន្តិ យត្រ ហិ នាម សាវកោ ឯវរូបំ ញស្សតិ វា ទក្ខតិ វា សក្ខឹ វា ករិស្សតិ ។

[៣២៨] ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមក អំពីភ្នំគិជ្ឈកូដ បានឃើញសាមណេរី កំពុងអណ្តែតទៅលើអាកាស សង្ឃាដីរបស់សាមណេរីនោះក្តី មានភ្លើងឆេះសន្ធោសន្ធៅ បាត្រក្តី ក៏មានភ្លើងឆេះសន្ធោសន្ធៅ វត្ថពន្ធចង្កេះក្តី ក៏មានភ្លើងឆេះសន្ធោសន្ធៅ រាងកាយក្តី ក៏មានភ្លើងឆេះសន្ធោសន្ធៅ សាមណេរីនោះក៏ចេះតែស្រែកថ្ងូរ ។ ម្នាលអាវុសោ ខ្ញុំមានសេចក្តីត្រិះរិះដូច្នេះថា ឱអស្ចារ្យណាស់ហ្ន៎ ឱប្លែកណាស់ហ្ន៎ ឃើអើ សត្វបែបនេះនឹងមានខ្លះដែរ យក្សបែបនេះនឹងមានខ្លះដែរ ការត្រឡប់បានអត្តភាពបែបនេះ នឹងមានខ្លះដែរតើ ។

[៣២៩] គ្រានោះ ព្រះមានព្រះភាគ ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ពួកសាវ័កមានចក្ខុកើតពិតហើយ ម្នាលភិក្ខុទាំងឡាយ ពួកសាវ័កមានញាណកើតពិតហើយ ដ្បិតថាសាវ័កនឹងដឹងឬឃើញនូវសាមណេរីបែបនេះ នឹងធ្វើជាសាក្សី (ដល់តថាគតបាន) ។

បុព្វេ មេ សា ភិក្ខវេ សាមណេរី ទិដ្ឋា អហោសិ ។ អបិ ចាហំ ន ព្យាកាសឹ អហាញ្ចេតំ ព្យាករេយ្យំ បរេ ចមេ ន សទ្ទហេយ្យុំ យេ មេ ន សទ្ទហេយ្យុំ តេសំ តំ អស្ស ទីឃរត្តំ អហិតាយ ទុក្ខាយ ។ ឯសា ភិក្ខវេ សាមណេរី កស្សបស្ស សម្មាសម្ពុទ្ធស្ស បា-វចនេ បាបសាមណេរី អហោសិ សា តស្ស កម្មស្ស វិបាកេន ពហូនិ វស្សានិ ពហូនិ វស្សសតានិ ព-ហូនិ វស្សសហស្សានិ ពហូនិ វស្សសតសហស្សានិ និរយេ បច្ចិត្វា តស្សេវ កម្មស្ស វិបាកាវសេសេន ឯវរូបំ អត្តភាវប្បដិលាភំ បដិសំវេទយតីតិ ។ ឯកា-ទសមំ ។

បារទារិកវគ្គោ ទុតិយោ ។

ម្នាលភិក្ខុទាំងឡាយ សាមណេរីនោះ តថាគតធ្លាប់បានឃើញមកពីមុនដែរ ។ តែថា តថាគតមិនទាន់បានព្យាករ បើតថាគតព្យាករហេតុនោះទៅ ជនទាំងឡាយដទៃមិនជឿតថាគត ពួកជនឯណាមិនជឿតថាគត ហេតុដែលមិនជឿនោះ នឹងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្ដីទុក្ខ ដល់ជនទាំងនោះ អស់កាលដ៏យូរ ។ ម្នាលភិក្ខុទាំងឡាយ សាមណេរីនោះ (ពីដើម) ជាសាមណេរលាមក ក្នុងសាសនាព្រះកស្សបសម្មាសម្ពុទ្ធ ដោយវិបាកនៃកម្មនោះ សាមណេរីនោះ ក៏ឆេះនៅក្នុងនរក អស់ឆ្នាំទាំងឡាយដ៏ច្រើន អស់រយឆ្នាំដ៏ច្រើន អស់ពាន់ឆ្នាំដ៏ច្រើន អស់សែនឆ្នាំដ៏ច្រើន ដោយសេសសល់វិបាកនៃកម្មនោះឯងទើបត្រឡប់បាននូវអត្តភាពបែបនេះ ។ ចប់សូត្រទី ១១ ។

ចប់ បារទារិកវគ្គ ទី ២ ។

# តស្ស ឧទ្ទានំ

កូបេ និមុគ្គោ ហិ សោ បារទារិកោ
គូថខាទិ អហុ ទុដ្ឋព្រាហ្មណោ
និច្ឆវិត្ថី អតិចារិនី អហុ
មង្គុលិត្ថី អហុ ឥក្ខណិត្ថិកា
ឱកិលិនី សប្បតឹ ករោតិ[១]
សីសច្ឆិន្នោ អហុ ចោរឃាតកោ
ភិក្ខុ ភិក្ខុនី សិក្ខមានា
សាមណេរោ អថ សាមណេរិកោ[២]
កស្សបស្ស វិនយស្ស បព្វជ្ជំ[៣]
បាបកម្មំ អករីសុ តាវទេតិ ។

លក្ខណសំយុត្តំ សត្តមំ សមត្តំ ។

---

១ ឱ. ម. សបតង្គារោ កិរី ។ ២ សាមណេរិយោ ។ ៣ វិនយស្មឹ បព្វជ្ជំ ។

# ឧទ្ទាននៃបារទារិកវគ្គនោះគឺ

*ប្រេតដែលមុជក្នុងរណ្តៅ ប្រេតនោះ (ពីដើម) ជាអ្នកប្រព្រឹត្ត បរទារិកកម្ម ប្រេតដែលទំពាស៊ីលាមក ប្រេតនោះ (ពីដើម) ធ្លាប់ជាព្រាហ្មណ៍អាក្រក់ ស្រីជានិច្ឆវីប្រេត (ពីដើម) ជាអ្នកប្រព្រឹត្តកន្លងចិត្តប្តី ស្រីជាមង្គុឡីប្រេត (ពីដើម) ជាស្រីមេមត់ ស្រីជាឱកិលិនីប្រេត (ពីដើម) ធ្វើ (ប្រទូស្ត) នឹងស្រីរួមប្តី សីសច្ឆិន្នប្រេត (ពីដើម) ជាអ្នកសម្លាប់ចោរ ភិក្ខុ ភិក្ខុនី សិក្ខមានា សាមណេរ សាមណេរី (ពីដើម) បួសក្នុងសាសនាព្រះកស្សបសម្មាសម្ពុទ្ធ បានធ្វើនូវកម្មដ៏លាមក ។*

ចប់ លក្ខណសំយុត្ត ទី ៧ ។

---

# ឱបម្មសំយុត្តំ

[៣៣០] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សា-
វត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។
តត្រ ខោ ភគវា... សេយ្យថាបិ ភិក្ខវេ កូដាគារស្ស
យា កាចិ គោបានសិយោ សព្វា តា កូដង្គមា កូ-
ដសមោសរណា កូដសមុគ្ឃាតា សព្វា តា សមុគ្ឃា-
តំ គច្ឆន្តិ ឯវមេវ ខោ ភិក្ខវេ យេ កេចិ អកុ-
សលា ធម្មា សព្វេ តេ អវិជ្ជាមូលកា អវិជ្ជាសមោស-
រណា អវិជ្ជាសមុគ្ឃាតា សព្វេ តេ សមុគ្ឃាតំ គច្ឆន្តិ ។
តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ អប្បមត្តា វិហរិស្សា-
មាតិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។ បឋមំ ។

# ឱបម្មសំយុត្ត

[៣៣០] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក្នុងទីនោះឯង ព្រះមានព្រះភាគ... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បង្កង់ឯណានីមួយនៃផ្ទះមានកំពូល បង្កង់ទាំងអស់នោះ ផាកទៅរកកំពូល ប្រជុំទៅរកកំពូល ប្រឈមទៅរកកំពូល បង្កង់ទាំងអស់នោះ ដល់នូវការប្រឈមទៅ យ៉ាងណា ម្នាលភិក្ខុទាំងឡាយ អកុសលធម៌ទាំងឡាយឯណានីមួយ អកុសលធម៌ទាំងអស់នោះ មានអវិជ្ជាជាមូល មានអវិជ្ជាជាទីប្រជុំ ប្រឈមទៅរកអវិជ្ជា អកុសលធម៌ទាំងអស់នោះ ដល់នូវការប្រឈមទៅ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ហេតុនោះ ក្នុងសាសនានេះ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះថា យើងទាំងឡាយជាអ្នកមិនប្រមាទ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។ ចប់សូត្រទី ១ ។

[៣៣១] សាវត្ថិយំ វិហរតិ... អថខោ ភគវា បរិត្តំ នខសិខាយំ បំសុំ អារោបេត្វា ភិក្ខូ អាមន្តេសិ តំ កឹ មញ្ញថ ភិក្ខវេ កតមំ នុ ខោ ពហុតរំ យោ ចាយំ មយា បរិត្តោ នខសិខាយំ បំសុ អារោបិតោ យា ចាយំ មហាបឋវីតិ ។ ឯតទេវ ភន្តេ ពហុតរំ យទិទំ មហាបឋវី អប្បមត្តកោយំ ភគវតា បរិត្តោ នខសិខាយំ បំសុ អារោបិតោ សង្ខម្បិ ន ឧបេតិ ឧបនិធម្បិ ន ឧបេតិ កលភាគម្បិ ន ឧបេតិ មហាបឋវី ឧបនិធាយ ភគវតា បរិត្តោ នខសិខាយំ បំសុ អារោបិតោតិ ។

[៣៣២] ឯវមេវ ខោ ភិក្ខវេ អប្បកា តេ សត្តា យេ មនុស្សេសុ បច្ចាជាយន្តិ អថខោ ឯតេយេវ ពហុតរា សត្តា យេ អញ្ញត្រ មនុស្សេហិ បច្ចាជាយន្តិ ។ តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ អប្បមត្តា វិហរិស្សាមាតិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។ ទុតិយំ ។

[៣៣១] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ចូកនូវអាចម៍ដីបន្តិចដោយចុងព្រះនខា ហើយត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់ហេតុនោះដូចម្តេច អាចម៍ដីបន្តិចដែលតថាគតចូកឡើងដោយចុងក្រចកឯណាក្តី មហាប្រឹថពីឯណាក្តី បណ្តាវត្ថុទាំងពីរនោះ វត្ថុឯណាច្រើនជាង ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន មហាប្រឹថពីនេះច្រើនក្រៃលែង អាចម៍ដីបន្តិចដែលព្រះអង្គចូកឡើងដោយចុងព្រះនខានេះ មានប្រមាណតិចពេកណាស់ អាចម៍ដីបន្តិចដែលព្រះមានព្រះភាគចូកឡើងដោយចុងព្រះនខា នឹងយកទៅប្រៀបធៀបនឹងមហាប្រឹថពី ក៏មិនដល់នូវកិរិយារាប់ផង មិនដល់នូវការប្រៀបធៀបផង មិនដល់នូវភាគនៃចំណិតផង ។

]៣៣២] ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលត្រឡប់បានមកកើតក្នុងពួកមនុស្ស មានប្រមាណតិចយ៉ាងនេះឯង ដ្បិតថាពួកសត្វដែលក្រៅអំពីត្រឡប់បានមកកើតជាមនុស្សនុ៎ះ មានចំនួនច្រើនណាស់ ។ ម្នាលភិក្ខុទាំងឡាយ ហេតុដូច្នោះ ក្នុងសាសនានេះ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះថា យើងទាំងឡាយជាអ្នកមិនប្រមាទ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។ ចប់សូត្រទី ២ ។

## ២៤៧



[៣៣៣] សាវត្ថិយំ វិហរតិ... តត្រ ខោ ភគវា... សេយ្យថាបិ ភិក្ខវេ យានិ កានិចិ កុលានិ ពហុត្ថិកានិ អប្បបុរិសានិ តានិ សុប្បធំសិយានិ ហោន្តិ ចោរេហិ កុម្ភត្ថេនកេហិ ។ ឯវមេវ ខោ ភិក្ខវេ យស្ស កស្សចិ ភិក្ខុនោ មេត្តា ចេតោវិមុត្តិ អភាវិតា អពហុលីកតា សោ សុប្បធំសិយោ ហោតិ អមនុស្សេហិ ។

[៣៣៤] សេយ្យថាបិ ភិក្ខវេ យានិ កានិចិ កុ-លានិ អប្បត្ថិកានិ ពហុបុរិសានិ តានិ ទុប្បធំសិយា-និ ហោន្តិ ចោរេហិ កុម្ភត្ថេនកេហិ ឯវមេវ ខោ ភិក្ខវេ យស្ស កស្សចិ ភិក្ខុនោ មេត្តា ចេតោវិមុត្តិ ភាវិតា

ឱបម្មសំយុត្ត តតិយសូត្រ ឧបមាដោយចោរលួចទ្រព្យដោយឆ្នាំង

[៣៣៣] ព្រះមានព្រះភាគ ទ្រង់គង់នៅទៀបក្រុងសាវត្ថី... គ្រានោះឯង ព្រះមានព្រះភាគ... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ត្រកូលទាំងឡាយណាមួយ ដែលមានស្រីច្រើន មានប្រុសតិច ត្រកូលទាំងនោះ ពួកចោរអ្នកលួចទ្រព្យដោយឆ្នាំង[១] រមែងបៀតបៀនបានដោយងាយ យ៉ាងណា ។ ម្នាលភិក្ខុទាំងឡាយ មេត្តាចេតោវិមុត្តិ ដែលភិក្ខុណាមួយមិនបានចម្រើនមិនបានធ្វើឲ្យរឿយៗ ហើយពួកអមនុស្ស តែងបៀតបៀនភិក្ខុនោះបានដោយងាយ យ៉ាងនោះឯង ។

[៣៣៤] ម្នាលភិក្ខុទាំងឡាយ ត្រកូលទាំងឡាយណាមួយ ដែលមានស្រីតិច ប្រុសច្រើន ត្រកូលទាំងនោះ ពួកចោរអ្នកលួចទ្រព្យដោយឆ្នាំង រមែងបៀតបៀនបានដោយកម្រ យ៉ាងណា ម្នាលភិក្ខុទាំងឡាយ មេត្តាចេតោវិមុត្តិ ដែលភិក្ខុណាមួយបានចម្រើន

---

១ ពួកចោរដែលអុជប្រទីបក្នុងឆ្នាំង ហើយចូលទៅក្នុងផ្ទះ ប្រាថ្នាដើម្បីនឹងបំភ្លឺមើលទ្រព្យរបស់ (អដ្ឋកថា) ។

ពហុលីកតា សោ ឧប្បជ្ជំសិយោ ហោតិ អមនុស្សេ-
ហិ ។ តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ មេត្តា នោ
ចេតោវិមុត្តិ ភាវិតា ភវិស្សតិ ពហុលីកតា យានី-
កតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធាតិ
ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។ តតិយំ ។

[៣៣៤] សាវត្ថិយំ វិហរតិ... យោ ភិក្ខវេ បុព្វណ្ហ-
សមយំ ឱក្ខាសតំ ទានំ ទទេយ្យ យោ មជ្ឈន្តិកសមយំ
ឱក្ខាសតំ ទានំ ទទេយ្យ យោ សាយណ្ហសមយំ
ឱក្ខាសតំ ទានំ ទទេយ្យ យោ វា បុព្វណ្ហសមយំ
អន្តមសោ គទ្ទូហនមត្តម្បិ មេត្តចិត្តំ ភាវេយ្យ យោ វា

បានធ្វើឲ្យរឿយៗ ហើយពួកអមនុស្សបៀតបៀនភិក្ខុនោះបានដោយកម្រ យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ហេតុដូច្នោះ ក្នុងសាសនានេះ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះថា មេត្តាចេតោវិមុត្តិ យើងទាំងឡាយ នឹងចម្រើនធ្វើឲ្យរឿយៗ ធ្វើឲ្យដូចជាយាន ធ្វើឲ្យជាទីនៅ តម្កល់ទុក រឿយៗ សន្សំទុក ប្រារព្ធដោយប្រពៃ ម្នាលភិក្ខុទាំងឡាយ អ្នក ទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។ ចប់សូត្រទី ៣ ។

[៣៣៥] ព្រះមានព្រះភាគ ទ្រង់គង់នៅទៀបក្រុងសាវត្ថី... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលឯណាឲ្យទានអស់ ១០០ ខ្ទះ ក្នុងបុព្វណ្ហសម័យក្តី បុគ្គលឯណាឲ្យទានអស់ ១០០ ខ្ទះ ក្នុងមជ្ឈន្តិក-សម័យក្តី បុគ្គលឯណាឲ្យទានអស់ ១០០ ខ្ទះ ក្នុងសាយណ្ហសម័យក្តី មួយទៀត បុគ្គលឯណាចម្រើនមេត្តចិត្ត ដោយហោចទៅសូម្បីអស់កាល ត្រឹមតែការរឹតទឹកដោះគោប៉ុណ្ណោះ ក្នុងបុព្វណ្ហសម័យក្តី បុគ្គលឯណា

មជ្ឈន្តិកសមយំ មយំ អន្តមសោ គទ្ទូហនមត្តម្បិ មេត្ត-
ចិត្តំ ភាវេយ្យ យោ វា សាយណ្ហសមយំ អន្តមសោ
គទ្ទូហនមត្តម្បិ មេត្តចិត្តំ ភាវេយ្យ ឥទំ តតោ មហប្ផ-
លតរំ ។ តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ មេត្តា នោ ចេ-
តោវិមុត្តិ ភាវិតា ភវិស្សតិ ពហុលីកតា យានីកតា
វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធាតិ ឯវញ្ហិ វោ
ភិក្ខវេ សិក្ខិតព្វន្តិ ។ ចតុត្ថំ ។

[៣៣៦] សាវត្ថិយំ វិហរតិ... សេយ្យថាបិ ភិក្ខវេ
សត្តិ តិណ្ហផលា អថ បុរិសោ អាគច្ឆេយ្យ អហំ
ឥមំ សត្តឹ តិណ្ហផលំ បាណិនា វា មុដ្ឋិនា វា បិដិលេ-
ណិស្សាមិ បដិកោដ្ដេស្សាមិ បដិវដ្ដេស្សាមីតិ ។ តំ កឹ
មញ្ញថ ភិក្ខវេ ភព្វោ នុ ខោ សោ បុរិសោ អមុំ សត្តឹ
តិណ្ហផលំ បាណិនា វា មុដ្ឋិនា វា បដិលេណេតុំ
បដិកោដ្ដេតុំ បដិវដ្ដេតុន្តិ ។ នោ ហេតំ ភន្តេ ។ តំ
កិស្ស ហេតុ ។ អសុ ហិ ភន្តេ សត្តិ តិណ្ហផលា

ចម្រើនមេត្តចិត្ត ដោយហោចទៅសូម្បីអស់កាលត្រឹមតែការរីតទឹកដោះគោប៉ុណ្ណោះ ក្នុងមជ្ឈន្តិកសម័យក្តី បុគ្គលឯណាចម្រើនមេត្តចិត្ត ដោយហោចទៅសូម្បីអស់កាលត្រឹមតែការរីតទឹកដោះគោប៉ុណ្ណោះ ក្នុងសាយណ្ហសម័យក្តី ការចម្រើនមេត្តចិត្តនេះ ឈ្មោះថាមានផលលើសលុបជាងទាននោះទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ ហេតុដូច្នោះ ក្នុងសាសនានេះ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះថា មេត្តាចេតោវិមុត្តិ យើងទាំងឡាយនឹងចម្រើន ធ្វើឲ្យដូចជាយាន ធ្វើឲ្យជាទីនៅតម្កល់ទុករឿយៗ សន្សំទុក ប្រារព្ធដោយប្រពៃ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះចុះ ។ ចប់សូត្រទី ៤ ។

[៣៣៦] ព្រះមានព្រះភាគ ទ្រង់គង់នៅទៀបក្រុងសាវត្ថី... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ដូចលំពែងមានផ្លែដ៏មុត ស្រាប់តែមានបុរសមកដល់គិតថា អាត្មាអញនឹងយកបាតដៃ ឬក្តាប់ដៃទះតប់ធ្វើលំពែងដែលមានផ្លែដ៏មុតនេះឲ្យខ្ទេរ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សម្គាល់ហេតុដូចម្តេច បុរសនោះគួរដើម្បីយកបាតដៃ ឬក្តាប់ដៃទះតប់លំពែងដែលមានផ្លែដ៏មុតឯណោះ ធ្វើឲ្យខ្ទេរបានដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនបានទេ ។ សេចក្តីនោះ ព្រោះហេតុអ្វី ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថាលំពែងមានផ្លែដ៏មុតឯណោះ

ង សុករា ចាណិជា វា មុដ្ឋិជា វា បដិលេណោតុំ បដិ-កោដ្ដេតុំ បដិវដ្ដេតុំ យាវទេវ ច បន សោ បុរិសោ កិលមថស្ស វិឃាតស្ស ភាគី អស្សាតិ ។

[៣៣៧] ឯវមេវ ខោ ភិក្ខវេ យស្ស កស្សចិ-ភិក្ខុនោ មេត្តា ចេតោវិមុត្តិ ភាវិតា ពហុលីកតា យា-នីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា ។ តស្ស ចេ អមនុស្សោ ចិត្តំ ខិបិតព្វំ មញ្ញេយ្យ ។ អថខោ ស្វេវ អមនុស្សោ កិលមថស្ស វិឃាតស្ស ភាគី ។ តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ មេត្តា នោ ចេតោវិមុត្តិ ភាវិតា ភវិស្សតិ ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធាតិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។ បញ្ចមំ ។

[៣៣៨] សាវត្ថិយំ វិហរតិ... សេយ្យថាបិ ភិក្ខវេ ចត្តារោ ទឡ្ហធម្មា ធនុគ្គហា សុសិក្ខិតា កតហត្ថា កតុបាសនា ចតុទ្ទិសា ឋិតា អស្សុ ។ អថ បុរិសោ

បុគ្គលមិនងាយនឹងយកបាតដៃ ឬក្តាប់ដៃទះតប់ ធ្វើឲ្យខូរបានឡើយ ឯបុរសនោះគប្បីបានតែចំណែកនៃសេចក្តីលំបាក និងសេចក្តីចង្អៀតចង្អល់ប៉ុណ្ណោះឯង ។

[៣៣៧] ម្នាលភិក្ខុទាំងឡាយ មេត្តាចេតោវិមុត្តិដែលភិក្ខុណាមួយ បានចម្រើន បានធ្វើឲ្យរឿយៗ បានធ្វើឲ្យដូចជាយាន បានធ្វើឲ្យជាទីនៅ បានតម្កល់ទុករឿយៗ បានសន្សំទុក បានប្រារព្ធល្អហើយក៏យ៉ាងនោះឯង ។ បើអមនុស្សគប្បីស្មានចិត្តភិក្ខុនោះថា គួរធ្វើឲ្យអណ្តែតអណ្តូង ។ អមនុស្សនោះឯង មុខជាបានតែចំណែកនៃសេចក្តីលំបាក និងសេចក្តីចង្អៀតចង្អល់ពុំខាន ។ ម្នាលភិក្ខុទាំងឡាយ ហេតុដូច្នោះ ក្នុងសាសនានេះ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះថា មេត្តា-ចេតោវិមុត្តិ យើងទាំងឡាយនឹងចម្រើន ធ្វើឲ្យរឿយៗ ធ្វើឲ្យដូចជាយាន ធ្វើឲ្យជាទីនៅ តម្កល់ទុករឿយៗ សន្សំទុក ប្រារព្ធល្អ ម្នាលភិក្ខុទាំង-ឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។ ចប់សូត្រទី ៥ ។

[៣៣៨] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ដូចជាខ្មាន់ធ្នូ ៤ នាក់ មានកម្លាំងដ៏មាំ-មួន ដែលបានសិក្សាដោយប្រពៃ មានសិល្បស្ទាត់ក្នុងដៃ បានសំដែងសិល្បរួចហើយ ឈរនៅក្នុងទិសទាំង ៤ ។ គ្រានោះ មានបុរសម្នាក់

២៦១

ឱបម្មសំយុត្តស្ស ឆដ្ឋសុត្តេ ធនុគ្គហូបមា

អាកង្ខេយ្យ អហំ ឥមេសំ ចតុន្នំ ទឡ្ហធម្មានំ ធនុគ្គហានំ សុសិក្ខិតានំ កតហត្ថានំ កតុបាសនានំ ចតុទ្ទិសា កណ្ឌេ ខិត្តេ អប្បតិដ្ឋិតេ បថវិយំ គហេត្វា អាហរិស្សាមីតិ ។ តំ កឹ មញ្ញថ ភិក្ខវេ ជវនោ បុរិសោ បរមេន ជវេន សមន្នាគតោតិ អលំ វចនាយាតិ ។ ឯកស្ស ចេបិ ភន្តេ ទឡ្ហធម្មស្ស ធនុគ្គហស្ស សុសិក្ខិតស្ស កតហត្ថស្ស កតុបាសនស្ស កណ្ឌំ ខិត្តំ អប្បតិដ្ឋិតំ បថវិយំ គហេត្វា អាហរេយ្យ ជវនោ បុរិសោ បរមេន ជវេន សមន្នាគតោតិ អលំ វចនាយ កោ បន វាទោ ចតុន្នំ ទឡ្ហធម្មានំ ធនុគ្គហានំ សុសិក្ខិតានំ កតហត្ថានំ កតុបាសនានន្តិ ។

ដើរមកដល់គិតថា កាលបើខ្មាន់ធ្នូទាំង ៤ នាក់នេះ ដែលមានកម្លាំងដ៏មាំមួន បានសិក្សាដោយប្រពៃ មានសិល្បស្ទាត់ក្នុងដៃ បានសំដែងសិល្បរួចហើយ បាញ់សរទៅក្នុងទិសទាំង ៤ មិនទាន់ធ្លាក់ដល់ផែនដីនៅឡើយ អាត្មាអញនឹងចាប់នាំយកមកឲ្យបាន ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់ហេតុដូចម្តេច បុរសដែលមានសំទុះ (នោះ) គួរនឹងនិយាយថាជាអ្នកប្រកបដោយសំទុះក្រៃលែងដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន សូម្បីតែខ្មាន់ធ្នូម្នាក់ ដែលមានកម្លាំងដ៏មាំមួន បានសិក្សាដោយប្រពៃ មានសិល្បស្ទាត់ក្នុងដៃ បានសំដែងសិល្បរួចហើយ បាញ់សរទៅមិនទាន់ធ្លាក់ដល់ផែនដីនៅឡើយ បុរសដែលមានសំទុះក៏ចាប់នាំយកមកបាន គួរនឹងនិយាយថាជាអ្នកប្រកបដោយសំទុះដ៏ក្រៃ-លែងបាន នឹងចាំបាច់ពោលទៅថ្វីដល់ខ្មាន់ធ្នូ ៤ នាក់ ដែលមានកម្លាំងមាំមួន បានសិក្សាដោយប្រពៃ មានសិល្បស្ទាត់ក្នុងដៃ បានសំដែងសិល្បរួចហើយ ។

[៣៣៩] យថា ច ភិក្ខវេ តស្ស បុរិសស្ស ជវោ យថា ច ចន្ទិមសុរិយានំ ជវោ តតោ សីឃតរោ ។ យថា ច ភិក្ខវេ តស្ស បុរិសស្ស ជវោ យថា ច ចន្ទិមសុរិយានំ ជវោ យថា ច យា ទេវតា ចន្ទិមសុរិយានំ បុរតោ ធាវន្តិ តាសំ ទេវតានំ ជវោ តតោ សីឃតរោ ។ យថា ច ភិក្ខវេ តស្ស បុរិសស្ស ជវោ យថា ច ចន្ទិមសុរិយានំ ជវោ យថា ច យា ទេវតា ចន្ទិមសុរិយានំ បុរតោ ធាវន្តិ តាសំ ទេវតានំ ជវោ តតោ សីឃតរំ អាយុសង្ខារា ខីយន្តិ[១] ។ តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ អប្បមត្តា វិហរិស្សាមាតិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។ ឆដ្ឋំ ។

១ ម. មិយ្យន្តិ ។

[៣៣៩] ម្នាលភិក្ខុទាំងឡាយ សំទុះនៃបុរសនោះយ៉ាងណាក្តី សំទុះនៃព្រះចន្ទ្រនិងព្រះអាទិត្យ ដែលលឿនជាងសំទុះបុរសនោះយ៉ាងណាក្តី ។ ម្នាលភិក្ខុទាំងឡាយ សំទុះនៃបុរសនោះយ៉ាងណាក្តី សំទុះនៃព្រះចន្ទ្រនិងព្រះអាទិត្យយ៉ាងណាក្តី សំទុះនៃទេវតាទាំងឡាយដែលស្ទុះទៅពីមុខព្រះចន្ទ្រនិងព្រះអាទិត្យនោះ លឿនជាងសំទុះនៃព្រះចន្ទ្រនិងព្រះអាទិត្យនោះទៅទៀតយ៉ាងណាក្តី ។ ម្នាលភិក្ខុទាំងឡាយ សំទុះនៃបុរសនោះយ៉ាងណាក្តី សំទុះនៃព្រះចន្ទ្រនិងព្រះអាទិត្យទាំងឡាយយ៉ាងណាក្តី សំទុះនៃទេវតាទាំងឡាយដែលស្ទុះទៅអំពីខាងមុខព្រះចន្ទ្រនិងព្រះអាទិត្យយ៉ាងណាក្តី អាយុសង្ខារទាំងឡាយ រមែងអស់ទៅឆាប់រហ័សជាងសំទុះទាំងនោះទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ ហេតុដូច្នេះ ក្នុងសាសនានេះ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះថា យើងទាំងឡាយជាអ្នកមិនប្រមាទ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។ ចប់សូត្រទី ៦ ។

ឱបម្មសំយុត្តស្ស សត្តមសុត្តេ មុទិង្គូបមា

[៣៤០] សាវត្ថិយំ វិហរតិ... ភូតបុព្វំ ភិក្ខវេ ទសារហានំ អានកោ នាម មុទិង្គោ អហោសិ ។ តស្ស ទសារហា អានកេ ផលិតេ(១) អញ្ញំ អាណឹ ឱទហឹសុ ។ អហុ ខោ សោ ភិក្ខវេ សមយោ យំ អានកស្ស មុទិង្គស្ស ចោរាណំ ចោក្ខរំ ផលកំ អន្តរធាយិ អាណិសង្ឃាតោ ច អវសិសយិ(២) ។ ឯវមេវ ខោ ភិក្ខវេ ភវិស្សន្តិ ភិក្ខូ អនាគតមទ្ធានំ យេ តេ សុត្តន្តា តថាគតភាសិតា គម្ភីរា គម្ភីរត្ថា លោកុត្តរា សុញ្ញតប្បដិសញ្ញុត្តា តេសុ ភញ្ញមានេសុ ន សុស្សូសិស្សន្តិ ន សោតំ ឱទហិស្សន្តិ ន អញ្ញាចិត្តំ ឧបដ្ឋាបេស្សន្តិ ន ច តេ ធម្មេ ឧគ្គហេតព្វំ បរិយាបុណិតព្វំ មញ្ញិស្សន្តិ ។ យេ បន តេ សុត្តន្តា កាវិកតា កាវេយ្យា ចិត្តក្ខរា ចិត្តព្យញ្ជនា ពាហិរកា សាវកភាសិតា តេសុ ភញ្ញមានេសុ សុស្សូសិស្សន្តិ សោតំ ឱទហិស្សន្តិ អញ្ញាចិត្តំ ឧបដ្ឋាបេស្សន្តិ តេ ច ធម្មេ ឧគ្គហេតព្វំ បរិយាបុណិតព្វំ មញ្ញិស្សន្តិ ។

១ ឃដិតេ ។ ២· អវសិស្សិំ ។

ឱបម្មសំយុត្ត សូត្រទី ៧ ឧបមាដោយសំភោរ

[៣៤០] ព្រះមានព្រះភាគ ទ្រង់គង់នៅ ទៀបក្រុងសាវត្ថី... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពីព្រេងនាយមក មានសំភោរមួយឈ្មោះអានកៈ[១] របស់ពួកក្សត្រនាមទសារហៈ ។ កាលបើរាងសំភោរឈ្មោះអានកៈនោះប្រេះធាហើយ ពួកក្សត្រទសារហៈ ក៏ពាសនូវរាងស្រោមដទៃភ្ជាប់អបទុក ។ ម្នាលភិក្ខុទាំងឡាយ មានសម័យដែលត្រូវតួរាងចាស់របស់សំភោរឈ្មោះអានកៈក៏ខូចបាត់ទៅ សល់នៅតែរាងស្រោម ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងដូចក្នុងកាលជាអនាគតទៅ ព្រះសូត្រទាំងឡាយឯណា ដែលតថាគតសំដែងហើយ ជាព្រះសូត្រដ៏ជ្រៅ មានអត្ថដ៏ជ្រៅ ជាលោកុត្តរៈ ប្រកបដោយសភាពដ៏សូន្យ ព្រះសូត្រទាំងនោះ កាលបើបុគ្គលពោល ពួកមហាជននឹងមិនស្តាប់ មិនដាក់ចុះនូវសោត មិនយកចិត្តទុកដាក់ដើម្បីដឹង ទាំងមិនសម្គាល់ធម៌ទាំងនោះថា គួររៀនឬគួរទន្ទេញឡើយ ។ បើព្រះសូត្រទាំងឡាយឯណា ដែលអ្នកប្រាជ្ញជាកវីបានធ្វើជាពាក្យកាព្យឃ្លោង មានអក្សរដ៏វិចិត្រ មានព្យញ្ជនៈដ៏វិចិត្រជាខាងក្រៅ ជាសាវកភាសិត ព្រះសូត្រទាំងនោះ កាលបុគ្គលពោល ទើបមហាជននឹងស្តាប់ នឹងដាក់ចុះនូវសោត នឹងយកចិត្តទុកដាក់ដើម្បីដឹង នឹងសម្គាល់នូវធម៌ទាំងនោះថា គួររៀន គួរទន្ទេញ ។

---

១ សំភោរមង្គល សម្រាប់វាយហៅមហាជនមកប្រជុំក្នុងថ្ងៃមានមហោស្រព (អដ្ឋកថា) ។

[៣៤១] ឯវមេវ តេសំ ភិក្ខវេ សុត្តន្តានំ តថាគតភាសិតានំ គម្ភីរានំ គម្ភីរត្ថានំ លោកុត្តរានំ សុញ្ញតប្បដិសញ្ញុត្តានំ អន្តរធានំ ភវិស្សតិ ។ តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ យេ តេ សុត្តន្តា តថាគតភាសិតា គម្ភីរា គម្ភីរត្ថា លោកុត្តរា សុញ្ញតប្បដិសញ្ញុត្តា តេសុ ភញ្ញមានេសុ សុស្សូសិស្សាម សោតំ ឱទហិស្សាម អញ្ញាចិត្តំ ឧបដ្ឋាបេស្សាម តេ ច ធម្មេ ឧគ្គហេតព្វំ បរិយាបុណិតព្វំ មញ្ញិស្សាមាតិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។ សត្តមំ ។

[៣៤២] ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

[៣៤១] ម្នាលភិក្ខុទាំងឡាយ ការវិនាសទៅនៃព្រះសូត្រ ដែលតថាគតសំដែងហើយទាំងនោះ ជាព្រះសូត្រដ៏ជ្រៅ មានអត្ថដ៏ជ្រៅ ជាលោកុត្តរៈ ប្រកបដោយសភាពដ៏សូន្យយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ហេតុដូច្នោះ ក្នុងសាសនានេះ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះថា ព្រះសូត្រទាំងឡាយឯណា ដែលព្រះតថាគតសំដែងហើយ ជាព្រះសូត្រដ៏ជ្រៅ មានអត្ថដ៏ជ្រៅ ជាលោកុត្តរៈ ប្រកបដោយសភាពដ៏សូន្យ ព្រះសូត្រទាំងនេះ កាលបុគ្គលពោល យើងនឹងប្រុងស្តាប់ ដាក់ចុះនូវសោត យកចិត្តទុកដាក់ដើម្បីដឹង នឹងសម្គាល់នូវធម៌ទាំងនោះថា គួររៀន គួរទន្ទេញ ដូច្នេះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។ ចប់សូត្រទី ៧ ។

[៣៤២] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងកូដាគារសាលា នាព្រៃមហាវន ទៀបក្រុងវេសាលី ។ ក្នុងទីនោះ ព្រះមានព្រះភាគ ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

ឱបម្មសំយុត្តស្ស អដ្ឋមសុត្តេ លិច្ឆវូបមា

[៣៤៣] ភគវា ឯតទវោច កលិង្គរូបធានា ភិក្ខវេ ឯតរហិ លិច្ឆវី វិហរន្តិ អប្បមត្តា អាតាបិនោ ឧបាសនស្មឹ តេសំ រាជា មាគធោ អជាតសត្តុ វេទេហិបុត្តោ ន លភតិ ឱតារំ ន លភតិ អារម្មណំ ។ ភវិស្សន្តិ ភិក្ខវេ អនាគតមទ្ធានំ លិច្ឆវី សុខុមាលា មុទុតលា ហត្ថបាទា[១] តេ មុទុកាសុ សេយ្យាសុ តូលពិម្ពោហនាសុ យាវ សុរិយុគ្គមនា សេយ្យំ កប្បិស្សន្តិ តេសំ រាជា មាគធោ អជាតសត្តុ វេទេហិបុត្តោ លច្ឆតិ ឱតារំ លច្ឆតិ អារម្មណំ ។

[៣៤៤] កលិង្គរូបធានា ភិក្ខវេ ឯតរហិ ភិក្ខូ វិហរន្តិ អប្បមត្តា អាតាបិនោ បធានស្មឹ តេសំ មារោ បាបិមា ន លភតិ ឱតារំ ន លភតិ អារម្មណំ ។ ភវិស្សន្តិ ភិក្ខវេ អនាគតមទ្ធានំ ភិក្ខូ សុខុមាលា មុទុតលា ហត្ថបាទា តេ មុទុកាសុ សេយ្យាសុ តូលពិម្ពោហ-

១ ឱ. មុទុតលុណហត្ថបាទា ។ ម. មទុតលុនហត្ថបាទា ។

ឱបម្មសំយុត្ត សូត្រទី ៨ ឧបមាដោយពួកស្តេចលិច្ឆវី

[៣៤៣] ព្រះមានព្រះភាគបានត្រាស់ពាក្យនេះថា ម្នាលភិក្ខុទាំងឡាយ ឥឡូវ ពួកស្តេចលិច្ឆវីមានអង្កត់ឧសជាខ្នើយ គឺថាយកអង្កត់ឧស ពកឈើគគីរ ធ្វើជាខ្នើយរងព្រះសិរនិងព្រះបាទ ជាអ្នកមិនប្រមាទ មានសេចក្តីព្យាយាមក្នុងការចូលទៅជិត (អាចារ្យ) ព្រះបាទអជាតសត្តុវេទេហិបុត្តជាឥស្សរៈក្នុងដែនមគធៈ ក៏មិនបាននូវចន្លោះ មិនបាននូវអារម្មណ៍ នៃស្តេចលិច្ឆវីទាំងនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលជាអនាគតទៅ ពួកស្តេចលិច្ឆវីជាសុខុមាលជាតិ មានផ្ទៃព្រះហស្តនិងព្រះបាទដ៏ទន់ ក្សត្រទាំងនោះនឹងសម្រេចសេយ្យាសលើក្រឡាបន្ទំដ៏ទន់ មានខ្នើយដ៏ក្រាស់ ដរាបដល់ថ្ងៃរះ ព្រះបាទអជាតសត្តុវេ-ទេហិបុត្តជាឥស្សរៈក្នុងដែនមគធៈ ក៏បាននូវចន្លោះ បាននូវអារម្មណ៍ នៃស្តេចលិច្ឆវីទាំងនោះ ។

[៣៤៤] ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ភិក្ខុទាំងឡាយមានអង្កត់ឧសជាខ្នើយ ជាអ្នកមិនប្រមាទ មានកិរិយាញ៉ាំងកិលេសឲ្យក្តៅក្នុងការធ្វើសេចក្តីព្យាយាម មារចិត្តបាប ក៏មិនបាននូវចន្លោះ មិនបាននូវអារម្មណ៍ នៃភិក្ខុទាំងនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលជាអនាគតទៅ ភិក្ខុទាំងឡាយជាសុខុមាលជាតិ មានផ្ទៃដៃនិងជើងដ៏ទន់ ភិក្ខុទាំងនោះ សម្រេចនូវការដេកលើដំណេកដ៏ទន់ មានខ្នើយដ៏ក្រាស់

ជាសុ យាវ សុរិយុគ្គមនា សេយ្យំ កប្បិស្សន្តិ តេសំ មាហេ ចាបិមា លច្ឆតិ ឱតារំ លច្ឆតិ អារម្មណំ ។ តស្មា-តិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ កលិង្គូបធានា វិហរិស្សាម អប្បមត្តា អាតាបិនោ បធានស្មិន្តិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។ អដ្ឋមំ ។

[៣៤៨] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សា-វត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេនាញ្ញតរោ នវោ ភិក្ខុ អតិវេលំ កុលានិ ឧបសង្កមតិ ។ តមេនំ ភិក្ខូ ឯវមាហំសុ មា អាយស្មា អតិវេលំ កុលានិ ឧបសង្កមីតិ ។ សោ ភិក្ខូហិ វុច្ចមានោ ឯវមាហ ឥមេ ហិ នាម ថេរា ភិក្ខូ កុលានិ ឧបសង្កមិតព្វំ[១] មញ្ញិស្សន្តិ

១ ឧបសង្កមិតព្វានីតិ បាឋោ យុត្តតរោ ។

ដរាបដល់ថ្ងៃរះ ឯមារចិត្តបាប ក៏បាននូវចន្លោះ បាននូវអារម្មណ៍ នៃភិក្ខុទាំងនោះ ។ ម្នាលភិក្ខុទាំងឡាយ ហេតុដូច្នោះ ក្នុងសាសនានេះ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះថា យើងទាំងឡាយមានអង្គត់ឧសជាខ្នើយ ជាអ្នកមិនប្រមាទ មានកិរិយាញ៉ាំងកិលេសឲ្យក្តៅ ក្នុងការធ្វើសេចក្តីព្យាយាម ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។ ចប់សូត្រទី ៨ ។

[៣៤៥] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក៏ក្នុងសម័យនោះឯង មានភិក្ខុបួសថ្មីមួយរូប ចូលទៅរកត្រកូលហួសវេលា ។ ភិក្ខុទាំងឡាយ និយាយនឹងភិក្ខុនោះយ៉ាងនេះថា លោកមានអាយុ កុំចូលទៅរកត្រកូលហួសវេលាឡើយ ។ ភិក្ខុនោះកាលបើពួកភិក្ខុនិយាយប្រាប់ ក៏បែរជាពោលយ៉ាងនេះថា អម្បាលយ៉ាងពួកភិក្ខុជាថេរៈទាំងនេះម្តេច ក៏គង់សម្គាល់នូវត្រកូលថាគួរគប្បីចូល

២៦៧

ឱបម្មសំយុត្តស្ស នវមសុត្តេ នាគោបមា

គិមង្គំ បជហន្តិ ។ អថខោ សម្ពហុលា ភិក្ខូ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ ឥធ ភន្តេ អញ្ញតរោ នវោ ភិក្ខុ អតិវេលំ កុលានិ ឧបសង្កមតិ តមេនំ ភិក្ខូ ឯវមាហំសុ មា អាយស្មា អតិវេលំ កុលានិ ឧបសង្កមីតិ សោ ភិក្ខូហិ វុច្ចមានោ ឯវមាហ ឥមេ ហិ នាម ថេរា ភិក្ខូ កុលានិ ឧបសង្កមិតព្វំ មញ្ញិស្សន្តិ គិមង្គំ បជហន្តិ ។

[៣៤៦] ភូតបុព្វំ ភិក្ខវេ អរញ្ញាយតនេ មហា សរសិ តំ នាគា ឧបនិស្សាយ វិហរន្តិ ។ តេ តំ សរសឹ ឱគហេត្វា សោណ្ឌាយ ភិសមុឡាលំ អព្ពុគ្គហេត្វា សុវិក្ខាលិតំ វិក្ខាលេត្វា អកទ្ទមំ សង្ខាទិត្វា[១] អជ្ឈោហរន្តិ តេសន្តំ វណ្ណាយ ចេវ ហោតិ ពលាយ ច ន ច តតោនិទានំ មរណំ វា និគច្ឆន្តិ

១ ឱ. ម. សង្ខាទិត្វា ។

ទៅរកបាន នឹងបាច់និយាយថ្វីត្រឹមខ្ញុំករុណា ។ គ្រានោះឯង ភិក្ខុច្រើនរូបចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុទាំងនោះអង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះ មានភិក្ខុបួសថ្មីមួយរូប ចូលទៅរកត្រកូលហួសវេលា ពួកភិក្ខុបាននិយាយនឹងភិក្ខុនោះយ៉ាងនេះថា លោកមានអាយុ កុំចូលទៅរកត្រកូលហួសវេលាឡើយ ភិក្ខុនោះ កាលបើពួកភិក្ខុនិយាយប្រាប់ ក៏បែរជានិយាយយ៉ាងនេះថា អម្បាលយ៉ាងពួកភិក្ខុជាថេរៈទាំងនេះម្តេច គង់សម្គាល់នូវត្រកូលថាគួរចូលទៅរកបាន នឹងបាច់ពោលទៅថ្វីត្រឹមខ្ញុំករុណា ។

[៣៤៦] ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលពីព្រេងនាយមក មានស្រះមួយធំ ក្នុងព្រៃរំលោង ដំរីទាំងឡាយតែងអាស្រ័យនៅនឹងស្រះធំនោះ ។ ដំរីទាំងនោះ ចុះទៅកាន់ស្រះនោះ ដកយកក្រអៅឈូកនិងមើមឈូកដោយប្រមោយ ហើយលាស់ឲ្យស្អាតល្អលាងឲ្យជ្រះភក់ហើយទើបបរិភោគ ឯសរីរៈនោះ របស់ដំរីទាំងនោះ ក៏មានសម្បុរល្អផង មានកម្លាំងផង ដំរីទាំងនោះក៏មិនដល់នូវមរណៈ

មរណមត្តំ វា ទុក្ខំ ។ តេសញ្ហិ ខោ បន ភិក្ខវេ មហាជាតានំ អនុសិក្ខមានា តរុណា ភិកច្ឆាថា តេ តំ សរសឹ ឱតរិត្វា សោណ្ឌាយ ភិសមុឡាលំ អព្ពុត្ត-ហេត្វា ន សុធោវិតំ វិក្ខាលេត្វា សកទ្ទមំ អសង្ខា-ទិត្វា អជ្ឈោហរន្តិ តេសន្តំ នេវ វណ្ណាយ ហោតិ ន ពលាយ តតោនិទានំ មរណំ វា និគច្ឆន្តិ មរណមត្តំ វា ទុក្ខំ ។

[៣៤៧] ឯវមេវ ខោ ភិក្ខវេ ឥធ ថេរា ភិក្ខូ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ គាមំ វា និគមំ វា បិណ្ឌាយ បវិសន្តិ តេ តត្ថ ធម្មំ ភា-សន្តិ តេសំ គិហី បសន្នា បសន្នាការំ ករោន្តិ តេ តំ លាភំ អគធិតា អមុច្ឆិតា អនជ្ឈាបន្នា អា-ទីនវទស្សាវិនោ និស្សរណបញ្ញា បរិភុញ្ជន្តិ តេសន្តំ វណ្ណាយ ចេវ ហោតិ ពលាយ ច ន ច តតោនិ-ទានំ មរណំ វា និគច្ឆន្តិ មរណមត្តំ វា ទុក្ខំ ។

ឬទុក្ខស្មើនឹងមរណៈ ព្រោះអាហារនោះជាហេតុឡើយ ។ ម្នាលភិក្ខុទាំងឡាយ មានពួកកូនដំរីក្មេង សិក្សាតាមដំរីធំៗទាំងនោះឯង ក៏នាំគ្នាចុះទៅកាន់ស្រះនោះ ដកយកក្រអៅឈូកនិងមើមឈូក ដោយប្រមោយមិនបានលាស់ឲ្យស្អាតល្អ មិនបានលាងនូវក្រអៅ និងមើមដែលមានភក់ចេញ ក៏បរិភោគទៅ សរីរៈនោះ របស់កូនដំរីក្មេងទាំងនោះក៏មិនមានសម្បុរល្អ មិនមានកម្លាំង កូនដំរីក្មេងទាំងនោះក៏ដល់នូវមរណៈ ឬទុក្ខស្មើនឹងមរណៈ ព្រោះអាហារនោះជាហេតុ ។

[៣៤៧] ម្នាលភិក្ខុទាំងឡាយ សេចក្តីនេះ មានឧបមេយ្យដូចជាពួកភិក្ខុជាថេរៈ ក្នុងសាសនានេះ ស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅកាន់ស្រុកឬនិគម ដើម្បីបិណ្ឌបាត ថេរៈទាំងនោះសំដែងធម៌ ក្នុងស្រុកនិគមនោះៗ មានពួកគ្រហស្ថគេជ្រះថ្លា ធ្វើនូវអាការជ្រះថ្លាចំពោះថេរៈទាំងនោះ ថេរៈទាំងនោះ ក៏មិនបានជាប់ចំពាក់ មិនបានវង្វេងមិនបានជ្រុលជ្រប់ នឹងលាភនោះឡើយ ជាអ្នកឃើញទោស មានបញ្ញា សម្រាប់រើខ្លួន ទើបបរិភោគ សរីរៈនោះ របស់ថេរៈទាំងនោះ ក៏មានសម្បុរល្អផង មានកម្លាំងផង ថេរៈទាំងនោះក៏មិនដល់នូវមរណៈ ឬទុក្ខស្មើនឹងមរណៈ ព្រោះលាភនោះជាហេតុឡើយ ។

២៦៩

ឱបម្មសំយុត្តស្ស នវមសុត្តេ នាគោបមា

តេសញ្ញេវ ខោ បន ភិក្ខវេ ថេរានំ ភិក្ខូនំ អនុសិក្ខមា-នានំ វា ភិក្ខូ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ គាមំ វា និគមំ វា បិណ្ឌាយ បវិសន្តិ តេ តត្ថ ធម្មំ ភាសន្តិ តេសំ គិហី បសន្នា បសន្នាការំ ករោន្តិ តេ តំ លាភំ គធិតា មុច្ឆិតា អជ្ឈោបន្នា អនាទីនវទស្សាវិនោ អនិស្សរណបញ្ញា បរិភុញ្ជន្តិ តេសន្តំ នេវ វណ្ណាយ ហោតិ ន ពលាយ តតោនិទានំ មរណំ វា និគច្ឆន្តិ មរណមត្តំ វា ទុក្ខំ ។ តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ អគធិតា អមុច្ឆិត្វា អនជ្ឈោបន្នា អាទីនវទស្សាវិនោ និស្សរណបញ្ញា បរិភុញ្ជិស្សាមាតិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។ នវមំ ។

ឱបម្មសំយុត្ត សូត្រទី ៩ ឧបមាដោយដំរី

ម្នាលភិក្ខុទាំងឡាយ ចំណែកពួកភិក្ខុដែលសិក្សាតាមពួកភិក្ខុជាថេរៈនោះឯង ក៏ស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅកាន់ស្រុកឬនិគម ដើម្បីបិណ្ឌបាត ភិក្ខុទាំងនោះក៏សំដែងធម៌ក្នុងស្រុកឬនិគមនោះៗ ពួកគ្រហស្ថក៏មានសេចក្តីជ្រះថ្លា ធ្វើអាការជ្រះថ្លាចំពោះភិក្ខុទាំងនោះ ភិក្ខុទាំងនោះ ក៏ជាប់ចំពាក់ វង្វេង ជ្រុលជ្រប់នឹងលាភនោះ ជាអ្នកមិនឃើញទោស មិនមានបញ្ញាសម្រាប់រើខ្លួនហើយបរិភោគឡើយ សរីរៈនោះ របស់ភិក្ខុទាំងនោះ ក៏មិនមានសម្បុរល្អផង មិនមានកម្លាំងផង ភិក្ខុទាំងនោះតែងដល់នូវមរណៈ ឬទុក្ខស្មើរនឹងមរណៈ ព្រោះលាភនោះជាហេតុ ។ ម្នាលភិក្ខុទាំងឡាយ ហេតុដូច្នោះ ក្នុងសាសនានេះ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះថា យើងទាំងឡាយ ជាអ្នកមិនជាប់ចំពាក់ មិនវង្វេង មិនជ្រុលជ្រប់ (នឹងលាភ) ឡើយ ត្រូវជាអ្នកឃើញទោស និងមានសញ្ញាសម្រាប់រើខ្លួនហើយទើបបរិភោគ ម្នាលភិក្ខុទាំង-ឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។ ចប់សូត្រទី ៩ ។

[៣៤៨] សាវត្ថិយំ វិហរតិ... តេន ខោ បន សម-យេន អញ្ញតរោ ភិក្ខុ អតិវេលំ កុលេសុ ចារិត្តំ អាបជ្ជ-តិ ។ តមេនំ ភិក្ខូ ឯវមាហំសុ មា អាយស្មា អតិវេលំ កុលេសុ ចារិត្តំ អាបជ្ជីតិ ។ សោ ភិក្ខូហិ វុច្ចមានោ ន រមតិ[១] ។ អថខោ សម្ពហុលា ភិក្ខូ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯ-កមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ ឥធ ភន្តេ អញ្ញតរោ ភិក្ខុ អតិវេលំ កុលេសុ ចារិត្តំ អាបជ្ជតិ តមេនំ ភិក្ខូ ឯវមាហំសុ មា អាយស្មា អតិវេលំ កុលេសុ ចារិត្តំ អាបជ្ជីតិ សោ ភិក្ខូហិ វុច្ចមានោ ន រមតីតិ ។

[៣៤៩] ភូតបុព្វំ ភិក្ខវេ វិឡារោ សន្ធិសមល-សង្កដិរេ ឋិតោ អហោសិ មុទុមូសឹ អាគមយមា-នោ យត្វាយំ មុទុមូសិ គោចរាយ បក្កមិស្សតិ

១ ឱ. ន. វិរមតិ ។

[៣៤៨] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ក៏ក្នុងសម័យនោះឯង មានភិក្ខុមួយរូប ត្រាច់ទៅក្នុងត្រកូលហួសវេលា ។ ពួកភិក្ខុបាននិយាយនឹងភិក្ខុនោះយ៉ាងនេះថា លោកមានអាយុ កុំត្រាច់ទៅក្នុងត្រកូលហួសវេលាឡើយ ។ ភិក្ខុនោះ កាលបើពួកភិក្ខុនិយាយប្រាប់ក៏មិនត្រេកអរ ។ គ្រានោះឯង ពួកភិក្ខុច្រើនរូបចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុទាំងនោះអង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះ ភិក្ខុមួយរូបត្រាច់ទៅក្នុងត្រកូលហួសវេលា ពួកភិក្ខុបាននិយាយនឹងភិក្ខុយ៉ាងនេះថា លោកមានអាយុ កុំត្រាច់ទៅក្នុងត្រកូលហួសវេលាឡើយដូច្នេះ ភិក្ខុនោះ កាលបើពួកភិក្ខុនិយាយប្រាប់ក៏មិនត្រេកអរ ។

[៣៤៩] ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលពីព្រេងនាយមក មានឆ្មាមួយឈរនៅក្បែរគំនរសម្រាមមានអាចម៍គោ ត្រង់ទីតនៃផ្ទះ ឃ្លាំចាំមើលកូនកណ្តុរហើយគិតថា កូនកណ្តុរនេះនឹងចេញទៅរក

តត្ថេវ នំ គហេត្វា ខាទិស្សាមីតិ ។ អថខោ ភិក្ខវេ មុទុមុសិ គោចរាយ បក្កាមិ ។ តមេនំ វិឡារោ គហេត្វា សហសា មំសំ ខាទិត្វា អជ្ឈោហរិ ។ តស្ស សោ មុទុមុសិ អន្តម្បិ ខាទិ អន្តគុណម្បិ ខាទិ ។ សោ តតោនិទានំ មរណម្បិ និគច្ឆតិ មរណមត្តម្បិ ទុក្ខំ ។

[៣៨០] ឯវមេវ ខោ ភិក្ខវេ ឥធេកច្ចោ ភិក្ខុ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ គាមំ វា និគមំ វា បិណ្ឌាយ បវិសតិ អរក្ខិតេនេវ កាយេន អរក្ខិតាយ វាចាយ អរក្ខិតេន ចិត្តេន អនុបដ្ឋិតាយ សតិយា អសំវុតេហិ ឥន្ទ្រិយេហិ តត្ថ បស្សតិ មាតុគ្គាមំ ទុន្និវត្ថំ វា ទុប្បារុតំ វា តស្ស មាតុគ្គាមំ ទិស្វាន ទុន្និវត្ថំ វា ទុប្បារុតំ វា រាគោ ចិត្តំ អនុទ្ធំសេតិ សោ រាគានុទ្ធំសេន ចិត្តេន មរណំ វា និគច្ឆតិ មរណមត្តំ វា ទុក្ខំ ។ មរណំ ហេតំ ភិក្ខវេ អរិយស្ស វិនយេ យោ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តតិ ។ មរណមត្តញ្ចេតំ[១] ភិក្ខវេ

---

១ ឱ. ម. មរណមត្តញ្ហេតំ ភិក្ខវេ ។

ចំណីក្នុងទីឯណា អាត្មាអញនឹងចាប់វាទំពាស៊ី ក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង កូនកណ្ដុរក៏ចេញទៅរកចំណី ។ ឆ្មាក៏ចាប់កណ្ដុរនោះខាំសាច់លេប (ទាំងរស់) យ៉ាងរហ័ស ។ កូនកណ្ដុរនោះ ក៏ខាំស៊ីនូវពោះវៀនធំផង ខាំស៊ីនូវពោះវៀនតូចផង របស់ឆ្មានោះ ។ ឆ្មានោះក៏ដល់នូវមរណៈ ឬទុក្ខស្មើរនឹងមរណៈ ព្រោះអាហារនោះជាហេតុ ។

[៣៥០] ម្នាលភិក្ខុទាំងឡាយ សេចក្ដីនេះ មានឧបមេយ្យដូចជាភិក្ខុពួកខ្លះក្នុងសាសនានេះ ស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅកាន់ស្រុកឬនិគម ដើម្បីបិណ្ឌបាត មានកាយមិនបានរក្សា មានវាចាមិនបានរក្សា មានចិត្តមិនបានរក្សា មានសតិមិនបានតម្កល់មាំ មានឥន្ទ្រិយមិនបានសង្រួម ដណ្ដប់សំពត់មិនស្រួល លុះឃើញមាតុគ្រាមស្លៀកសំពត់មិនស្រួល ដណ្ដប់សំពត់មិនស្រួលហើយ រាគៈក៏កម្ចាត់ចិត្តរបស់ភិក្ខុនោះ លុះភិក្ខុនោះមានចិត្តដែលរាគៈកម្ចាត់ហើយ ក៏ដល់នូវមរណៈ ឬទុក្ខស្មើរនឹងមរណៈ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុឯណាពោលលាសិក្ខា ត្រឡប់ទៅកាន់ភេទថោកទាប ភិក្ខុនោះឈ្មោះថាដល់នូវមរណៈនោះ ក្នុងវិន័យរបស់ព្រះអរិយៈ ។ ម្នាលភិក្ខុទាំងឡាយ

ទុក្ខំ យមិទំ អញ្ញតរំ សង្កិលិដ្ឋំ អាបត្តឹ អាបជ្ជតិ យថារូបាយ អាបត្តិយា វុដ្ឋានំ បញ្ញាយតិ ។ តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ រក្ខិតេន កាយេន រក្ខិតាយ វាចាយ រក្ខិតេន ចិត្តេន ឧបដ្ឋិតាយ សតិយា សំវុតេហិ ឥន្ទ្រិយេហិ គាមំ វា និគមំ វា បិណ្ឌាយ បវិសិស្សាមាតិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។ ទសមំ ។

[៣៨១] សាវត្ថិយំ វិហរតិ... អស្សុត្ថ នោ តុម្ហេ ភិក្ខវេ រត្តិយា បច្ចូសសមយំ សិគាលស្ស វស្សមានស្សាតិ ។ ឯវំ ភន្តេ ។ ឯសោ ខោ ភិក្ខវេ ជរសិគាលោ ឧក្កណ្ណកេន នាម រោគជាតេន ផុដ្ឋោ ។ សោ យេន យេន ឥច្ឆតិ តេន តេន គច្ឆតិ យត្ថ យត្ថ ឥច្ឆតិ តត្ថ តត្ថ តិដ្ឋតិ យត្ថ យត្ថ ឥច្ឆតិ តត្ថ តត្ថ និសីទតិ យត្ថ យត្ថ ឥច្ឆតិ តត្ថ តត្ថ និបជ្ជតិ ។ សីតកោបិ នំ វាតោ ឧបវាយតិ ។

ភិក្ខុត្រូវអាបត្តិ ជាគ្រឿងសៅហ្មងឯណានីមួយ បានចេញចាកអាបត្តិ តាមសភាពដ៏សមគួរ នេះឈ្មោះថាដល់នូវទុក្ខស្មើរនឹងមរណៈ ។ ម្នាលភិក្ខុទាំងឡាយ ហេតុដូច្នោះ ក្នុងសាសនានេះ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះថា យើងទាំងឡាយ ត្រូវជាអ្នករក្សាកាយ រក្សាវាចា រក្សាចិត្ត តម្កល់សតិឲ្យមាំ សង្រួមឥន្ទ្រិយ សិមចូលទៅកាន់ស្រុកឬនិគម ដើម្បីបិណ្ឌបាត ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។ ចប់សូត្រទី ១០ ។

[៣៩១] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយបានឮរឿងនៃសត្វចចក កាលដែលនៅក្នុងបច្ចូសសម័យនៃរាត្រីដែរឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ ចចកចាស់នោះឯងកើតរោគអង្គែ ។ ចចកចាស់នោះ ប្រាថ្នានឹងដើរទៅក្នុងទីណាៗ ក៏ដើរទៅក្នុងទីនោះៗបាន ប្រាថ្នានឹងឈរក្នុងទីណាៗ ក៏ឈរក្នុងទីនោះៗបាន ប្រាថ្នានឹងអង្គុយក្នុងទីណាៗ ក៏អង្គុយក្នុងទីនោះៗបាន ប្រាថ្នានឹងដេកក្នុងទីណាៗ ក៏ដេកក្នុងទីនោះៗបាន ។ ខ្យល់ដ៏ត្រជាក់ក៏ចេះតែបក់មកត្រូវចចកចាស់នោះ ។

២៧៣

ឱបម្មសំយុត្តស្ស ទសមសុត្តេ កតញ្ញូកតវេទិតា

[៣៨២] សាធុ ខ្វាស្ស ភិក្ខវេ យំ ឥធេកច្ចោ សក្យបុត្តិយប្បដិញ្ញោ ឯវរូបម្បិ អត្តភាវប្បដិលាភំ បដិ-សំវេទិយេថ ។ តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ អប្បមត្តា វិហរិស្សាមាតិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។ ឯកា-ទសមំ ។

[៣៨៣] សាវត្ថិយំ វិហរតិ... អស្សុត្ថ នោ តុម្ហេ ភិក្ខវេ រត្តិយា បច្ចូសសមយំ សិគាលស្ស វស្សមា-នស្សាតិ ។ ឯវំ ភន្តេ ។ សិយា ខោ ភិក្ខវេ តស្មិំ ជ-រសិគាលេ កាចិ កតញ្ញុតា កតវេទិតា ន ត្វេវ ឥ-ធេកច្ចេ សក្យបុត្តិយប្បដិញ្ញេ សិយា កាចិ កតញ្ញុ-តា កតវេទិតា ។ តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ

ឱបម្មសំយុត្ត ទ្វាទសមសូត្រ អំពីកតញ្ញូនិងកតវេទិតា

[៣៩២] ម្នាលភិក្ខុទាំងឡាយ ប្រពៃណាស់ ភិក្ខុពួកខ្លះ ក្នុងសាសនានេះ បានបេ្តជ្ញាខ្លួនជាសក្យបុត្រ ហើយក៏ត្រឡប់មកទទួល គឺត្រឡប់បានអត្តភាពបែបនេះក៏មានដែរ ម្នាលភិក្ខុទាំងឡាយ ហេតុដូច្នោះ ក្នុងសាសនានេះ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះថា យើងទាំងឡាយជាអ្នកមិនប្រមាទ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។ ចប់សូត្រទី ១១ ។

[៣៩៣] ព្រះមានព្រះភាគ ទ្រង់គង់នៅ ជិតក្រុងសាវត្ថី... ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយបានឮរឿងនៃសត្វចចក កាលដែលនៅក្នុងបច្ចូសម័យនៃរាត្រីដែរឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ ចចកចាស់ ចួនកាលក៏មានសេចក្តីកតញ្ញូកតវេទិតាធម៌ខ្លះដែរ ឯបុគ្គលពួកខ្លះ ក្នុងសាសនានេះ ដែលបេ្តជ្ញាខ្លួនជាសក្យបុត្រ បែរជាមិនមានសេចក្តីកតញ្ញូកតវេទិតាធម៌ខ្លះ ទៅវិញក៏មាន ។ ម្នាលភិក្ខុទាំង-ឡាយ ហេតុដូច្នោះ ក្នុងសាសនានេះ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះថា

២៧៤



កតញ្ញុនោ ភវិស្សាម កតវេទិនោ ន ច នោ អម្ហេសុ អប្បកម្បិ កតំ វិនសិស្សតីតិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។ ទ្វាទសមំ ។

ឱបម្មសំយុត្តំ អដ្ឋមំ សមត្តំ ។

## តស្ស ឧទ្ទានំ

កូដំ នខសិខ កុលំ
ឱក្ខា សត្តិ ធនុគ្គហោ
អាណិ កលិង្គរោ នាគោ
វិឡារោ ទ្វេ សិគាលកាតិ ។

យើងទាំងឡាយជាអ្នកមានសេចក្តីកតញ្ញូកតវេទី ឧបការៈសូម្បីមានប្រមាណតិច ដែលគេធ្វើចំពោះយើងទាំងឡាយ នឹងមិនវិនាសបាត់បង់ឡើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។

ចប់សូត្រទី ១២ ។

ចប់ ឱបម្មសំយុត្ត ទី ៨ ។

# ឧទ្ទាននៃឱបម្មសំយុត្តនោះគឺ

និយាយអំពីកំពូលផ្ទះ ១ ចុងនៃក្រចក ១ ត្រកូល ១ ខ្ទះ ១
លំពែង ១ ខ្មាន់ធ្នូ ១ រាងសំភោរ ១ អង្កត់ឧស ១ ដំរី ១
ឆ្មា ១ សត្វចចកពីរលើក ។

# ភិក្ខុសំយុត្តំ

[៣៨៧] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ អាយស្មា មហាមោគ្គល្លានោ ភិក្ខូ អាមន្តេសិ អាវុសោ ភិក្ខវេតិ ។ អាវុសោតិ ខោ ភិក្ខូ អាយស្មតោ មហាមោគ្គល្លានស្ស បច្ចស្សោសុំ ។

[៣៨៨] អាយស្មា មហាមោគ្គល្លានោ ឯតទវោច ឥធ មយ្ហំ អាវុសោ រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ អរិយោ តុណ្ហីភាវោ អរិយោ តុណ្ហីភាវោតិ វុច្ចតិ កតមោ នុ ខោ អរិយោ តុណ្ហីភាវោតិ ។ តស្ស មយ្ហំ អាវុសោ ឯតទហោសិ

# ភិក្ខុសំយុត្ត

[៣៩៤] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក្នុងទីនោះឯង ព្រះមហាមោគ្គល្លានមានអាយុ ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុមានអាយុទាំងឡាយ ។ ភិក្ខុទាំង-ឡាយទទួលពាក្យព្រះមហាមោគ្គល្លានមានអាយុថា ករុណា លោកមានអាយុ ។

[៣៩៥] ព្រះមហាមោគ្គល្លានមានអាយុ បានពោលពាក្យដូច្នេះថា ម្នាលអាវុសោ ក្នុងទីឯណោះ ខ្ញុំនៅក្នុងទីដ៏ស្ងាត់ សម្ងំនៅតែម្នាក់ឯង ក៏មានបរិវិតក្កៈក្នុងចិត្តកើតឡើងយ៉ាងនេះថា ពាក្យដែលគេពោលថា សភាពស្ងៀមដ៏ប្រសើរ សភាពស្ងៀមដ៏ប្រសើរ ដូច្នេះ តើសភាពស្ងៀមដ៏ប្រសើរដូចម្តេចទៅ ។ ម្នាលអាវុសោ ខ្ញុំនោះមានសេចក្តីត្រិះរិះ

ឥធ ភិក្ខុ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទ-
នំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ
បីតិសុខំ ទុតិយជ្ឈានំ ឧបសម្បជ្ជ វិហរតិ អយំ វុច្ចតិ
អរិយោ តុណ្ហីភាវោតិ ។ សោ ខ្វាហំ អាវុសោ វិតក្កវិ-
ចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯ-
កោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិ-
យជ្ឈានំ ឧបសម្បជ្ជ វិហរាមិ ។ តស្ស មយ្ហំ អាវុសោ
ឥមិនា វិហារេន វិហរតោ វិតក្កសហគតា សញ្ញា
មនសិការា សមុទាចរន្តិ ។ អថខោ មំ អាវុសោ
ភគវា ឥទ្ធិយា ឧបសង្កមិត្វា ឯតទវោច មោគ្គល្លាន
មោគ្គល្លាន មា ព្រាហ្មណ អរិយំ តុណ្ហីភាវំ បមាទោ
អរិយេ តុណ្ហីភាវេ ចិត្តំ សណ្ឋាបេហិ អរិយេ តុណ្ហីភាវេ
ចិត្តំ ឯកោទិភាវំ ករោហិ អរិយេ តុណ្ហីភាវេ ចិត្តំ
សមាទហាតិ ។ សោ ខ្វាហំ អាវុសោ អបរេន សមយេន
វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ
ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ
ទុតិយជ្ឈានំ ឧបសម្បជ្ជ វិហរាមិ ។ យំ ហិ[១] អាវុសោ

១ ឱ. ម. យំ ហិ តំ អាវុសោ ។

យ៉ាងនេះថា ភិក្ខុក្នុងសាសនានេះ រម្ងាប់វិតក្កៈវិចារៈហើយ ដល់នូវទុតិ-យជ្ឈានដែលមានក្នុងខ្លួន ប្រកបដោយសេចក្តីជ្រះថ្លា មានភាវៈនៃចិត្តដ៏ខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតិនិងសុខៈដែលកើតមកអំពីសមាធិ នេះលោកពោលថា សភាពស្ងៀមដ៏ប្រសើរ ។ ម្នាលអាវុសោ ខ្ញុំនោះក៏រម្ងាប់វិតក្កៈវិចារៈ ចូលកាន់ទុតិយជ្ឈានដែលមានក្នុងខ្លួន ជាទីជ្រះថ្លា មានភាវៈនៃចិត្តខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតិនិងសុខៈដែលកើតមកអំពីសមាធិ ។ ម្នាលអាវុសោ កាលខ្ញុំនោះកំពុងសម្រេចសម្រាន្តនៅដោយវិហារធម៌នេះ ក៏មានសញ្ញានិងមនសិការៈដែលមានវិតក្កៈជាអារម្មណ៍ តាំងឡើងទៀត ។ ម្នាលអាវុសោ គ្រានោះឯង ព្រះមានព្រះភាគស្តេចចូលទៅរកខ្ញុំដោយឫទ្ធិ ហើយបានត្រាស់ដូច្នេះថា ម្នាលមោគ្គល្លាន ម្នាលមោគ្គល្លាន ម្នាលព្រាហ្មណ៍ អ្នកកុំប្រមាទនូវសភាពស្ងៀមដ៏ប្រសើរឡើយ ចូរតម្កល់ចិត្តក្នុងសភាពស្ងៀមដ៏ប្រសើរ ចូរធ្វើចិត្តឲ្យជាភាវៈខ្ពស់ឯកក្នុងសភាពស្ងៀមដ៏ប្រសើរ ចូរតម្កល់ចិត្តស្មើក្នុងសភាពស្ងៀមដ៏ប្រសើរចុះ ។ ម្នាលអាវុសោ សម័យក្រោយមក ខ្ញុំនោះក៏រម្ងាប់វិតក្កៈវិចារៈរួចហើយ ចូលកាន់ទុតិយជ្ឈានដែលមានក្នុងខ្លួន ជាទីជ្រះថ្លា មានភាវៈនៃចិត្តខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតិនិងសុខៈដែលកើតមកអំពីសមាធិ ។ ម្នាលអាវុសោ

សម្មា វទមានោ វទេយ្យ សត្ថារា អនុគ្គហិតោ សាវកោ មហាភិញ្ញតំ បត្តោតិ ។ មមន្តំ សម្មា វទមានោ វទេយ្យ សត្ថារា អនុគ្គហិតោ សាវកោ មហាភិញ្ញតំ បត្តោតិ ។ បឋមំ ។

[៣៨៦] សាវត្ថីនិទានំ ។ តត្រ ខោ អាយស្មា សារីបុត្តោ ភិក្ខូ អាមន្តេសិ អាវុសោ ភិក្ខវេតិ ។ អាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ សារីបុត្តស្ស បច្ចស្សោសុំ ។

[៣៨៧] អាយស្មា សារីបុត្តោ ឯតទវោច ឥធ មយ្ហំ អាវុសោ រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ អត្ថិ នុ ខោ តំ កិញ្ចិ លោកស្មឹ យស្ស មេ វិបរិណាមញ្ញថាភាវា ឧប្បជ្ជេយ្យុំ សោកបរិទេវទុក្ខទោមនស្សុបាយាសាតិ ។ តស្ស មយ្ហំ អាវុសោ ឯតទហោសិ នត្ថិ ខោ តំ កិញ្ចិ លោកស្មឹ យស្ស មេ វិបរិណាមញ្ញថាភាវា ឧប្បជ្ជេយ្យុំ សោកបរិទេវទុក្ខទោមនស្សុបាយាសាតិ ។

បុគ្គលពោលដោយប្រពៃ នូវពាក្យឯណាថា ព្រះសាស្តាទ្រង់អនុគ្រោះសាវ័កដែលដល់នូវអភិញ្ញាធំគឺអភិញ្ញា ៦ ។ បុគ្គលពោលដោយប្រពៃនូវពាក្យនោះថា ព្រះសាស្តាអនុគ្រោះសាវ័កដែលបានអភិញ្ញាធំគឺអភិញ្ញា ៦ ដូច្នេះ គឺពោលចំពោះខ្ញុំហ្នឹងឯង ។ ចប់សូត្រទី ១ ។

[៣៩៦] សាវត្ថីនិទាន ។ ក្នុងទីនោះឯង ព្រះសារីបុត្តមានអាយុហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុមានអាយុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលពាក្យព្រះសារីបុត្តមានអាយុថា ករុណា អាវុសោ ។

[៣៩៧] ព្រះសារីបុត្តមានអាយុ បានពោលពាក្យដូច្នេះថា ម្នាលអាវុសោ ក្នុងទីឯណោះ ខ្ញុំបាននៅក្នុងទីដ៏ស្ងាត់ សម្ងំនៅ ក៏មានបរិវិតក្កៈកើតឡើងក្នុងចិត្តយ៉ាងនេះថា សេចក្តីសោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត ចង្អៀតចង្អល់ចិត្ត គប្បីកើតឡើងដល់អាត្មាអញ ព្រោះការប្រែប្រួលនិងផ្លាស់ប្តូរនៃសត្វនិងសង្ខារឯណា សត្វនិងសង្ខារតិចតួចក្នុងលោកមានខ្វះដែរឬ ។ ម្នាលអាវុសោ ខ្ញុំនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា សេចក្តីសោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត ចង្អៀតចង្អល់ចិត្ត មិនគប្បីកើតឡើងដល់អាត្មាអញ ព្រោះការប្រែប្រួលនិងផ្លាស់ប្តូរនៃសត្វនិងសង្ខារឯណា សត្វនិងសង្ខារនោះតិចតួចក្នុងលោកមិនមានសោះឡើយ ។

[៣៩៨] ឯវំ វុត្តេ អាយស្មា អានន្ទោ អាយស្មន្តំ សារីបុត្តំ ឯតទវោច សត្ថុបិ ខោ តេ អាវុសោ សារីបុត្ត វិបរិណាមញ្ញថាភាវា ឧប្បជ្ជេយ្យុំ សោកបរិទេវទុក្ខ-ទោមនស្សុបាយាសាតិ ។ សត្ថុបិ ខោ មេ អាវុសោ វិបរិណាមញ្ញថាភាវា ឧប្បជ្ជេយ្យុំ សោកបរិទេវទុក្ខ-ទោមនស្សុបាយាសា អបិច មេ ឯវមស្ស មហេសក្ខោ វត ភោ សត្ថា អន្តរហិតោ មហិទ្ធិកោ មហានុភាវោ សចេ ហិ ភគវា ចិរំ ទីឃមទ្ធានំ តិដ្ឋេយ្យ តទស្ស ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បា-យ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានន្តិ ។

[៣៥៨] កាលព្រះសារីបុត្តពោលយ៉ាងនេះហើយ ព្រះអានន្ទមានអាយុ ក៏បាននិយាយនឹងព្រះសារីបុត្តមានអាយុ យ៉ាងនេះថា ម្នាលសារីបុត្តមានអាយុ សេចក្តីសោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត ចង្អៀតចង្អល់ចិត្ត មិនកើតដល់លោក ព្រោះការប្រែប្រួលនិងផ្លាស់ប្តូរនៃព្រះសាស្តាដែរឬ ។ ម្នាលអាវុសោ សេចក្តីសោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត ចង្អៀតចង្អល់ចិត្ត មិនគប្បីកើតឡើងដល់ខ្ញុំពិត ព្រោះការប្រែប្រួលនិងផ្លាស់ប្តូរនៃព្រះសាស្តាទេ តែថាខ្ញុំមានសេចក្តីត្រិះរិះយ៉ាងនេះថា អើហ្ន៎ ព្រះសាស្តាមានស័ក្តិធំ មានឫទ្ធិច្រើន មានអានុភាពច្រើន បាត់បង់ទៅហើយ ប្រសិនបើជាព្រះមានព្រះភាគ ព្រះអង្គគប្បីគង់នៅអស់កាលជាយូរអង្វែងទៅ ការគង់នៅរបស់ព្រះអង្គនោះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីគុណ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ។

## ២៧៩



តថា ហិ បនាយស្មតោ សារីបុត្តស្ស ទីឃរត្តំ អហង្ការ-
មមង្ការមានានុសយា សុសមូហតា តស្មា អាយស្មតោ
សារីបុត្តស្ស សត្ថុបិ វិបរិណាមញ្ញថាភាវា នុប្បជ្ជេយ្យុំ
សោកបរិទេវទុក្ខទោមនស្សុបាយាសាតិ ។ ទុតិយំ ។

[៣៨៩] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សា-
វត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។
តេន ខោ បន សមយេន អាយស្មា ច សារីបុត្តោ
អាយស្មា ច មហាមោគ្គល្លានោ រាជគហេ វិហរន្តិ វេឡុ-
វនេ កលន្ទកនិវាបេ ឯកវិហារេ ។ អថខោ អាយស្មា
សារីបុត្តោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេ-
នាយស្មា មហាមោគ្គល្លានោ តេនុបសង្កមិ ឧបសង្ក-
មិត្វា អាយស្មតា មហាមោគ្គល្លានេន សទ្ធឹ សម្មោទិ
សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ
និសីទិ ។

ព្រោះថា អហង្ការ(ទិដ្ឋិ) មមង្ការ(តណ្ហា) និងមានានុស័យ ព្រះសារីបុត្តមានអាយុ បានដកចេញស្រឡះអស់កាលយូរហើយ ហេតុដូច្នេះទើបសេចក្តីសោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត ចង្អៀតចង្អល់ចិត្ត មិនគប្បីកើតឡើងដល់ព្រះសារីបុត្តមានអាយុ ព្រោះការប្រែប្រួលផ្លាស់ប្តូរនៃព្រះសាស្តាឡើយ ។ ចប់សូត្រទី ២ ។

[៣៥៩] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក៏ក្នុងសម័យនោះឯង ព្រះសារីបុត្តមានអាយុ និងព្រះមហាមោគ្គល្លានមានអាយុ គង់នៅក្នុងវិហារជាមួយគ្នា[១] ក្នុងវត្តវេឡុវន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ គ្រានោះឯងព្រះសារីបុត្តមានអាយុ ចេញអំពីទីសម្ងំ ក្នុងសាយណ្ហសម័យ ហើយចូលទៅរកព្រះមហាមោគ្គល្លានមានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះមហាមោគ្គល្លានមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។

១ ក្នុងល្វែងជាមួយគ្នា (អដ្ឋកថា) ។

[៣៦០] ឯកមន្តំ និសិន្នោ ខោ អាយស្មា សារីបុត្តោ អាយស្មន្តំ មហាមោគ្គល្លានំ ឯតទវោច វិប្បសន្នានិ ខោ តេ អាវុសោ មោគ្គល្លាន ឥន្ទ្រិយានិ បរិសុទ្ធោ មុខវណ្ណោ បរិយោទាតោ សន្តេន នូនាយស្មា មហាមោគ្គល្លានោ អជ្ជ វិហារេន វិហាសីតិ ។ ឱឡារិកេន ខ្វាហំ អាវុសោ អជ្ជ វិហារេន វិហាសឹ អបិច មេ អហោសិ ធម្មីកថាតិ ។ កេន សទ្ធឹ បនាយស្មតោ មហាមោគ្គល្លានស្ស អហោសិ ធម្មីកថាតិ ។ ភគវតា ខោ មេ អាវុសោ សទ្ធឹ អហោសិ ធម្មីកថាតិ ។ ទូរេ ខោ អាវុសោ ភគវា ឯតរហិ សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ កិន្នុ ខោ អាយស្មា មហាមោគ្គល្លានោ ភគវន្តំ ឥទ្ធិយា ឧបសង្កមិ ឧទាហុ ភគវា អាយស្មន្តំ មហាមោគ្គល្លានំ ឥទ្ធិយា ឧបសង្កមីតិ ។

[៣៦០] លុះព្រះសារីបុត្តមានអាយុ អង្គុយក្នុងទីដ៏សមគួរ ហើយ ក៏បានពោលនឹងព្រះមហាមោគ្គល្លានមានអាយុ ដូច្នេះថា ម្នាលអាវុសោមោគ្គល្លាន ឥន្ទ្រិយទាំងឡាយរបស់លោកថ្លាដល់ម្ល៉េះ សម្បុរមុខក៏បរិសុទ្ធផូរផង់ ថ្ងៃនេះ មហាមោគ្គល្លានមានអាយុ នៅដោយធម៌ជាគ្រឿងនៅល្អិតពេកណាស់ ។ ព្រះមហាមោគ្គល្លានតបថា ម្នាលអាវុសោ ថ្ងៃនេះ ខ្ញុំនៅដោយធម៌ជាគ្រឿងនៅគ្រោតគ្រាតពេកណាស់ តែជាធម្មីកថារបស់ខ្ញុំមាន ។ ចុះធម្មីកថារបស់មហាមោគ្គល្លានមានអាយុ មានជាមួយនឹងបុគ្គលណា ។ ម្នាលអាវុសោ ឥឡូវនេះ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ឆ្ងាយពេកណាស់ តើព្រះមហាមោគ្គល្លានដ៏មានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ ដោយឫទ្ធិឬ ឬក៏ព្រះមានព្រះភាគស្តេចចូលមករកព្រះមហាមោគ្គល្លានមានអាយុ ដោយឫទ្ធិវិញ ។

ន ខ្វាហំ អាវុសោ ភគវន្តំ ឥទ្ធិយា ឧបសង្កមិ នបិ មំ ភគវា ឥទ្ធិយា ឧបសង្កមិ អបិ ច មេ យាវតា ភគវា ឯត្តាវតា ទិព្វចក្ខុំ វិសុជ្ឈិ ទិព្វា ច សោតធាតុ ភគ-វតោបិ យាវតាហំ ឯត្តាវតា ទិព្វចក្ខុំ វិសុជ្ឈិ ទិព្វា ច សោតធាតូតិ ។ យថាកថំ បនាយស្មាតោ មហា-មោគ្គល្លានស្ស ភគវតោ សទ្ធឹ អហោសិ ធម្មី កថាតិ ។

[៣៦១] ឥធាហំ អាវុសោ ភគវន្តំ ឯតទវោចំ អារទ្ធវីរិយោ អារទ្ធវីរិយោតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ អារទ្ធវីរិយោ ហោតីតិ ។ ឯវំ វុត្តេ មំ អាវុសោ ភគវាបិ ឯតទវោច ឥធ មោគ្គល្លាន

ម្នាលអាវុសោ ខ្ញុំមិនបានចូលទៅគាល់ព្រះមានព្រះភាគ ដោយឫទ្ធិទេ ចំណែកព្រះមានព្រះភាគ ក៏ពុំបានមករកខ្ញុំដោយឫទ្ធិដែរ តែថាព្រះមានព្រះភាគ ព្រះអង្គមានទិព្វចក្ខុនិងទិព្វសោតធាតុដ៏បរិសុទ្ធ កំណត់ត្រឹមណា ទិព្វចក្ខុនិងទិព្វសោតធាតុរបស់ខ្ញុំក៏បរិសុទ្ធ កំណត់ត្រឹមណោះដែរ ខ្ញុំមានទិព្វចក្ខុនិងទិព្វសោតធាតុដ៏បរិសុទ្ធ កំណត់ត្រឹមណា ទិព្វចក្ខុនិងទិព្វសោតធាតុរបស់ព្រះមានព្រះភាគក៏បរិសុទ្ធ កំណត់ត្រឹមណោះដែរ ។ ចុះធម្មីកថារបស់ព្រះមហាមោគ្គល្លានមានអាយុ មានជាមួយនឹងព្រះមានព្រះភាគ ដោយប្រការដូចម្តេចទៅ ។

[៣៦១] ម្នាលអាវុសោ ក្នុងទីឯណោះ ខ្ញុំបានក្រាបបង្គំទូលសួរព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យដែលពោលថា (ភិក្ខុ) មានព្យាយាមប្រារព្ធហើយ មានព្យាយាមប្រារព្ធហើយ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុមានព្យាយាមប្រារព្ធហើយ តើដោយហេតុមានប៉ុន្មាន ។ ម្នាលអាវុសោ កាលខ្ញុំក្រាបបង្គំទូលសួរយ៉ាងនេះហើយ ព្រះមានព្រះភាគបានត្រាស់នឹងខ្ញុំដូច្នេះថា ម្នាលមោគ្គល្លាន

ភិក្ខុ អារទ្ធវីរិយោ វិហរតិ កាមំ តចោ ច នហារុ ច អដ្ឋិ ច អវសិស្សតុ សរីរេ ឧបសុស្សតុ មំសលោហិតំ យន្តំ បុរិសថាមេន បុរិសវីរិយេន បុរិសបរក្កមេន បត្តព្វំ ន តំ អបាបុណិត្វា វីរិយស្ស សណ្ឋានំ ភវិស្សតីតិ ឯវំ ខោ មោគ្គល្លាន អារទ្ធវីរិយោ ហោតីតិ ។ ឯវំ ខោ មេ អាវុសោ ភគវតា សទ្ធឹ អហោសិ ធម្មីកថាតិ ។

[៣៦២] សេយ្យថាបិ អាវុសោ ហិមវតោ បព្វតរាជស្ស បរិត្តា បាសាណសក្ខរា យាវទេវ ឧបនិក្ខេបនមត្តាយ ឯវមេវ ខោ មយំ អាយស្មតោ មហាមោគ្គល្លានស្ស យាវទេវ ឧបនិក្ខេបមត្តាយ អាយស្មា ហិ មហាមោគ្គល្លានោ មហិទ្ធិកោ មហានុភាវោ អាកង្ខមានោ កប្បំ តិដ្ឋេយ្យាតិ ។

ភិក្ខុក្នុងសាសនានេះ មានព្យាយាមប្រារព្ធដោយតាំងចិត្តថា ស្បែកក្តី សរសៃក្តី ឆ្អឹងក្តី ចូរសល់នៅចុះ ឯសាច់និងឈាមក្នុងសរីរៈចូររីងស្ងួតទៅក៏ដោយ (បើ) មិនទាន់ដល់គុណជាតដែលគេគប្បីដល់ ដោយកម្លាំងនៃបុរស ដោយព្យាយាមនៃបុរស ដោយការប្រឹងប្រែងនៃបុរសទេ ក៏មិនបញ្ឈប់សេចក្តីព្យាយាមឡើយ ម្នាលមោគ្គល្លាន យ៉ាងនេះឯង ឈ្មោះថា ភិក្ខុមានសេចក្តីព្យាយាមប្រារព្ធហើយ ។ ម្នាលអាវុសោ ធម្មីកថារបស់ខ្ញុំ មានជាមួយនឹងព្រះមានព្រះភាគ យ៉ាងនេះឯង ។

[៣៦២] ម្នាលអាវុសោ ដុំថ្មតូចលើកយកទៅដាក់ផ្ទឹមក្នុងទីជិតនៃស្តេចភ្នំហិមពាន្ត យ៉ាងណា ខ្ញុំនយើងលើកយកទៅផ្ទឹមក្នុងទីជិតនៃព្រះមហាមោគ្គល្លានមានអាយុ ក៏យ៉ាងនោះដែរ ព្រោះថា ព្រះមហា-មោគ្គល្លានមានអាយុ មានឫទ្ធិច្រើន មានអានុភាពច្រើន ប្រាថ្នាបិតនៅអស់ ១ អាយុកប្បក៏បាន ។

[៣៦៣] សេយ្យថាបិ អាវុសោ មហតិយា លោណឃដាយ បរិត្តា លោណសក្ខរា យាវទេវ ឧបនិក្ខេបនមត្តាយ ឯវមេវ ខោ មយំ អាយស្មតោ សារីបុត្តស្ស យាវទេវ ឧបនិក្ខេបនមត្តាយ អាយស្មា ហិ សារីបុត្តោ ភគវតា អនេកបរិយាយេន ថោមិតោ វណ្ណិតោ បសត្ថោ

សារីបុត្តោ ច បញ្ញាយ
សីលេន ឧបសមេន ច
យោបិ បារគតោ ភិក្ខុ
ឯវ សោ បរមោ សិយាតិ ។

ឥតិហ តេ[១] ឧភោ មហានាគា អញ្ញមញ្ញស្ស សុភាសិតំ សុលបិតំ សមនុមោទឹសូតិ ។ តតិយំ ។

[៣៦៤] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អញ្ញតរោ នវោ ភិក្ខុ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ វិហារំ បវិសិត្វា អប្បោស្សុក្កោ

១ ឱ. ឥតិហេតេ ។

[៣៦៣] ម្នាលអាវុសោ ដុំអំបិលតូចបង់ទៅក្នុងថ្លាំងអំបិលដ៏ធំយ៉ាងណា ខ្លួនយើងលើកយកទៅផ្ទឹមនឹងព្រះសារីបុត្តមានអាយុ ក៏យ៉ាងនោះដែរ ដ្បិតថា ព្រះសារីបុត្តមានអាយុ ព្រះមានព្រះភាគទ្រង់ស្ញើច ទ្រង់ពណ៌នាគុណ ទ្រង់សរសើរ ដោយអនេកបរិយាយថា

ព្រះសារីបុត្ត (ប្រកប) ដោយបញ្ញា ដោយសីល ដោយការរម្ងាប់ ជាភិក្ខុ ដល់នូវត្រើយ ជាបុគ្គលប្រសើរមែនពិត ។

មហានាគទាំងគូនោះ ស្មោះសរ រីករាយ នឹងសុភាសិតដែលលោកពោលល្អដល់គ្នានិងគ្នា ដោយប្រការដូច្នេះ ។ ចប់សូត្រទី ៣ ។

[៣៦៤] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក្នុងសម័យនោះឯង ភិក្ខុថ្មីមួយរូបត្រឡប់មកពីបិណ្ឌបាត ក្នុងវេលាខាងក្រោយភត្ត ក៏ចូលទៅកាន់វិហារ ជាអ្នកមិនមាន

តុណ្ហីភូតោ សង្កតាយតិ(១) ន ភិក្ខូនំ វេយ្យាវច្ចំ ករោតិ ចីវរការសមយេ ។ អថខោ សម្ពហុលា ភិក្ខូ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។

[៣៦៨] ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ ឥធ ភន្តេ អញ្ញតរោ ភិក្ខុ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ វិហារំ បវិសិត្វា អប្បោស្សុក្កោ តុណ្ហីភូតោ សង្កតាយិស្សតិ(២) ន ភិក្ខូនំ វេយ្យាវច្ចំ ករោតិ ចីវរការសមយេតិ ។ អថខោ ភគវា អញ្ញតរំ ភិក្ខុំ អាមន្តេសិ ឯហិ ត្វំ ភិក្ខុ មម វចនេន តំ ភិក្ខុំ អាមន្តេហិ សត្ថា តំ អាវុសោ អាមន្តេតីតិ ។ ឯវំ ភន្តេតិ ខោ សោ ភិក្ខុ ភគវតោ បដិស្សុណិត្វា យេន សោ ភិក្ខុ តេនុបសង្កមិ ឧបសង្កមិត្វា តំ ភិក្ខុំ ឯតទវោច សត្ថា តំ អាវុសោ អាមន្តេតីតិ ។ ឯវមាវុសោតិ ខោ សោ ភិក្ខុ តស្ស ភិក្ខុនោ បដិស្សុណិត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។

---

១ ឱ. សង្កាសាយតិ ។ ម. សង្កសាយតិ ។ ២ ឱ. ម. សង្កសាយតិ ។

សេចក្តីខ្វល់ខ្វាយ មានសភាពតោះតើយ មិនជួយធ្វើនូវការខ្វល់ខ្វាយ ដល់ភិក្ខុទាំងឡាយ ក្នុងសម័យដែលធ្វើចីវរឡើយ ។ គ្រានោះឯង ពួកភិក្ខុច្រើនរូប ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។

[៣៦៥] លុះភិក្ខុទាំងនោះ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះ ភិក្ខុថ្មីមួយរូបត្រឡប់មកពីបិណ្ឌបាត ក្នុងវេលាខាងក្រោយភត្ត ក៏ចូលទៅកាន់វិហារ ជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយ មានសភាពតោះតើយ មិនជួយធ្វើការខ្វល់ខ្វាយ ដល់ភិក្ខុទាំងឡាយ ក្នុងសម័យដែលធ្វើចីវរឡើយ ។ គ្រានោះឯង ព្រះមានព្រះភាគត្រាស់ហៅភិក្ខុមួយរូបទៀតមកថា ម្នាលភិក្ខុ អ្នកចូរមក អ្នកចូរទៅហៅភិក្ខុនោះតាមពាក្យតថាគតថា ម្នាលអាវុសោ ព្រះសាស្តាត្រាស់ហៅអ្នក ។ ភិក្ខុនោះទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ហើយចូលទៅរកភិក្ខុនោះ លុះចូលទៅដល់ហើយ បាននិយាយប្រាប់ភិក្ខុនោះ ដូច្នេះថា ម្នាលអាវុសោ ព្រះសាស្តាត្រាស់ហៅអ្នក ។ ភិក្ខុនោះទទួលពាក្យភិក្ខុនោះថា ករុណា អាវុសោ ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។

ឯកាមន្តំ និសិន្នំ ខោ តំ ភិក្ខុំ ភគវា ឯតទវោច សច្ចំ កិរ ត្វំ ភិក្ខុ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ វិហារំ បវិសិត្វា អប្បោស្សុក្កោ តុណ្ហីភូតោ សង្កតាយិស្សសិ[១] ន ភិក្ខូនំ វេយ្យាវច្ចំ ករោសិ ចីវរការសមយេតិ ។ អហម្បិ ខោ ភន្តេ សកំ កិច្ចំ ករោមីតិ ។

[៣៦៦] អថខោ ភគវា តស្ស ភិក្ខុនោ ចេតសា ចេតោ បរិវិតក្កមញ្ញាយ ភិក្ខូ អាមន្តេសិ មា ខោ តុម្ហេ ភិក្ខវេ ឯតស្ស ភិក្ខុនោ ឧជ្ឈាយិត្ថ ឯសោ ខោ ភិក្ខវេ ភិក្ខុ ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី អកិច្ឆលាភី អកសិរលាភី យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតីតិ ។

---
១ ឱ. ម. សង្កសាយសិ ។

លុះភិក្ខុនោះអង្គុយក្នុងទីសមគួរហើយ ទើបព្រះមានព្រះភាគត្រាស់សួរដូច្នេះថា ម្នាលភិក្ខុ ឮថាអ្នកត្រឡប់មកពីបិណ្ឌបាត ក្នុងវេលាខាងក្រោយភត្ត ក៏ចូលទៅកាន់វិហារ ជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយ មានសភាពតោះតើយ មិនជួយធ្វើការខ្វល់ខ្វាយដល់ភិក្ខុទាំងឡាយ ក្នុងសម័យដែលធ្វើចីវរ ពិតឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះខ្ញុំព្រះអង្គកំពុងជាប់ធ្វើកិច្ចរបស់ខ្ញុំព្រះអង្គដែរ ។

[៣៦៦] គ្រានោះឯង ព្រះមានព្រះភាគ ជ្រាបនូវបរិវិតក្កៈក្នុងចិត្តរបស់ភិក្ខុនោះ ដោយព្រះហឫទ័យព្រះអង្គ ហើយត្រាស់ហៅពួកភិក្ខុមកថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំពោលទោសភិក្ខុនុ៎ះឡើយ ម្នាលភិក្ខុទាំងឡាយ ដ្បិតភិក្ខុនោះជាអ្នកបានដូចសេចក្តីប្រាថ្នា បានដោយមិនលំបាក បានដោយមិនខុសកាលវេលា នូវឈានទាំង ៤ អាស្រ័យនឹងចិត្តដ៏ឧត្តម ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន កុលបុត្តទាំងឡាយចេញចាកផ្ទះចូលមកកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ឯណា ក៏បានធ្វើឲ្យជាក់ច្បាស់ បានដល់ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវអនុត្តរធម៌នោះ ជាទីបំផុតនៃព្រហ្មចរិយៈ ។

[៣៦៧] ឥទមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា

ជយិទំ សិថិលមារព្ភ
ជយិទំ អប្បថាមសា[១]
និព្វានំ អធិគន្តព្វំ
សព្វគន្ថប្បមោចនំ[២]
អយំ ច ទហរោ ភិក្ខុ
អយមុត្តមបោរិសោ
ធារេតិ អន្តិមំ ទេហំ
ជេត្វា មារំ សវាហនន្តិ ។ ចតុត្ថំ ។

[៣៦៨] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិ-យំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ អាយស្មា សុជាតោ យេន ភគវា តេនុ-បសង្កមិ ឧបសង្កមិត្វា ។

១ ឱ. ម. អប្បេន ថាមសា ។ ២ សព្វទុក្ខប្បមោចនំ ។

[៣៦៧] ព្រះមានព្រះភាគ បានត្រាស់ព្រះពុទ្ធដីកានេះ លុះព្រះសុគតជាសាស្តាត្រាស់ព្រះពុទ្ធដីកានេះរួចហើយ ទើបទ្រង់ត្រាស់ព្រះពុទ្ធដីកានេះតទៅទៀតថា

បុគ្គលប្រារព្ធព្យាយាមធូរថយ មិនបានដល់ព្រះនិព្វាននេះ
ដែលជាទីញុំាងសត្វ ឲ្យរួចចាកគន្ថៈ គឺកិលេសទាំងពួងទេ
បុគ្គលមានកម្លាំងព្យាយាមតិច ក៏មិនបានដល់ព្រះនិព្វាននេះ
ដែលជាទីញុំាងសត្វឲ្យរួចចាកគន្ថៈ គឺកិលេសទាំងពួងដែរ
ភិក្ខុនេះជាភិក្ខុកម្លោះ ភិក្ខុនេះជាបុរសដ៏ឧត្តម ទ្រទ្រង់នូវ
អត្តភាពជាទីបំផុត បានឈ្នះនូវមារព្រមទាំងពាហនៈ ។

ចប់សូត្រទី ៤ ។

[៣៦៨] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ព្រះសុជាតមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ ។

ភិក្ខុសំយុត្តស្ស បញ្ចមសុត្តេ និគមគាថា

[៣៦៩] អទ្ទសា ខោ ភគវា អាយស្មន្តំ សុជាតំ ទូរតោ វ អាគច្ឆន្តំ ទិស្វាន ភិក្ខូ អាមន្តេសិ ឧភយេនេវាយំ ភិក្ខវេ កុលបុត្តោ សោភតិ[១] យញ្ច អភិរូបោ ទស្សនីយោ បាសាទិកោ បរមាយ វណ្ណបោក្ខរតាយ សមន្នាគតោ យស្ស ចត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតីតិ ។

[៣៧០] ឥទមវោច ភគវា ។ បេ ។ សត្ថា

សោភតិ វតាយំ ភិក្ខុ
ឧជុភូតេន ចេតសា
វិប្បយុត្តោ វិសញ្ញុត្តោ
អនុបាទាយ និព្វុតោ
ធារេតិ អន្តិមំ ទេហំ
ជេត្វា មារំ សវាហនន្តិ ។ បញ្ចមំ ។

១ សោភតិ វត ។

ភិក្ខុសំយុត្ត បញ្ចមសូត្រ និគមគាថា

[៣៦៩] ព្រះមានព្រះភាគ បានទតឃើញព្រះសុជាតដ៏មានអាយុ កំពុងមកអំពីចម្ងាយ លុះទតឃើញហើយ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ កុលបុត្រនេះល្អដោយហេតុទាំង ២ យ៉ាងគឺ កុលបុត្តមានរូបល្អ គួរឲ្យពិតពិលរមិលមើល ជាទីជ្រះថ្លាប្រកបដោយសម្បុរដ៏ល្អក្រៃលែង ១ ពួកកុលបុត្តចេញចាកចូលមកកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ឯណា ក៏បានធ្វើឲ្យនូវអនុត្តរធម៌នោះ ជាទីបំផុតនៃព្រហ្មចរិយៈ ១ ។

[៣៧០] ព្រះមានព្រហភាគ បានត្រាស់ព្រះពុទ្ធដីកានេះ ។ បេ ។ ព្រះសាស្តាត្រាស់ថា

ភិក្ខុនេះមានចិត្តត្រង់ ប្រាសចាកកិលេសហើយ មិនប្រកប
(ដោយកិលេស) មានទុក្ខរលត់ហើយ ព្រោះមិនបាន
ប្រកាន់ ទើបឈ្មោះថាល្អពិត ទ្រទ្រង់នូវអត្តភាពជាទីបំផុត
បានឈ្នះនូវមារព្រមទាំងពាហនៈហើយ ។ ចប់សូត្រទី ៥ ។

[៣៧១] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ អាយស្មា លកុណ្ឌកភទ្ទិយោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ។

[៣៧២] អទ្ទសា ខោ ភគវា អាយស្មន្តំ លកុណ្ឌកភទ្ទិយំ ទូរតោ វ អាគច្ឆន្តំ ទិស្វាន ភិក្ខូ អាមន្តេសិ បស្សថ នោ តុម្ហេ ភិក្ខវេ ឯតំ ភិក្ខុំ អាគច្ឆន្តំ ទុព្វណ្ណំ ទុទ្ទសិកំ ឱកោដិមកំ ភិក្ខូនំ បរិភូតរូបន្តិ ។ ឯវំ ភន្តេ ។ ឯសោ ខោ ភិក្ខវេ ភិក្ខុ មហិទ្ធិកោ មហានុភាវោ ន ច សា សមាបត្តិ សុលភរូបា យា តេន ភិក្ខុនា អសមាបន្នបុព្វា យស្ស ចត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតីតិ ។

[៣៧១] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ព្រះលកុណ្ដកភទ្ទិយៈមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ ។

[៣៧២] ព្រះមានព្រះភាគ ទ្រង់ទតឃើញព្រះលកុណ្ដកភទ្ទិយៈមានអាយុ កំពុងមកអំពីចម្ងាយ លុះទតឃើញហើយ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញភិក្ខុដែលកំពុងមកនុ៎ះ មានសម្បុរអាក្រក់ លំបាកមើល តូចទាប មានរូបគួរឲ្យភិក្ខុទាំងឡាយមើលងាយដែរឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនុ៎ះមានឫទ្ធិច្រើន មានអានុភាពច្រើន សមាបត្តិឯណា ដែលភិក្ខុនោះមិនធ្លាប់ចូល សមាបត្តិនោះ បុគ្គលដទៃមិនបានដោយងាយឡើយ មួយទៀត ពួកកុលបុត្តចេញចាកផ្ទះចូលមកកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ឯណា ភិក្ខុនោះក៏បានត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ បានសម្រេចដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវអនុត្តរធម៌នោះ ដែលជាទីបំផុតនៃព្រហ្មចរិយៈ ។

[៣៧៣] ឥទមវោច ភគវា ។ បេ ។ សត្ថា
ហំសា កុញ្ចា មយូរា ច
ហត្ថិយោ បសទមិគា(១)
សព្វេ សីហស្ស ភាយន្តិ
នត្ថិ កាយស្មិំ តុល្យតា
ឯវមេវ មនុស្សេសុ
ទហរោ ចេបិ បញ្ញវា
សោ ហិ តត្ថ មហា ហោតិ
នេវ ពាលោ សរីរវាតិ ។ ទស្នំ ។

[៣៧៤] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ តេន ខោ បន សមយេន អាយស្មា វិសាខោ បញ្ចាលបុត្តោ ឧបដ្ឋានសាលាយំ ភិក្ខូ ធម្មិយា កថាយ សន្ទស្សេតិ សមាទបេតិ សមុត្តេជេតិ សម្បហំសេតិ ចោរិយា វាចាយ វិសដ្ឋាយ អនេលគឡាយ អត្ថស្ស វិញ្ញាបនិ-យា បរិយាបន្នាយ អនិស្សិតាយ ។

១ ឱ. ម. បសទាមិគា ។

ភិក្ខុសំយុត្ត សត្តមសូត្រ ការញ៉ាំងពួកភិក្ខុឲ្យឃើញច្បាស់ដោយធម្មីកថា

[៣៧៣] ព្រះមានព្រះភាគ បានត្រាស់ព្រះពុទ្ធដីកានេះ ។ បេ ។ ព្រះសាស្តាត្រាស់ថា

ពួកហង្ស ក្រៀល ក្ងោក ដំរី ម្រឹគក្តាន់ សត្វទាំងអស់នោះ រមែងខ្លាចរាជសីហ៍ តែនឹងយករាងកាយទៅប្រៀបធៀបគ្នាមិនបានឡើយ (យ៉ាងណា) បណ្តាមនុស្សទាំងឡាយ ប្រសិនបើមនុស្សកំលោះទេ តែមានប្រាជ្ញា គង់គេនឹងបានជាធំក្នុងពួកមនុស្សនោះ មនុស្សពាលមានតែសរីរៈ មិនជាធំក្នុងពួកមនុស្សទេ យ៉ាងនោះឯង ។ ចប់សូត្រទី ៦ ។

[៣៧៤] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងកូដាគារសាលា នាព្រៃមហាវន ទៀបក្រុងវេសាលី ។ ក៏ក្នុងសម័យនោះឯង ព្រះវិសាខៈមានអាយុ ជាបុត្តនៃអ្នកស្រុកបញ្ចាល បានញ៉ាំងពួកភិក្ខុក្នុងឧបដ្ឋានសាលាឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ដោយសំដីអ្នកបុរីដ៏ល្អ ឥតមានទោស ជាសំដីញ៉ាំងជនដទៃឲ្យដឹងច្បាស់នូវប្រយោជន៍ រាប់ចូលក្នុងសច្ចៈ មិនអាស្រ័យនូវវដ្តៈឡើយ ។

[៣៧៤] អថខោ ភគវា សាយណ្ហសមយំ បដិ-
សល្លានា វុដ្ឋិតោ យេន ឧបដ្ឋានសាលា តេនុបសង្កមិ
ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ និសជ្ជ ខោ
ភគវា ភិក្ខូ អាមន្តេសិ កោ នុ ខោ ភិក្ខវេ ឧបដ្ឋាន-
សាលាយំ ភិក្ខូ ធម្មិយា កថាយ សន្ទស្សេតិ សមា-
ទបេតិ សមុត្តេជេតិ សម្បហំសេតិ ពោរិយា វាចាយ
វិស្សដ្ឋាយ អនេលគឡាយ អត្ថស្ស វិញ្ញាបនិយា
បរិយាបន្នាយ អនិស្សិតាយាតិ ។ អាយស្មា ភន្តេ
វិសាខោ បញ្ចាលបុត្តោ ឧបដ្ឋានសាលាយំ ភិក្ខូ
ធម្មិយា កថាយ សន្ទស្សេតិ សមាទបេតិ សមុត្តេជេតិ
សម្បហំសេតិ ពោរិយា វាចាយ វិស្សដ្ឋាយ អនេល-
គឡាយ អត្ថស្ស វិញ្ញាបនិយា បរិយាបន្នាយ អនិស្សិតា-
យាតិ ។ អថខោ ភគវា អាយស្មន្តំ វិសាខំ បញ្ចាល-
បុត្តំ អាមន្តេសិ សាធុ សាធុ វិសាខ សាធុ ខោ ត្វំ
វិសាខ ភិក្ខូ ធម្មិយា កថាយ សន្ទស្សេសិ ។ បេ ។
អត្ថស្ស វិញ្ញាបនិយា បរិយាបន្នាយ អនិស្សិតាយាតិ ។

[៣៧៥] គ្រានោះឯង ព្រះមានព្រះភាគ ចេញចាកផលសមាបត្តិ ក្នុងសាយណ្ហសម័យ ស្តេចចូលទៅឯឧបដ្ឋានសាលា លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លុះព្រះមានព្រះភាគទ្រង់គង់ហើយ ក៏ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ អ្នកណាហ្ន៎ អាចញ៉ាំងពួកភិក្ខុក្នុងឧបដ្ឋានសាលាឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ដោយសំដីអ្នកបុរីដ៏ល្អ ឥតមានទោស ជាសំដីញ៉ាំងជនដទៃឲ្យដឹងចាស់នូវប្រយោជន៍ រាប់ចូលក្នុងសច្ចៈ មិនអាស្រ័យនូវវដ្តៈបាន ។ បពិត្រព្រះអង្គដ៏ចម្រើន វិសាខបញ្ចាលបុត្តមានអាយុ អាចញ៉ាំងពួកភិក្ខុក្នុងឧបដ្ឋានសាលាឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ដោយសំដីអ្នកបុរីល្អ ឥតមានទោស ជាសំដីញ៉ាំងជនដទៃឲ្យដឹងច្បាស់នូវប្រយោជន៍ រាប់ចូលក្នុងសច្ចៈ មិនអាស្រ័យនូវវដ្តៈ ។ គ្រានោះឯង ព្រះមានព្រះភាគ ត្រាស់នឹងវិសាខបញ្ចាលបុត្តមានអាយុថា ប្រពៃហើយ ប្រពៃហើយ វិសាខៈ ម្នាលវិសាខៈ អ្នកអាចញ៉ាំងពួកភិក្ខុឲ្យឃើញច្បាស់ដោយធម្មីកថា ។ បេ ។ ជាសំដីញ៉ាំងជនដទៃឲ្យដឹងច្បាស់នូវប្រយោជន៍ រាប់ចូលក្នុងសច្ចៈ មិនអាស្រ័យនូវវដ្តៈ ជាការប្រពៃណាស់ហើយ ។

២៩១

## ភិក្ខុសំយុត្តស្ស អដ្ឋមសុត្តំ ភគវន្តូបសង្កមនំ

[៣៧៦] ឥទមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា

នាភាសមាន ជានន្តិ
មិសំ ពាលេហិ បណ្ឌិតំ
ភាសមានញ្ច ជានន្តិ
ទេសេន្តំ អមតំ បទំ
ភាសយេ ជោតយេ ធម្មំ
បគ្គណ្ហេ ឥសិនំ ធជំ
សុភាសិតធជា ឥសយោ
ធម្មោ ហិ ឥសិនំ ធជោតិ ។ សត្តមំ ។

[៣៧៧] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ អាយស្មា នន្ទោ ភគវតោ មាតុច្ឆាបុត្តោ អាកោដិតប្បច្ចាកោដិតានិ ចីវរានិ បារុបិត្វា អក្ខីនិ អញ្ជិត្វា អច្ឆំ បត្តំ គហេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។

[៣៧៦] ព្រះមានព្រះភាគ បានត្រាស់ព្រះពុទ្ធដីកានេះ លុះព្រះសុគតជាសាស្តា បានត្រាស់ព្រះពុទ្ធដីកានេះហើយ ទើបទ្រង់ត្រាស់ព្រះពុទ្ធដីកានេះតទៅទៀតថា

បណ្ឌិតដែលច្រឡំដោយពួកពាល កាលបើមិនទាន់និយាយ
ពួកជនគេក៏មិនស្គាល់ លុះតែបណ្ឌិតនោះពោលឬសំដែងនូវ
ឧបាយនៃព្រះនិព្វាន ទើបពួកជនគេស្គាល់បាន បុគ្គលគប្បី
ពោលបំភ្លឺ លើកតម្កើងនូវធម៌ជាទង់ជ័យនៃឥសីទាំងឡាយ
ពួកឥសីមានសុភាសិតជាទង់ជ័យ ដ្បិតថាព្រះធម៌ជាទង់ជ័យ
នៃពួកឥសី ។ ចប់សូត្រទី ៧ ។

[៣៧៧] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ព្រះនន្ទមានអាយុ ជាបុត្រនៃព្រះមាតុច្ឆា (កូនម្តាយមីង) នៃព្រះមានព្រះភាគ គ្រងចីវរទាំងឡាយដែលជំទាំងសង-ខាង បន្តក់ភ្នែកហើយ កាន់យកបាត្រដ៏រលោង ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។

[៣៧៨] ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ នន្ទំ ភគវា ឯតទវោច ឯតំ ខោ តេ នន្ទ បដិរូបំ កុលបុត្តស្ស សទ្ធា អគារស្មា អនគារិយំ បព្វជិតស្ស យំ ត្វំ អាកោដិតបច្ចាកោដិតានិ ចីវរានិ ធារេយ្យាសិ អក្ខីនិ ច អញ្ជេយ្យាសិ អច្ឆំ បត្តំ ធារេយ្យាសិ ឯតំ ខោ តេ នន្ទ បដិរូបំ កុលបុត្តស្ស សទ្ធា អគារស្មា អនគារិយំ បព្វជិតស្ស យំ ត្វំ អារញ្ញិកោ ច អស្សសិ បិណ្ឌបាតិកោ ច បំសុកូលិកោ ច កាមេសុ ច អនបេក្ខោ វិហរេយ្យាសីតិ ។

[៣៧៩] ឥទមវោច ។ បេ ។ សត្ថា

កទាហំ នន្ទំ បស្សេយ្យំ
អារញ្ញំ បំសុកូលិកំ
អញ្ញាតុញ្ឆេន[១] យាបេន្តំ
កាមេសុ អនបេក្ខិនន្តិ ។

---

១ ឱ. អញ្ញាតុញ្ឆេន ។ ម. អញ្ញាតុច្ឆេន ។

[៣៧៨] លុះព្រះនន្ទមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ទើបព្រះមានព្រះភាគត្រាស់ព្រះពុទ្ធដីកានេះថា ម្នាលនន្ទ ការណ៍ដែលអ្នកគ្រងចីវរទាំងឡាយ ដែលជំទាំងសងខាង បន្តក់ភ្នែករួចប្រើប្រាស់បាត្រដ៏រលោងយ៉ាងនេះ មិនសមគួរដល់ខ្លួនអ្នក ដែលជាកុលបុត្តចេញចាកផ្ទះមកកាន់ផ្នួសដោយសទ្ធាឡើយ ម្នាលនន្ទ លុះតែអ្នកប្រព្រឹត្តអារញ្ញិក-ធុតង្គ បិណ្ឌបាតិកធុតង្គ បង្សុកូលិកធុតង្គ ជាអ្នកមិនប្រាថ្នាក្នុងកាមទាំងឡាយយ៉ាងនេះ ទើបសមគួរដល់ខ្លួនអ្នក ដែលជាកុលបុត្តចេញចាកផ្ទះមកកាន់ផ្នួសដោយសទ្ធាមែន ។

[៣៧៩] ព្រះមានព្រះភាគ បានត្រាស់ព្រះពុទ្ធដីកានេះ ។ បេ ។ ព្រះសាស្តាត្រាស់ថា

អង្កាល់ទៅ ទើបតថាគតឃើញនន្ទថា ជាអ្នកប្រព្រឹត្តអារញ្ញិ-
កធុតង្គ បង្សុកូលិកធុតង្គ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយ
ភោជនដ៏លាយច្រឡំ ជាអ្នកមិនប្រាថ្នាក្នុងកាមទាំងឡាយ ។

ភិក្ខុសំយុត្តស្ស នវមសុត្តេ តិស្សស្ស ឱវាទទានំ

[៣៨០] អថខោ អាយស្មា នន្ទោ អបរេន សមយេន អារញ្ញិកោ ច អាសិ បិណ្ឌបាតិកោ ច បំសុកូលិកោ ច កាមេសុ ច អនបេក្ខោ វិហាសីតិ ។ អដ្ឋមំ ។

[៣៨១] សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ អាយស្មា តិស្សោ ភគវតោ បិតុច្ឆាបុត្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ទុក្ខី ទុម្មនោ អស្សូនិ បវត្តយមានោ ។

[៣៨២] អថខោ ភគវា អាយស្មន្តំ តិស្សំ ឯតទវោច កឹ នុ ខោ ត្វំ តិស្ស ឯកមន្តំ និសិន្នោ ទុក្ខី ទុម្មនោ អស្សូនិ បវត្តយមានោតិ ។ តថា ហិ បន មំ ភន្តេ ភិក្ខូ សមន្តា វាចាយ សន្និតោទកេន សញ្ជម្ភរឹ អកំសូតិ ។ តថា ហិ បន ត្វំ តិស្ស វត្តា ច

[៣៨០] សម័យខាងក្រោយមក ទើបព្រះនន្ទមានអាយុ ជាអ្នកប្រព្រឹត្តអារញ្ញិកធុតង្គ បិណ្ឌបាតិកធុតង្គ បង្សុកូលិកធុតង្គ មិនប្រាថ្នាក្នុងកាមទាំងឡាយ ។ ចប់សូត្រទី ៨ ។

[៣៨១] ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ព្រះតិស្សៈមានអាយុ ជាបុត្តនៃព្រះបិតុច្ឆា (កូនម្តាយមីងខាងបិតា) ព្រះមានព្រះភាគ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ក៏កើតទុក្ខទោមនស្ស យំសម្រក់ទឹកភ្នែកបណ្តើរ ។

[៣៨២] គ្រានោះឯង ព្រះមានព្រះភាគ បានត្រាស់សួរព្រះតិស្សៈមានអាយុដូច្នេះថា ម្នាលតិស្សៈ ហេតុអ្វីបានជាអ្នកអង្គុយក្នុងទីដ៏សមគួរ កើតទុក្ខទោមនស្ស យំសម្រក់ទឹកភ្នែកដូច្នេះ ។ ព្រះតិស្សៈក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ដ្បិតភិក្ខុទាំងឡាយជុំវិញខ្ញុំព្រះអង្គបានចាក់ដោតដោយជន្ទួញគឺសំដី ។ ម្នាលតិស្សៈ អ្នកឯងជាអ្នកស្តីថា

វចនក្ខមោ ន ខោ តេ តំ តិស្ស បដិរូបំ កុលបុត្តស្ស សទ្ធា អគារស្មា អនគារិយំ បព្វជិតស្ស យំ ត្វំ វត្តា នោ ច វចនក្ខមោ ឯតំ ខោ តេ តិស្ស បដិរូបំ កុល-បុត្តស្ស សទ្ធា អគារស្មា អនគារិយំ បព្វជិតស្ស យំ ត្វំ វត្តា[១] ច អាសិ វចនក្ខមោ ចាតិ ។

[៣៨៣] ឥទមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា

កឹ នុ កុជ្ឈសិ មា កុជ្ឈិ
អក្កោធោ តិស្ស តេ វរំ
កោធមានមក្ខវិនយត្ថំ ហិ
តិស្ស ព្រហ្មចរិយំ វុស្សតីតិ ។ នវមំ ។

១ ឱ. ម. យំ ត្វំ វត្តាស្ស ។

គេផង គួរជាអ្នកបេះអត់ទ្រាំនឹងសម្តីគេវិញ ម្នាលតិស្សៈ បើអ្នកឯងជាអ្នកស្តីថាគេ តែមិនបេះអត់ទ្រាំនឹងសម្តីគេវិញ ដោយហេតុណា ហេតុនោះមិនសមគួរដល់ខ្លួនអ្នក ដែលជាកុលបុត្តចេញចាកផ្ទះ ចូលមកកាន់ផ្នួសដោយសទ្ធាឡើយ ម្នាលតិស្សៈ លុះតែអ្នកឯងជាអ្នកស្តីថាឱ្យគេ តែជាអ្នកបេះអត់ទ្រាំនឹងសម្តីគេវិញ ដោយហេតុណា ហេតុនោះ ទើបសមគួរដល់ខ្លួនអ្នក ដែលជាកុលបុត្តចេញចាកផ្ទះ មកកាន់ផ្នួសដោយសទ្ធា ។

[៣៨៣] ព្រះមានព្រះភាគ បានត្រាស់ព្រះពុទ្ធដីកានេះ លុះព្រះសុគតជាសាស្តាត្រាស់ព្រះពុទ្ធដីកានេះហើយ ទើបទ្រង់ត្រាស់ព្រះពុទ្ធដីកានេះតទៅទៀតថា

ម្នាលតិស្ស អ្នកក្រោធថ្វី អ្នកកុំក្រោធ សេចក្តីមិនក្រោធជាធម៌ដ៏ប្រសើររបស់អ្នកហើយ ម្នាលតិស្សៈ ដ្បិតថា បុគ្គលប្រព្រឹត្តព្រហ្មចរិយៈ ដើម្បីតែកម្ចាត់បង់នូវក្រោធ នូវសេចក្តីប្រកាន់ និងសេចក្តីរំលុបគុណគេ ។ ចប់សូត្រទី ៩ ។

[៣៨៤] ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ ថេរនាមកោ ឯកវិហារី ចេវ ហោតិ ឯកវិហារស្ស ច វណ្ណវាទី ។ សោ ឯកោ គាមំ បិណ្ឌាយ បវិសតិ ឯកោ បដិក្កមតិ ឯកោ រហោ និសីទតិ ឯកោ ចង្កមំ អធិដ្ឋាតិ ។ អថខោ សម្ពហុលា ភិក្ខូ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ ឥធ ភន្តេ អញ្ញតរោ ភិក្ខុ ថេរនាមកោ ឯកវិហារី ឯកវិហារស្ស ច វណ្ណវាទីតិ ។

ភិក្ខុសំយុត្ត ទសមសូត្រ ភិក្ខុបាននាមជាថេរៈ

[៣៨២] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ ក៏ក្នុងសម័យនោះឯង មានភិក្ខុមួយរូបបាននាមជាថេរៈ គង់នៅតែម្នាក់ឯងផង ពោលសរសើរចំពោះកិរិយានៅតែម្នាក់ឯងផង ។ ភិក្ខុនោះចូលទៅកាន់ស្រុក ដើម្បីបិណ្ឌបាតតែម្នាក់ឯង ត្រឡប់មកវិញតែម្នាក់ឯង អង្គុយក្នុងទីស្ងាត់តែម្នាក់ឯង អធិដ្ឋានចង្រ្កមតែម្នាក់ឯង ។ គ្រានោះឯង ភិក្ខុច្រើនរូបចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុទាំងនោះអង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះ ភិក្ខុមួយរូបបាននាមជាថេរៈ នៅតែម្នាក់ឯងផង ពោលសរសើរចំពោះកិរិយានៅតែម្នាក់ឯងផង ។

[៣៨៥] អថខោ ភគវា អញ្ញតរំ ភិក្ខុំ អាមន្តេសិ ឯហិ ត្វំ ភិក្ខុ មម វចនេន ថេរំ ភិក្ខុំ អាមន្តេហិ សត្ថា តំ អាវុសោ ថេរំ អាមន្តេតីតិ ។ ឯវំ ភន្តេតិ ខោ សោ ភិក្ខុ ភគវតោ បដិស្សុណិត្វា យេនាយស្មា ថេរោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ ថេរំ ឯតទវោច សត្ថា តំ អាវុសោ ថេរំ អាមន្តេតីតិ ។ ឯវមាវុសោតិ ខោ អាយស្មា ថេរោ តស្ស ភិក្ខុនោ បដិស្សុណិត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិ-វាទេត្វា ឯកមន្តំ និសីទិ ។

[៣៨៦] ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ ថេរំ ឯតទវោច សច្ចំ កិរ ឯកវិហារី ឯកវិហារស្ស ច វណ្ណវាទីតិ ។ ឯវំ ភន្តេ ។ យថា កថំ បន ត្វំ ថេរ ឯកវិហារី ឯកវិហារស្ស ច វណ្ណវាទីតិ ។

[៣៨៥] គ្រានោះឯង ព្រះមានព្រះភាគត្រាស់ហៅភិក្ខុមួយរូបទៀតមកបង្គាប់ថា ម្នាលភិក្ខុ អ្នកចូរមក អ្នកចូរទៅហៅភិក្ខុជាថេរៈតាមពាក្យតថាគតថា ម្នាលអាវុសោ ព្រះសាស្តាត្រាស់ហៅអ្នកជាថេរៈ ។ ភិក្ខុនោះទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយចូលទៅរកព្រះថេរៈមានអាយុ លុះចូលទៅដល់ហើយបានពោលពាក្យនេះនឹងព្រះថេរៈមានអាយុថា ម្នាលអាវុសោ ព្រះសាស្តាត្រាស់ហៅអ្នកជាថេរៈ ។ ព្រះថេរៈមានអាយុ ទទួលពាក្យភិក្ខុនោះថា អើ អាវុសោ ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។

[៣៨៦] លុះព្រះថេរៈមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយទើបព្រះមានព្រះភាគទ្រង់ត្រាស់សួរដូច្នេះថា ម្នាលថេរៈ ឮថាអ្នកនៅតែម្នាក់ឯង ពោលសរសើរចំពោះកិរិយានៅតែម្នាក់ឯង ពិតឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលថេរៈ ចុះអ្នកនៅតែម្នាក់ឯងផង ពោលសរសើរចំពោះកិរិយានៅតែម្នាក់ឯងផង ដោយប្រការដូចម្តេច ។

ឥធាហំ ភន្តេ ឯកោ គាមំ បិណ្ឌាយ បវិសាមិ ឯកោ បដិក្កមាមិ ឯកោ រហោ និសីទាមិ ឯកោ ចង្កមំ អធិដ្ឋាមិ ឯវំ ខ្វាហំ ភន្តេ ឯកវិហារី ឯកវិហារស្ស ច វណ្ណវាទីតិ ។

[៣៨៧] អត្ថេសោ ថេរ ឯកវិហារោ ច សោ នត្ថីតិ វទាមិ អបិច តេ ថេរ យថា ឯកវិហារោ វិត្ថារតវេន បរិបុណ្ណោ ហោតិ តំ សុណាហិ សាធុកំ មនសិការោហិ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ ។ បេ ។

[៣៨៨] កថញ្ច ថេរ ឯកវិហារោ វិត្ថារតវេន បរិបុណ្ណោ ហោតិ ឥធ ថេរ យំ អតីតំ តំ បហីនំ យំ អនាគតំ តំ បដិនិស្សដ្ឋំ បច្ចុប្បន្នេសុ ច អត្តភាវប្បដិលាភេសុ ឆន្ទរាគោ សុប្បដិវិនីតោ ឯវំ ខោ ថេរ ឯកវិហារោ វិត្ថារតវេន បរិបុណ្ណោ ហោតីតិ ។

បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីនេះ ខ្ញុំព្រះអង្គតែម្នាក់ឯង ចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ត្រឡប់មកវិញតែម្នាក់ឯង អង្គុយក្នុងទីស្ងាត់តែម្នាក់ឯង អធិដ្ឋានចង្រ្កមតែម្នាក់ឯង បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងនេះ ខ្ញុំព្រះអង្គឈ្មោះថានៅតែម្នាក់ឯងផង ពោលសរសើរចំពោះកិរិយានៅតែម្នាក់ឯងផង ។

[៣៨៧] ម្នាលថេរៈ កិរិយានៅតែម្នាក់ឯងនុ៎ះ មានហើយ តថាគតមិនពោលថា មិនមានទេ ម្នាលថេរៈ ប៉ុន្តែកិរិយានៅតែម្នាក់ឯងរបស់អ្នកនោះ ឈ្មោះថាបរិបូណ៌ដោយពិស្តារក្រៃពេក ដោយប្រការឯណា អ្នកចូរស្តាប់នូវប្រការនោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ ព្រះករុណា ព្រះអង្គ ។ បេ ។

[៣៨៨] ម្នាលថេរៈ ចុះកិរិយានៅតែម្នាក់ឯង ឈ្មោះថាបរិបូណ៌ដោយពិស្តារក្រៃពេក ដោយប្រការដូចម្តេច ម្នាលថេរៈ ក្នុងសាសនានេះ របស់ឯណាជាអតីត របស់នោះក៏បាត់ទៅហើយ របស់ឯណា ជាអនាគត របស់នោះក៏លះបង់ចោល ឆន្ទរាគ ក្នុងការបានចំពោះនូវអត្តភាពជាបច្ចុប្បន្ន បុគ្គលកម្ចាត់បង់ចេញល្អហើយ ម្នាលថេរៈ យ៉ាងនេះឯងឈ្មោះថាកិរិយានៅម្នាក់ឯង បរិបូណ៌ដោយពិស្តារក្រៃពេក ។

[៣៨៩] ឥទមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា

សព្វាភិភុំ សព្វវិទុំ សុមេធំ
សព្វេសុ ធម្មេសុ អនូបលិត្តំ
សព្វំ ជហំ តណ្ហាក្ខយេ វិមុត្តំ
តមហំ នរំ ឯកវិហារីតិ ព្រូមីតិ ។ ទសមំ ។

[៣៩០] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ អាយស្មា មហាកប្បិនោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ។

[៣៩១] អទ្ទសា ខោ ភគវា អាយស្មន្តំ មហាកប្បិនំ ទូរតោ វ អាគច្ឆន្តំ ទិស្វាន ភិក្ខូ អាមន្តេសិ

[៣៨៩] ព្រះមានព្រះភាគ បានត្រាស់ព្រះពុទ្ធដីកានេះ លុះព្រះសុគតជាសាស្តា ត្រាស់ព្រះពុទ្ធដីកានេះហើយ ទើបទ្រង់ត្រាស់ព្រះពុទ្ធដីកានេះតទៅទៀតថា

ជនណា អ្នកគ្របសង្កត់ធម៌ទាំងអស់ ដឹងនូវធម៌ទាំងអស់ មានប្រាជ្ញាល្អ មិនជាប់ចំពាក់ក្នុងពួកធម៌ទាំងអស់ លះបង់នូវធម៌ទាំងអស់ មានចិត្តចុះស៊ប់ក្នុងព្រះនិព្វានជាទីអស់ទៅនៃតណ្ហា ទើបតថាគតហៅជននោះ ថាអ្នកនៅតែម្នាក់ឯង ។ ចប់សូត្រទី ១០ ។

[៣៩០] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ព្រះមហាកប្បិនមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ ។

[៣៩១] ព្រះមានព្រះភាគ បានទតឃើញ ព្រះមហាកប្បិនដ៏មានអាយុ កំពុងមកអំពីចម្ងាយ លុះទតឃើញហើយ ក៏ត្រាស់ហៅភិក្ខុ

បស្សថ នោ តុម្ហេ ភិក្ខវេ ឯតំ ភិក្ខុំ អាគច្ឆន្តំ ឱទាតំ តនុកំ តុង្គនាសិកន្តិ ។ ឯវំ ភន្តេ ។ ឯសោ ខោ ភិក្ខវេ ភិក្ខុ មហិទ្ធិកោ មហានុភាវោ ន ច សា សមាបត្តិ សុលភរូបា យា តេន ភិក្ខុនោ អសមា-បន្នបុព្វា យស្ស ចត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសា-នំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតីតិ ។

[៣៩២] ឥទមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា

ខត្តិយោ សេដ្ឋោ ជនេតស្មឹ
យេ គោត្តប្បដិសារិនោ
វិជ្ជាចរណសម្បន្នោ
សោ សេដ្ឋោ ទេវមានុសេ

ទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញភិក្ខុនុ៎ះកំពុងដើរមក មានសម្បុរស រាងតូចស្តើង មានច្រមុះកោង ឬទេ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះឯង មានឫទ្ធិច្រើន មានអានុភាពច្រើន សមាបត្តិឯណា ដែលភិក្ខុនោះមិនធ្លាប់ចូល សមាបត្តិនោះ បុគ្គលដទៃមិនបានដោយងាយឡើយ មួយទៀត ពួកកុលបុត្តចេញចាកផ្ទះចូលមកកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ឯណា ក្នុងបច្ចុប្បន្ន នូវអនុត្តរធម៌នោះ ជាទីបំផុតនៃព្រហ្មចរិយៈ ។

[៣៩២] ព្រះមានព្រះភាគ បានត្រាស់ព្រះពុទ្ធដីកានេះ លុះព្រះសុគតជាសាស្តា ត្រាស់ព្រះពុទ្ធដីកានេះហើយ ទើបទ្រង់ត្រាស់ព្រះពុទ្ធដីកានេះតទៅទៀតថា

ពួកជនឯណា ដែលប្តេជ្ញានូវគោត្រ បណ្តាពួកជននោះ
ក្សត្រប្រសើរវិសេសក្នុងពពួកសត្វ បុគ្គលឯណា បរិបូណ៌
ដោយវិជ្ជានិងចរណៈ បុគ្គលនោះ ប្រសើរវិសេសក្នុងទេវតា

ទិវា តបតិ អាទិច្ចោ

រត្តិមាភាតិ ចន្ទិមា

សន្នទ្ធោ ខត្តិយោ តបតិ

ឈាយី តបតិ ព្រាហ្មណោ

អថ សព្វមហោរត្តំ

ពុទ្ធោ តបតិ តេជសាតិ ។ ឯកាទសមំ ។

[៣៩៣] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ ទ្វេ ភិក្ខូ សហាយកា អាយស្មតោ មហាកប្បិនស្ស សទ្ធិវិហារិនោ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ។

[៣៩៤] អទ្ទសា ខោ ភគវា តេ ភិក្ខូ ទូរតោវ អាគច្ឆន្តេ ទិស្វាន ភិក្ខូ អាមន្តេសិ បស្សថ នោ តុម្ហេ ភិក្ខវេ ឯតេ ទ្វេ ភិក្ខូ សហាយកេ អាគច្ឆន្តេ មហាកប្បិនស្ស សទ្ធិវិហារិនោតិ ។ ឯវំ

និងមនុស្ស ព្រះអាទិត្យរុងរឿងក្នុងវេលាថ្ងៃ ព្រះចន្ទភ្លឺស្វាង ក្នុងវេលារាត្រី ក្សត្រលុះតែទ្រង់គ្រឿងទើបរុងរឿង ខីណាសវព្រាហ្មណ៍មានឈានទើបរុងរឿង ចំណែកខាងព្រះពុទ្ធ រុងរឿងដោយតេជះ ទាំងថ្ងៃទាំងយប់ ។ ចប់សូត្រទី ១១ ។

[៣៩៣] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុពីររូបជាសំឡាញ់នឹងគ្នា ជាសទ្ធិវិហារិករបស់ព្រះមហាកប្បិនមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ ។

[៣៩៤] ព្រះមានព្រះភាគបានទតឃើញ ភិក្ខុទាំងនោះកំពុងមកអំពីចម្ងាយ លុះទតឃើញហើយ ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញភិក្ខុទាំងពីររូបនុ៎ះជាសំឡាញ់នឹងគ្នាកំពុងដើរមក ជាសទ្ធិវិហារិករបស់មហាកប្បិនឬទេ ។ ព្រះករុណា

ភន្តេ ។ ឯតេ ខោ ភិក្ខវេ ភិក្ខូ មហិទ្ធិកា មហានុភាវា ន ច សា សមាបត្តិ សុលភរូបា យា តេហិ ភិក្ខូហិ អសមាបន្នបុព្វា យស្ស ចត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តីតិ ។

[៣៩៨] ឥទមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា

សហាយា វតិមេ ភិក្ខូ
ចិររត្តំ សមេនិកា[១]
សមេតិ នេសំ សទ្ធម្មោ
ធម្មេ ពុទ្ធប្បវេទិតេ
សុវិនីតា កប្បិនេន
ធម្មេ អរិយប្បវេទិតេ
ធារេន្តិ អន្តិមំ ទេហំ
ជេត្វា មារំ សវាហនន្តិ ។ ទ្វាទសមំ ។

ភិក្ខុសំយុត្តំ នវមំ សមត្តំ ។

---

១ ឱ. ម. សមេតិកា ។

ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនុ៎ះឯង មានឫទ្ធិច្រើន មានអានុភាពច្រើន សមាបត្តិឯណា ដែលភិក្ខុនោះមិនធ្លាប់ចូល សមាបត្តិនោះ បុគ្គលដទៃមិនបានដោយងាយឡើយ មួយទៀត ពួកកុលបុត្តដែលចេញចាកផ្ទះចូលមកកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ឯណា ភិក្ខុទាំងនោះក៏បានត្រាស់ដឹង បានធ្វើឲ្យជាក់ច្បាស់ បានដល់ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវអនុត្តរធម៌នោះ ជាទីបំផុតនៃព្រហ្មចរិយៈ ។

[៣៩៥] ព្រះមានព្រះភាគ បានត្រាស់ព្រះពុទ្ធដីកានេះ លុះព្រះសុគតជាសាស្តាត្រាស់ព្រះពុទ្ធដីកានេះហើយ ទើបទ្រង់ត្រាស់ព្រះពុទ្ធដីកានេះតទៅទៀតថា

ភិក្ខុទាំងនេះ ជាសំឡាញ់នឹងគ្នា ជាអ្នកមានលទ្ធិត្រូវគ្នាជាយូរណាស់ហើយ ទាំងព្រះសទ្ធម្មរបស់ភិក្ខុទាំងនោះ ក៏ត្រូវគ្នាក្នុងធម៌ដែលព្រះពុទ្ធសំដែងហើយ (ភិក្ខុទាំងនោះ) កប្បិនភិក្ខុបានទូន្មានហើយ ក្នុងធម៌ដែលព្រះអរិយៈសំដែងហើយ ភិក្ខុទាំងនោះ ទ្រទ្រង់នូវអត្តភាពជាទីបំផុត បានឈ្នះមារព្រមទាំងពាហនៈ ។ ចប់សូត្រទី ១២ ។

ចប់ ភិក្ខុសំយុត្តទី ៩ ។

# តស្សុទ្ទានំ

កោលិតោ ឧបតិស្សោ ច
ឃដោ ចាបិ បវុច្ចតិ
នវោ សុជាតោ ភទ្ទិ ច
វិសាខនន្ទោ តិស្សោ ច
ថេរនាមោ ច កប្បិនោ
សហាយេន ច ទ្វាទសាតិ ។

និទានវគ្គស្ស សំយុត្តកោ ។

# តស្ស ឧទ្ទានំ

អភិសមយធាតុសំយុត្តំ
អនមតគ្គេន កស្សបំ
សក្ការរាហុលលក្ខណោ-
បម្មភិក្ខុនោ និនានោ
ទុតិយោ តេន បវុច្ចតីតិ[១] ។

និទានវគ្គសំយុត្តំ សមត្តំ ។

១ និទានាភិសមយធាតុ អនមតគ្គេន កស្សបំ សក្ការរាហុលលក្ខណោ ឱបម្មភិក្ខុនា វគ្គោ ទុតិយោ តេន វុច្ចតីតិ ។

# ឧទ្ទាននៃភិក្ខុសំយុត្តនោះគឺ

*ពោលអំពីព្រះកោលិតៈ (មោគ្គល្លាន) ១ ឧបតិស្សៈ (សារីបុត្ត) ១ សេចក្តីប្រៀបដូចជាផ្ទាំង ១ ភិក្ខុបួសថ្មី ១ សុជាតត្ថេរ ១ លកុណ្ឋកភទ្ទិយត្ថេរ ១ វិសាខត្ថេរ ១ នន្ទត្ថេរ ១ តិស្សត្ថេរ ១ ភិក្ខុនាមជាថេរៈ ១ កប្បិនត្ថេរ ១ ភិក្ខុពីររូបជាសំឡាញ់នឹងគ្នា ១ រួមជា ១២ ។*

សំយុត្តនៃនិទានវគ្គ

# ឧទ្ទាននៃសំយុត្តនោះគឺ

*អភិសមយសំយុត្ត ១ ធាតុសំយុត្ត ១ អនមតគ្គសំយុត្ត ១ កស្សបសំយុត្ត ១ សក្ការសំយុត្ត ១ រាហុលសំយុត្ត ១ លក្ខណសំយុត្ត ១ ឱបម្មសំយុត្ត ១ ភិក្ខុសំយុត្ត ១ និទានវគ្គទី ២ លោកសំដែងដោយសំយុត្តនោះ (រួមជា ១០) ។*

ចប់ និទានវគ្គសំយុត្ត ។

# សុត្តន្តបិដកេ សំយុត្តនិកាយស្ស និទានវគ្គោ

# ចតុត្ថោ ភាគោ

---

# ធាតុសំយុត្តំ

## នានត្តវគ្គោ

## មាតិកា

អង្កេ

ធាតុសំយុត្តស្ស នានត្តវគ្គេ ធាតុនានត្តំ........................................................ ៣

ឧទ្ទានំ .......................................................... ១៩

## សត្តធាតុវគ្គោ

ធាតុសំយុត្តស្ស សត្តធាតុវគ្គេ អាភាធាត្វាទិ.................................................... ២១

កាមវិតក្កាទិឧប្បត្តិ................................................................ ២៣

នេក្ខម្មវិតក្កាទិឧប្បត្តិ............................................................ ២៥

តិណុក្កូបមា ...................................................................... ២៧

# សុត្តន្តបិដក សំយុត្តនិកាយ និទានវគ្គ

# ចតុត្ថភាគ

---

# ធាតុសំយុត្ត

# នានត្តវគ្គ

## មាតិកា

លេខទំព័រ


ធាតុសំយុត្ត នានត្តវគ្គ ធាតុមានសភាពផ្សេងៗ ........................................... ៣

ឧទ្ទាន ........................................................................ ១៩


# សត្តធាតុវគ្គ


ធាតុសំយុត្ត សត្តធាតុវគ្គ អាភាធាតុជាដើម.................................................. ២១

ការកើតឡើងនៃកាមវិតក្កជាដើម .......................... ២៣

ការកើតឡើងនៃនេក្ខម្មវិតក្កជាដើម................ .......... ២៥

ឧបមាដោយគប់ស្មៅ.................................. ......... ២៧

# មាតិកាបត្តានិ

## មាតិកា

អង្កេ

ធាតុសំយុត្តស្ស សត្តធាតុវគ្គេ អវិជ្ជាធាតុ........................................................ ២៩
ធាតុសោសំសន្ទនំ............................................ ៣១
ភិក្ខូ អាមន្តនំ .................................................... ៣៣
ហីនាធិមុត្តិកាទិ................................................. ៣៥
កល្យាណាធិមុត្តិកាទិ......................................... ៣៧
អស្សទ្ធាទិ ........................................................ ៣៩
អស្សទ្ធាទិសំសន្ទនំ .......................................... ៤១
អហិរិកាទិសំសន្ទនំ .......................................... ៤៧
អនោត្តប្បាទិសំសន្ទនំ ...................................... ៤៩
កុសីតាទិសំសន្ទនំ............................................ ៥១

## ទសកម្មបថវគ្គោ

ធាតុសំយុត្តស្ស ទសកម្មបថវគ្គេ បាណាតិបាត្យាទិសំសន្ទនំ ........................... ៥៥
មិច្ឆាទិដ្ឋិកាទិសំសន្ទនំ .................................. ៥៩
ឧទ្ធានំ ........................................................ ៦១

# សង្ខឹកាចង្អុលប្រាប់មាតិកា

## មាតិកា

លេខទំព័រ

ធាតុសំយុត្ត សត្តធាតុវគ្គ អវិជ្ជាធាតុ............................................................ ២៩
ការត្រូវគ្នាដោយធាតុ............................................ ៣១
ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយ................................ ៣៣
ពួកជនមានអធ្យាស្រ័យថោកទាបជាដើម .............. ៣៥
ពួកជនមានអធ្យាស្រ័យល្អជាដើម.......................... ៣៧
ពួកជនមិនមានសទ្ធាជាដើម ................................ ៣៩
ការត្រូវគ្នានៃជនមិនមានសទ្ធាជាដើម.................... ៤១
ការត្រូវគ្នានៃជនមិនខ្មាសបាបជាដើម.................... ៤៧
ការត្រូវគ្នានៃជនមិនខ្លាចបាបជាដើម...................... ៤៩
ការត្រូវគ្នានៃជនខ្ជិលច្រអូសជាដើម ...................... ៥១

## ទសកម្មបថវគ្គ

ធាតុសំយុត្ត ទសកម្មបថវគ្គ ការត្រូវគ្នានៃសត្វអ្នកសម្លាប់សត្វជាដើម............. ៥៥
ការត្រូវគ្នានៃសត្វមានទិដ្ឋិខុសជាដើម.................. ៥៩
ឧទ្ទាន............................................................ ៦១

# មាតិកាបត្តានិ

## ចតុត្ថាតុវគ្គោ

## មាតិកា អង្គេ

ធាតុសំយុត្តស្ស ចតុត្ថាតុវគ្គេ ពោធិសត្តស្ស បរិវិតក្កនំ .................................. ៦៣
បឋវីធាតុអស្សាទនាទិ ........................................ ៦៥
ចតុន្នំ ធាតូនំ នអព្ភញ្ញាណាទិ........................... ៦៩
បឋវីធាតុសុខតា ................................................ ៧១
បឋវីធាតុនិរោធោ............................................... ៧៣
ចតុធាតុនប្បជាននំ ............................................ ៧៥
បឋវីធាតុប្បជាននាទិ .......................................... ៧៧

# អនមតគ្គសំយុត្តំ

## តិណកដ្ឋវគ្គោ

អនមតគ្គសំយុត្តស្ស តិណកដ្ឋវគ្គេ អស្សុពហុតរភាវោ..................................... ៨១
កប្បបុច្ឆា............................................................... ៨៥
សាសបូបមា ........................................................ ៨៧
កប្បពហុតរភាវោ ............................................ ៨៩

# សង្ខឹកាចង្អុលច្រាប់មាតិកា

ចតុទ្វាតុវគ្គ

## មាតិកា

លេខទំព័រ

ធាតុសំយុត្ត ចតុទ្វាតុវគ្គ សេចក្តីត្រិះរិះរបស់ព្រះពោធិសត្វ ........................... ៦៣
អានិសង្សនៃបឋវីធាតុជាដើម ................................ ៦៥
កិរិយាមិនដឹងច្បាស់នូវធាតុទាំងបួនជាដើម............ ៦៩
ភាវៈនៃសេចក្តីសុខរបស់បឋវីធាតុ.......................... ៧១
កិរិយារលត់នៃបឋវីធាតុ......................................... ៧៣
ការមិនដឹងច្បាស់នូវចតុធាតុ ................................. ៧៥
ការមិនដឹងច្បាស់នូវបឋវីធាតុជាដើម ...................... ៧៧

# អនមតគ្គសំយុត្ត

### *តិណកដ្ឋវគ្គ*

អនមតគ្គសំយុត្ត តិណកដ្ឋវគ្គ ភាពនៃទឹកភ្នែកច្រើន........................................ ៨១
ការសួររកកប្ប ..................................................... ៨៥
ឧបមាដោយគ្រាប់ស្ពៃ........................................... ៨៧
កប្បមានចំនួនច្រើនណាស់ .................................. ៨៩

# មាតិកាបត្តានិ

## មាតិកា អង្កេ

អនមតគ្គសំយុត្តស្ស តិណកដ្ឋវគ្គេ សរណាគមនំ............................................ ៩១
និគមវចនំ ............................................................ ៩៣
ឧទ្ទានំ.................................................................. ៩៥

## ទុគ្គតវគ្គោ

អនមតគ្គសំយុត្តស្ស ទុគ្គតវគ្គេ ភគវន្តូបសង្កមនំ............................................ ៩៧
សាធុការទានំ........................................................ ៩៩
អនបិតុភូតបុព្វភាវោ ..............................................១០១
ភិក្ខាមន្តនំ ............................................................១០៣
ភូតបុព្វកថា ..........................................................១០៥
វេបុល្លបព្វតសមញ្ញា ..............................................១០៧
និគមវចនំ .............................................................១០៩

## កស្សបសំយុត្តំ

កស្សបសំយុត្តស្ស បឋមសុត្តេ សន្តុដ្ឋភាវោ.................................................... ១១៣
ទុតិយសុត្តេ អនោត្តាបិភាវោ................................. ១១៥

# សង្ខឹកាចង្អុលច្រាប់មាតិកា

## មាតិកា

លេខទំព័រ

អនមតគ្គសំយុត្ត តិណកដ្ឋវគ្គ ការដល់នូវសរណៈ ........................................ ៩១

និគមវចនៈ.......................................................... ៩៣

ឧទ្ទាន.................................................................. ៩៥

## ទុគ្គតវគ្គ

អនមតគ្គសំយុត្ត ទុគ្គតវគ្គ ពួកបាវេយ្យាកភិក្ខុចូលទៅគាល់ព្រះមានព្រះភាគ ... .... ៩៧

ទ្រង់ប្រទាននូវសាធុការៈ ....................................... ៩៩

ភាពនៃបុគ្គលមិនធ្លាប់កើតជាបិតា.......................... ១០១

ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយ................................ ១០៣

និយាយអំពីរឿងព្រេង........................................... ១០៥

ឈ្មោះនៃភ្នំវេបុល្ល.................................................. ១០៧

និគមវចនៈ.......................................................... ១០៩

## កស្សបសំយុត្ត

កស្សបសំយុត្ត បឋមសូត្រ ភាពនៃបុគ្គលអ្នកសន្តោស .................................. ១១៣

ទុតិយសូត្រ ភាពនៃបុគ្គលមិនមានការដុតកម្តៅកិលេស ................ ១១៥

# មាតិកាបត្តានិ

## មាតិកា

អង្កេ

កស្សបសំយុត្តស្ស ទុតិយសុត្តេ អនោត្តាបិភាវោ............................................ ១១៧
ឱត្តាបិភាវោ ................................................. ១១៩
តតិយសុត្តេ កុលូបកភាវោ............................................... ១២១
ចតុត្ថសុត្តេ កុលូបកភាវោ............................................... ១២៥
បញ្ចមសុត្តេ ភគវន្តូបសង្កមនំ........................................... ១២៩
អត្តវសសម្បស្សនំ ......................................... ១៣១
ឆដ្ឋសុត្តេ ភគវន្តូបសង្កមនំ........................................... ១៣៣
ភគវន្តុបុច្ឆា.................................................... ១៣៥
អច្ចយប្បដិគ្គហណំ....................................... ១៣៧
សត្តមសុត្តេ បរិហានភាវោ............................................... ១៣៩
អបរិហានភាវោ ............................................ ១៤១
វុឌ្ឍិភាវោ ...................................................... ១៤៣
អដ្ឋមសុត្តេ អារញ្ញិកត្តាវណ្ណនាទិ ...................................... ១៤៥
អារញ្ញិកត្តាវណ្ណនាទិ ...................................... ១៤៧

# សង្ខឹកចង្អុលប្រាប់មាតិកា

## មាតិកា

លេខទំព័រ


កស្សបសំយុត្ត ទុតិយសូត្រ ភាពនៃបុគ្គលមិនមានសេចក្តីខ្លាចបាប.................. ១១៧

ភាពនៃបុគ្គលមានសេចក្តីខ្លាចបាប...................... ១១៩

តតិយសូត្រ ភាពនៃភិក្ខុអ្នកចូលទៅកាន់ត្រកូល...................... ១២១

ចតុត្ថសូត្រ ភាពនៃភិក្ខុអ្នកចូលទៅកាន់ត្រកូល...................... ១២៥

បញ្ចមសូត្រ ព្រះមហាកស្សបចូលទៅគាល់ព្រះមានព្រះភាគ............១២៩

ការឃើញអំណាចប្រយោជន៍............................. ១៣១

ឆដ្ឋសូត្រ ព្រះមហាកស្សបចូលទៅគាល់ព្រះមានព្រះភាគ............១៣៣

បុច្ឆារបស់ព្រះមានព្រះភាគ................................ ១៣៥

ការទ្រង់ទទួលអត់ទោស.................................... ១៣៧

សត្តមសូត្រ ភាពនៃសេចក្តីសាបសូន្យ.................................. ១៣៩

ភាពនៃសេចក្តីមិនសាបសូន្យ............................ ១៤១

ភាពនៃសេចក្តីចម្រើន........................................ ១៤៣

អដ្ឋមសូត្រ សេចក្តីសរសើរគុណនៃការនៅក្នុងព្រៃជាដើម................១៤៥

សេចក្តីមិនសរសើរគុណនៃការនៅក្នុងព្រៃជាដើម .................... ១៤៧

៣០៩

# មាតិកាបត្តានិ

## មាតិកា អង្គេ


កស្សបសំយុត្តស្ស នវមសុត្តេ បឋមជ្ឈានំ........................................................ ១៤៩
អាកាសានញ្ចាយតនំ........................................ ១៥១
ឥទ្ធិវិធំ .............................................................. ១៥៣
បុព្វេនិវាសោ..................................................... ១៥៥
ទិព្វចក្ខុ............................................................. ១៥៧
ទសមសុត្តេ មហាកស្សបូបសង្កមនំ ..................................... ១៥៩
សូចិពាណិជកូបមា ....................................... ....១៦១
មហាកស្សបបដិបុច្ឆា ........................................ ១៦៣
ឯកាទសមសុត្តេ តិកភោជនប្បញ្ញត្តត្ថោ................................. ១៦៥
ថុល្លនន្ទានត្តមនា ............................................... ១៦៧
មហាកស្សបវាចា ............................................... ១៦៩
ទ្វាទសមសុត្តេ សារីបុត្តបុច្ឆា................................................... ១៧៥
តេរសមសុត្តេ សារីបុត្តបុច្ឆា .................................................. ១៧៧
សទ្ធម្មានន្តរធានំ ............................................... ១៧៩

# សង្ខឹកាចង្អុលប្រាប់មាតិកា

## មាតិកា

លេខទំព័រ


កស្សបសំយុត្ត នវមសូត្រ បឋមជ្ឈាន ........................................................ ១៤៩

អាកាសានញ្ចាយតនជ្ឈាន .................................. .១៥១

ឥទ្ធិវិធៈ .............................................................. ១៥៣

បុព្វេនិវាស ........................................................ ១៥៥

ទិព្វចក្ខុ .............................................................. ១៥៧

ទសមសូត្រ ពួកភិក្ខុនីចូលទៅរកព្រះមហាកស្សប .................. ១៥៩

ឧបមាដោយឈ្មួញម្ជុល ...................................... ១៦១

ការសួរបញ្ជាក់របស់ព្រះមហាកស្សប .................... ១៦៣

ឯកាទសមសូត្រ ប្រយោជន៍នៃការបញ្ញត្តតិកភោជន.............. ១៦៥

សេចក្តីមិនពេញចិត្តរបស់ថុល្លនន្ទាភិក្ខុនី................ ១៦៧

វាចារបស់ព្រះមហាកស្សប .................................. ១៦៩

ទ្វាសមសូត្រ ការសាកសួររបស់ព្រះសារីបុត្ត .......................... ១៧៥

តេរសមសូត្រ ការសាកសួររបស់ព្រះសារីបុត្ត........................ ១៧៧

សេចក្តីមិនសាបសូន្យទៅនៃព្រះសទ្ធម្ម.................. ១៧៩

# មាតិកាបត្តានិ

## លាភសក្ការសំយុត្តំ

### សុទ្ធកវគ្គោ

## មាតិកា

អង្កេ

លាភសក្ការសំយុត្តស្ស សុទ្ធកវគ្គេ លាភសក្ការសិលោកទារុណោ .................. ១៨៣

លុទ្ធាទិវចនាធិប្បាយោ ............................. ១៨៥

កំសឡក្ខូបមា.......................................... .១៨៧

លាភសក្ការសិលោកទារុណោ .................. ១៨៩

សក្ការាភិភូតភាវោ ..................................... ១៩៣

ឧទ្ធានំ...................................................... ១៩៥

### ចាតិវគ្គោ

លាភសក្ការសំយុត្តស្ស បាតិវគ្គេ លាភសក្ការសិលោកាភិភូតភាវោ.................. ១៩៧

### មាតុគ្គាមវគ្គោ

លាភសំក្ការសំយុត្តស្ស មាតុគ្គាមវគ្គេ សាវកប្បមាណភាវោ.............................. ២០១

លាភសក្ការសិលោកស្សនា-

ទិនប្បជាននំ ............................................ ២០៣

# សង្ខេបចង្អុលប្រាប់មាតិកា

# លាភសក្ការសំយុត្ត

## សុទ្ធកវគ្គ

## មាតិកា

លេខទំព័រ

លាភសក្ការសំយុត្ត សុទ្ធកវគ្គ លាភសក្ការៈនិងសេចក្តីសរសើរជារបស់អាក្រក់.............១៨៣

អធិប្បាយអំពីពាក្យថាព្រានជាដើម .................. ១៨៥

ឧបមាដោយសត្វកំពោង ................................ ១៨៧

លាភសក្ការៈនិងសេចក្តីសរសើរជារបស់អាក្រក់ ..... ១៨៩

ភាពនៃបុគ្គលត្រូវសក្ការៈគ្របសង្កត់.................. ១៩៣

ឧទ្ទាន ............................................................ ១៩៥

*បាតិវគ្គ*

លាភសក្ការសំយុត្ត បាតិវគ្គ ភាពនៃបុគ្គលត្រូវលាភសក្ការៈគ្របសង្កត់............. ១៩៧

*មាតុគ្គាមវគ្គ*

លាភសក្ការសំយុត្ត មាតុគ្គាមវគ្គ ភាពនៃសាវកជាខ្មាត.................................. ២០១

ការមិនដឹងអានិសង្សជាដើមនៃលាភសក្ការៈនិង

សេចក្តីសរសើរ................................................ ២០៣

# មាតិកាបត្តាជិ

## មាតិកា អង្កេ

លាភសក្ការសំយុត្តស្ស មាតុគ្គាមវគ្គេ លាភសក្ការសិលោកទារុណោ ............... ២០៥
អានន្ទបុច្ឆា............................................ ២០៧
ឧទ្ទានំ២................................................ ២០៩

## ភេទវគ្គោ

លាភសក្ការសំយុត្តស្ស ភេទវគ្គេ លាភសក្ការសិលោកទារុ-
ណភាវោ ............................................... ២១១
អស្សតរូបមា ........................................ ២១៣
ចណ្ឌកុក្កុរូបមា ...................................... ២១៥
លាភសក្ការសិលោកទារុ-
ណភាវោ ............................................... ២១៧
ឧទ្ទានំ .................................................. ២១៩

## រាហុលសំយុត្តំ

## អប្បមាទវគ្គោ

រាហុលសំយុត្តស្ស អប្បមាទវគ្គេ សឡាយតនានំ អនិច្ចតាទិ.......................... ២២១
ចក្ខុវិញ្ញាណាទិនិព្វិន្ទនំ............................ ២២៣

# សង្ខឹកចង្អុលប្រាប់មាតិកា

## មាតិកា

លេខទំព័រ

លាភសក្ការសំយុត្ត មាតុគ្គាមវគ្គ លាភសក្ការៈនិងសេចក្តីសរសើរជារបស់អាក្រក់.... ..២០៥

ការសាកសួររបស់ព្រះអានន្ទ ........................ ២០៧

ឧទ្ទាន ....................................................... ២០៩

### ភេទវគ្គ

លាភសក្ការសំយុត្ត ភេទវគ្គ លាភសក្ការៈនិងសេចក្តីសរសើរជារបស់អាក្រក់............ ២១១

ឧបមាដោយមេសេះអស្សតរ ........................ ២១៣

ឧបមាដោយឆ្កែកាច.................................... ២១៥

លាភសក្ការៈនិងសេចក្តីសរសើរជារបស់អាក្រក់........២១៧

ឧទ្ទាន ....................................................... ២១៩

# រាហុលសំយុត្ត

### អប្បមាទវគ្គ

រាហុលសំយុត្ត អប្បមាទវគ្គ ការមិនទៀងជាដើមនៃអាយតនៈទាំងប្រាំមួយ............................ ២២១

សេចក្តីនឿយណាយចំពោះចក្ខុវិញ្ញាណជាដើម.......២២៣

# មាតិកាបត្តាដិ

## មាតិកា អង្កេ

រាហុលសំយុត្តស្ស អប្បមាទវគ្គេ ចក្ខុសម្ផស្សជាវេទនាទិនិព្វិន្ទនំ ........................ ២២៥
រូបតណ្ហាទិនិព្វិន្ទនំ ........................................... ២២៧
រូបាទិនិព្វិន្ទនំ .................................................. ២២៩

## អនុសយវគ្គោ

រាហុលសំយុត្តស្ស អនុសយវគ្គេ សឡាយតនំ អនិច្ចាទិ ................................ ២៣៣
មានសមុច្ឆា .................................................. ២៣៥
មានសព្យាករណំ ........................................... ២៣៧

## លក្ខណសំយុត្តំ

## អដ្ឋិសង្ខលិកវគ្គោ

លក្ខណសំយុត្តស្ស អដ្ឋិសង្ខលិកវគ្គេ គោឃាតកវិបាកោ................................. ២៤១
សូករិកវិបាកោ .............................................. ២៤៣
សូចិកវិបាកោ................................................. ២៤៥
ឧទ្ទានំ............................................................ ២៤៧

# សន្ទឹកាចង្អុលប្រាប់មាតិកា

## មាតិកា

លេខទំព័រ

រាហុលសំយុត្ត អប្បមាទវគ្គ សេចក្តីនឿយណាយចំពោះចក្ខុសម្ផស្សជាវេទនា
ជាដើម............................................................ ២២៥
សេចក្តីនឿយណាយចំពោះរូបតណ្ហាជាដើម........ ២២៧
សេចក្តីនឿយណាយចំពោះរូបជាដើម ................ ២២៩

### *អនុសយវគ្គ*

រាហុលសំយុត្ត អនុសយវគ្គ សេចក្តីមិនទៀងជាដើមនៃអាយតនៈទាំងប្រាំមួយ....................២៣៣
ការសួររកចិត្ត..................................................... ២៣៥
ការព្យាករណ៍នូវចិត្ត........................................... ២៣៧

## លក្ខណសំយុត្ត

### *អដ្ឋិសង្ខលិកវគ្គ*

លក្ខណសំយុត្ត អដ្ឋិសង្ខលិកវគ្គ វិបាកនៃអ្នកសម្លាប់គោ................................ ២៤១
វិបាកនៃអ្នកសម្លាប់ជ្រូក ..................................... ២៤៣
វិបាកនៃអ្នកញុះញង់គេ ....................................... ២៤៥
ឧទ្ទាន ............................................................... ២៤៧

# មាតិកាបត្តានិ

## ចារជាតិកាវគ្គោ

## មាតិកា

អង្គេ

លក្ខណសំយុត្តស្ស បារទាវិកវគ្គេ ឥក្ខណិកាវិបាកោ........................................ ២៥៩
បាបសាមណេរវិបាកោ................................ ២៥១
បាបសាមណេរីវិបាកោ................................ ២៥៣

## ឱបម្មសំយុត្តំ

ឱបម្មសំយុត្តស្ស តតិយសុត្តេ កុម្ភត្ថេនកចោរូបមា ........................................... ២៥៧
បញ្ចមសុត្តេ សត្យូបមា........................................................ ២៥៩
ឆដ្ឋសុត្តេ ធនុគ្គហូបមា........................................................ ២៦១
សត្តមសុត្តេ មុទិង្គូបមា........................................................ ២៦៣
អដ្ឋមសុត្តេ លិច្ឆវូបមា........................................................ ២៦៥
នវមសុត្តេ នាគោបមា ........................................................ ២៦៧
ទសមសុត្តេ ឥន្ទ្រិយអសំវរោ................................................ ២៧១
កតញ្ញូកតវេទិតា ................................................................... ២៧៣

# សង្ខឹកចង្អុលប្រាប់មាតិកា

## *បារទារិកវគ្គ*

## មាតិកា

លេខទំព័រ


លក្ខណសំយុត្ត បារទារិកវគ្គ វិបាកនៃស្រីមេមត់ ........................................ ២៤៩

វិបាករបស់សាមណេរលាមក ............................ ២៥១

វិបាករបស់សាមណេរីលាមក ............................ ២៥៣


## *ឱបម្មសំយុត្ត*


ឱបម្មសំយុត្ត តតិយសូត្រ ឧបមាដោយចោរលួចទ្រព្យដោយឆ្នាំង................. ២៥៧

បញ្ចមសូត្រ ឧបមាដោយលំពែង........................................ ២៥៩

ឆដ្ឋសូត្រ ឧបមាដោយខ្នាន់ធ្នូ........................................ ២៦១

សត្តមសូត្រ ឧបមាដោយសំភោរ........................................ ២៦៣

អដ្ឋមសូត្រ ឧបមាដោយពួកស្តេចលិច្ឆវី................................ ២៦៥

នវមសូត្រ ឧបមាដោយដំរី ................................................ ២៦៧

ទសមសូត្រ ការមិនបានសង្រួមឥន្ទ្រិយ ................................ ២៧១

កតញ្ញូនិងកតវេទិតា........................................ ២៧៣

# មាតិកាបត្តានិ

# ភិក្ខុសំយុត្តំ

## មាតិកា

អង្កេ


ភិក្ខុសំយុត្តស្ស ទុតិយសុត្តេ សារីបុត្តបរិវិតក្កនំ.............................................. ២៧៧

តតិយសុត្តេ មហាមោគ្គល្លានូបសង្កមនំ................................ ២៧៩

អារទ្ធវិរិយបុច្ឆា ................................................. ២៨១

ចតុត្ថសុត្តេ អប្បោសុក្កោ.................................................. .២៨៣

ភិក្ខាមន្តនំ ....................................................... ២៨៥

បញ្ចមសុត្តេ និគមគាថា...................................................... ២៨៧

សត្តមសុត្តេ ធម្មីកថាសន្ទេសនា........................................... ២៨៩

អដ្ឋមសុត្តេ ភគវន្តូបសង្កមនំ................................................ ២៩១

នវមសុត្តេ តិស្សស្ស ឱវាទទានំ ........................................ ២៩៣

ទសមសុត្តេ ថេរនាមកោ ភិក្ខុ............................................... ២៩៥

ឯកាទសមសុត្តេ និគមគាថា................................................ ២៩៩

ទ្វាទសមសុត្តេ និគមគាថា .................................................. ៣០១

# សង្ខេបចង្អុលប្រាប់មាតិកា

## ភិក្ខុសំយុត្ត

## មាតិកា

លេខទំព័រ

ភិក្ខុសំយុត្ត ទុតិយសូត្រ បរិវិតក្កៈរបស់ព្រះសារីបុត្ត ........................................ ២៧៧

តតិយសូត្រ ព្រះសារីបុត្តចូលទៅរកព្រះមហាមោគ្គល្លាន ............. ២៧៩

ការសួររកភិក្ខុមានព្យាយាមប្រារព្ធ............................ ២៨១

ចតុត្ថសូត្រ ភិក្ខុមិនមានសេចក្ដីខ្វល់ខ្វាយ .................................. ២៨៣

ទ្រង់ហៅពួកភិក្ខុ ..................................................... ២៨៥

បញ្ចមសូត្រ និគមគាថា ............................................................ ២៨៧

សត្តមសូត្រ ការញ៉ាំងភិក្ខុឲ្យឃើញច្បាស់ដោយធម្មីកថា ............... ២៨៩

អដ្ឋមសូត្រ ព្រះនន្ទចូលទៅគាល់ព្រះមានព្រះភាគ...................... ២៩១

នវមសូត្រ ទ្រង់ប្រទានឱវាទដល់ព្រះតិស្ស ............................... ២៩៣

ទសមសូត្រ ភិក្ខុមាននាមជាថេរៈ.................................................. ២៩៥

ឯកាទសមសូត្រ និគមគាថា ...................................................... ២៩៩

ទ្វាទសមសូត្រ និគមគាថា.......................................................... ៣០១

